# គិហិប្បតិបត្តិពិស្តារ

បណ្ឌិត ឈឹម ឡូច

រៀបរៀង

មាន

## កំណើតបុណ្យចំនួន៣៥មាន

កឋិន, ផ្កាប្រាក់, ចូលឆ្នាំ, ភ្ជុំបិណ្ឌ, ចំរើនព្រះជន្ម, ប្រទីប, សាងក, បង្សុកូល ព្រះពុទ្ធរូបជាដើម

បោះពុម្ពដំបូង

ផ្សាយចេញពី

បណ្ណាគារត្រៃរតន៍លេខ ១៣៦

វិថីខេមរភូមិន្ទ ភ្នំពេញ

ព.ស.២៥៤០ គ.ស. ១៩៩៦

ដើម្បីដាក់ក្នុង "eLibrary of Cambodia

# គិហិប្បដិបត្តិពិស្តារ

កក្កដា 2015

បណ្ឌិត ឈឹម ខួច

រៀបរៀង

មាន

## កំណើតបុណ្យចំនួន៣៥មាន

## កឋិន, ផ្កាប្រាក់, ចូលឆ្នាំ, ភ្ជុំបិណ្ឌ, ចំរើនព្រះជន្ម, ប្រទីប, សាងក, បង្សុកូលព្រះពុទ្ធរូបជាដើម


បោះពុម្ពលើកទី១

ផ្សាយចេញពី

បណ្ណាគារគ្រូរតន៍លេខ ១៣៦

វិថីខេមរភូមិន្ទ ភ្នំពេញ

ព.ស ២៥៤០ គ.ស ១៩៩៦

# មាតិការឿង


| ឈ្មោះធម៌ | ទំព័រ |
|---|---|
| ១- រតនត្តយបូជា | ១ |
| ២- ពុទ្ធរតនប្បណាម | ២ |
| ៣- ធម្មរតនប្បណាម | ៦ |
| ៤- សង្ឃរតនប្បណាម | ១០ |
| ៥- រតនប្បណាមបែបសង្ខេប | ១៦ |
| ៦- សុភមង្គលកថា | ២០ |
| ៧- បាលីខមាទោសនិងថ្វាយខ្លួន | ២២ |
| ៨- អាជីវៈនៃឧបាសក | ៣១ |
| ៩- វិបត្តិនៃឧបាសក | ៣២ |
| ១០- សម្បត្តិនៃឧបាសក | ៣៣ |
| ១១- គុណនៃឧបាសក | ៣៤ |
| ១២- វិធីសមាទាននិច្ចសីល | ៣៦ |
| ១៣- វិធីសមាទានឧបោសថសីល | ៤៣ |
| ១៤- ឯកជ្ឈសមាទាន | ៥០ |
| ១៥- កំណើតសរណគមន៍ | ៥៦ |
| ១៦- កំណើតនិច្ចសីល | ៥៨ |

# មាតិការឿង


| ឈ្មោះធម៌ | | ទំព័រ |
|---|---|---|
| ១៧- | កុរុធម្មជាតក | ៥៩ |
| ១៨- | កំណើតឧបោសថសីល | ៧៣ |
| ១៩- | កំណើតនមោ | ៩៣ |
| ២០- | កំណើតបរិត្ត | ១០០ |
| ២១- | កំណើតកឋិន | ១១១ |
| ២២- | បុណ្យចំរើនព្រះជន្ម | ១១៧ |
| ២៣- | កំណើតបង្សុកូល | ១២២ |
| ២៤- | បុណ្យភ្ជុំបិណ្ឌ | ១២៥ |
| ២៥- | បុណ្យបូជាព្រះចន្ទ | ១២៩ |
| ២៦- | កំណើតបុណ្យផ្កាប្រាក់ | ១៣១ |
| ២៧- | បុណ្យចូលឆ្នាំ | ១៣៣ |
| ២៨- | កំណើតសំពត់សាដក | ១៣៦ |
| ២៩- | កំណើតបុណ្យប្រទីប | ១៤៤ |
| ៣០- | ពិធីឆ្លងបុណ្យ | ១៥៤ |
| ៣១- | កំណើតសីល១០ | ១៦០ |
| ៣២- | កំណើតមហាបង្សុកូល | ១៦៣ |

# មាតិការឿង


| ឈ្មោះធម៌ | | ទំព័រ |
|---|---|---|
| ៣៣- | កំណើតឈាបនកិច្ច | ១៦៥ |
| ៣៤- | កំណើតបុណ្យទេសនាមហាជាតក៍ | ១៦៧ |
| ៣៥- | កំណើតព្រះពុទ្ធរូប | ១៦៨ |
| ៣៦- | បត្តិទានគាថា | ១៧៥ |
| ៣៧- | បត្តិភាសនាយាចនគាថា | ១៧៨ |
| ៣៨- | ទេវតាបកាសគាថា | ១៧៩ |
| ៣៩- | ធម្មទេសនានាយាចនគាថា | ១៨០ |
| ៤០- | សម្តែងអំពីវិធីវេរភត្ត ១៤ ប្រការ | ១៨៣ |
| ៤១- | បាលីវេរដុំថ្មជានិមិត្តសីមា | ២០១ |
| ៤២- | បាលីវេររោងឧបោសថ( គឺវិហារ) | ២០១ |
| ៤៣- | បញ្ហាទាន | ២០២ |
| ៤៤- | ធ្វើទានបច្ច័យ ៤ ចំពោះសង្ឃ | ២០៤ |
| ៤៥- | របៀបវេរបច្ច័យ ៤ ជាសង្ឃទាន | ២០៥ |
| ៤៦- | អំពីពាក្យថាសង្ឃ | ២០៦ |
| ៤៧- | នមស្ការបូជនីយវត្ថុជាទីគោរព | ២០៨ |
| ៤៨- | នមស្ការព្រះរតនត្រ័យ | ២០៩ |

# មាតិការឿង

| ឈ្មោះធម៌ | | ទំព័រ |
|---|---|---|
| ៤៩- | ចតុរារក្ខកម្មដ្ឋាន | ២១១ |
| ៥០- | ពុទ្ធបាននមក្ការគាថា | ២១៣ |
| ៥១- | សុខាភិយាចនគាថា | ២១៥ |
| ៥២- | ការឧទ្ទិសផលបុណ្យនិងការប្រាថ្នា | ២១៧ |
| ៥៣- | ការសូមខមាទោសចំពោះសព្វសត្វ | ២១៩ |
| ៥៤- | សេចក្តីរំលឹកចំពោះអ្នករក្សាសីល | ២២០ |

# បទសរភញ្ញ វសន្តតិលកា

១- សូមថ្វាយបង្គំ ព្រះសម្មាសម្ពុទ្ធប្រសើរបំផុតក្នុងលោកា
ជាគ្រូនៃមនុស្ស និងទេព្តាទ្រង់ត្រាស់ទេស្នាប្រដៅសត្វ :
ចង្អុលឱ្យដើរផ្លូវកណ្តាល មាគ៌ាត្រកាលអាចកំចាត់
ទុក្ខភ័យចង្រៃឱ្យខ្ចាយបាត់ អាចកាត់សង្សា-រៈទុក្ខ បាន ។

២ សាស្តាព្រះអង្គនៅសព្វថ្ងៃ សត្វមាននិស្ស័យពីបូរាណ
ប្រឹងរៀនប្រឹងស្តាប់ចេះចាំបាន កាន់តាមលំអានបានក្តីសុខ :
ឥតមានសុខណា ស្មើក្តី-ស្ងប់ បញ្ចប់ត្រឹមសុខឃ្លាតចាគ-ទុក្ខ
តាំងពីលោកនេះតទៅមុខ ក្តីសុខនិងមាន ព្រោះធម៌-ស្ងប់ ។

៣ ខ្ញុំសូមបង្គំផ្គោះព្រះធម៌ ព្រះសង្ឃបវរ ទាំងគ្រប់សព្វ
រួមជាត្រៃរ័ត្ន គួរគោរព ជាម្លប់ត្រជាក់ នៃលោកា
ព្រះរូបព្រះធាតុ នៃព្រះពុទ្ធ វិសុទ្ធតាងអង្គព្រះសា-ស្តា
សូមគុណត្រៃរ័ត្ន ជួយខេមរា ឱ្យបានសុខា តរៀង-ទៅ

ថ្ងៃទី ១២ កុម្ភៈ ១៩៦៥

សម្តេចព្រះមហាសុមេធាធិបតី

ជ.ណ. ជោតញ្ញាណោ ព្រះសង្ឃរាជ គណៈមហានិកាយ

## រតនត្តយបូជា

*ថ្វាយគ្រឿងសក្ការៈដល់ព្រះរតនត្រ័យ*

ឥមេហិ ទីបធូបាទិសក្ការេហិ ពុទ្ធំ អភិបូជយាមិ មាតាបិតាទីនំ គុណវន្តានញ្ច មយ្ហញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ឥមេហិ ទីបធូបាទិសក្ការេហិ ធម្មំ អភិបូជយាមិ មាតាបិតាទីនំ គុណវន្តានញ្ច មយ្ហញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ឥមេហិ ទីបធូបាទិសក្ការេហិ សង្ឃំ អភិបូជយាមិ មាតាបិតាទីនំ គុណវន្តានញ្ច មយ្ហញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

ប្រែថា : ខ្ញុំព្រះករុណាសូមបូជាចំពោះ នូវ { ព្រះពុទ្ធ / ព្រះធម៌ / ព្រះសង្ឃ } ជាម្ចាស់ដោយគ្រឿងសក្ការៈទាំងឡាយមានទៀននិងធូបជាដើមនេះ ដើម្បីសេចក្ដីចំរើនដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់អ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់ខ្ញុំព្រះករុណាផង អស់កាលជាអង្វែងទៅហោង ។

# ពុទ្ធរតនប្បណាម

*ថ្វាយបង្គំព្រះពុទ្ធរតនៈ*

នមោ តស្ស

ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ប្រែថា: វីកិរិយានមស្សការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រវិពចំពោះព្រះអង្គឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។ សូត្របាលី ៣ ចប់ សំរាយ តែ ១ ចប់ ក៏បាន ។ ។

យោ សន្និសិន្នោ វរពោធិមូលេ

មារំ សសេនំ មហតី វិជេយ្យា

សម្ពោធិមាគច្ឆិ អនន្តញាណោ

លោកុត្តមោ តំ បនមាមិ ពុទ្ធំ ។

ប្រែថា: ព្រះសម្មាសម្ពុទ្ធអង្គឯណា ទ្រង់គង់ចំរើននូវព្រះអនាបាណស្សតិកម្មដ្ឋានលើរតនបល្ល័ង ក្រោមម្លប់ពោធិព្រឹក្សដ៏ប្រសើរ បានផ្ចាញ់នូវមារាធិរាជព្រមទាំងសេនាដ៏ច្រើន ហើយទ្រង់ត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ មានប្រាជ្ញារកទីបំផុត

គ្មាន ព្រះអង្គប្រសើរជាងសត្វលោក ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធអង្គនោះដោយគោរព ។

**ក្រាបថ្វាយបង្គំម្តង**

នមស្សការព្រះសម្មាសម្ពុទ្ធដូចសេចក្តីខាងលើនេះ គឺនមស្សការដោយសង្ខេប មិនបានញែកកាលចេញជាពាឡើយ បើនមស្សការដោយពិស្តារវិញ ទើបញែកកាលចេញជា ៣ ដូចសេចក្តីខាងក្រោមនេះ ។

យេ ច ពុទ្ធា អតីតា ច
យេ ច ពុទ្ធា អនាគតា
បច្ចុប្បន្នា ច យេ ពុទ្ធា
អហំ វន្ទាមិ សព្វទា ។

ប្រែថា ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គណា ដែលបានត្រាស់ជាព្រះពុទ្ធនិព្វានកន្លងទៅហើយក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គណាដែលបានត្រាស់ជាព្រះពុទ្ធក្នុងកាលខាងមុខក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គណាដែលបានត្រាស់ជាព្រះពុទ្ធក្នុងភទ្រកប្បនេះក្តី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធទាំងឡាយនោះគ្រប់កាលទាំងពួង ។

**ក្រាបថ្វាយបង្គំម្តង**

រួចហើយគប្បីតាំងចិត្តរំឭកដល់គុណទាំង ១០ ព្រះនាម ដោយបង្អោនកាយវាចាថា៖

ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណ
សម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ
សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។

ប្រែថា ឥតិបិ សោ ភគវា អរហំ ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវ ពោលគឺកិលេសព្រមទាំងវាសនា គឺកាយបយោគ នឹងវចីបយោគ សម្មាសម្ពុទ្ធោ ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ វិជ្ជាចរណសម្បន្នោ ទ្រង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា៣ នឹងវិជ្ជា៨ និងចរណៈ១៥ សុគតោ ទ្រង់ព្រះនាមថា សុគតោ ព្រោះព្រះអង្គមានដំណើរល្អយាងទៅកាន់សុន្ទរស្ថាន គឺអមតមហានិព្វាន លោកវិទូ ទ្រង់ព្រះនាមថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក អនុត្តរោ ទ្រង់ព្រះនាមថា អនុត្តរោ ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន បុរិសទម្មសារថិ ទ្រង់ព្រះនាមថា បុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរស ដែលមានឧបនិស្ស័យ គួរនឹងទូន្មានបាន សត្ថាទេវមនុស្សានំ ទ្រង់ព្រះនាមថា

សត្ថាទេវមនុស្សានំ ព្រោះព្រះអង្គជាសាស្ត្រាចារ្យនៃទេវតានិងមនុស្សទាំងឡាយ ពុទ្ធោ ទ្រង់ព្រះនាមថា ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ហើយញុំាងអ្នកដទៃឱ្យត្រាស់ដឹងផង ភគវា ទ្រង់ព្រះនាមថា ភគវា ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ទាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។

រឭកដល់ពុទ្ធគុណរួចហើយ គប្បីប្រកាសប្ដេជ្ញាខ្លួនដោយពាក្យសច្ចៈថា

នត្ថិ មេ សរណំ អញ្ញំ
ពុទ្ធោ មេ សរណំ វរំ
ឯតេន សច្ចវជ្ជេន
ហោតុ មេ ជយមង្គលំ

ប្រែថា នត្ថិ មេ សរណំ អញ្ញំ វត្ថុដទៃជាទីពឹងទីរឭកនៃខ្ញុំព្រះករុណាមិនមានឡើយ ពុទ្ធោ មេ សរណំ វរំ មានតែព្រះពុទ្ធជាម្ចាស់ជាទីពឹងទីរឭកដ៏ប្រសើររបស់ខ្ញុំព្រះករុណា ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ សូមសិរីសួស្ដីជ័យមង្គល ចូរមានដល់ខ្ញុំព្រះករុណាដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

បេ្តជ្ញាដូច្នេះរួចហើយ គប្បីសូត្រសូមខមាទោសនឹងព្រះពុទ្ធជាម្ចាស់ថា:

ឧត្តមង្គេន វន្ទេហំ

បាទបំសុំ វរុត្តមំ

ពុទ្ធេ យោ ខលិតោ

ទោសោ ពុទ្ធោ ខមតុ តំ មមំ ។

ប្រែថា ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវលំអងធូលីព្រះបាទនៃព្រះសម្មាសម្ពុទ្ធដ៏ប្រសើរខ្ពង់ខ្ពស់ ដោយអវៈយវៈដ៏ឧត្តមគឺត្បូង ពុទ្ធេ យោ ខលិតោ ទោសោ ទោសឯណាដែលខ្ញុំព្រះករុណាធ្វើឱ្យភ្លាំងភ្លាត់ហើយក្នុងព្រះពុទ្ធជាម្ចាស់ ពុទ្ធោ ខមតុ តំ មមំ សូមព្រះពុទ្ធជាម្ចាស់អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។

ធម្មរតនប្បណាម

*ថ្វាយបង្គំធម្មរតនៈ*

អដ្ឋង្គិការិយបថោ ជនានំ

មោក្ខប្បវេសាយ ឧជូ ច មគ្គោ

ធម្មោ អយំ សន្តិករោ បណីតោ

## និយ្យានិកោ តំ នមាមិ ធម្មំ ។

ប្រែថា ព្រះសទ្ធម្មឯណា ជាធម៌ប្រកបដោយអង្គ ៨ ប្រការ ជាគន្លងដំណើរនៃ ព្រះអរិយបុគ្គលជាម្ចាស់ ជាផ្លូវដ៏ត្រង់ញុំាំងកិរិយាញុំាំងជន ដែលប្រាថ្នានូវព្រះនិព្វាន ឲ្យចូលទៅកាន់ព្រះនិព្វានពេន ព្រះធម៌នេះជាធម៌ធ្វើឲ្យត្រជាក់រម្ងាប់នូវភ្លើងទុក្ខ ភ្លើងកិលេស ជាធម៌ដ៏ឧត្តម ជាគុណញុំាំងសត្វឲ្យចេញចាកសង្សារទុក្ខ ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវ ព្រះសទ្ធម្មនោះដោយគោរព ។

**ក្រាបថ្វាយបង្គំម្តង**

នមស្សការដល់ព្រះសទ្ធម្មដូចសេចក្តីខាងលើនេះ គឺនមស្សការដោយសង្ខេប មិនបានញែកកាលចេញជា ៣ ឡើយ បើនមស្សការដោយពិស្តារវិញ ទើបញែកកាលជា ៣ ដូចសេចក្តីខាងក្រោម:

យេ ច ធម្មា អតីតា ច
យេ ច ធម្មា អនាគតា
បច្ចុប្បន្នា ច យេ ធម្មា
អហំ វន្ទាមិ សព្វទា ។

ប្រែថា ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ដែលនិព្វានកន្លងទៅហើយក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធនឹងមានមក ក្នុងកាលខាងមុខក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធទ្រង់ ប្រតិស្ឋានទុកក្នុងកាលសព្វថ្ងៃនេះក្តី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះធម៌ ទាំងឡាយនោះគ្រប់កាលទាំងពួង ។

**ក្រាបថ្វាយបង្គំម្តង**

រួចហើយគប្បីតាំងចិត្តរឭកដល់ធម្មគុណដោយបង្អោនវាចាថា :

ស្វាក្ខាតោ ភគវតា ធម្មោ

សន្ទិដ្ឋិកោ អកាលិកោ

ឯហិបស្សិកោ ឱបនយិកោ

បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ

ប្រែថា ស្វាក្ខាតោ ភគវតា ធម្មោ ព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដក ជាធម៌គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងហើយដោយល្អ ធម្មោ ព្រះនព្វលោក-កុត្តរធម៌ មាន ៩ ប្រការគឺមគ្គ ៤ ផល ៤ និព្វាន ១ សន្ទិដ្ឋិកោ ជាធម៌គឺព្រះអរិយបុគ្គលទាំងពួងដឹងពិតឃើញពិតដោយបច្ចវេក្ខណញ្ញាណ គឺថានឹងបានដឹងដោយស្តាប់ដោយជឿបុគ្គលដទៃនោះ ៗ ក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង អកាលិកោ ជាធម៌ឱ្យនូវផលមិនរង់ចាំកាល គឺថាកាលបើព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយផលក៏កើតក្នុងលំដាប់គ្នាមិនបានយឺតយូរឡើយ ឯហិបស្សិកោ ជាធម៌គួរដល់ឯហិ-បស្សវិធី គឺថាបើព្រះអរិយបុគ្គលដែលបានសម្រេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គលដទៃឱ្យចូលមកមើលបាន ឱបនយិកោ ជាធម៌គឺព្រះអរិយបុគ្គល គប្បីបង្អោនចូលមកទុកក្នុងខ្លួនដោយអំណាចនៃភាវនា បច្ចត្តំ វេទិតព្វោ វិញ្ញូហិ ជាធម៌គឺអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹងគប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។

រឭកដល់ព្រះធម្មគុណដូច្នេះរួចហើយ គប្បីប្រកាសប្ដេជ្ញាខ្លួនដោយពាក្យសច្ចៈថា :

នត្ថិ មេ សរណំ អញ្ញំ
ធម្មោ មេ សរណំ វរំ
ឯតេន សច្ចវជ្ជេន
ហោតុ មេ ជយមង្គលំ ។

ប្រែថា នត្ថិ មេ សរណំ អញ្ញំ វត្ថុដទៃជាទីពឹងទីរឭកនៃខ្ញុំព្រះករុណាមិនមានឡើយ ធម្មោ មេ សរណំ វរំ មានតែព្រះធម៌ជាម្ចាស់ជាទីពឹងទីរឭកដ៏ប្រសើររបស់ខ្ញុំព្រះករុណា ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ សូមសិរីសួស្ដីជយមង្គលចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

ប្ដេជ្ញាខ្លួនដូច្នោះរួចហើយ គប្បីសូត្រសូមខមាទោស នឹងព្រះធម៌ជាម្ចាស់ថា :

ឧត្តមង្គេន វន្ទេហំ
ធម្មញ្ច ទុវិធំ វរំ
ធម្មេ យោ ខលិតោ ទោសោ

ធម្មោ ខមតុ តំ មមំ ។

ប្រែថា ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះធម៌ដ៏ប្រសើរមានពីរប្រការ គឺ ព្រះបរិយត្តិធម៌និងព្រះនព្វលោកុត្តរធម៌ ដោយអវៈយវៈដ៏ឧត្តមគឺត្បូង ធម្មេ យោ ខលិតោ ទោសោ ទោសឯណាដែលខ្ញុំព្រះករុណាធ្វើឱ្យភ្លាំងភ្លាត់ហើយក្នុង ព្រះធម៌ជាម្ចាស់ ធម្មោ ខមតុ តំ មមំ សូមព្រះធម៌ជាម្ចាស់អត់នូវទោសនោះដល់ខ្ញុំព្រះព្រះករុណា ។

**ក្រាបថ្វាយបង្គំទូល**

## សង្ឃរតនប្បណាម

*ថ្វាយបង្គំព្រះសង្ឃរតនៈ*

សង្ឃោ វិសុទ្ធោ វរទក្ខិណេយ្យោ
សន្តិន្ទ្រិយោ សព្វមលប្បហីនោ
គុណេហិនេកេហិ សមិទ្ធិបត្តោ
អនាសវោ តំ បនមាមិ សង្ឃំ ។

ប្រែថាព្រះអរិយសង្ឃឯណាដ៏បរិសុទ្ធវិសេស ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ មានឥន្ទ្រិយរម្ងាប់បង់ហើយ មានមន្ទិលគឺរាគាទិក្កិលេសបន្សាត់បង់ហើយ

ជាព្រះសង្ឃដល់ហើយនូវកិរិយាសម្រេចដោយគុណទាំងឡាយដ៏ច្រើន ជាព្រះសង្ឃមានអាសវធម៌មិនមាន គឺថាជាព្រះខីណាស្រព ខ្ញុំព្រះករុណាសូមក្រាបថ្វាយ បង្គំនូវព្រះអរិយសង្ឃនោះដោយគោរព ។

**ក្រាបថ្វាយបង្គំម្ដង**

នមស្សការដល់ព្រះអរិយសង្ឃដូចខាងលើនេះ គឺនមស្សការដោយសង្ខេប មិនបានវែកញែកកាលចេញជា៣ ឡើយ បើនមស្សការដោយពិស្ដារវិញទើបញែកកាលចេញជា ៣ ដូចសេចក្ដីខាងក្រោមនេះ :

យេ ច សង្ឃា អតីតា ច
យេ ច សង្ឃា អនាគតា
បច្ចុប្បន្នា ច យេ សង្ឃា
អហំ វន្ទាមិ សព្វទា ។

ប្រែថា ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គនឹងផលកន្លងទៅហើយក្ដី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គនឹងផលក្នុងកាលខាងមុខក្ដី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គ នឹងផលក្នុងកាលជាបច្ចុប្បន្ននេះក្ដី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសង្ឃទាំងឡាយនោះគ្រប់កាលទាំងពួង ។

**ក្រាបថ្វាយបង្គំម្ដង**

រួចហើយគប្បីតាំងចិត្តរឭកដល់សង្ឃគុណដោយបង្អោនកាយវាចាថា:

សុបដិបន្នោ ភគវតោ សាវកសង្ឃោ
ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ
ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ
សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ
យទិទំ ចត្តារិ បុរិសយុគានិ
អដ្ឋបុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ
អាហុនេយ្យោ បាហុនេយ្យោ
ទក្ខិណេយ្យោ អញ្ជលិករណីយោ
អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

ប្រែថា សុបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺ ប្រតិបត្តិតាមគន្លងព្រះនព្វលោកុត្តរធម៌ ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគលោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមបដិបទា ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជា

សាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ជាស្ថានក្សេមផុតចាកទុក្ខទាំងពួង **សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សម គួរដល់សាមីចិកម្ម គឺ ប្រតិបត្តិគួរដល់សីល សមាធិ បញ្ញា **យទិទំ ចត្តារិ បុរិសយុគានិ** ព្រះសង្ឃឯណាបើរាប់ជាគូនៃបុរសទាំងឡាយមាន ៤ គូគឺ ព្រះសង្ឃ ដែលបានសម្រេចនូវសោតាបត្តិមគ្គនិងសោតាបត្តិផលជាគូ ១ សកទាគាមិមគ្គ និងសកទាគាមិផលជាគូ១ អនាគាមិមគ្គនិងអនាគាមិផលជាគូ១ អរហត្តមគ្គ និង អរហត្តផលជាគូ ១ **អដ្ឋបុរិសបុគ្គលា** បើរាប់រៀងជាបុរសបុគ្គល មាន៨ គឺ ព្រះសង្ឃដែល បានសម្រេចនូវសោតាបត្តិមគ្គ ១ សោតាបត្តិផល ១ សកទាគាមិមគ្គ ១ សកទាគាមិផល ១ អនាគាមិមគ្គ១ អនាគាមិផល ១ អរហត្តមគ្គ ១ អរហត្តផល **ឯស ភគវតោ សាវកសង្ឃោ** ព្រះសង្ឃទាំងនោះជាសង្ឃសាវកនៃព្រះដ៏មានព្រះភាគ **អាហុនេយ្យោ** លោកគួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយនាំមកអំពីចម្ងាយបង្អោនចូលមកបូជា **បាហុនេយ្យោ** លោកគួរទទួលនូវអាគន្តុកទាន គឺទានដែលបុគ្គលតាក់តែងដើម្បីញាតិនិងមិត្រ ដែលមកអំពីទិសផ្សេងៗ ហើយបង្អោនចូលមកបូជា **ទក្ខិណេយ្យោ** លោកគួរទទួលនូវទានដែលបុគ្គលជឿនូវកម្មនឹងផលនៃកម្ម

ហើយបូជា អញ្ជលិករណីយោ លោកគួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជគឺបុណ្យនៃសត្វលោករកខេត្តដទៃក្រៃលែងជាងគ្មាន ។

រឭកដល់សង្ឃគុណ ដូច្នេះរួចហើយ គប្បីប្រកាសប្ដេជ្ញាខ្លួនដោយពោលពាក្យសច្ចៈថា :

នត្ថិ មេ សរណំ អញ្ញំ
សង្ឃោ មេ សរណំ វរំ
ឯតេន សច្ចវជ្ជេន
ហោតុ មេ ជយមង្គលំ ។

ប្រែថា នត្ថិ មេ សរណំ អញ្ញំ វត្ថុដទៃជាទីពឹងទីរឭកនៃខ្ញុំព្រះករុណាមិនមានឡើយ សង្ឃោ មេ សរណំ វរំ មានតែព្រះសង្ឃជាទីពឹងទីរឭកដ៏ប្រសើររបស់ខ្ញុំព្រះករុណា ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ សូមសិរីសួស្ដីជយមង្គលចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

ប្ដេជ្ញាដូច្នេះរួចហើយ គប្បីសូត្រសូមខមាទោសនឹងព្រះសង្ឃជាម្ចាស់ថា :

ឧត្តមង្គេន វន្ទេហំ
សង្ឃញ្ច ទុវិធោត្តមំ
សង្ឃេ យោខលិតោ ទោសោ
សង្ឃោ ខមតុ តំ មមំ ។

ប្រែថា ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះសង្ឃដ៏ប្រសើរមានពីរប្រការគឺ សម្មតិសង្ឃ និងអរិយសង្ឃដោយអវៈយវៈដ៏ឧត្តមគឺត្បូង សង្ឃេ យោ ខលិតា ទោសោ ទោសឯណាដែលខ្ញុំព្រះករុណាធ្វើឱ្យភ្លាំងភ្លាត់ ហើយក្នុងព្រះសង្ឃជាម្ចាស់ សង្ឃោ ខមតុ តំ មមំ សូមព្រះសង្ឃជាម្ចាស់អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។

**គ្រាបថ្វាយបង្គំរួច**

វិធីនមស្សការថ្វាយបង្គំនូវព្រះរតនត្រ័យមិនចំពោះកាល និងថ្វាយបង្គំនូវព្រះរតនត្រ័យក្នុងកាលទាំង៣ និងសេចក្ដីរឭកគុណព្រះរតនត្រ័យ និងពាក្យប្ដេជ្ញាខ្លួនចំពោះព្រះរតនត្រ័យ និងថ្វាយបង្គំសូមខមាទោសចំពោះព្រះរតនត្រ័យទាំង៥ន័យដែលបានពោលមកហើយក្នុងខាងដើមនោះ ក៏ចប់ប៉ុណ្ណោះដោយពិស្ដារ ។ អ្នកដែលមានសទ្ធាប្រាថ្នា នឹងនមស្សការដល់ព្រះរតនត្រ័យនោះបើមានពេលឱកាសល្មម និងសូត្រនមស្សការទាំង ៣ បទឱ្យបានចប់សព្វគ្រប់ដោយសេចក្ដីពិស្ដារដូចបែបយ៉ាងខាងដើមនោះ ។

## រតនប្បណាម បែបសង្ខេប

*ព្រមទាំងបូជាគ្រឿងសក្ការៈ*

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ប្រែដូចមុន

ឥតិបិសោ ភគវា អរហំ ។ល។ ភគវាតិ

តំ អរហាទិគុណសំយុត្តំ (១) ពុទ្ធំ សិរសា នមាមិ

តញ្ច ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ ។

ប្រែថា ឥតិបិ សោ ភគវា អរហំ ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសិកសត្រូវពោលគឺកិលេស ព្រមទាំងវាសនាគឺកាយបយោគនិងវិចីបយោគ ។ល។ ភគវាទ្រង់ព្រះនាមថា ភគវា ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ជាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ·តំ អរហា ទិគុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គប្រកបព្រមហើយដោយគុណមានគុណថា អរហំ ជាដើមនោះ ដោយសិរសាគឺត្បូង តញ្ច ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ ។

(១) - ពាក្យថា "អរហាទិគុណសំយុត្តំ" នេះបើប្រើជា "អរហត្តាទិគុណសំយុត្តំ" យ៉ាងនេះវិញក៏បាន ។

ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះសម្មាសម្ពុទ្ធជាម្ចាស់នោះដោយគ្រឿងសក្ការៈទាំងឡាយមានប្រមាណប៉ុណ្ណោះ ។

**គ្រាបថ្វាយបង្គំម្ដង**

ស្វាក្ខាតោ ភគវតា ធម្មោ ។ល។
បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។
តំ ស្វាក្ខាតាទិគុណសំយុត្តំ [១]
ធម្មំ សិរសា នមាមិ ។
ភញ្ជ ធម្មំ ឥមេហិ
សក្ការេហិ អភិបូជយាមិ ។

ប្រែថា ស្វាក្ខាតោ ភគវតា ធម្មោ ព្រះបរិយត្តិធម៌ គឺ ព្រះត្រៃបិដក ជាធម៌គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងហើយដោយល្អ ។ល។ បច្ចត្តំ វេទិតព្វោ វិញ្ញូហិ ជាធម៌គឺអ្នកប្រាជ្ញទាំងឡាយមានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹងគប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន តំ ស្វាក្ខាតាទិគុណសំយុត្តំ ធម្មំ សិរសា នមាមិ ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះធម៌ជាម្ចាស់ ដ៏ប្រកបព្រមហើយ ដោយគុណមានគុណថា ស្វាក្ខាតោ ជាដើមនោះដោយសិរសាគឺត្បូង

[១] ពាក្យថា "ស្វាក្ខាតាទិគុណសំយុត្តំ" នេះបើប្រើជា ស្វាក្ខាតតាទិគុណសំយុត្តិ យ៉ាងនេះវិញក៏បាន ។

តញ្ច ធម្មំ ឥមេហិ សក្ការេហិ អភិបូជយាមិ ខ្ញុំព្រះករុណាសូមបូជាចំពោះនូវព្រះធម៌ជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយមានប្រមាណប៉ុណ្ណោះ ។

**ព្រះបទ្ទ័ះយបទុំម្តូខ**

សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ។ល។
អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។
តំ សុប្បដិបន្នោ ទិគុណេសំយុត្តំ(១) សង្ឃំ
សិរសា នមាមិ តញ្ច សង្ឃំ
ឥមេហិ សក្ការេហិ អភិបូជយាមិ

ប្រែថា សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវកនៃព្រះមានព្រះភាគលោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លងព្រះនព្វលោកុត្តរធម៌ ។ល។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស លោកជាបុញ្ញក្ខេត្តគឺជាទីដុះឡើងនៃពូជគឺបុណ្យនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន តំ សុដិប្បន្នាទិគុណេសំយុត្តំ សង្ឃំ សិរសា នមាមិ ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះសង្ឃជាម្ចាស់ ដ៏ប្រកបព្រមហើយដោយគុណមានគុណថា សុប្បដិ-

(១)- ពាក្យថា "សុប្បដិបន្នាទិគុណសំយុត្តំ" នេះបើប្រែថា សុប្បន្នតាទិគុណសំយុត្តិ យ៉ាងនេះវិញក៏បាន ។

បន្ទោ ជាដើមនោះដោយសិរសាតីត្បូង ឥមញ្ច សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ ខ្ញុំព្រះករុណាសូមបូជាចំពោះនូវព្រះសង្ឃជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយមានប្រមាណប៉ុណ្ណេះ ។

**ក្រាបថ្វាយបង្គំម្ដង**

ឥច្ចេវមច្ចន្ត នមស្សនេយ្យំ
នមស្សមានោ រតនត្តយំ យំ
បុញ្ញាភិសន្ទំ វិបុលំ អលត្ថំ
តស្សានុភាវេន ហតន្តរាយោ ។

ខ្ញុំសូមនមស្ការ លើកហត្ថាឱនសិរសី បង្គំគុណទាំងបី ខ្ពស់លើសលុបលោកាចារ្យ សូមបុណ្យកងកុសល ឱ្យបានដល់យើងខ្ញុំណា ពេញពោរស្មើធារា ដូចជលសាធំទូលាយ សូមឱ្យកំចាត់បង់ អពមង្គលទាំងឡាយ ឱ្យចៀសចេញចាកឆ្ងាយ ក្ដីអន្តរាយកុំបីមាន ដោយកំលាំងអនុភាព បញ្ញាលាភជាប្រធាន កងបុញ្ញរាសីមាន សូមបានក្សាន្តកុំមានមោះ ដោយគុណនមស្ការ ត្រ័យរតនាប្រសើរខ្ពស់ សូមបុញ្ញានិសង្សនោះ ជាក់ដល់ឋាននិព្វានហោង ។

# សុភមង្គលកថា

ពាក្យពោលប្រកាសសូមសេចក្ដីល្អ សេចក្ដីចំរើនគ្រប់យ៉ាង ។

ហោតុ សព្វំ សុមង្គលំ
រក្ខន្តុ សព្វទេវតា
សព្វពុទ្ធានុភាវេន
សោត្ថិ ហោតុ និរន្តរំ ។

ប្រែថា ហោតុ សព្វំ សុមង្គលំ សុមង្គលគឺសេចក្ដីចំរើនដ៏ល្អគ្រប់យ៉ាង ចូរមានដល់ខ្ញុំ រក្ខន្តុ សព្វទេវតា ទេវតាទាំងពួងទាំងឡាយចូររក្សានូវខ្ញុំ សព្វពុទ្ធានុភាវេន ដោយអនុភាពនៃព្រះពុទ្ធគ្រប់ព្រះអង្គ សោត្ថិ ហោតុ និរន្តរំ សូមសិរីសួស្ដីចូរមានដល់ខ្ញុំឱ្យបានគ្រប់ពេលកុំបីមានចន្លោះឡើយ ។

ហោតុ សព្វំ សុង្គលំ
រក្ខន្តុ សព្វទេវតា
សព្វធម្មានុភាវេន
សោត្ថិ ហោតុ និរន្តរំ ។

ប្រែថា ហោតុ សព្វំ សុមង្គលំ សុមង្គលគឺសេចក្តីចំរើនដ៏ល្អគ្រប់យ៉ាង ចូរមានដល់ខ្ញុំ រក្ខន្តុ សព្វទេវតា ទេវតាទាំងពួងទាំងឡាយចូររក្សានូវខ្ញុំ សព្វធម្មានុភាវេន ដោយអនុភាពនៃព្រះធម៌ទាំងពួង សោត្ថិ ហោតុ និរន្តរំ សូមសិរីសួស្តីចូរមានដល់ខ្ញុំឱ្យបានគ្រប់ពេលកុំបីមានចន្លោះឡើយ ។

ហោតុ សព្វំ សុមង្គលំ

រក្ខន្តុ សព្វទេវតា

សព្វសង្ឃានុភាវេន

សោត្ថិ ហោតុ និរន្តរំ ។

ប្រែថា ហោតុ សព្វំ សុមង្គលំ សុមង្គល គឺសេចក្តីចំរើនដ៏ល្អគ្រប់យ៉ាង ចូរមានដល់ខ្ញុំ រក្ខន្តុ សព្វទេវតា ទេវតាទាំងពួងទាំងឡាយ ចូររក្សានូវខ្ញុំ សព្វសង្ឃានុភាវេន ដោយអនុភាពនៃព្រះសង្ឃទាំងពួង សោត្ថិ ហោតុ និរន្តរំ សូមសិរីសួស្តីចូរមានដល់ខ្ញុំ ឱ្យបានគ្រប់ពេលកុំបីមានចន្លោះឡើយ ។

ចប់ត្រៃប្រណាមដោយសង្ខេបតែប៉ុណ្ណោះ

## បាលីខមាទោសនិងថ្វាយខ្លួន

អច្ចយោ មំ ភន្តេ អច្ចគមា យថាពាលំ យថា

យោ
មុឡ្ហំ យថា អកុសលំ } ហំ ភន្តេ កាយេន វា
យា

វាចាយ វា មនសា វា

ភគវតោ
} វា ធម្មស្ស វា សង្ឃស្ស វា អគារវិ
ពុទ្ធស្ស

ភគវា
ស្ស អយ្យោ
អកាសី ត } មេភន្តេ } អច្ចយំ អច្ចយតោ
ស្សា អយ្យា
សង្ឃោ

ត្
ត្
បដិគ្គណ្ហ ន្ } អាយតី សំវរាយ ប្រែថា បពិត្រ
ត្

| | | |
|---|---|---|
| ព្រះ | ដ៏មានព្រះភាគ<br>ករុណា<br>ករុណាទាំងឡាយ<br>សង្ឃ | ដ៏ចំរើនទោសកំហុសដែល |

ប្រព្រឹត្តកន្លងគ្របសង្កត់ហើយនូវខ្ញុំព្រះករុណា តាមដោយខ្ញុំព្រះករុណាជាមនុស្ស ល្ងង់ខ្លៅជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស

| | | |
|---|---|---|
| បពិត្រព្រះ | ដ៏មានព្រះភាគ<br>ករុណា<br>ករុណាទាំងឡាយ<br>សង្ឃ | ដ៏ចំរើន ក្រែងខ្ញុំព្រះករុណាបាន |

| | | |
|---|---|---|
| ធ្វើហើយនូវសេចក្ដី ល្មើសមិនគោរពព្រះ | ដ៏មានព្រះភាគ<br>ពុទ្ធជាម្ចាស់ | ក្ដី |

ដល់ព្រះធម៌ក្ដី ដល់ព្រះសង្ឃក្ដី ដោយកាយក្ដី ដោយវាចាក្ដី ដោយចិត្តក្ដី

| | | | |
|---|---|---|---|
| បពិត្រព្រះ | ដ៏មានព្រះភាគ<br>ករុណា<br>ករុណាទាំងឡាយ<br>សង្ឃ | ដ៏ចំរើនសូមព្រះ | ដ៏មានព្រះភាគ<br>ករុណា<br>ករុណាទាំងឡាយ<br>សង្ឃ |

អត់នូវទោសកំហុសនោះដល់ខ្ញុំព្រះករុណា ព្រោះអំពើនៃទោសនោះជាសេចក្ដីខុសពិត ដើម្បីនឹងបានសង្រួមគឺថានឹងប្រព្រឹត្តឱ្យល្អតទៅក្នុងខាងមុខនោះហោង ។

រួចបើជាបុគ្គលឬគណៈសង្ឃដែលនៅជាប្រធាន នៅទីនោះត្រូវទទួលថា

សាធុ ប្រែថាប្រពៃហើយ ។

បើបុរសត្រូវសូត្រថា យោហំ ថា តស្ស មេ បើស្ត្រីត្រូវសូត្រថា យាហំ ថា តស្សា មេ តាមគួរដល់បាលីភាសាដែលត្រូវផ្លាស់តាមបុរសស្ត្រី ទោះបុរសក្តី ស្ត្រីក្តី បើសូមខមាទោសក្នុងទីចំពោះព្រះភក្ត្រព្រះពុទ្ធរូប ឬ ចំពោះនឹងព្រះសថូបព្រះចេតីយ ដែលបញ្ចុះព្រះសារីរិកធាតុ ព្រះសម្មាសម្ពុទ្ធនោះត្រូវសូត្រថា ភគវតោ វាំ ថា ភន្តេ ភគវាំ ថា បដិគ្គណ្ហតុ បើចំពោះនឹងភិក្ខុ ១ រូប ត្រូវសូត្រថា ពុទ្ធស្ស វាំ ថា ភន្តេអយ្យោ ថា បដិគ្គណ្ហតុ បើចំពោះគណៈគឺភិក្ខុ ២ រូប ឬ ៣ រូបត្រូវសូត្រថាពុទ្ធស្សវាំ ថា ភន្តេ សង្ឃោ ថាបដិគ្គណ្ហតុ ត្រង់សេចក្តី ប្រែក៏មានរបៀបតាមជួរបាលីដែលគាបនោះដែរ ។

បើសុទ្ធតែបុរស ឬ សុទ្ធតែស្ត្រីច្រើននាក់ ឬបុរសនឹងស្ត្រីច្រើននាក់លាយគ្នាតាំងពីពីរនាក់ឡើងទៅ ហើយសូត្រសូមខមាទោសព្រមគ្នានោះ ត្រូវសូត្រថា

អច្ចយោ នោ ភន្តេ អច្ចគមា យថាពា { លេ / លា } យថាមុ

{ ឡ្ហេ / ឡ្ហា } យថាអកុស { លេ / លា } { យេ / យា } មយំ ភន្តេ កាយេន វាំ

វាចាយ វា មនសា វា { ភគវតោ / ពុទ្ធស្ស } វា ធម្មស្ស វា សង្ឃស្ស វា

អគារវំ អករិម្ហា { តេសំ / តាសំ } នោ ភន្តេ { ភគវា / អយ្យោ / អយ្យា / សង្ឃោ }

អច្ចយំ អច្ចយតោ បដិគ្គណ្ហ { តុ / តុ / ន្តុ / តុ } អាយតឹ សំវរាយ

សេចក្ដីប្រែដូចគ្នានឹងបែបមុន ប្លែកគ្នាតែត្រង់ពាក្យថា ខ្ញុំព្រះករុណានោះ ក្នុងទីនេះត្រឡប់ប្រែថា ខ្ញុំព្រះករុណាទាំងឡាយដូច្នេះវិញ ក្រៅអំពីនោះ នៅដូចគ្នាទាំងអស់ ។

បើបុរសត្រូវថា យថាពាលេ យថាមុឡ្ហេ យថាអកុសលេ យេ មយំ ថា តេសំ នោ បើស្ត្រីត្រូវថា យថាពាលា យថាមុឡ្ហា

យថាអកុសលា យា មយំ តាសំ នោ បើទុកជាគ្នាច្រើនមានបុរស មានស្ត្រីលាយគ្នាហើយសូត្រសូមខមាទោសព្រមគ្នានោះ ក៏ត្រូវតែសូត្រខុសគ្នា ត្រង់បទដែលគាបនោះដែរ វៀរលែងតែត្រង់បទដែលគាប ៣ អន្លើ គឺត្រង់បទថា ភគវតោ វា ពុទ្ធស្ស វា ភគវា អយ្យោ អយ្យា សង្ឃោ បដិគ្គណ្ហតុ បដិគ្គណ្ហន្តុ នេះត្រូវសូត្រដូចគ្នាទាំងបុរសទាំងស្ត្រី តែបើគ្នាច្រើន ហើយសូត្រសូមខមាទោសព្រមគ្នាទាំងអស់នោះ បើមិនបាច់សូត្រដោយពាក្យជា ពហុវចនៈតាមបែបខាងក្រោយនេះ នឹងសូត្រដោយពាក្យជាឯកវចនៈតាមបែបមុន នោះក៏បាន ព្រោះសូត្រសូមខមាទោសទាំងអស់គ្នាលុះបានសូមខមាទោសនឹងព្រះ រតនៈត្រ័យដូច្នេះរួចហើយ គប្បីបញ្ចេញវចីភេទប្តេជ្ញាខ្លួនជាអ្នកដល់ព្រះត្រៃ សរណគមន៍ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាទីពឹងទីរឭកដើម្បីនឹងឱ្យឡើង នាម បញ្ញត្តិជាឧបាសក ឬ ឧបាសិកាក្នុងព្រះពុទ្ធសាសនាតទៅ ឯប្តេជ្ញាខ្លួននោះនឹង ប្តេជ្ញាក្នុងទីចំពោះព្រះភក្ត្រព្រះពុទ្ធរូបក៏បាន ចំពោះនឹងព្រះសថូប ឬ ព្រះចេតិយ ដែលបញ្ចុះព្រះសារីរិកធាតុព្រះដ៏មានបុណ្យក៏បាន ចំពោះមុខបុគ្គល ឬ គណៈ ឬ សង្ឃក៏បានបើបុរសតែម្នាក់ហើយប្តេជ្ញាខ្លួនចំពោះមុខបុគ្គល ឬ គណៈសង្ឃនោះ ត្រូវប្តេជ្ញាដោយពោលថា ឯសាហំ ភន្តេ សុចិរបរិនិព្វុតម្បិ តំ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | អយ្យោ | | តុ | | |
| | សកំ | | | | | | |
| ឧបា | | មំ | អយ្យា | ធារេ | ន្តុ | អជ្ជតគ្គេ បាណុបេតំ | |
| | សិកំ | | | | | | |
| | | | សង្ឃោ | | តុ | | |

| | | |
|---|---|---|
| | ករុណា | |
| ប្រែថា បពិត្រព្រះករុណា | ទាំងឡាយ | ដ៏ចំរើន ខ្ញុំព្រះករុណាសូម |
| | សង្ឃ | |

ដល់នូវព្រះដ៏មានព្រះភាគ ដែលទ្រង់បរិនិព្វានទៅអស់ កាលយូរអង្វែង ហើយនោះផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក

| | | |
|---|---|---|
| ករុណា | សក | |
| សូមព្រះករុណាទាំងឡាយ | ជ្រាបនូវខ្ញុំព្រះករុណាថាជាឧបា | បាន |
| សង្ឃ | សិកា | |

ដល់ហើយនូវព្រះរតនត្រ័យជាទីពឹងទីរឭកស្មើដោយជីវិត តាំងអំពីថ្ងៃនេះជាដើម រៀងទៅ ។

រូបបុគ្គលឬគណៈឬសង្ឃត្រូវទទួលថា សាធុ ប្រែថាដូចមុន បើបុរស ត្រូវថា ឧបាសកំ បើស្ត្រីត្រូវថា ឧបាសិកំ ត្រង់ពាក្យថា អយ្យោ ធារេតុ អយ្យា ធារេន្តុ សង្ឃោ ធារេតុ នេះមានសេចក្ដីអធិប្បាយដូចក្នុងវិធីសូមខមាទោស ខាងដើម ។

បើគ្នាច្រើនតាំងពីពីរនាក់ឡើងទៅ ទោះសុទ្ធតែបុរសក្ដី សុទ្ធតែជាស្ត្រីក្ដី បុរសនិងស្ត្រីលាយគ្នាក្ដី ត្រូវសូត្រថា :

ឯ {តេ / តា} មយំ ភន្តេ សុចិរបរិនិព្វុតម្បិ តំ ភគវន្តំ

សរណំ គច្ឆាម ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបា {សកេ / សិកាយោ} នោ

{អយ្យោ / អយ្យា / សង្ឃោ} ធារេ {តុ / ន្តុ / តុ} អជ្ជតគ្គេបាណុបេ {តេ / តា} សរណំ

គ {តេ / តា} ។ សេចក្តីប្រែដូចគ្នានឹងបែបមុន ប្លែកគ្នាតែត្រង់

ពាក្យមុនថា ខ្ញុំព្រះករុណា នោះក្នុងទីនេះថា ខ្ញុំព្រះករុណាទាំងឡាយដូច្នេះវិញ ក្រៅអំពីនោះដូចគ្នាទាំងអស់ ។

បើបុរសតែម្នាក់ ឬស្ត្រីតែម្នាក់ហើយសូត្រប្តេជ្ញាខ្លួនចំពោះព្រះពុទ្ធរូប ឬព្រះសថូបព្រះចេតិយ ដែលបញ្ចុះព្រះសារីរិកធាតុព្រះដ៏មានបុណ្យនោះត្រូវពោលប្តេជ្ញា ដោយពាក្យថា :

ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច

សកំ
ឧបា } មំ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ ។
សិកំ

ប្រែថា បពិត្រព្រះដ៏មានព្រះភាគដ៏ចំរើន ខ្ញុំព្រះករុណាសូមដល់នូវព្រះដ៏មានព្រះភាគផង នូវព្រះធម៌ផង នូវព្រះសង្ឃផងជាទីពឹងទីរឭកសូមព្រះដ៏មានព្រះភាគទ្រង់ជ្រាបនូវខ្ញុំព្រះករុណាថាជាឧបា សក / សិកា } បានដល់ហើយនូវព្រះរតនត្រ័យជាទីពឹងទីរឭកស្មើដោយជីវិត តាំងអំពីថ្ងៃនេះជាដើមរៀងទៅ ។

បើគ្នាច្រើនក៏ត្រូវសូត្រដូចន័យមុន ខុសគ្នាត្រង់ពាក្យថា ភគវន្តំ ថា ភគវា ប៉ុណ្ណោះ បើគ្នាច្រើនហើយនឹងសូត្រប្ដេជ្ញាខ្លួនព្រមគ្នាដោយពាក្យជាឯកវចនៈក៏បាន ព្រោះសូត្រប្ដេជ្ញាខ្លួនព្រមទាំងអស់គ្នា ។

បុរសឬស្ត្រី កាលបើបានពោលពាក្យប្ដេជ្ញាខ្លួនជាអ្នកបានដល់ព្រះត្រៃសរណគមន៍ ជាទីពឹងទីរឭកដូច្នេះហើយ ក៏បាននាមបញ្ញត្តិថា ឧបាសក ឬ ឧបាសិកាក្នុងខណៈនោះឯង ។ វិធីសូមខមាទោសក្ដី វិធីប្ដេជ្ញាខ្លួនជាឧបាសកឧបាសិកាក្ដី បើអ្នកដែលមិនសូវចេះសូត្រជាបាលី នឹងសូត្រជាសេចក្ដីសំរាយតាមភាសារបស់ខ្លួននោះក៏បាន បើចេះសូត្រទាំងបាលី ទាំងសេចក្ដីប្រែជាសំរាយផង ដូចបានពោលមកហើយនោះជាការប្រពៃពិត តែកុំសូត្រតែបាលីទទេដោយមិនដឹងសេចក្ដី ថាជាអ្វី

នោះឡើយ ព្រោះកិច្ចដែលសូត្រខមាទោសនឹងប្ដេជ្ញាខ្លួននេះ ចំពោះយកសទ្ធា គឺសេចក្ដីជឿជាក់នឹងបញ្ញា ជាសម្មាទិដ្ឋិដែលដឹងពិត យល់ត្រូវពិតជាប្រមាណ ។

**ចប់បុព្វភាគប្បដិបត្តិតែប៉ុណ្ណោះ**

# អាជីវៈនៃឧបាសក

កិរិយាលះបង់នូវជំនួញខុស ៥ ប្រការ ហើយប្រកបកិច្ចការចិញ្ចឹមជីវិតដោយត្រឹមត្រូវតាមធម៌ ឈ្មោះថាអាជីវៈនៃឧបាសក ដូចមានពុទ្ធប្បញ្ញត្តិដែលព្រះសម្មាសម្ពុទ្ធទ្រង់ហាមចំពោះនឹងភិក្ខុទាំងឡាយថា បញ្ចិមា ភិក្ខវេ វណិជ្ជា ឧបាសកេន អករណីយា ម្នាលភិក្ខុទាំងឡាយ ជំនួញខុសទាំងឡាយ៥ប្រការ ឧបាសកមិនគប្បីធ្វើឡើយ ជំនួញខុស ៥ ប្រការនោះគឺ :

១- សត្ថវណិជ្ជា ជួញគ្រឿងសាស្ត្រាវុធ សម្រាប់ប្រហារ គឺធ្វើគ្រឿងសាស្ត្រាវុធនោះដោយខ្លួនឯង ឬឱ្យអ្នកដទៃគេធ្វើឱ្យឬបានមកដោយហេតុឯណាមួយ ហើយលក់នូវគ្រឿងសាស្ត្រាវុធនោះ ។

២- សត្តវណិជ្ជា ជួញមនុស្ស ។

៣- មំសវណិជ្ជា ជួញសាច់ គឺចិញ្ចឹមនូវសត្វទាំងឡាយ មានជ្រូកជាដើម លុះដល់សត្វទាំងឡាយនោះចំរើនធំឡើងក៏សម្លាប់យកសាច់លក់ ។

៤- មជ្ជវណិជ្ជា ជួញទឹកស្រវឹង គឺផ្សំគ្រឿងឯណា ១ ឱ្យកើតឡើងដោយខ្លួនឯង ឬ ទិញគេយកមកហើយលក់នូវទឹកស្រវឹងនោះ ។

៥- វិសវណិជ្ជា ជួញថ្នាំពិស គឺចាត់ចែងផ្សំថ្នាំពិសឱ្យកើតឡើងដោយខ្លួនឯង ឬឱ្យគេផ្សំឱ្យ ឬបានមកដោយហេតុឯណាមួយ ហើយលក់នូវថ្នាំពិសនោះ ។

ឧបាសក កាលបើវៀរចាកជំនួញខុសទាំង ៥ ប្រការនេះហើយបានប្រកប កិច្ចការចិញ្ចឹមជីវិតដោយធម៌ ឈ្មោះថាមានអាជីវធម៌ដោយប្រពៃ ។

## វិបត្តិនៃឧបាសក

ធម្មជាតិដែលញ៉ាំងសីលនិងអាជីវធម៌នៃឧបាសកឱ្យវិនាស ឈ្មោះថា វិបត្តិ ។ នោះមាន ៥ យ៉ាងគឺ :

១- អស្សទ្ធោ ហោតិ ឧបាសកមិនជឿគុណព្រះរតនត្រ័យ ។

២- ទុស្សីលោ ហោតិ ឧបាសកទ្រុស្តសីល ។

៣- កោតុហលមង្គលិកោ ហោតិ ឧបាសកប្រកបដោយមង្គល ភ្ញាក់ផ្អើល ។

៤- មង្គលំ បច្ចេតិ នោ កម្មំ ឧបាសកប្រកាន់ជឿថា មង្គលមានឫក្សពារវេលាជាដើមឱ្យផល មិនប្រកាន់ជឿកម្មជាអកុសលឱ្យ ផលឡើយ ។

៥- ឥតោ ច ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ តត្ថ ច បុព្វេការំ ករោតិ ឧបាសកស្វែងរកតែទក្ខិណេយ្យបុគ្គលខាងក្រៅព្រះពុទ្ធ សាសនានោះ ។

ឧបាសកឯណា ប្រកបដោយវិបត្តិ ៥ យ៉ាងនេះ ត្រង់វិបត្តិឯណាមួយហើយ ឧបាសកនោះឈ្មោះថា ឧបាសកចណ្ឌាល គឺឧបាសកដូចជាមនុស្សចណ្ឌាលផង ឈ្មោះថា ឧបាសកមលៈគឺ ឧបាសកមានធម៌ជាមន្ទិលសៅហ្មងផង ឈ្មោះថាឧបាសក បដិកិដ្ឋៈគឺឧបាសកដែលអ្នកប្រាជ្ញទាំងឡាយលោកតិះដៀលផង ។

## សម្បត្តិនៃឧបាសក

ធម្មជាតិដែលញ៉ាំងសីលនិងអាជីវធម៌នៃឧបាសក ឱ្យបរិបូណ៌ឱ្យបរិសុទ្ធប្រពៃឈ្មោះថា សម្បត្តិ១ នោះមាន ៥ យ៉ាងគឺ :

១- សទ្ធោ ហោតិ ឧបាសកមានសេចក្ដីជឿជាក់ច្បាស់ក្នុងគុណព្រះរតនត្រ័យថា ។

២- សីលវា ហោតិ ឧបាសកមានសីល ។

៣- ន កោតុហលមង្គលិកោ ហោតិ ឧបាសកមិនប្រកបដោយមង្គលភ្ញាក់ផ្អើល ។

៤- កម្មំ បច្ចេតិ នោ មង្គលំ ឧបាសកប្រកាន់ជឿថាកម្មជាកុសលនិងអកុសលឱ្យផល មិនប្រកាន់ជឿថាមង្គលមានឫកពារវេលាជាដើមឱ្យផលឡើយ ។

៥- ន ឥតោ ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ ឥធ ច បុព្វការំ ករោតិ ឧបាសកមិនស្វែងរកទក្ខិណេយ្យបុគ្គល គឺបដិគ្គាហកៈ អ្នកទទួលទានខាងក្រៅព្រះពុទ្ធសាសនាឡើយ ហើយធ្វើទានតែក្នុងទក្ខិណេយ្យបុគ្គលក្នុងព្រះពុទ្ធសាសនា ។ ឧបាសកឯណាប្រកបដោយសម្បត្តិ ៥ យ៉ាងនេះហើយ ឧបាសកនោះឈ្មោះថា ឧបាសករតនៈគឺ ឧបាសកដូចជារតនៈវត្ថុមានកែវជាដើមផង ឈ្មោះថា ឧបាសកបទុមៈ គឺ ឧបាសកដូចជាផ្កាឈូកមានពណ៌ក្រហមផង ឈ្មោះថាឧបាសកបុណ្ឌរិកៈ គឺឧបាសកដូចជាផ្កាឈូកមានពណ៌សផង ។

## គុណនៃឧបាសក -

ធម៌សំរាប់ឧបាសកឧបាសិកាប្រតិបត្តិគ្រប់រូប ដើម្បីនឹងឱ្យចំរើននូវសម្បត្តិទាំងពួងឈ្មោះថាគុណ ។ នេះជារបស់ឧបាសកឧបាសិកា ហៅថាឧបាសកគុណ មាន ១០ យ៉ាងគឺ :

១- សង្ឃេន សទ្ធឹ សមាន សុខទុក្ខោ ហោតិ ឧបាសកអ្នករួមសេចក្ដីសុខទុក្ខមួយអន្លើដោយភិក្ខុសង្ឃ គឺថាបើភិក្ខុសង្ឃមានសេចក្ដីសុខក៏ត្រេកអរ បើភិក្ខុសង្ឃមានសេចទីទុក្ខ ក៏ព្រួយជាមួយផង ។

២- កាយិកវាចសិកញ្ច សុរក្ខិតំ ហោតិ ឧបាសកមានកាយកម្មនិងវចីកម្មរក្សាហើយដោយប្រពៃ :

៣- ធម្មោ អធិបតេយ្យោ ហោតិ ឧបាសកមានធម៌ជាអធិបតី គឺថាកាលបើប្រព្រឹត្តធ្វើអ្វីៗ រមែងកាន់យកធម៌ ជាធំជាទីតាំង ជាទីអាងមាំមិនខុស មិនឱ្យឃ្លៀងឃ្លាតអំពីធម៌ឡើយ ។

៤- យថា ថាមេន សំវិភាគរតោ វ ហោតិ ឧបាសកជាអ្នកត្រេកអរ ក្នុងការបរិច្ចាគទាន តាមសមគួរដល់កំឡាំងនៃខ្លួន គឺធ្វើទានតាមសមគួរដល់ទ្រព្យតិចនិងច្រើន បើមានតិចក៏ធ្វើតិច បើមានច្រើនក៏ធ្វើច្រើន មិនមានមច្ឆរិយធម៌គ្របសង្កត់សន្ដានចិត្តឡើយ ។

៥- ជិនសាសនំ ជានិតុញ្ច វាយមតិ ឧបាសកឧស្សាហ៍ព្យាយាមដើម្បីនឹងឱ្យដឹងច្បាស់នូវសាសនៈ គឺពាក្យប្រៀនប្រដៅ ពាក្យបណ្ដាំនៃព្រះជិនស្រី ។

៦- សម្មាទិដ្ឋិកោ វ ហោតិ ឧបាសកជាសម្មាទិដ្ឋិ គឺមានប្រាជ្ញាឃើញត្រូវតាមសេចក្ដីពិត ។

៧- អបគតោ កោតុហលមង្គលិកោ វ ហោតិ ឧបាសកប្រាសចាកមង្គលភ្ញាក់ផ្អើល ហើយជាអ្នកមិនប្រកាន់ជឿថា មង្គលមានឫក្សពារវេលាជាដើមឱ្យផលឡើយ ប្រកាន់ជឿតែកម្មជាកុសល និងអកុសលថាឱ្យផល ។

៨- ជីវិតហេតុបិ អញ្ញំ សត្ថារំ ន ឧទ្ទិសតិ ឧបាសកបើជាមានហេតុគួរដល់នូវសេចក្តីវិនាសជីវិតក្តី ក៏មិនលះបង់ព្រះរតនត្រ័យ ហើយត្រឡប់ទៅកាន់យកមនុស្សដទៃជាគ្រូអាចារ្យជាទីពឹងរបស់ខ្លួន ថាប្រសើរជាងព្រះរតនត្រ័យនោះឡើយ ។

៩- សមគ្គារាមោ វ ហោតិ ឧបាសកមានសេចក្តីត្រេកអរក្នុងសាមគ្គីធម៌ គឺសេចក្តីព្រមព្រៀងគ្នា ។

១០- សាសនេ ចរតិ ឧបាសកប្រព្រឹត្តល្អក្នុងព្រះពុទ្ធសាសនា គឺប្រព្រឹត្តតាមតែធម៌វិន័យជាពុទ្ធសាសនា ។

ឧបាសកគុណទាំង១០យ៉ាងនេះ ឧបាសក ឧបាសិកាគប្បីប្រតិបត្តិឱ្យសុចរិតផូរផង់ក្នុងព្រះពុទ្ធសាសនា ហើយឱ្យបានជាបច្ច័យនៃនិព្វានសម្បត្តិផង ។

**ចប់ឧបាសកនិទ្ទេសដោយសង្ខេបប៉ុណ្ណេះ**

## វិធីសមាទាននិច្ចសីល

ពុទ្ធសាសនិកជនដែលបានដល់ព្រះត្រៃសរណគមន៍ បានឡើងនាមបញ្ញត្តិជាឧបាសកឧបាសិកាហើយ កាលបើនឹងសមាទាននូវនិច្ចសីល ៥ ជាបច្ចេកសមាទានអំពីបុគ្គលដទៃ គឺភិក្ខុឬសាមណេរនោះ គប្បីសូត្រនមស្សការថ្វាយបង្គំរំឭកគុណព្រះរតនត្រ័យដោយសង្ខេបជាមុន រួចហើយត្រូវសូមនូវនិច្ចសីលព្រមទាំងត្រៃសរណៈគមន៍ ចំពោះនឹងភិក្ខុ ឬ សាមណេរដែលនឹងសមាទាននោះថា :

ឧកាស { អហំ / មយំ } ភន្តេ វិសុំវិសុំ

រក្ខនត្ថាយ តិសរណេន សហ បញ្ច សីលានិ យាចា { មិ / ម }

{ ទុតិ / តតិ } យម្បិ { អហំ / មយំ } ភន្តេ វិសុំវិសុំ រក្ខនត្ថាយ តិសរណេន

សហ បញ្ច សីលានិ យាចា { មិ / ម } ប្រែថា សូមគោរព

បពិត្រព្រះករុណាដ៏ចំរើន ខ្ញុំព្រះ { ករុណា / ករុណាទាំងឡាយ } សូមនូវ

សីលទាំងឡាយ ៥ មួយអន្លើដោយត្រៃសរណគមន៍ ដើម្បីប្រយោជន៍ និងរក្សា

ផ្សេង១ គ្នា បពិត្រព្រះករុណាដ៏ចំរើនខ្ញុំព្រះ { ករុណា / ករុណាទាំងឡាយ } សូមនូវ

សីលទាំងឡាយ ៥ មួយអន្លើដោយត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សា

ផ្សេងៗគ្នាជាគំរប់ { ពីរដងផង / បីដងផង } ។ ឬនឹង

សូមថា ឧកាស { អហំ / មហំ } ភន្តេ វិសុំវិសុំ រក្ខនត្ថាយ តិសរ

ណេន សហ បញ្ចង្គសមន្នាគតំ និច្ចសីលំ

យាចា { មិ / ម } អនុគ្គហំ កត្វា សីលំ ទេថ { មេ / នោ } ភន្តេ { ទុតិ / តតិ } យម្បិ

{ អហំ / មយំ } ភន្តេ វិសុំវិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ចង្គ

សមន្នាគតំ និច្ចសីលំ យាចា { មិ / ម } អនុគ្គហំ កត្វា សីលំ

ទេថ { មេ / នោ } ភន្តេ ប្រែថា សូមគោរព បពិត្រព្រះករុណាដ៏ចំរើន

ខ្ញុំព្រះ { ករុណា / ករុណាទាំងឡាយ } សូមនូវនិច្ចសីល ប្រកបព្រមដោយ

អង្គ ៥ មួយអន្លើ ដោយព្រះត្រៃសរណាគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗគ្នា បពិត្រព្រះករុណាដ៏ចំរើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្ដីអនុគ្រោះឲ្យនូវសីលដល់ខ្ញុំព្រះ { ករុណា / ករុណាទាំងឡាយ } បពិត្រព្រះករុណាដ៏ចំរើនខ្ញុំព្រះ { ករុណា / ករុណាទាំងឡាយ } សូមនូវនិច្ចសីល

ប្រកបដោយអង្គ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗគ្នា ជាគំរប់ { ពីរដងផង / បីដងផង } បពិត្រព្រះករុណាដ៏ចំរើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្ដីអនុគ្រោះដល់ខ្ញុំ ព្រះ { ករុណា / ករុណាទាំងឡាយ } ។

(សូមដូច្នេះក៏បាន តាមសេចក្ដីពេញចិត្តរបស់អ្នកសូម) ។

បើអ្នកសមាទានតែម្នាក់ត្រូវថា អហំ ថា យាចាមិ ត្រង់ ប្រែត្រូវថាខ្ញុំព្រះករុណាសូមថា មេ ត្រង់ប្រែត្រូវថាដល់ខ្ញុំព្រះករុណា បើគ្នាច្រើនតាំងពីពីរនាក់ឡើងទៅ នឹងសូមតែម្នាក់ថា មយំ ថា យាចាម ក៏បាន ត្រង់ប្រែត្រូវថាខ្ញុំព្រះករុណាទាំងឡាយ សូមថា នោ ត្រង់ប្រែត្រូវថា ដល់ខ្ញុំព្រះករុណាទាំងឡាយតែថាបើគ្នាច្រើន ហើយសូត្រសូមព្រមទាំងអស់គ្នានោះ និងសូមសូត្រថា អហំ ថា

យាចាមិ ថា មេ ក៏បានព្រោះសូមទាំងអស់គ្នា លុះសូមដូច្នេះហើយ លោកអ្នកឱ្យសីល លោកសូត្រ នមោ ៣ ចប់ ហើយលោកឱ្យត្រៃសរណគមន៍ និងនិច្ចសីល អ្នកសមាទានត្រូវទទួលថាតាមលោកដោយបញ្ចេញវចីភេទឱ្យច្បាស់លាស់ កុំទទួលខ្សឹបៗ ។

លោកសូត្រ នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស (៣ដង) ប្រែថា កិរិយានមស្សការថ្វាយបង្គំ នៃខ្ញុំព្រះករុណាចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។

ពុទ្ធំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭក ។

ធម្មំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណាសូមដល់នូវព្រះធម៌ជាទីពឹងទីរឭក ។

សង្ឃំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃជាទីពឹងទីរឭក ។

ទុតិយម្បិ { ពុទ្ធំ / ធម្មំ / សង្ឃំ } សរណំ គច្ឆាមិ ខ្ញុំព្រះករុណាសូមដល់នូវព្រះ

| | | | | |
|---|---|---|---|---|
| ពុទ្ធ<br>ធម្ម<br>សង្ឃ | ជាទីពឹងទីរឭក ជាគំរប់ពីរដងផង | តតិយម្បិ | ពុទ្ធំ<br>ធម្មំ<br>សង្ឃំ | សរណំ |

| | | |
|---|---|---|
| គច្ឆាមិ ខ្ញុំព្រះករុណាសូមដល់នូវព្រះ | ពុទ្ធ<br>ធម្ម<br>សង្ឃ | ជាទីពឹងទីរឭក ជាគំរប់បីដងផង ។ |

លោកថា តិសរណគ្គហណំ បរបុណ្ណំ ប្រែថាកិរិយាកាន់យកព្រះត្រៃសរណគមន៍ បរិបូណ៌តែប៉ុណ្ណោះ ។ ត្រូវទទួលថា អាម ភន្តេ ប្រែថា ករុណាលោកម្ចាស់ ។ ហើយលោកឱ្យនិច្ចសីលជាបច្ចេកសមាទានថា :

បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ

ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុ វៀរចាកកិរិយាធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះកន្លងគឺសម្លាប់សត្វ ។

អទិន្នា ទានា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឱ្យដោយកាយឬដោយវាចារ .

កាមេសុ មិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ។

មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាន នូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក.

សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកហេតុជាទីតាំង នៃសេចក្ដីប្រមាទគឺផឹកនូវទឹកស្រវឹងគឺសុរានិងមេរយ ។

រួចហើយលោកអ្នកឱ្យសីលលោកពោលដាស់តឿនក្រើនរំឭកថា :

ឥមានិ បញ្ច សិក្ខាបទានិ សាធុកំ កត្វា អប្បមាទេន

និច្ចកាលំ សម្មារក្ខិតព្វំ ប្រែថា អ្នក / អ្នកទាំងឡាយ } គប្បី

ធ្វើនូវសិក្ខាបទទាំងឡាយ ៥ នេះជាប្រពៃ ត្រូវរក្សាឱ្យល្អអស់កាលជានិច្ច ដោយសេចក្ដីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។ បើអ្នកសមាទានតែម្នាក់ត្រូវថា "អ្នក" បើគ្នាច្រើនត្រូវថា "អ្នកទាំងឡាយ" ។

អ្នកសមាទានត្រូវទទួលថា អាម ភន្តេ (ប្រែដូចមុន) ហើយលោកសម្ដែងអនិសង្សសីលឱ្យស្ដាប់តទៅទៀតថា :

សីលេន សុគតឹ យន្តិ

សីលេន ភោគសម្បទា

សីលេន និព្វុតឹ យន្តិ
តស្មា សីលំ វិសោធយេ ។

ប្រែថា សត្វទាំងឡាយទៅកាន់ឋានសួគ៌បានក៏ព្រោះសីល សត្វទាំងឡាយបរិបូណ៌ដោយភោគក៏ព្រោះសីល សត្វទាំងឡាយបានទៅកាន់ទីរំលត់ទុក្ខ គឺព្រះនិព្វានក៏ព្រោះសីល ព្រោះហេតុនោះបុគ្គលជាសប្បុរស គប្បីជំរះនូវសីលឱ្យបរិសុទ្ធ កុំឱ្យសៅហ្មង។ អ្នកសមាទានត្រូវទទួលថា សាធុ ប្រែថា ប្រពៃហើយ ។

**វិធីសមាទាននិច្ចសីលជាបច្ចេកសមាទានចប់តែប៉ុណ្ណេះ**

## វិធីសមាទានឧបោសថសីល

ឧបាសកឧបាសិកាជាអ្នករក្សានូវឧបោសថសីល កាលបើដល់ថ្ងៃជិតនឹងរក្សានូវឧបោសថសីល គឺថ្ងៃមុន ១ ថ្ងៃដែលកំណត់ ថានឹងរក្សានូវឧបោសថសីលនោះ គប្បីចាត់ចែងការងារដែលគួរនឹងចាត់ចែង មានវិធីចាត់ចែងនូវអាហារជាដើម ដែលជាការងាយ គឺខ្លួននឹងត្រូវធ្វើ ឬនឹងត្រូវឱ្យគេធ្វើក្នុងថ្ងៃស្អែក គឺក្នុងថ្ងៃឧបោសថកាលឱ្យហើយក្នុងថ្ងៃនោះមុន តែកុំចាត់ចែងការងារដែលមិនប្រកបដោយធម៌ គឺខ្លួនជាឧបាសកឧបាសិកាមិនគួរនឹងចាត់ចែងនោះ ឡើយ។

លុះព្រឹកឡើងជាថ្ងៃឧបោសថកាល ត្រូវរក្សានូវឧបោសថសីល គប្បីភ្ញាក់ឡើងអំពីព្រលឹម ហើយខ្ពុរមាត់ជំរះធ្មេញឱ្យស្អាតរួចហើយ បើបានសមាទានពី

ព្រលឹមនោះមិនទាន់ទេ ក៏គប្បីកំណត់នូវឧបោសថកាល គឺកាលជាទីរក្សានូវឧបោសថសីលក្នុង ១ ថ្ងៃ ១ យប់នោះ ដោយបញ្ចេញអធិដ្ឋានថា :

អជ្ជ ឧបោសថោ ឥមញ្ច រត្តិំ ឥមញ្ច ទិវសំ

ឧបោសថិ { កោ / កា } ភវិស្សាមិ ប្រែថា ថ្ងៃនេះជាថ្ងៃត្រូវរក្សានូវឧបោសថសីល ខ្លួនអញនឹងជាអ្នករក្សានូវឧបោសថសីលអស់ថ្ងៃនេះនិងយប់នេះ ។

បើឧបាសកត្រូវថា ឧបោសថិកោ បើឧបាសិកាត្រូវថា ឧបោសថិកា ។

បើមិនចេះបាលី នឹងអធិដ្ឋានតាមភាសារបស់ខ្លួន ៗ ក៏គួរដោយពិត លុះអធិដ្ឋានកំណត់កាលដូច្នេះរួចហើយ ត្រូវតាំងវិរតិចេតនាវៀរចាកសីលភេទ គឺហេតុដែលជាទីទំលាយនៃសីលនោះៗ ឱ្យគ្រប់សិក្ខាបទទាំង ៨ កាលបើបានអធិដ្ឋានដូច្នេះរួចហើយ តអំពីពេលនោះមក ក៏គប្បីសមាទាននូវឧបោសថសីលអំពីបុគ្គលដទៃមានភិក្ខុជាដើម តាមកាលដ៏គួរចុះ បើទុកជាដល់ពេលព្រះអាទិត្យរះខ្ពស់ឡើងប្រមាណពេញពន្លឺធំ បើបានសមាទានក្តី ក៏ឈ្មោះថាបានសមាទានដោយប្រពៃ ឈ្មោះថាបានរក្សានូវឧបោសថសីលពេញកាលកំណត់ ១ ថ្ងៃ ១ យប់

ដោយបរិបូណ៌ ព្រោះអ្នកសមាទានបានធ្វើនូវឧបោសថកាល មិនឱ្យខ្វះខាតទាំងវិរតិចេតនា សោតក៏កើតក្លាបរិបូណ៌ក្នុងសន្តាន និងបានផលានិសង្សច្រើន ។

កាលបើឧបាសកឧបាសិកា នឹងសមាទាននូវឧបោសថសីលប្រកបព្រមដោយអង្គ ៨ ជាបច្ចេកសមាទាន អំពីបុគ្គលដទៃគឺភិក្ខុ ឬ សាមណេរនោះ គប្បីសូត្រនមស្សការថ្វាយបង្គំរំឭកដល់គុណព្រះរតនត្រ័យ ដោយសង្ខេបជាមុនរួចហើយ ត្រូវសូមនូវឧបោសថសីល ព្រមទាំងព្រះត្រៃសរណគមន៍ ចំពោះនឹងភិក្ខុ ឬសាមណេរ ដែលខ្លួននឹងសមាទាននោះថា :

ឧកាស { អហំ / មយំ } ភន្តេ វិសុំវិសុំ រក្ខនត្ថាយ

តិសរណេន សហ អដ្ឋសីលានិ យាចា { មិ / ម } { ទុតិ / តតិ } យម្បិ { អហំ / មយំ }

ភន្តេ វិសុំវិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋសីលានិ យាចា { មិ / ម } ប្រែដូចក្នុងវិធីសូមនិច្ចសីលខាងដើម ប្លែកគ្នាតែត្រង់ថា អដ្ឋ សីលានិ ប្រែថានូវសីលទាំងឡាយ ៨ ។

ឬនឹងសូមថា ឧកាស { អហំ / មយំ } ភន្តេ វិសុំវិសុំ រក្ខនត្ថាយ

តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ

យាចា (មិ / ម) អនុគ្គហំ កត្វា សីលំ ទេថ (មេ / នោ) ភន្តេ (ទុតិ / តតិ)

យម្បិ (អហំ / មយំ) ភន្តេវិសុំវិសុំ រក្ខនត្ថាយ តិសរណេន សហ

អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចា (មិ / ម) អនុគ្គហំ កត្វា

សីលំ ទេថ (មេ / នោ) ភន្តេ ប្រែថា សូមគោរព បពិត្រព្រះករុណាដ៏ចំរើន

ខ្ញុំព្រះ (ករុណា / ករុណាទាំងឡាយ) សូមនូវឧបោសថសីល ប្រកបព្រមដោយអង្គ ៨ មួយ

អន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេង ៗ គ្នា បពិត្រ

ព្រះករុណាដ៏ចំរើន សូមព្រះករុណា ធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់

ខ្ញុំព្រះ (ករុណា / ករុណាទាំងឡាយ) សូមនូវឧបោសថសីលព្រមដោយអង្គ ៨ មួយអន្លើ

ដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍ នឹងរក្សាផ្សេងៗគ្នាជាគំរប់

ពីរដងផង } បពិត្រព្រះករុណា ដ៏ចំរើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្តី
បីដងផង

អនុគ្រោះឱ្យនូវសីលដល់ ខ្ញុំព្រះ { ករុណា / ករុណាទាំងឡាយ } ។ សូមដូច្នេះក៏បាន

តាមសេចក្តីពេញចិត្តរបស់អ្នកសូម សេចក្តីអធិប្បាយអំពីអ្នកសូមតែម្នាក់ និង ច្រើននាក់នោះ ដូចគ្នានឹងវិធីសូត្រនិច្ចសីលខាងដើម ។

រួចហើយលោកអ្នកឱ្យសីលលោកតាំង នមោ ៣ ចប់ ហើយលោកឱ្យព្រះត្រៃសរណគមន៍ អ្នកសមាទានត្រូវទទួលថាតាមលោកដូចវិធីសមាទាននិច្ចសីលខាងដើម រួចហើយលោកឱ្យនូវឧបោសថសីលជាបច្ចេកសមាទានថា :

បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ (ប្រែដូចនិច្ចសីល) ។

អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ (ប្រែដូចនិច្ចសីល) ។

អព្រហ្មចរិយា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុ វៀរចាកកិរិយាប្រព្រឹត្តនូវធម៌មិនប្រសើរ គឺសេពនូវមេថុនធម្ម ។

មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ (ប្រែដូចនិច្ចសីល) ។

សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ (ប្រែដូចនិច្ចសីល) ។

វិកាលភោជនា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាបរិភោគនូវភោជនាហារក្នុងកាលខុស ។

នច្ច គីត វាទិត វិសូកទស្សនមាលា គន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយារាំនិងច្រៀង និងប្រគំនឹងមើលនូវល្បែង ដែលជាសត្រូវដល់កុសលធម៌ និងកិរិយាទ្រទ្រង់ និងប្រដាប់និងតាក់តែងស្អិតស្អាងរាងកាយដោយផ្កាកំរងនិងគ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ ។

ឧច្ចាសយនមហាសយនា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកទីសេនាសនដ៏ខ្ពស់ហួសប្រមាណ នឹងទីសេនាសនៈដ៏ប្រសើរ ។

រួចហើយអ្នកសមាទានសូត្រកំណត់ ឧបោសថកាលថា ឥមំ អដ្ឋង្គសមន្នាគតំ ពុទ្ធប្បញ្ញត្តំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សម្មទេវ អភិរក្ខិតុំ សមាទិយាមិ ប្រែថា ខ្ញុំព្រះករុណាសូមសមាទាននូវឧបោសថសីលដ៏ប្រកបព្រមដោយអង្គ ៨ ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់បញ្ញត្តទុកហើយនេះ ដើម្បីរក្សាឱ្យបរិបូណ៌ប្រពៃអស់កាលកំណត់ថ្ងៃនេះនឹងយប់នេះ សូមកុសលចូលជាឧបនិស្ស័យ ធ្វើឱ្យច្បាប់នូវព្រះនិព្វានពួដ៏អនាគតទៅឯមុខនោះហោង ។

បាលីនេះ គ្រាន់តែជាពាក្យសម្រាប់ពោលកំណត់កាលឱ្យដឹងថា ឧបោសថសីលទាំង ៨ សិក្ខាបទនេះ អ្នកសមាទានត្រូវរក្សាត្រឹម ១ ថ្ងៃ ១ យប់នោះប៉ុណ្ណោះ ហេតុនោះបើអ្នកសមាទាន បានចេះដឹងច្បាស់ប្រាកដក្នុងឧបោសថកាលហើយ មិនបាច់ សូត្រក៏បាន តែបើទុកជាចេះដឹងច្បាស់ប្រាកដហើយនឹងសូត្របាលីនេះព្រមទាំងសេចក្ដីប្រែជាសំរាយផងនោះក៏ជាការប្រពៃណាស់ ជាហេតុនាំឱ្យរឹតតែចេះស្ទាត់ប្រាកដទាំងអស់គ្នាឡើង ។ រួចហើយលោកអ្នកឱ្យសីលលោកពោលដាស់តឿនក្រើនរំឭកថា ឥមានិ អដ្ឋ សិក្ខាបទានិ ឧបោសថសីលវសេន ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សធុកំ កត្វា អប្បមាទេន សម្មា រក្ខិតព្វំ ប្រែថា

| | | |
|---|---|---|
| រក្ខិតព្វំ ប្រែថា | អ្នក / អ្នកទាំងឡាយ | គប្បីធ្វើនូវសិក្ខាបទទាំងឡាយ |

៨ នេះឱ្យប្រពៃ ត្រូវរក្សាឱ្យល្អដោយអំណាចឧបោសថសីល អស់កាលកំណត់ត្រឹម ១ ថ្ងៃ ១ យប់នេះ ដោយសេចក្តីមិនប្រមាទ គឺថា កុំធ្វេសប្រហែសឡើយ។ អ្នកសមាទានត្រូវទទួលថា អាម ភន្តេ (ប្រែដូចមុន) ។ ហើយលោកសំដែងអានិសង្សសីលឱ្យស្តាប់តទៅទៀតថា :

សីលេន សុគតី យន្តិ
សីលេន ភោគសម្បទា
សីលេន និព្វុតី យន្តិ
តស្មា សីលំ វិសោធយេ ។

(ប្រែដូចមុន) អ្នកសមាទានត្រូវទទួលថា សាធុ (ប្រែដូចមុន) ។

**វិធីសមាទានឧបោសថសីលជាបច្ចេកសមាទានចប់តែប៉ុណ្ណេះ ៕**

## ឯកជ្ឈសមាទាន

បើឧបាសកឧបាសិកានឹងសមាទាននិច្ចសីលជាឯកជ្ឈសមាទាន ព្រមទាំងត្រៃសរណគមន៍ផងនោះ ត្រូវសូមដូច្នេះ :

អហំ<br>
ឧកាស } ភន្តេ តិសរណេន សហ ឯកជ្ឈំ<br>
មយំ

កត្វា បញ្ចង្គសមន្នាគតំ និច្ចសីលំ យាចា {មិ / ម} អនុគ្គហំ

កត្វា សីលំ ទេថ {មេ / នោ} ភន្តេ {ទុតិ / តតិ} យម្បិ

{អហំ / មយំ} ភន្តេ តិសរណេន សហ ឯកជ្ឈំ កត្វា បញ្ចង្គសមន្នា

គតំ និច្ចសីលំ យាចា {មិ / ម} អនុគ្គហំ កត្វា សីលំ ទេថ

{មេ / នោ} ភន្តេ ប្រែថា សូមគោរព បពិត្រព្រះករុណាដ៏ចំរើន

ខ្ញុំព្រះ {ករុណា / ករុណាទាំងឡាយ} សូមនូវនិច្ចសីលប្រកបព្រមដោយអង្គ ៥

ធ្វើឱ្យជាឯកជ្ឈៈ គឺសមាទានរួមតែម្តង មួយអន្លើដោយព្រះត្រៃសរណគមន៍

បពិត្រព្រះករុណាដ៏ចំរើន សូមព្រះករុណា មេត្តាធ្វើនូវ សេចក្តីអនុគ្រោះ ឱ្យនូវ

| | | |
|---|---|---|
| សីលដល់ខ្ញុំព្រះ | ករុណា<br>ករុណាទាំងឡាយ | } បពិត្រព្រះករុណាដ៏ចំរើន |
| ខ្ញុំព្រះ | ករុណា<br>ករុណាទាំងឡាយ | } សូមនូវនិច្ចសីលប្រកបព្រមដោយអង្គ ៥ |

ធ្វើឱ្យជាឯកជ្ឈៈ គឺសមាទានរួមតែម្តង មួយអន្លើដោយព្រះសរណគមន៍ ជាគំរប់

| | |
|---|---|
| ពីរដងផង<br>បីដងផង | } បពិត្រព្រះករុណាដ៏ចំរើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្តី |

អនុគ្រោះឱ្យនូវសីលដល់ខ្ញុំព្រះ { ករុណា / ករុណាទាំងឡាយ ។

រួចលោកអ្នកអោយសីលលោកតាំង នមោ ៣ ចប់ រួចហើយលោកឱ្យព្រះត្រៃសរណគមន៍ រួចប្រាប់អំពីកិច្ចការកាន់យកនូវព្រះត្រៃសរណគមន៍ដូចក្នុងវិធីបច្ចេកសមាទានខាងដើម រួចហើយលោកឱ្យនិច្ចសីលជាឯកជ្ឈសមាទានថា បញ្ចង្គសមន្នាគតំ និច្ចសីលំ សមាទិ យាមិ ប្រែថា ខ្ញុំព្រះករុណាសូមសមាទាននូវនិច្ចសីលប្រកបព្រមដោយអង្គ៥ ។ អ្នកសមាទានត្រូវទទួលថាតាមលោក ឬ លោកនឹងឱ្យថា បញ្ចសីលានិ យាចាមិ ប្រែថា ខ្ញុំព្រះករុណាសូមសមាទាននូវសីលទាំងឡាយ ៥ ។ ដូច្នេះក៏បាន អ្នកសមាទានត្រូវទទួលថាតាម

លោក រួចហើយលោកពោលដាស់តឿនក្រើនរំឭកថា ឥមំ បញ្ចង្គសមន្នាគតំ និច្ចសីលំ សាធុកំ កត្វា អប្បមាទេន និច្ចកាលំ សម្មារក្ខិតព្វំ

ប្រែថា { អ្នក / អ្នកទាំងឡាយ } គប្បីធ្វើនូវនិច្ចសីលប្រកបព្រមដោយអង្គ ៥ នេះ ឱ្យប្រពៃ ត្រូវរក្សាឱ្យល្អអស់កាលជានិច្ច ដោយសេចក្ដីមិនប្រមាទ គឺថាកុំធ្វេសប្រហែសឡើយ ។ អ្នកសមាទានត្រូវទទួលថា អាម ភន្តេ (ប្រែដូចមុន) រួចហើយ លោកសម្ដែងអានិសង្សសីលឱ្យស្ដាប់តទៅទៀត ដូចក្នុងវិធីបច្ចេកសមាទានខាងដើម ។

សមាទានតែប៉ុណ្ណេះក៏ជាការស្រេច ឥតមានសូត្រញែកឈ្មោះសិក្ខាបទទាំង ៥ រាយ ១ ម្ដង ១ ដូចបច្ចេកសមាទាននោះឡើយ សមាទានតែប៉ុណ្ណេះហើយត្រូវរក្សាដោយតាំងវិរតិចេតនា វៀរឱ្យគ្រប់សិក្ខាបទក្នុងនិច្ចសីលទាំង ៥ ដែលខ្លួនបានចេះចាំស្ទាត់ហើយនោះទៅ ។ បើឧបាសកឧបាសិកានិងសមាទានឧបោសថសីលជាឯកជ្ឈសមាទាន ព្រមទាំងត្រៃសរណគមន៍ផងនោះ ត្រូវសូមដូច្នេះថា :

{ អហំ / ឧកាស / មយំ } ភន្តេ តិសរណេន សហ ឯកជ្ឈំ

កត្វា អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចា{មិ | ម} អនុគ្គហំ កត្វា

សីលំ ទេថ {មេ | នោ} ភន្តេ {ទុតិ | តតិ} យម្បិ {អហំ | មយំ} ភន្តេ

តិសរណេន សហ ឯកជ្ឈំ កត្វា អដ្ឋង្គសមន្នាគតំ

ឧបោសថំ យាចា{មិ | ម} អនុគ្គហំ កត្វា សីលំ

ទេថ {មេ | នោ} ភន្តេ ប្រែដូចវិធីសូមនិច្ចសីល ជាឯកជ្ឈសមាទានខាងដើម

ប្លែកត្រង់បទថា អដ្ឋង្គសមន្នាគតំ ឧបោសថំ ប្រែថា នូវឧបោសថប្រកបព្រមដោយអង្គ ៨ ប៉ុណ្ណោះ ក្រៅពីនោះដូចគ្នាទាំងអស់ ។ រួចលោកអ្នកឱ្យសីលលោកតាំង នមោ ៣ ចប់ ហើយលោកឱ្យព្រះត្រៃសរណគមន៍ រួចប្រាប់អំពីកិច្ចការកាន់យកនូវព្រះត្រៃសរណគមន៍ដូចន័យមុនរួចហើយ លោកឱ្យឧបោសថ-សីលជាឯកជ្ឈសមាទានថា អដ្ឋង្គសមន្នាគតំ ឧបោសថំ សមាទិយាមិ ប្រែថា ខ្ញុំព្រះករុណាសូមសមាទាននូវឧបោសថសីល ប្រកបព្រមដោយអង្គ ៨ ។

អ្នកសមាទាន ត្រូវទទួលថាតាមលោក ឬ លោកនឹងឱ្យថា អដ្ឋសីលានិ សមាទិយាមិ ប្រែថា ខ្ញុំព្រះករុណាសូមសមាទាននូវសីលទាំងឡាយ ៨។ ដូច្នេះក៏បាន អ្នកសមាទានត្រូវទទួលថាតាមលោករួចហើយអ្នកសមាទានសូត្រកំណត់ឧបោសថកាលថា ឥមំ អដ្ឋង្គ សមន្នាគតំ ពុទ្ធប្បញ្ញត្តំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សម្មទេវ អភិរក្ខិតុំ សមាទិយាមិ (ប្រែដូចមុន) ។ រួចហើយលោកពោលដាស់តឿនក្រើនរំឭកថា ឥមំ អដ្ឋង្គសមន្នាគតំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សាធុកំ

កត្វា អប្បមាទេន សម្មា រក្ខិតព្វំ ប្រែថា អ្នក / អ្នកទាំងឡាយ } គប្បីធ្វើ

នូវឧបោសថសីលប្រកបព្រមដោយអង្គ ៨ នេះឱ្យប្រពៃ ត្រូវរក្សាល្អអស់កាលកំណត់ត្រឹមមួយថ្ងៃមួយយប់នេះ ដោយសេចក្តីមិនប្រមាទ គឺថាកុំធ្វេសប្រហែសឡើយ អ្នកសមាទានត្រូវទទួលថា អាម ភន្តេ (ប្រែដូចមុន) ។ ហើយលោកសំដែងអនិសង្សសីលឱ្យស្តាប់តទៅទៀត ដូចន័យមុន ។ សមាទានតែប៉ុណ្ណេះក៏ជាការស្រេច ឥតមានញែកឈ្មោះសិក្ខាបទទាំង ៨ រាយមួយម្តង ១ ដូចបច្ចេកសមាទាននោះឡើយ សមាទានតែប៉ុណ្ណេះហើយ ត្រូវរក្សាដោយតាំងវិរតិចេតនា វៀរឱ្យគ្រប់សិក្ខាបទទាំង ៨ ក្នុងឧបោសថសីល ដែលខ្លួនបានចេះចាំស្ទាត់ហើយនោះ ។

**ទីធីសមាទានសីលជាឯកជ្ឈសមាទានចប់តែប៉ុណ្ណេះ**

សូម្បីឧបាសកឧបាសិកានឹងអធិដ្ឋាននិច្ចសីល ឬឧបោសថសីលដោយខ្លួនឯងក្តី ក៏គប្បីបញ្ចេញវចីភេទអធិដ្ឋានតាមបែបជាបច្ចេកៈ ឬ ជាឯកជ្ឈៈ ដូចបានពោលមកហើយនោះចុះ ។

ត្រង់វិធីដែលលោកសំដែងអានិសង្សសីល ឱ្យអ្នកសមាទានស្តាប់នោះ បើលោកអ្នកឱ្យសីលលោកឈ្លាសចេះចាំច្រើន ហើយអាចនឹងសំដែងក្នុងពេលនោះបាន ក៏គួរនឹងសំដែងតាមន័យប្លែកៗ ដោយអាងដល់ព្រះពុទ្ធភាសិត ឱ្យអ្នកសមាទានបានស្តាប់ក៏ជាការប្រពៃពេក អ្នកសមាទានស្តាប់ហើយ ក៏នឹងកើតមានសេចក្តីជ្រះថ្លាព្រមទាំងចម្រើនសតិបញ្ញាដោយ ក្រៃលែងឡើងទៀត ហើយនឹងមានផលានិសង្សច្រើនដល់លោកអ្នកឱ្យសីល និង អ្នកសមាទាន ។

**ចប់វិធីសមាទានសីលតែប៉ុណ្ណេះ ៚**

## កំណើតសរណគមន៍

**ប**. ហេតុដែលកើតសរណគមន៍ មានប៉ុន្មានយ៉ាង ?

**វិ**. ហេតុដែលកើតសរណគមន៍ មាន ៣ យ៉ាងគឺ :

**១- ពុទ្ធាទីសុ វត្ថូសុ សទ្ធា បដិលាភោ ច** បាន ចំពោះនូវសេចក្តីជឿក្នុងវត្ថុទាំងឡាយ មានព្រះពុទ្ធជាដើម :

**២-សទ្ធាមូលិកា សម្មាទិដ្ឋិ ច** យល់ឃើញល្អត្រឹមត្រូវ

មានសទ្ធាជាឫសគល់ :

៣-ទិដ្ឋុជុកម្ម ចៈ ការធ្វើនូវទិដ្ឋិឱ្យត្រង់ .

**ប៉ុ.** អ្នកណាដែលដល់នូវសរណគមន៍មុនគេ ?

**វិ.** អ្នកដល់នូវសរណគមន៍មុនគេគឺ ពាណិជទាំង ២ នាក់ គឺ : តបុស្សៈ ១ ភល្លិកៈ ១ ពាណិជទាំង ២ នោះ បានជួបនឹងព្រះអង្គកណ្ដាលផ្លូវ កាលព្រះអង្គយាងទៅប្រោសបញ្ចវគ្គីយ៍ ក៏បានស្ដាប់ធម៌ហើយមានចិត្តជ្រះថ្លា ប្រគល់កាយថ្វាយខ្លួនចំពោះព្រះពុទ្ធ ព្រះធម៌ ឈ្មោះថាទ្វេវាចិកសរណគមន៍ ហើយក៏បានថ្វាយសត្តុវដុំសត្តុវផង់ក្នុងពេលនោះ ក៏សូមព្រះកេសធាតុរបស់ព្រះអង្គ ៨ សរសៃយកទៅទុកសំរាប់នមស្ការបូជា នេះអ្នកដល់នូវសរណគមន៍មុនគេបង្អស់ ។

**ប៉ុ.** ចុះអ្នកណាដល់នូវត្រៃសរណគមន៍មុនគេ ?

**វិ.** អ្នកដល់នូវត្រៃសរណគមន៍មុនគេគឺ : ឪពុកយសកុលបុត្រ ១ និងសក្យមហានាម១ ដល់នូវត្រៃសរណគមន៍មុនគេ ឈ្មោះថាតេវាចិកសរណគមន៍ ។

**ប៉ុ.** ចុះក្នុងពុទ្ធសាសនា អ្នកណាជាឧបាសកមុនគេនោះ ?

**វិ.** ឧបាសកមុនគេនោះគឺ : សក្យមហានាម ដូចពុទ្ធដីកាថា យតោ ខោ មហានាម ឧបាសកោ ពុទ្ធំ សរណំ គតោ ហោតិ ធម្មំ

សរណំ គតោ ហោតិ សង្ឃំ សរណំ គតោ ហោតិ ឯត្តាវតា ខោ មហានាម ឧបាសកោ ហោតិ ។

បពិត្រមហានាម បុគ្គលជាឧបាសកដល់នូវព្រះពុទ្ធជាទីពឹងទីរឭក ដល់នូវព្រះធម៌ជាទីពឹងទីរឭក ដល់នូវព្រះសង្ឃជាទីពឹងទីរឭក ដោយហេតុឯណាពិត. បពិត្រមហានាម ហេតុមានប្រមាណប៉ុណ្ណេះ បុគ្គលនោះឈ្មោះថា ឧបាសក ។

ឬ- តស្មា ឧបាសកោតិ វុច្ចតិ ព្រោះហេតុអ្វី គ្រហស្ថនោះបានជាព្រះពុទ្ធឱ្យឈ្មោះថាឧបាសក ?

វិ- រតនត្តយំ ឧបាសនតោ គ្រហស្ថនោះព្រះពុទ្ធឱ្យឈ្មោះថាឧបាសកព្រោះចូលទៅអង្គុយជិតព្រះរតនត្រ័យ ។

## កំណើតនិច្ចសីល

ឬ- និច្ចសីលនេះ កើតពីត្រឹមណាមក អ្នកណារក្សាមុនគេ ?

វិ- និច្ចសីលនេះ កើតតាំងពីមុនព្រះពុទ្ធបានត្រាស់ តែបានឃើញក្នុងកុរុធម្មជាតក កាលព្រះបាទធនញ្ជ័យបានរក្សាទុកមុនគេបង្អស់ ដូចមានក្នុងកុរុធម្មជាតកថា:

## កុរុធម្មជាតក

អតីតេ កុរុរដ្ឋេ ឥន្ទបត្តនគរេ ធនញ្ជយេ រជ្ជំ ការេន្តេ ពោធិសត្តោ តស្ស អគ្គមហេសិយា កុច្ឆិម្ហិ បដិសន្ធឹ គហេត្វា ។ បេ ។ ភិក្ខុនា នាម ហត្ថេហិ បាទេហិ វាចាយ ច សញ្ញមេនំ ភវិតព្វន្តិ ។

កាលកន្លងទៅហើយ ព្រះបាទធនញ្ជ័យសោយរាជសម្បត្តិក្នុងកុរុរដ្ឋ ក្រុងឥន្ទបត្ត ព្រះពោធិសត្វចាប់បដិសន្ធិក្នុងផ្ទៃអគ្គមហេសី ព្រះធនញ្ជ័យរាជ លុះបានដឹងក្តី ចេញទៅស្វែងរករៀនសិល្បសាស្ត្រនៅនគរតក្កសីលា ដល់ត្រឡប់មកនគរវិញ ក្សត្រិយ៍ជាព្រះវររាជបិតាប្រទាននាទីជាឧបរាជ លុះអំណើះអំពីព្រះវររាជបិតាទៅ ព្រះអង្គសោយរាជសម្បត្តិ ទ្រង់ទសពិធរាជធម៌មិនឱ្យមានមោះម៉ង រក្សាខ្ជាប់ខ្ជួននូវ កុរុធម៌ គឺសីល ៥ ទ្រង់បានអប់រំជននៅក្នុងសង្គមព្រះអង្គ ព្រមទាំងសហការីឱ្យរក្សានូវកុរុធម៌ដូចព្រះអង្គដែរ ដូចយ៉ាងព្រះវរជននីនាថព្រះអង្គ ព្រះអគ្គមហេសីព្រះអង្គ ឧបរាជ, ព្រាហ្មណ៍បុរោហិត អាមាត្យអ្នកកាន់ខ្សែបររថ, នាយសារថី, សេដ្ឋី, មហាអាមាត្យ, នាយឃ្លាំង, នាយឆ្មាំទ្វារ, នាងវណ្ណទាសីជាស្រីផ្កាមាស។ ហេតុដែលជន ១១ រូប រក្សានូវកុរុធម៌ផូរផង់ល្អ បានជារដ្ឋមានភ្លៀងធ្លាក់ឱ្យសម្បូរសប្បាយដោយសុភិក្ខា។ ឯក្នុងកលិង្គរដ្ឋ ទន្តបុរីនគរ ដែលព្រះបាទកាលិង្គៈសោយរាជ្យនោះ ពុំមានភ្លៀងឱ្យចុះឡើយ ។ ពួកប្រជាជនក្នុងកលិង្គរដ្ឋ

ចូលចិត្តថា កុរុរដ្ឋដែលមានភ្លៀងបរិបូណ៌ ដោយសារមានដំរីមង្គល ១ ឈ្មោះ អញ្ជនវសភៈ ក៏នាំគ្នាចូលទៅក្រាបបង្គំទូលព្រះរាជារបស់ខ្លួន ។ ព្រះរាជាក៏ប្រើព្រាហ្មណ៍ទាំងឡាយឱ្យទៅសូមដំរីអំពីព្រះមហាក្សត្រិយ៍ នាំចូលមកកលិង្គរដ្ឋ ។ ទុកណាជាព្រាហ្មណ៍នាំដំរីចូលមកដល់ហើយក៏ដោយ ក៏នៅតែគ្មានភ្លៀង ទើបព្រះបាទកាលិង្គរាជទ្រង់ព្រះចិន្តាច្បាស់ថា ព្រះរាជាអង្គនោះរក្សានូវកុរុធម៌ បានជាមានភ្លៀងធ្លាក់ក្នុងដែនព្រះអង្គ ។ ទ្រង់ក៏ប្រើព្រាហ្មណ៍និងអាមាត្យទាំងឡាយ ឱ្យទៅសូមកត់ចម្លងនូវកុរុធម៌ក្នុងក្រាំងមាសនាំមកនគរ ។ កាលដែលពួកព្រាហ្មណ៍និងអាមាត្យនាំគ្នាចូលទៅសូមចម្លង ពួកជនទាំងនោះមានព្រះរាជាជាដើម ក៏ប្រកែក ព្រោះមានសេចក្ដីសង្ស័យបន្តិចបន្តួចក្នុងសីលរបស់ខ្លួន បាននិយាយថាសីលរបស់យើងទាំងឡាយមិនបរិសុទ្ធទេ កាលបើពួកព្រាហ្មណ៍និងអាមាត្យចេះតែទទូចអង្វរករច្រើនពេក ក៏សំដែងឱ្យ ។ ព្រះបាទកាលិង្គៈ បានទទួលកុរុធម៌ ក្នុងក្រាំងដែលគេនាំយកមកថ្វាយ ហើយសមាទានដោយគោរព ។ ភ្លៀងក៏ឱរចុះពេញដែន បានក្សេមក្សាន្តសប្បាយដោយសុភិក្ខា ។ ព្រះបរមសាស្ដាសំដែងនូវអតីតនិទាននេះចប់ហើយ ទ្រង់សមោធានជាតកថា អ្នកទាំងឡាយចូរចាំទុកនូវជាតកយ៉ាងនេះថា នាងគណិកាក្នុងកាលនោះ គឺនាងឧប្បលវណ្ណា. នាយឆ្នាំទ្វារ គឺបុណ្ណៈ. អ្នកកាន់ខ្សែ គឺព្រះកច្ចាយនៈ. មហាអាមាត្យជានាយឃ្លាំង គឺមោគ្គល្លាន. សេដ្ឋី គឺព្រះសារីបុត្ត. នាយសារថី គឺព្រះអនុរុទ្ធ ព្រាហ្មណ៍បុរោហិត គឺ ព្រះកស្សបត្ថេរ. ឧបរាជ គឺនន្ទបណ្ឌិតមហេសី គឺរាហុលមាតា. ព្រះជនេត្តិកា គឺព្រះមហាមាយាទេវី.

កុរុរាជ គឺព្រះតថាគត ។ លុះទ្រង់ត្រាស់ប្រជុំជាតកហើយ ទ្រង់តិះដៀលភិក្ខុនោះថា ម្នាលភិក្ខុ បណ្ឌិតទាំងឡាយក្នុងកាលមុនគ្រាន់តែមានសេចក្ដីសង្ស័យកើតឡើងបន្តិចបន្តួចប៉ុណ្ណោះ ក៏បារម្ភក្រែងបែកធ្លាយសីលរបស់ខ្លួន ចុះអ្នកឯងបួសក្នុងព្រះពុទ្ធសាសនាត្រឡាំង ហេតុអ្វីក៏ធ្វើនូវបាណាតិបាត ដែលជាកម្មមានទម្ងន់ដល់ម្ល៉េះ បុគ្គលត្រូវសង្រួមទាំងដៃ ទាំងជើង ទាំងវាចាឱ្យរៀបរយល្អ ទើបហៅថាភិក្ខុ ។

**បុ**- ក្នុងពុទ្ធសាសនា អ្នកណារក្សានិច្ចសីលមុនគេ ?

**វិ**- ក្នុងពុទ្ធសាសនា អ្នកដែលរក្សានិច្ចសីលមុនគេ គឺសក្យមហានាម ដូចពុទ្ធដីកាថា :

យតោ ខោ មហានាម ឧបាសកោ បាណាតិបាតោ បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ ហោតិ ឯត្តាវតា ខោ មហានាម ឧបាសកោ សីលវា ហោតិ ។

បពិត្រមហានាម ឧបាសកវៀរចាកអំពើធ្វើសត្វមានជីវិតឱ្យវិនាសធ្លាក់ទៅ វៀរចាកអំពើកាន់យកនូវវត្ថុនូវជារបស់អ្នកដទៃ ដែលម្ចាស់គេមិនបានឱ្យដោយ

កាយ ឬដោយវាចា. វៀរចាកអំពើប្រព្រឹត្តខុសក្នុងកាមទាំងឡាយ. វៀរចាកពាក្យកុហក. វៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹងគឺសុរានិងមេរយ្យ ដោយហេតុឯណាពិត. បពិត្រមហានាម ហេតុមានប្រមាណប៉ុណ្ណោះឯងឧបាសកឈ្មោះថាអ្នកមានសីល ។

បុ- សីលទាំង ៥ នេះ មានអានិសង្សដូចគ្នា ឬផ្សេងគ្នា ?

វិ- សីលទាំង ៥ នេះ មានអនិសង្សផ្សេងគ្នា ដូចមានសេចក្ដីតទៅនេះ :

## បាណាតិបាតមានអានិសង្ស ២១ យ៉ាងគឺ

១-អង្គប្បច្ចង្គសម្បន្នតា ភាពជាបុគ្គលមានអវៈយវៈតូចធំ បរិបូណ៌ គឺមិនវិកលវិការអវយវៈណាមួយឡើយ :

២-អារោហបរិណាហសម្បត្តិជវសម្បត្តិតា ភាពជាបុគ្គលមានសេចក្ដីបរិបូណ៌ ដោយកំពស់និងទំហំ និងបរិបូណ៌ដោយសន្ទុះឬល្បឿនរហ័ស ។

៣-សុប្បតិដ្ឋិតបាទតា ភាពជាបុគ្គលមានជើងឈរស៊ប់ ឬ តាំងនៅស៊ប់ល្អ គឺមិនខ្ចកខ្ចើត ។

៤-ចារុតា ភាពជាបុគ្គលល្អល្អះសមរម្យ .

៥-មុទុតា ភាពជាបុគ្គលទន់ភ្លន់ ឬ ស្លូតបូត .

៦-សុចិតា ភាពជាបុគ្គលស្អាត .

៧-សូរតា ភាពជាបុគ្គលក្លៀវក្លាអង់អាចក្នុងកណ្ដាលប្រជុំបរិស័ទ .

៨-មហព្វលតា ភាពជាបុគ្គលមានកម្លាំងច្រើន .

៩-វិស្សត្ថវចនតា ភាពជាបុគ្គលមានពាក្យគ្បោះក្បាយ ឬ ជ្រះល្អ គឺមិនស្ទាកស្ទារ .

១០-លោកប្បិយតា ភាពជាបុគ្គលជាទីស្រឡាញ់នៃជន .

១១-អភេជ្ជបរិសតា ភាពជាបុគ្គលមានបរិស័ទមិនបែកខ្ញែក ឬមិនព្រាត់ប្រាស់ .

១២-អច្ឆម្ភិតា ភាពជាបុគ្គលមិនរន្ធត់ញាប់ញ័រ .

១៣-ទុប្បធំសតា ភាពជាបុគ្គលដែលគេគំចាត់គំចាយបានដោយក្រ ឬគេបំបែកបំបាក់មិនបាន .

១៤-បរូបក្កមេនាមរណតា ភាពជាបុគ្គលមិនមានសេចក្ដីស្លាប់ ដោយព្យាយាមនៃបុគ្គលដទៃ ឬដោយសេចក្ដីបៀតបៀននៃបុគ្គលដទៃ.

១៥-អនន្តបរិវារតា ភាពជាបុគ្គលអ្នកមានបរិវារមិនមានទីបំផុត គឺថារាប់មិនអស់ .

១៦-សុរូបតា ភាពជាបុគ្គលជាអ្នកមានរូបល្អ .

១៧-សុសណ្ឋានតា ភាពជាបុគ្គលមានសណ្ឋានទ្រង់ទ្រាយ ឬរាងរៅល្អ ដំណើរល្អ .

១៨-អប្បាពាធតា ភាពជាបុគ្គលមានជម្ងឺដម្កាត់តិច ឬមិនមានជម្ងឺឈឺចាប់ .

១៩-អសោចិតា ភាពជាបុគ្គលមិនមានសេចក្ដីសោយសោក ឬក្រៀមក្រំ .

២០-បិយេហិ មនាបេហិ សទ្ធឹ អវិប្បយោគតា ភាពជាបុគ្គលមិនមានសេចក្ដីព្រាត់ប្រាសចាកសត្វនិងសង្ខារ ដែលជាទីស្រឡាញ់ពេញចិត្ត

២១-ទីឃាយុតា ភាពជាបុគ្គលអ្នកមានអាយុវែង ។

## អធិដ្ឋានទានមានអានិសង្ស ១២ យ៉ាង គឺ :

១-មហទ្ធនតា ភាពជាបុគ្គលមានទ្រព្យច្រើន .

២-ពហូតធនញ្ញតា ភាពជាបុគ្គលមានទ្រព្យនិងធញ្ញជាតិក្រាស់ក្រែល ឬសម្បូណ៌ .

៣-អនង្គភោគតា ភាពជាបុគ្គលមានភោគៈមិនមានទីបំផុត គឺចាយមិនអស់ .

៤-អនុប្បន្នភោគុប្បត្តិតា ភាពជាបុគ្គលមានកិរិយាកើតនៃទ្រព្យដែលមិនទាន់កើតឡើង គឺថាទ្រព្យណាដែលមិនទាន់បានមក មុខជានឹងបានសំរេចដូចបំណង .

៥-ឧិនប្បន្នភោគត្ថាវរតា ភាពជាបុគ្គលមានភោគៈដែលកើតឡើងហើយមានភោគៈមាំមួន មិនមានវិនាសដោយហេតុណាមួយ .

៦-ឥច្ឆិតានំ ភោគានំ ខិប្បដិលាភតា ភាពជាបុគ្គលអ្នកបានចំពោះយ៉ាងឆាប់នៃភោគៈទាំងឡាយ ដែលខ្លួនប្រាថ្នាហើយ .

៧-រាជ ចោរុទកគ្គិ អប្បិយទាយាទាទីហិ អសាធារណភោគតា ភាពជាបុគ្គលមានភោគៈមិនសាធារណៈទូទៅដល់ស្តេចចោរ. ទឹក. ភ្លើង នឹង ញាតិដែលមិនជាទីស្រឡាញ់ជាដើម គឺថាមិនវិនាសដោយស្តេចរឹបជាន់ ចោរលួច. ទឹកលិច ភ្លើងឆេះ និងញាតិមិត្របោកប្រាស់ .

៨-អសាធារណប្បដិលាភិតា ភាពជាបុគ្គលមានកិរិយាបាននូវទ្រព្យមិនទូទៅ (គឺមិនមានអ្នកណាបានដូច. ប្លែកតែឯងក្នុងស្រុកជាច់គេ).

៩-លោកុត្តរធនប្បដិលាភិតា ភាពជាបុគ្គលបានចំពោះនូវទ្រព្យជាលោកុត្តរៈ គឺអរិយទ្រព្យ ៧ ប្រការ .

១០-នត្ថិភាវស្ស អជាននតា ភាពជាបុគ្គលមិនបានដឹងនូវភាវៈគ្មាន ( គឺមិនស្គាល់ក្រ ) .

១១-នត្ថិភាវស្ស អស្សវនតា ភាពជាបុគ្គលមិនមានកិរិយាឮនូវភាវៈគ្មាន គឺមិនដែលឮពាក្យថាគ្មានដូចអនុរុទ្ធ.

១២-សុខវិហារតា ភាពជាបុគ្គលមានប្រក្រតី នៅជាសុខស្រួល ។

កាមេសុមិច្ឆាចារាសិក្ខាបទមានអានិសង្ស ២០ យ៉ាងគឺ

១-វិគតបច្ចិត្ថកតា ភាពជាបុគ្គលមានបុគ្គលជាបច្ចាមិត្រទៅប្រាសហើយ គឺថាមិនមានសត្រូវណាបៀតបៀន .

២-សព្វជនស្ស បិយតា ភាពជាបុគ្គលជាទីស្រឡាញ់នៃជនទាំងពួង.

៣-អន្នបានវត្ថសយនាទីនំ បដិលាភិតា ភាពជាបុគ្គលអ្នកបានចំពោះ នូវវត្ថុមានគ្រឿងស៊ី. ផឹក. សំពត់និងទីដេកជាដើមមិនខ្វះ .

៤-សុខសយនតា ភាពជាបុគ្គលដេកជាសុខ គឺថាមិនមាននិមិត្តអាក្រក់ .

៥-សុខប្បដិពុជ្ឈនតា ភាពជាបុគ្គលភ្ញាក់ជាសុខ គឺថាមិនមមើមមាយ ផ្ដេសផ្ដាស .

៦-អបាយភយវិនិមុត្តតា ភាពជាបុគ្គលអ្នករួចចាកភ័យក្នុងអបាយ.

៧-ឥត្ថិភាវប្បដិលាភស្ស វា នបុំសកត្តប្បដិលាភស្ស វា អភព្វតា ភាពជាបុគ្គលអ្នកមិនគួរដើម្បីជួបប្រទះនូវភាវៈនៃខ្លួនជាស្ត្រីផង ជាខ្ទើយផង (នេះចំពោះតែបុរស).

៨-អក្កោធនតា ភាពជាបុគ្គលមិនមានសេចក្ដីក្រោធ.

៩-សក្កច្ចការិតា ភាពជាបុគ្គលមានទម្លាប់ធ្វើការយ៉ាងហ្មត់ចត់.

១០-ឫជ្ជុកការិតា ភាពជាបុគ្គលមានទម្លាប់ខាងធ្វើការយ៉ាងជាក់ស្ដែង (មានថ្វីដៃយ៉ាងចំណាន).

១១-អបតិតកណ្ណតា ភាពជាបុគ្គលអ្នកមិនមានស្លាធ្លាក់ចុះ គឺមានឆ្អឹងស្លាមិនទោរទន់.

១២-អនធោមុខតា ភាពជាបុគ្គលមិនមានមុខសំយុងចុះ.

១៣-ឥត្ថិបុរិសានំ អញ្ញមញ្ញប្បិយតា ភាពជាបុគ្គលជាទីស្រឡាញ់ នៃបុរសស្ត្រីផងគ្នា.

១៤-បរិបុណ្ណិន្ទ្រិយតា ភាពជាបុគ្គលអ្នកមានឥន្ទ្រីយ៍បរិបូណ៌.

១៥-បរិបុណ្ណលក្ខណតា ភាពជាបុគ្គលអ្នកមានលក្ខណៈបរិបូណ៌.

១៦-និរាសង្កតា ភាពជាបុគ្គលមិនមានសេចក្ដីរង្កៀស ឬ ថប់ព្រែង (មានសត្រូវណាមួយបៀតបៀន) .

១៧-អប្បោស្សុក្កតា ភាពជាបុគ្គលអ្នកមិនសូវមានសេចក្ដីខ្វល់ខ្វាយ រវល់ ។ ជាអ្នកទំនេរ (គឺមិនបាច់ខំប្រកបការងារគង់បានទ្រព្យសម្បត្តិ) .

១៨-សុខវិហារិតា ភាពជាបុគ្គលអ្នកមានប្រក្រតីនៅជាសុខ .

១៩-អកុតោភយតា ភាពជាបុគ្គលអ្នកមិនមានភ័យអំពីភព អំពីអារម្មណ៍ណាមួយ .

២០-បិយាវិប្បយោគភាវតា ភាពជាបុគ្គលអ្នកមិនមានសេចក្ដីព្រាត់ប្រាសចាកសត្វនិងសង្ខារ ដែលជាទីស្រឡាញ់ .

មុសាវាទសិក្ខាបទមានអានិសង្ស ១៤ យ៉ាងគឺ :

១-វិប្បសន្និន្ទ្រិយតា ភាពជាបុគ្គលអ្នកមានឥន្ទ្រីយ៍ថ្លាយង់ ឬស្រស់បស់ស្អាតបាត .

២-វិស្សត្ថមធុរភាណិតា ភាពជាបុគ្គលអ្នកមានសំដីដ៏ពិរោះ .

៣-សមសិតសុទ្ធទន្តតា ភាពជាបុគ្គលអ្នកមានធ្មេញដ៏រាបស្មើជិតស្និទ្ធល្អ.

៤-នាតិថូលតា ភាពជាបុគ្គលអ្នកមិនធាត់ពេក .

៥-នាតិកីសតា ភាពជាបុគ្គលអ្នកមិនស្គមពេក .

៦-នាតិរស្សតា ភាពជាបុគ្គលអ្នកមិនទាបពេក .

៧-នាតិទីឃតា ភាពជាបុគ្គលអ្នកមិនខ្ពស់ពេក .

៨-សុខសម្ផស្សតា ភាពជាបុគ្គលអ្នកមានសម្ផស្សស្រួល .

៩-ឧប្បលគន្ធមុខតា ភាពជាបុគ្គលអ្នកមានក្លិនផ្កាឧប្បលក្នុងមាត់ (គឺមានមាត់ក្រអូបដូចផ្កាឧប្បល) .

១០-សុស្សូសកបរិជនតា ភាពជាបុគ្គលអ្នកមានជនជាមិត្តបរិវារ ឬអ្នកកំដរហែហម. អ្នកស្ដាប់ពាក្យបង្គាប់ .

១១-អាទេយ្យវចនតា ភាពជាបុគ្គលអ្នកមានពាក្យដែលអ្នកផងគួរពោលរាប់រក .

១២-កមលុប្បលទលសទិសមុទុលោហិតតនុជិវ្ហតា ភាពជាបុគ្គលអ្នកមានអណ្ដាតស្ដើងក្រហមទន់ ប្រហែលនឹងត្របកផ្កាឈូក ឬផ្កាឧប្បល.

១៣-អនុទ្ធតតា ភាពជាបុគ្គលអ្នកមិនមានរើរុះ ឬ មិនសើរើរវើរវាយ .

១៤-អបគតមច្ឆតា ភាពជាបុគ្គលអ្នកប្រាសចាកភាសា និយាយជាប់ឬ តាដិត១ ។

សុរាមេរយសិក្ខាបទមានអានិសង្ស ៣៥ យ៉ាង គឺ:

១-អតីតានាគតប្បច្ចុប្បន្នេសុ កិច្ចករណីយេសុ ខិប្បជិវិជាននតា ភាពជាបុគ្គលអ្នកមានសេចក្តីយល់ក្នុងកិច្ចដែលខ្លួនត្រូវធ្វើទាំងឡាយដែលជាអតីត អនាគត នឹងបច្ចុប្បន្នយ៉ាងឆាប់ .

២-សទាឧបដ្ឋិតស្សតិតា ភាពជាបុគ្គលអ្នកមានស្មារតីតាំងមាំអស់កាលទាំងពួង .

៣-អនុមត្តកតា ភាពជាបុគ្គលអ្នកមិនឆ្កួត .

៤-ញាណវន្តតា ភាពជាបុគ្គលអ្នកមានញាណ ( ប្រាជ្ញា)

៥-អនេឡតា ភាពជាបុគ្គលអ្នកមិនមានទោស គឺថ្លង់

៦-អជឡតា ភាពជាបុគ្គលអ្នកមិនលីលា ភ្លីភ្លើ .

៧-អមូគតា ភាពជាបុគ្គលអ្នកមិនគ .

៨-អមទតា ភាពជាបុគ្គលអ្នកមិនមានសេចក្តីស្រវឹង .

៩-អប្បមត្តតា ភាពជាបុគ្គល អ្នកមិនមានធ្វេសប្រហែស .

១០-អសម្មោហតា ភាពជាបុគ្គល អ្នកមិនមានសេចក្ដីវង្វេងភាន់ច្រឡំ ។

១១-អច្ឆិម្ភិតា ភាពជាបុគ្គល មិនរន្ធត់តក់ស្លុត .

១២-សារម្ភិតា ភាពជាបុគ្គល អ្នកមិនមានសេចក្ដីប្រណាំងប្រជែង .

១៣-អនិស្សុកិតា ភាពជាបុគ្គល អ្នកមិនមានសេចក្ដីច្រណែនឈ្នានីស .

១៤-អប្បោស្សុក្កតា ភាពជាបុគ្គល អ្នកមិនមានសេចក្ដីខ្វល់ខ្វាយ ឬជាអ្នកទំនេរ .

១៥-សុខិតតា ភាពជាបុគ្គល អ្នកស្រណុកកាយសប្បាយចិត្ត.

១៦-អភិសម្មតតា ភាពជាបុគ្គលត្រូវអ្នកផង សន្មត់យ៉ាងវិសេស ឬ យ៉ាងឆើតឆាយ គឺលើកដំកើងជាអ្នកមុខអ្នកការក្នុងស្រុកភូមិដែលខ្លួននៅ

១៧-សច្ចវាទិតា ភាពជាបុគ្គលអ្នកមានទម្លាប់ខាងពោលពាក្យពិតមែន គឺពាក្យសច្ចៈ .

១៨-អបិសុណតា ភាពជាបុគ្គល អ្នកមិនមានទម្លាប់ខាងពោលពាក្យញុះញង់ ឬសៀកសៀត បំបែកបំបាក់ .

១៩-អផរុសតា ភាពជាបុគ្គល អ្នកមិនទម្លាប់ខាងពោលពាក្យអាក្រក់ ឬគម្រោះបញ្ឆោះបោះបោក គឺពាក្យផរុសវាទ .

២០-អសម្ផប្បវាទិតា ភាពជាបុគ្គលអ្នកមិនមានទម្លាប់ ខាងពោលពាក្យ ប៉ប៉ាច់ប៉ប៉ោចរោយរាយបំផ្លើស ឬពាក្យបំផ្លេចបំផ្លាញនូវសេចក្ដីសុខចម្រើនរបស់បុគ្គលដទៃ .

២១-រត្តិន្ទិវមន្ទិតតា ភាពជាបុគ្គលមិនកៀចក្រាញ ឬដំអក់ដំងើចអស់ពេលយប់ថ្ងៃ .

២២-កតញ្ញុតា ភាពជាបុគ្គលដឹងនូវឧបការៈ ដែលអ្នកដទៃធ្វើហើយដល់ខ្លួន ( សេចក្ដីកតញ្ញូ).

២៣-កតវេទិតា ភាពជាបុគ្គលអ្នកញ៉ាំងឧបការៈ ដែលគេធ្វើហើយឱ្យច្បាស់លាស់ ( គឺតបឧបការៈដល់គេវិញ) .

២៤-អមច្ឆរិយតា ភាពជាបុគ្គលអ្នកមិនមានសេចក្ដីកំណាញ់ .

២៥-ចាគវន្តតា ភាពជាបុគ្គលអ្នកមិនមានចាគ .

២៦-សីលវន្តតា ភាពជាបុគ្គលអ្នកមានសីល .

២៧-ឧជុកតា ភាពជាបុគ្គលអ្នកត្រង់ .

២៨-អក្កោធនតា ភាពជាបុគ្គលអ្នកមិនមានសេចក្ដីក្រោធ.

២៩-ហិរិមន្តតា ភាពជាបុគ្គលអ្នកមានហិរិ .

៣០-ឧត្តប្បិតា ភាពជាបុគ្គលអ្នកមានឧត្តប្បៈ .

៣១-ឧជុទិដ្ឋិតតោ ភាពជាបុគ្គលអ្នកមានទិដ្ឋិត្រង់ .

៣២-មហាបញ្ញតា ភាពជាបុគ្គលមានប្រាជ្ញាច្រើន .

៣៣-មេធាវិតោ ភាពជាបុគ្គលអ្នកមានប្រាជ្ញា ដែលទទួលចាំនូវអត្ថនឹងធម៌ សូម្បីយ៉ាងឆាប់ ( មេធាវី ) .

៣៤-បណ្ឌិតតា ភាពជាបុគ្គលអ្នកទៅតាមប្រាជ្ញាដែលនៅក្នុងប្រយោជន៍សូម្បីយ៉ាងល្អិត ( គឺបណ្ឌិត ).

៣៥-អត្ថានត្ថកុសលតា ភាពជាបុគ្គអ្នកឈ្លៀវឆ្លាតក្នុងអំពើជាប្រយោជន៍ និងមិនជាប្រយោជន៍ ។

## កំណើតឧបោសថ

ឧបោសថនេះកើតអំពីនាងវិសាខាបានរក្សាមុនគេ ដូចមានក្នុងឧបោសថសូត្រ អង្គុត្តរនិកាយ តិកនិបាត ។

សម័យមួយព្រះមានជោគ ទ្រង់សម្រាន្តឥរិយាបថនៅប្រាសាទនៃមិគារមាតា ក្នុងវត្តបុព្វារាម ទៀបក្រុងសាវត្ថី ។

សម័យនោះ នាងវិសាខាមិគារមាតា ចូលទៅក្រាបថ្វាយបង្គំគាល់ព្រះមានជោគ ក្នុងថ្ងៃឧបោសថ អង្គុយនៅក្នុងទីមួយដ៏សមគួរ ។ ព្រះមានជោគទ្រង់ត្រាស់ចំពោះនាងវិសាខាមិគារមាតាថា ម្នាលនាងវិសាខា នាងមកអំពីទីណាតាំងថ្ងៃដូច្នេះ ? នាងវិសាខាមិគារមាតាក្រាបតបថា : បពិត្រព្រះអង្គដ៏ចំរើន ថ្ងៃនេះខ្ញុំម្ចាស់សមាទានឧបោសថ ។ ព្រះមានជោគទ្រង់ត្រាស់ថា: ម្នាលនាងវិសាខា ឧបោសថនេះមាន ៣ យ៉ាង ឧបោសថ ៣ យ៉ាងដូចម្ដេចខ្លះ ? គឺគោបាលកុបោសថ ១ និគណ្ឋុបោសថ ១ អរិយុបោសថ ១ ។ ម្នាលនាងវិសាខា ដូចម្ដេចហៅថាគោបាលកុបោសថ ? ម្នាលនាងវិសាខា យ៉ាងដូចម្ដេចមិញ ? អ្នកឃ្វាលគោស៊ីឈ្នួល កាលបើរាប់ប្រគល់ហ្វូងគោឱ្យដល់ម្ចាស់ក្នុងសាយណ្ហសម័យរួចហើយ រមែងគិតពិចារណា ថ្ងៃនេះហ្វូងគោត្រាច់ទៅក្នុងប្រទេសឯណោះ ផឹកទឹកប្រទេសឯណោះៗ នឹងផឹកទឹកក្នុងប្រទេសឯណោះ ម្នាលនាងវិសាខា យ៉ាងដូច្នេះឯង អ្នករក្សាឧបោសថ ក្នុងសាសនានេះរមែងគិតពិចារណាថា: ថ្ងៃនេះអញស៊ីនំចំណីនេះ ៗ បរិភោគភោជនេះ ៗ ដល់ថ្ងៃស្អែកអញនឹងទំពារស៊ីនំនេះៗ និងបរិភោគភោជននេះៗ អ្នករក្សាឧបោសថនោះញ៉ាំងថ្ងៃឱ្យកន្លងទៅដោយសេចក្ដីលោភ ដោយចិត្តដែលប្រកបដោយអភិជ្ឈាបែបនេះ ម្នាលនាងវិសាខា យ៉ាងនេះឯងហៅថាគោបាលកុបោសថ ម្នាលនាងវិសាខា គោបាលកុបោសថដែលបុគ្គលរក្សាបែបនេះ មិនមានផលច្រើនទេ មិនមានអានិសង្សច្រើនទេ មិនមានពន្លឺច្រើនទេ មិនមានរស្មីច្រើនទេ ។

ម្នាលនាងវិសាខា ដូចម្ដេចហៅថានិគណ្ឋុបោសថ ម្នាលនាងវិសាខា មានពួកនិគ្រណ្ឋខ្លះ ដែលប្រកបដោយជាតិជាសាមណៈរមែងបបួលណែនាំសាវក យ៉ាងនេះថា នែបុរសដ៏ចំរើន អ្នកចូលមកអាយ ពួកសត្វដែលអាស្រ័យនៅក្នុងទិស ខាងកើត ពីត្រឹមមួយរយយោជន៍ចេញទៅ អ្នកចូលតម្លោះអាជ្ញាទៅរកវា (កុំសម្លាប់) បៀតបៀនវា ពួកសត្វដែលអាស្រ័យនៅក្នុងទិសខាងលិច ពីត្រឹមមួយ រយយោជន៍ចេញទៅ អ្នកចូលតម្លោះអាជ្ញាទៅរកវា ពួកសត្វដែលអាស្រ័យនៅក្នុង ទិសខាងត្បូង ពីត្រឹមមួយរយយោជន៍ចេញទៅ អ្នកចូលតម្លោះអាជ្ញាទៅរកវា ពួកសត្វដែលអាស្រ័យនៅទិសខាងជើង ពីត្រឹមមួយរយយោជន៍ចេញទៅ អ្នកចូល តម្លោះអាជ្ញាទៅរកវា រមែងបបួលណែនាំដោយសេចក្ដីអាណិតមេត្តាដោយសេចក្ដី អនុគ្រោះចំពោះសត្វពួកខ្លះ បបួលណែនាំដោយមិនមានសេចក្ដីអាណិតមេត្តា ដោយមិនមានសេចក្ដីអនុគ្រោះចំពោះសត្វពួកខ្លះដូច្នេះ ដល់ថ្ងៃឧបោសថ ពួក និគ្រណ្ឋទាំងនោះបបួលណែនាំសាវកយ៉ាងនេះថា: នែបុរសដ៏ចំរើន អ្នកចូលទម្លាក់ ចុះនូវសម្ពត់ទាំងអស់ចេញ ហើយពោលបរិកម្មថា នាហំ ក្វចិនិ កស្សចិ កិញ្ចនំ តស្មឹ ន ច មម ក្វចិនិ កិស្មិញ្ចិ កិញ្ចនំ នត្ថិ: អាត្មាអញជាអ្នកមិនរវល់ក្នុងកង្វល់អ្វីនីមួយ របស់បុគ្គលណាមួយទាំងក្នុងកង្វល់ ដោយបរិក្ខារអ្វីណាមួយរបស់អាត្មាអញ ឬ របស់បុគ្គលណាមួយក៏ដោយ សេចក្ដី កង្វល់ក្នុងបរិក្ខារអ្វីនីមួយមិនមានឡើយ តែមាតាបិតារបស់គេរមែងដឹងថា នេះ បុត្ររបស់យើងគេក៏ដឹងថា នេះមាតាបិតារបស់អញ កូនប្រពន្ធរបស់គេរមែងដឹងថា

នេះភស្តារបស់យើង គេរមែងដឹងថា នេះកូនប្រពន្ធរបស់អញ ទាសកម្មកររបស់គេរមែង ដឹងថានេះជាចៅហ្វាយនាយរបស់យើង គេរមែងដឹងថា នេះទាសកម្មកររបស់អញ ពួកនិគ្រណ្ឋបបួលណែនាំសាវកក្នុងពាក្យសច្ចៈដូច្នេះ ក្នុងសម័យណា សម័យនោះឈ្មោះថា គេបបួលណែនាំក្នុងពាក្យមុសាវាទ តថាគតពោលថាការបបួលណែនាំរបស់នេះគេ ចូលក្នុងមុសាវាទ ដល់កន្លងរាត្រីនោះទៅ គេរមែងបរិភោគនូវភោគទ្រព្យដែលបុគ្គលមិនបានឱ្យសោះ (គឺបច្ច័យដែលបុគ្គលមិនបានប្រគេនតថាគត ពោលចំពោះការបរិភោគរបស់គេនោះ ចូលក្នុងអទិន្នាទាន) ។

ម្នាលនាងវិសាខា ដែលហៅថា និគណ្ឋុបោសថបែបនេះ. ម្នាលនាងវិសាខា និគណ្ឋុបោសថដែលគេរក្សាបែបនេះ មិនមានផលទេ មិនមានអានិសង្សទេ មិនមានពន្លឺទេ មិនមានរស្មីទេ ម្នាលនាង វិសាខា ដូចម្ដេចហៅថា អរិយុបោសថ? ម្នាលនាងវិសាខា ការដុសលាងជំរះចិត្ត ដែលសៅហ្មងឱ្យស្អាតផូរផង់ ដោយប្រឹងប្រែងហៅអរិយុបោសថ ម្នាលនាងវិសាខា ការដុសលាងជំរះចិត្ត ដែលសៅហ្មងអោយស្អាតផូរផង់ ដោយសេចក្ដីប្រឹងប្រែង ដោយប្រការដូចម្ដេច? ម្នាលនាងវិសាខា អរិយសាវកក្នុងសាសនានេះរំលឹកជា រឿយ១ ចំពោះតថាគតថា ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ឆ្ងាយចាកសត្រូវគឺ កិលេសទ្រង់ត្រាស់ដឹងធម៌ចំពោះព្រះអង្គ ទ្រង់បរិបូណ៌ដោយគុណវិជ្ជានិងវត្តចរិយា ទ្រង់មានដំណើរល្អយាងទៅកាន់ព្រះនិព្វាន ទ្រង់ជ្រាបច្បាស់នូវត្រៃលោកទ្រង់ប្រសើរដោយសីលាទិគុណផុតលោក ទ្រង់ជាសារថីទូន្មានសត្វលោកទ្រង់ជាសាស្ដា របស់ទេវតានិងមនុស្ស

ទាំងឡាយទ្រង់ជាអ្នកត្រាស់ដឹងនូវសច្ចធម៌ ទ្រង់ជាអ្នកខ្ចាត់ ចោលនូវដំណើរត្រាច់រង្គាត់កើតស្លាប់ក្នុងត្រៃភព កាលបើអរិយសាវករលឹករឿយៗ ចំពោះតថាគតយ៉ាងនេះ ចិត្តរមែងជ្រះថ្លាសេចក្តីរីករាយរមែងកើតឡើង ឧបក្កិលេសរបស់ចិត្តទាំងប៉ុន្មាន ក៏រមែងលះបង់បាន ម្នាលនាងវិសាខា យ៉ាងណាមិញ ការដុសលាងជំរះក្បាលដែលសៅហ្មង ឱ្យស្អាតផូរផង់ដោយសេចក្តីប្រឹងប្រែង ម្នាលនាងវិសាខា ការដុសលាងជំរះក្បាល ដែលសៅហ្មងឱ្យស្អាតផូរផង់ដោយ សេចក្តីប្រឹងប្រែងដោយប្រការដូចម្តេច? គឺត្រូវអាស្រ័យគ្រឿងកក់អាស្រ័យដីស្អិត អាស្រ័យទឹក អាស្រ័យសេចក្តីព្យាយាមរបស់បុរស ដ៏សមគួរដល់ការនោះ ម្នាលនាងវិសាខា ការដុសលាងជំរះក្បាលដែលសៅហ្មងឱ្យស្អាតផូរផង់ ដោយសេចក្តីប្រឹងប្រែងយ៉ាងនេះ. ម្នាលនាងវិសាខា ការដុសលាងជំរះចិត្តដែលសៅហ្មងឱ្យ ស្អាតផូរផង់ដោយសេចក្តីប្រឹងប្រែងយ៉ាងនោះដែរ ម្នាលនាងវិសាខា ការដុសលាងជំរះចិត្តដែលសៅហ្មងឱ្យស្អាតផូរផង់ ដោយសេចក្តីប្រឹងប្រែងដោយប្រការ ដូចម្តេច ? ម្នាលនាងវិសាខា អរិយសាវកក្នុងសាសនានេះ រឭករឿយៗចំពោះតថាគតថា ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ឆ្ងាយចាកសឹកសត្រូវគឺកិលេស ។ល។ ទ្រង់ត្រាស់ដឹងនូវសច្ចៈធម៌ ទ្រង់ខ្ចាត់ចោលនូវដំណើរវិលកើតស្លាប់ក្នុងត្រៃភព កាលបើអរិយសាវករឭករឿយៗចំពោះតថាគតយ៉ាងនេះ ចិត្តរមែងជ្រះថ្លា សេចក្តីរីករាយរមែងកើតឡើង ឧបក្កិលេសរបស់ចិត្តទាំងប៉ុន្មាន ក៏រមែងលះបង់បាន ម្នាលនាងវិសាខា អរិយសាវកនេះ តថាគតឱ្យឈ្មោះថារក្សានូវព្រហ្មឧបោសថ

ឱ្យឈ្មោះថាបានទៅរួមជាមួយនឹងព្រហ្ម គឺបុគ្គលដ៏ប្រសើរ ចិត្តរបស់អរិយសាវក នោះសោតរមែងជ្រះថ្លា សេចក្តីរីករាយរមែងកើត នៅប្រារព្ធចំពោះបុគ្គលដ៏ប្រសើរ ឧបក្កិលេសរបស់ចិត្តទាំងប៉ុន្មាន ក៏រមែងលះបង់បាន ម្នាលនាងវិសាខា ការដុស លាងជំរះចិត្តដែលសៅហ្មងឱ្យស្អាតផូរផង់ដោយសេចក្តីប្រឹងប្រែងយ៉ាងនេះ ។

ម្នាលនាងវិសាខា ការដុសលាងជំរះចិត្តដែលសៅហ្មងឱ្យស្អាតផូរផង់ ដោយសេចក្តីប្រឹងប្រែង ( នៅមានទៀត ) ម្នាលនាងវិសាខា ការដុសលាងចិត្តដែល សៅហ្មងឱ្យស្អាតផូរផង់ ដោយសេចក្តីប្រឹងប្រែង ដោយប្រការដូចម្តេច? ម្នាលនាងវិសាខា អរិយសាវកក្នុងសាសនានេះ រលឹករឿយៗចំពោះធម៌ថា ធម៌ ២ ប្រការ គឺព្រះបរិយត្តិធម៌និងព្រះនពលោកុត្តរធម៌ ជាធម៌ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងហើយដោយល្អ ជាធម៌គឺព្រះអរិយបុគ្គលគប្បីឃើញច្បាស់ចំពោះ ខ្លួន ជាធម៌ឱ្យនូវផលមិនរង់ចាំកាល ជាធម៌គួរនឹងហៅបុគ្គលដទៃឱ្យចូល មកមើលផងបាន ជាធម៌គឺព្រះអរិយបុគ្គលគប្បីបង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ គឺព្រះវិញ្ញូជនទាំងឡាយគប្បីដឹងចំពោះខ្លួន កាលបើអរិយសាវកនោះរលឹករឿយៗ ចំពោះធម៌ ចិត្តរមែងជ្រះថ្លា សេចក្តីរីករាយរមែងកើតឡើងឧបក្កិលេសរបស់ចិត្ត ទាំងប៉ុន្មាន ក៏រមែងលះបង់បាន ម្នាលនាងវិសាខា យ៉ាងណាមិញ ការដុស លាងជំរះកាយដែលសៅហ្មងឱ្យស្អាតផូរផង់ដោយសេចក្តីប្រឹងប្រែង ម្នាលនាងវិ សាខា ការដុសលាងជំរះកាយដែលសៅហ្មងឱ្យស្អាតផូរផង់ ដោយសេចក្តីប្រឹងប្រែង ដោយប្រការដូចម្តេច ? គឺអាស្រ័យអម្បោះសម្រាប់កូត. អាស្រ័យរំអិលសម្រាប់

ដុស អាស្រ័យទឹក. អាស្រ័យសេចក្តីព្យាយាមរបស់បុរសដ៏សមគួរដល់ការនោះ ម្នាលនាងវិសាខា ការដុសលាងជំរះកាយដែលសៅហ្មងឱ្យស្អាតផូរផង់ ដោយសេចក្តីប្រឹងប្រែងយ៉ាងនោះឯង ម្នាលនាងវិសាខា ការដុសលាងជំរះចិត្តដែលសៅហ្មងឱ្យផូរផង់ ដោយសេចក្តីប្រឹងប្រែងយ៉ាងនោះដែរ ម្នាលនាងវិសាខា ការដុសលាងជំរះចិត្ត ដែលសៅហ្មងឱ្យស្អាតផូរផង់ដោយសេចក្តីប្រឹងប្រែង ដោយប្រការដូចម្តេច? ម្នាលនាងវិសាខា អរិយសាវកក្នុងសាសនានេះ រឭករឿយៗចំពោះធម៌ថា ធម៌២ប្រការគឺ ព្រះបរិយត្តិធម៌និងព្រះនពលោកុត្តរធម៌ ជាធម៌ដែលព្រះមានជោគទ្រង់ត្រាស់សំដែងហើយដោយល្អ ។បេ។ ជាធម៌គឺវិញ្ញូជនទាំងឡាយ គប្បីដឹងចំពោះខ្លួន កាលបើអរិយសាវកនោះរឭករឿយៗចំពោះធម៌ ចិត្តរមែងជ្រះថ្លា សេចក្តីរីករាយរមែងកើតឡើង ឧបក្កិលេសរបស់ចិត្តទាំងប៉ុន្មាន ក៏រមែងលះបង់បាន ម្នាលនាងវិសាខាការដុសលាងជំរះចិត្តដែលសៅហ្មងឱ្យស្អាតផូរផង់ដោយសេចក្តី ប្រឹងប្រែងយ៉ាងនោះឯង ។

ម្នាលនាងវិសាខា ការដុសលាងជំរះចិត្ត ដែលសៅហ្មងឱ្យស្អាតឱ្យផូរផង់ ដោយសេចក្តីប្រឹងប្រែង(នៅមានទៀត) ។

ម្នាលនាងវិសាខា ការដុសលាងជំរះចិត្ត ដែលសៅហ្មងឱ្យស្អាតផូរផង់ ដោយប្រការដូចម្តេច ?

ម្នាលនាងវិសាខា អរិយសាវកក្នុងសាសនានេះ រឭករឿយៗចំពោះសង្ឃថា ព្រះសង្ឃសាវករបស់ព្រះមានព្រះភាគប្រតិបត្តិល្អ ព្រះសង្ឃសាវករបស់

ព្រះមានព្រះភាគប្រតិបត្តិត្រង់ ព្រះសង្ឃរបស់ព្រះមានព្រះភាគប្រតិបត្តិដើម្បីត្រាស់ដឹង ព្រះសង្ឃសាវករបស់ព្រះមានព្រះភាគប្រតិបត្តិគួរដល់សាមីចិកម្ម ព្រះសង្ឃសាវករបស់ព្រះមានព្រះភាគនុ៎ះ ចាត់ជាគូមាន ៤ គូ ចាត់ជាបុគ្គលមាន ៨ ព្រះសង្ឃសាវករបស់ព្រះមានព្រះភាគនុ៎ះ គួរទទួលនូវអាគន្តុកទាន ដែលគេតាក់តែងសម្រាប់ភ្ញៀវ គួរទទួលនូវទានដែលគេឧទ្ទិសចំពោះអ្នកមានសីល គួរទទួលនូវទានដែលគេបង្អោនចូលមកបូជាដោយសទ្ធា គួរដល់អញ្ជលិកម្ម. ជាបុញ្ញក្ខេត្ត ដ៏ខ្ពង់ខ្ពស់បំផុតរបស់សត្វលោក។ កាលបើអរិយសាវកនោះ រឮករឿយៗចំពោះសង្ឃ ចិត្តរមែងជ្រះថ្លា សេចក្ដីរីករាយរមែងកើតឡើង ឧបក្កិលេសរបស់ចិត្តទាំងប៉ុន្មានក៏រមែងលះបង់បាន។ ម្នាលនាងវិសាខា យ៉ាងណាមិញការដុសលាងជំរះសំពត់ដែលសៅហ្មងឱ្យស្អាតផូរផង់ដោយសេចក្ដីប្រឹងប្រែង ម្នាលនាងវិសាខាការដុសលាងសំពត់ដែលសៅហ្មងឱ្យស្អាតផូរផង់ ដោយសេចក្ដីប្រឹងប្រែងដោយប្រការដូចម្ដេច ? គឺត្រូវអាស្រ័យដីប្រៃ. អាស្រ័យទឹកក្បុង. អាស្រ័យគោម័យ. អាស្រ័យទឹក. អាស្រ័យសេចក្ដីព្យាយាមរបស់បុរសដ៏គួរដល់កាលនោះ ម្នាលនាងវិសាខា ការដុសលាងជំរះសំពត់ដែលសៅហ្មងឱ្យស្អាតផូរផង់ ដោយសេចក្ដីប្រឹងប្រែងយ៉ាងនេះឯង ។

ម្នាលនាងវិសាខា ការដុសលាងជំរះចិត្តដែលសៅហ្មង ឱ្យស្អាតផូរផង់ ដោយសេចក្ដីប្រឹងប្រែងយ៉ាងនោះដែរ ម្នាលនាងវិសាខា ការដុសលាងជំរះចិត្តដែលសៅហ្មងឱ្យស្អាតផូរផង់ ដោយសេចក្ដីប្រឹងប្រែង ដោយប្រការដូចម្ដេច ?

ម្នាលនាងវិសាខា អរិយសាវកក្នុងសាសនានេះរឭករឿយ ៗ ចំពោះសង្ឃថា : ព្រះសង្ឃជាសាវករបស់ព្រះដ៏មានព្រះភាគ ប្រតិបត្តិល្អ ។ បេ ។ ជាបុញ្ញក្ខេត្ត ដ៏ខ្ពង់ខ្ពស់បំផុតរបស់សត្វលោក. កាលបើអរិយសាវកនោះរឭករឿយ ៗចំពោះសង្ឃ ចិត្តរមែងជ្រះថ្លា សេចក្តីរីករាយកើតឡើង ឧបក្កិលេសរបស់ចិត្តរមែងលះបង់បាន ម្នាលនាងវិសាខា អរិយសាវកនោះ តថាគតឱ្យឈ្មោះថា បានរក្សា នូវសង្ឃុបោសថ ឈ្មោះថា បានរួមជាមួយនឹងសង្ឃ ចិត្តរបស់អរិយសាវកនោះ សោតរមែងជ្រះថ្លា សេចក្តីរីករាយរមែងកើតឡើងប្រារព្ធចំពោះសង្ឃ ទាំងឧបក្កិលេសរបស់ចិត្តទាំងប៉ុន្មានក៏រមែងលះបង់បាន ម្នាលនាងវិសាខា ការជុសលាងជំរះចិត្តសៅហ្មងឱ្យស្អាតផូរផង់ ដោយសេចក្តីប្រឹងប្រែងយ៉ាងនោះឯង ។

ម្នាលនាងវិសាខា ការជុសលាងជំរះចិត្ត ដែលសៅហ្មងឱ្យស្អាតផូរផង់ ដោយសេចក្តីប្រឹងប្រែង (នៅមានទៀត) ម្នាលនាងវិសាខា ការជុសលាងជំរះចិត្ត ដែលសៅហ្មងឱ្យស្អាតផូរផង់ ដោយសេចក្តីប្រឹងប្រែង ដោយប្រការដូចម្តេច ? ម្នាលនាងវិសាខា អរិយសាវកក្នុងសាសនានេះ រឭករឿយ ៗចំពោះសីលរបស់ខ្លួនថា: សីលទាំងឡាយរបស់អញឥតដាច់ ឥតធ្លុះ ឥតពព្រុស ឥតពពាល ជាសីលអ្នកជា ដែលអ្នកប្រាជ្ញតែងសរសើរមិនប៉ះពាល់ដោយតណ្ហា និងទិដ្ឋិ ជាសីលប្រព្រឹត្តទៅព្រមដើម្បីសមាធិ កាលបើអរិយសាវករឭករឿយ ៗចំពោះសីល ចិត្តរមែងជ្រះថ្លា សេចក្តីរីករាយរមែងកើតឡើង ឧបក្កិលេសរបស់ចិត្តទាំងប៉ុន្មាន

រមែងលះបង់បាន ម្នាលនាងវិសាខា យ៉ាងណាមិញ ការជុសលាងជិរះកញ្ចក់ ដែលសៅហ្មងឱ្យស្អាតផូរផង់ ដោយសេចក្ដីប្រឹងប្រែង ។

ម្នាលនាងវិសាខា ការជុសលាងជិរះកញ្ចក់ ដែលសៅហ្មងឱ្យស្អាតផូរផង់ ដោយសេចក្ដីប្រឹងប្រែង ដោយប្រការដូចម្ដេច ? គឺត្រូវអាស្រ័យប្រេង អាស្រ័យផេះ អាស្រ័យច្រាសកន្ទុយសត្វ អាស្រ័យព្យាយាមរបស់បុរសដ៏សមគួរដល់កាលនោះ ម្នាលនាងវិសាខា ការជុសលាងជិរះកញ្ចក់ ដែលសៅហ្មងឱ្យស្អាតផូរផង់ដោយសេចក្ដីប្រឹងប្រែងយ៉ាងនេះឯង ម្នាលនាងវិសាខា ការជុសលាងជិរះចិត្ត ដែលសៅហ្មងឱ្យស្អាតផូរផង់ ដោយសេចក្ដីប្រឹងប្រែងយ៉ាងនោះដែរ ម្នាលនាងវិសាខា ការជុសលាងជិរះចិត្តដែលសៅហ្មងឱ្យស្អាតផូរផង់ ដោយសេចក្ដីប្រឹងប្រែងដោយប្រការដូចម្ដេច ? ម្នាលនាងវិសាខា អរិយសាវកក្នុងសាសនានេះ រឭករឿយៗ ចំពោះសីលរបស់ខ្លួនថា: សីលទាំងឡាយ របស់អាត្មាអញ ឥតដាច់ ឥតធ្លុះ ។បេ។ ជាសីលប្រព្រឹត្តទៅព្រមដោយសមាធិ" កាលបើអរិយសាវករឭករឿយៗ ចំពោះសីលរបស់ខ្លួន ចិត្តរមែងជ្រះថ្លា សេចក្ដីរីករាយរមែងកើតឡើង ឧបក្កិលេសរបស់ចិត្តទាំងប៉ុន្មាន ក៏រមែងលះបង់បាន ។

ម្នាលនាងវិសាខា អរិយសាវកនេះ តថាគតឱ្យឈ្មោះថា បានសិក្សានូវសីលឧបោសថ ឈ្មោះថាបានរួមជាមួយនឹងសីល ចិត្តរបស់អរិយសាវកនោះសោត ក៏រមែងជ្រះថ្លា សេចក្ដីរីករាយរមែង កើតឡើង ប្រារព្ធចំពោះសីល ទាំងឧបក្កិលេស

របស់ចិត្តទាំងប៉ុន្មាន ក៏រមែងលះបង់បាន ម្នាលនាងវិសាខា ការដុសលាងជំរះចិត្ត ដែលសៅហ្មង ឱ្យស្អាតផូរផង់ដោយសេចក្តីប្រឹងប្រែង យ៉ាងនេះឯង ។

ម្នាលនាងវិសាខា ការដុសលាងជំរះចិត្ត ដែលសៅហ្មងឱ្យស្អាត ផូរផង់ ដោយសេចក្តីប្រឹងប្រែង (នៅមានទៀត) ម្នាលនាងវិសាខា ការដុសលាង ជំរះ ចិត្តដែលសោហ្មង ឱ្យស្អាតផូរផង់ដោយសេចក្តីប្រឹងប្រែង ដោយប្រការដូចម្តេច ?

ម្នាលនាងវិសាខា អរិយសាវកក្នុងសាសនានេះរឭករឿយៗ ចំពោះទេវតា ទាំងឡាយថា មានទេវតាទាំងឡាយនៅជាន់ចាតុម្មហារាជិកា មានទេវតាទាំង ឡាយនៅជាន់តាវតឹង្ស មានទេវតាទាំងឡាយនៅជាន់យាមា មានទេវតាទាំង ឡាយនៅជាន់តុសិត មានទេវតាទាំងឡាយនៅជាន់និម្មានរតី មានទេវតា ទាំងឡាយ នៅជាន់បរិនិម្មិតវសវត្តី មានទេវតាទាំងឡាយនៅក្នុងពួកព្រហ្ម មាន ទេវតាទាំងឡាយនៅជាន់លើនោះទៀត ទេវតាទាំងឡាយនោះប្រកប ដោយសទ្ធា មានសភាពយ៉ាងណា ទើបច្យុតអំពីមនុស្សលោកនេះ ឡើងទៅកើតក្នុងទេវលោក ទាំងឡាយនោះ សទ្ធាមានសភាពយ៉ាងនោះរបស់អាត្មាអញមានព្រម ទេវតាទាំង ឡាយនោះប្រកបដោយសីល មានសភាពយ៉ាងណា ទើបច្យុតអំពីមនុស្សលោកនេះ បានឡើងទៅកើតក្នុងទេវលោកទាំងឡាយនោះ សីលមានសភាពយ៉ាងនោះ របស់ អាត្មាអញមានព្រម ទេវតាទាំងឡាយនោះប្រកបដោយសុតៈ(ការស្តាប់. ការចេះ ចាំ) មានសភាពយ៉ាងណា ទើបច្យុតអំពីមនុស្សលោកនេះ បានឡើងទៅកើតក្នុង ទេវតាទាំងឡាយនោះ សុតៈមានសភាពយ៉ាងនោះ របស់អញមានព្រម

ទេវតាទាំងឡាយនោះប្រកបដោយចាគៈ (ការបរិច្ចាគទាន) មានសភាពយ៉ាងណា ទើបច្យុតអំពីមនុស្សលោកនេះ បានឡើងទៅកើតក្នុងទេវលោកទាំងឡាយនោះ មានសភាពយ៉ាងនោះរបស់អាត្មាអញមានព្រម ទេវតាទាំងឡាយនោះប្រកបបញ្ញា (ការដឹងខុសត្រូវ) មានសភាពយ៉ាងណា ទើបច្យុតអំពីមនុស្សលោកនេះ បានឡើងទៅកើតក្នុងទេវតាទាំងឡាយ បញ្ញាមានសភាពយ៉ាងនោះ របស់អាត្មាអញមានព្រម កាលបើអរិយសាវកនោះរឭករឿយៗ ចំពោះសទ្ធា. សីល. សុតៈ ចាគៈ. បញ្ញារបស់ខ្លួនផង របស់ទេវតាទាំងឡាយផង ចិត្តរមែងជ្រះថ្លា សេចក្ដីរីករាយរមែងកើតឡើង ឧបក្កិលេសរបស់ចិត្តទាំងប៉ុន្មាន ក៏រមែងលះបង់បាន ម្នាលនាងវិសាខា យ៉ាងណាមិញ ការដុសលាងជំរះមាស ដែលសៅហ្មងឱ្យស្អាតផូរផង់ ដោយសេចក្ដីប្រឹងប្រែង ។

ម្នាលនាងវិសាខា ការដុសលាងជំរះមាស ដែលសៅហ្មងឱ្យស្អាតផូរផង់ ដោយសេចក្ដីប្រឹងប្រែង ដោយប្រការដូចម្ដេច ? គឺត្រូវអាស្រ័យចង្ក្រាន ត្រូវអាស្រ័យដីប្រៃ ត្រូវអាស្រ័យជ័ររង់. ត្រូវអាស្រ័យបំពង់ផ្លុំនិងសណ្ដាស (ដែកជំបៀត) ត្រូវអាស្រ័យព្យាយាមរបស់បុរសដ៏សមគួរដល់ការនោះ ម្នាលនាងវិសាខា ការដុសលាងជំរះមាស ដែលសៅហ្មងឱ្យស្អាតផូរផង់ ដោយសេចក្ដីប្រឹងប្រែងយ៉ាងនេះឯង ។

ម្នាលនាងវិសាខា ដុសលាងជំរះចិត្ត ដែលសៅហ្មងឱ្យស្អាតផូរផង់ ដោយសេចក្ដី ប្រឹងប្រែងយ៉ាងនោះដែរ ម្នាលនាងវិសាខា ការដុះលាងជំរះចិត្ត

ដែលសៅហ្មងឱ្យស្អាតផូរផង់ដោយសេចក្ដីប្រឹងប្រែង ដោយប្រការដូចម្ដេច? ម្នាលនាងវិសាខា អរិយសាវកក្នុងសាសនានេះ រឭករឿយៗ ចំពោះទេវតាទាំងឡាយថា: មានទេវតាទាំងឡាយ នៅជាន់ចាតុម្មហារាជិកា. មានទេវតាទាំងឡាយនៅជាន់តាវតឹង្ស ។ បេ ។ មានទេវតាទាំងឡាយនៅក្នុងពួកព្រហ្មមានទេវតាទាំងឡាយនៅជាន់លើនោះទៅទៀត ទេវតាទាំងឡាយនោះប្រកបដោយសទ្ធា មានសភាពយ៉ាងណា ទើបច្យុតអំពីមនុស្សលោកនេះ ឡើងទៅកើតក្នុងទេវលោកទាំងឡាយនោះ សទ្ធាមានសភាពយ៉ាងណានោះ របស់អាត្មាអញមានព្រមទេវតាទាំងឡាយនោះ ប្រកបដោយ សីល: សុត: ចាគ: បញ្ញាមានសភាពយ៉ាងណា ទើបច្យុតអំពីមនុស្សលោកនេះ បានឡើងទៅកើតក្នុងទេវលោកទាំងឡាយនោះ សីល: សុត: ចាគ: បញ្ញា មានសភាពយ៉ាងនោះរបស់អាត្មាអញមានព្រម កាលបើអរិយសាវកនោះ រឭករឿយៗចំពោះសទ្ធាសីល: សុត: ចាគ: បញ្ញា របស់ខ្លួនផង ចិត្តរមែងជ្រះថ្លា សេចក្ដីរីករាយរមែងកើតឡើង ឧបក្កិលេសរបស់ចិត្តទាំងប៉ុន្មាន ក៏រមែងលះបង់បាន ម្នាលនាងវិសាខាអរិយសាវកនេះ តថាគតឱ្យឈ្មោះថា បានរក្សានូវទេវតុបោសថ ឈ្មោះថាបាននៅរួមជាមួយនឹងទេវតាទាំងឡាយ ចិត្តរបស់អរិយសាវកនោះសោត រមែងជ្រះថ្លាសេចក្ដីរីករាយរមែងកើតឡើងប្រារព្ធចំពោះទេវតាទាំងឡាយ ទាំងឧបក្កិលេសរបស់ចិត្តទាំងប៉ុន្មានក៏រមែងលះបង់បាន ម្នាលនាងវិសាខា ការជុសលាងជំរះចិត្តដែលសៅហ្មង ឱ្យស្អាតផូរផង់ ដោយសេចក្ដីប្រឹងប្រែងយ៉ាងនេះឯង ។

ម្នាលនាងវិសាខា អរិយសាវកនោះឯង រមែងនឹករំពឹងពិចារណាឃើញច្បាស់ដូច្នេះថា ព្រះអរហន្តទាំងឡាយ រមែងលះបង់ការសម្លាប់សត្វ វៀរស្រឡះចាកការសម្លាប់សត្វមានអាជ្ញាដាក់ចុះ មានគ្រឿងសាស្ត្រាដាក់ចុះ មានសេចក្ដីខ្មាស់បាប ដល់នូវការអាណិតអាសូរសត្វ មានសេចក្ដីអនុគ្រោះដោយប្រយោជន៍ដល់សព្វសត្វ ដរាបដល់អស់អាយុជីវិតថ្ងៃនេះសូម្បីអាត្មាអញ ក៏សូមលះបង់នូវការសម្លាប់សត្វវៀរស្រឡះចាកការសម្លាប់សត្វ មានអាជ្ញាដាក់ចុះ មានគ្រឿងសាស្ត្រាដាក់ចុះ មានសេចក្ដីខ្មាសបាប ដល់នូវការអាណិតអាសូរសត្វ មានសេចក្ដីអនុគ្រោះដោយប្រយោជន៍ដល់សព្វសត្វ អស់យប់នេះនិងថ្ងៃនេះអាត្មាអញសូមរក្សាឧបោសថធ្វើគ្រាប់តាមព្រះអរហន្តទាំងឡាយដោយអង្គនេះផង ។ ព្រះអរហន្តទាំងឡាយរមែងលះបង់នូវការកាន់យកនូវវត្ថុដែលម្ចាស់មិនបានឱ្យ វៀរស្រឡះចាកការកាន់យកនូវវត្ថុដែលម្ចាស់មិនបានឱ្យ កាន់យកតែវត្ថុដែលម្ចាស់បានឱ្យ ប្រាថ្នាតែវត្ថុដែលម្ចាស់បានឱ្យ មានអត្តភាពជាអ្នកស្អាត មិនមែនជាអ្នកលួចដរាបអស់មួយជីវិតថ្ងៃនេះសូម្បីអាត្មាអញ ក៏សូមលះបង់នូវការកាន់យកនូវវត្ថុដែលម្ចាស់មិនបានឱ្យកាន់យកនូវដែលម្ចាស់បានឱ្យប្រាថ្នាតែវត្ថុដែលម្ចាស់បានឱ្យ មានអត្តភាពជាអ្នកស្អាត មិនជាអ្នកលួចអស់យប់នេះនឹងថ្ងៃនេះ អាត្មាអញសូមរក្សាឧបោសថធ្វើគ្រាប់តាមព្រះអរហន្តទាំងឡាយដោយអង្គនេះផង ។ ព្រះអរហន្តទាំងឡាយរមែងលះបង់នូវការប្រព្រឹត្តធម៌ដ៏ប្រសើរ ជាអ្នកប្រព្រឹត្តធម៌មិនប្រសើរ ជាអ្នកប្រព្រឹត្តឆ្ងាយចាកអព្រហ្មចរិយ ជាអ្នកវៀរចាកស្រឡះចាកមេថុន ដែលជា

ធម៌របស់អ្នកស្រុក ដរាបដល់អស់ជីវិត ថ្ងៃនេះសូមអាត្មាអញក៏សូមលះបង់នូវការប្រព្រឹត្តធម៌ដ៏ប្រសើរ ជាអ្នកប្រព្រឹត្តឆ្ងាយចាកអព្រហ្មចរិយជាអ្នកវៀរចាកស្រឡះចាកមេថុន ដែលជាធម៌របស់អ្នកស្រុកអស់យប់នេះនិងថ្ងៃនេះ អាត្មាអញសូមរក្សាឧបោសថធ្វើគ្រាប់តាមព្រះអរហន្តទាំងឡាយដោយអង្គនេះផង ។

ព្រះអរហន្តទាំងឡាយ រមែងលះបង់នូវការពោលពាក្យកុហក វៀរស្រឡះចាកការពោលពាក្យកុហក ជាអ្នកពោលនូវពាក្យពិត ជាអ្នកពោលពាក្យពិតភ្ជាប់ពាក្យពិតមិនឱ្យមានចន្លោះ ជាអ្នកពោលពាក្យរឹងជំហរមិនរេរ៉ះ ជាអ្នកពោលពាក្យអាងហេតុផលគួរជឿបាន ជាអ្នកពោលពាក្យមិនឃ្លៀងឃ្លាត បង្វែងលោកដរាបដល់អស់ជីវិត ថ្ងៃនេះសូម្បីអាត្មាអញក៏សូមលះបង់នូវការពោលពាក្យកុហក វៀរស្រឡះចាកការពោលពាក្យកុហក ជាអ្នកពោលនូវពាក្យពិតពោលនូវពាក្យពិតភ្ជាប់ពាក្យពិត មិនឱ្យមានចន្លោះ ជាអ្នកពោលពាក្យរឹងជំហរមិនរេរ៉ះ ជាអ្នកពោលពាក្យអាងហេតុផលគួរជឿបាន ជាអ្នកមិនពោលពាក្យឃ្លៀងឃ្លាតបង្វែងលោកអស់យប់នេះ និងថ្ងៃនេះ អាត្មាអញសូមរក្សានូវឧបោសថ ធ្វើគ្រាប់តាមព្រះអរហន្តទាំងឡាយដោយអង្គនេះផង ។ ព្រះអរហន្តទាំងឡាយរមែងលះបង់នូវសុរានិងមេរ័យ ដែលជាទីតាំងនៃសេចក្ដីប្រមាទ ជាអ្នកវៀរចាកស្រឡះចាកការផឹកនូវសុរានិងមេរ័យ ដែលជាទីតាំងនៃសេចក្ដីប្រមាទដរាបដល់អស់ជីវិត ថ្ងៃនេះសូម្បីអាត្មាអញក៏សូមលះបង់ នូវការផឹកនូវសុរានិងមេរ័យ ដែលជាទីតាំងនៃសេចក្ដីប្រមាទ ។ អ្នកវៀរស្រឡះចាកការផឹកនូវសុរានិងមេរ័យ ដែលជាទីតាំងនៃ

សេចក្ដីប្រមាទ អស់យប់នេះនិងថ្ងៃនេះ អាត្មាអញសូមរក្សាឧបោសថធ្វើត្រាប់តាមព្រះអរហន្តទាំងឡាយដោយអង្គនេះផង ។

ព្រះអរហន្តទាំងឡាយ រមែងបរិភោគនូវភត្តតែមួយពេល[១] តមការបរិភោគក្នុងរាត្រី វៀរចាកការបរិភោគក្នុងវិកាល ដរាបដល់អស់មួយជីវិត ថ្ងៃនេះសូម្បីអាត្មាអញ ក៏សូមបរិភោគនូវភត្តតែមួយពេល តមការបរិភោគក្នុងរាត្រី វៀរចាកការបរិភោគភោជនក្នុងកាល អស់យប់នេះនិងថ្ងៃនេះ អាត្មាអញសូមរក្សាឧបោសថ ធ្វើត្រាប់តាមព្រះអរហន្តទាំងឡាយដោយអង្គនេះផង ។

ព្រះអរហន្តទាំងឡាយ រមែងវៀរស្រឡះចាកការរាំច្រៀង ដេញដី និងការមើលនូវល្បែងផ្សេងៗ ដែលជាសត្រូវនូវកុសលធម៌ ចាកការទ្រទ្រង់នូវផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបផ្សេងៗ ដែលជាទីតាំងនៃការប្រដាប់ស្អិតស្អាងរាងកាយ ដរាបដល់អស់ថ្ងៃនេះសូម្បីអាត្មាអញក៏សូមវៀរស្រឡះចាកការរាំច្រៀង ដេញ ដី និងការមើលនូវល្បែងផ្សេងៗ ដែលជាសត្រូវដល់កុសលធម៌ ចាកការទ្រទ្រង់នូវផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបផ្សេងៗ ដែលជាទីតាំងនៃការប្រដាប់ស្អិតស្អាងរាងកាយ អស់យប់នេះនិងថ្ងៃនេះ អាត្មាអញសូមរក្សាឧបោសថ ធ្វើត្រាប់ព្រះអរហន្តទាំងឡាយ ដោយអង្គនេះផង ។

ព្រះអរហន្តទាំងឡាយ រមែងលះបង់នូវទីដេក ទីអង្គុយដ៏ខ្ពស់ និងទីដេក

(១)- ពេលភត្តមាន ២ គឺ បាតរាភត្ត = ភត្តពេលព្រឹក ពីព្រឹមអរុណរះដល់ថ្ងៃត្រង់ ១. សាយមាសភត្ត= ភត្តពេលល្ងាច ពីកន្លងថ្ងៃត្រង់ទៅដល់អរុណថ្មីរះ ១ ។

ទីអង្គុយដ៏ប្រសើរ សម្រេចនូវឥរិយាបថ ដេក អង្គុយដ៏ទាប លើគ្រែក្តី លើកម្រាលស្មៅក្តីដរាបដល់អស់ជីវិត ថ្ងៃនេះ សូមអាត្មាអញក៏សូមលះបង់នូវទីដេក ទីអង្គុយដ៏ខ្ពស់ និងទីដេក ទីអង្គុយដ៏ប្រសើរ សម្រេចនូវឥរិយាបថដេក អង្គុយដ៏ទាប លើគ្រែក្តី លើកម្រាលស្មៅក្តី អស់យប់នេះនិងថ្ងៃនេះ អាត្មាអញសូមរក្សាឧបោសថ ធ្វើត្រាប់តាមព្រះអរហន្តទាំងឡាយដោយអង្គនេះផង ។

ម្នាលនាងវិសាខា អរិយុបោសថយ៉ាងនេះឯង ។ ម្នាលនាងវិសាខា អរិយុបោសថដែលបុគ្គលរក្សាយ៉ាងនេះ ទើបបានផលច្រើន មានអនិសង្សច្រើន មានពន្លឺច្រើន មានរស្មីច្រើន មានផលច្រើនយ៉ាងណា? មានអនិសង្សច្រើនយ៉ាងណា ? មានពន្លឺច្រើនយ៉ាងណា ? មានរស្មីច្រើនយ៉ាងណា ? ម្នាលនាងវិសាខា យ៉ាងណាមិញ បុគ្គលដែលសោយរាជ្យ ជាឥស្សរិយាធិបតេយ្យក្នុងជនបទធំៗ ទាំង ១៦ ដែលសម្បូរដោយរតន៏ទាំង ៧ ប្រការជនបទណាខ្លះ ? គឺអង្គ ១. មគធ ១. កាសី ១. កោសលៈ ១. វជ្ជី ១. មល្លៈ ១. ចេតិ ១. វំសៈ ១. កុរុ ១. បញ្ចាលៈ ១. មច្ឆៈ ១. សុរសេន ១. អស្សកៈ ១. អវន្តី ១. គន្ធារ ១. កម្ពោជៈ ១. ឥស្សរិយាធិបតេយ្យរបស់បុគ្គលនោះមិនដល់ចំណិតភាគទី ១៦ ចុងបំផុតនៃឧបោសថ ប្រកបដោយអង្គ ៨ ដែលលោកបែងចែកចេញ ១៦ ភាគ ១៦ដង បានជាដូច្នោះ ព្រោះហេតុអ្វី ? ម្នាលនាងវិសាខា រាជសម្បត្តិរបស់មនុស្ស បើលើកយកទៅប្រៀបសេចក្តីសុខទិព្វរបស់ទេវតាទាំងឡាយ ក៏ឃើញថាត្រមោចគួរអាណិត ម្នាលនាងវិសាខា ៥០ ឆ្នាំ របស់មនុស្ស បានតែយប់១ ថ្ងៃ ១

ទិព្វរបស់ទេវតាជាន់ចាតុម្មហារាជ យប់ ថ្ងៃទិព្វ ៣០ ត្រូវជា ១ ខែ ទិព្វ. ១២ ខែទិព្វ ត្រូវជា ១ ឆ្នាំទិព្វ ៥០ ឆ្នាំទិព្វ ជាអយុប្បមាណនៃទេវតាទាំងឡាយជាន់ចាតុម្មហារាជ រឿងនេះជាភ័ស្តុតាង ១ ។

ម្នាលនាងវិសាខា ស្ត្រីក្តី បុរសក្តីក្នុងសាសនានេះ បានរក្សានូវឧបោសថប្រកបដោយអង្គ ៨ ដល់ធ្វើមរណកាលទម្លាយកាយទៅ រមែងបានចូលទៅកើតជាមួយនឹងទេវតាទាំងឡាយ ក្នុងជាន់ចាតុម្មហារាជ ។ ម្នាលនាងវិសាខា អាស្រ័យហេតុនេះឯង បានជាតថាគតពោលថា រាជសម្បត្តិរបស់មនុស្ស បើលើកយកទៅប្រៀបសេចក្តីសុខទិព្វឃើញថាត្រមោចគួរឱ្យអាណិត ម្នាលនាងវិសាខា ១០០ឆ្នាំមនុស្សបានតែយប់ ១ ថ្ងៃ ១ ទិព្វ របស់ទេវតាជាន់តាវតឹង្ស យប់ថ្ងៃទិព្វ ៣០ ត្រូវជា១ ខែទិព្វ១២ ខែទិព្វ ត្រូវជា ១ ឆ្នាំទិព្វ ១០០ឆ្នាំ ជាអាយុប្បមាណនៃជាន់ទេវតាទាំងឡាយជាន់តាវតឹង្ស រឿងនេះជាភ័ស្តុតាង ១ ។

ម្នាលនាងវិសាខា ស្ត្រីក្តី បុរសក្តីក្នុងសាសនានេះ បានរក្សានូវឧបោសថប្រកបដោយអង្គ ៨ ដល់ធ្វើមរណកាលទម្លាយកាយទៅរមែងបានចូលទៅកើតជាមួយនឹងទេវតាក្នុងជាន់តាវតឹង្ស ម្នាលនាងវិសាខា អាស្រ័យហេតុនេះឯង បានជាតថាគតពោលថា រាជសម្បត្តិរបស់មនុស្ស បើលើកយកទៅប្រៀបនឹងសេចក្តីសុខទិព្វឃើញថា ត្រមោចគួរឱ្យអាណិត ម្នាលនាងវិសាខា ២០០ឆ្នាំរបស់មនុស្ស បានតែយប់ ១ ថ្ងៃ១ ទិព្វរបស់ទេវតាជាន់យាមា យប់ថ្ងៃទិព្វ ៣០ ត្រូវជា

១ខែ ទិព្វ ១២ ខែទិព្វ ត្រូវជា ១ ឆ្នាំ ទិព្វ ២០០០ ឆ្នាំទិព្វ ជាអាយុប្បមាណនៃទេវតាទាំងឡាយជាន់យាមា ម្នាលនាងវិសាខា រឿងនេះជាភ័ស្តុតាង១ ។

ម្នាលនាងវិសាខា ស្ត្រីក្តី បុរសក្តី ក្នុងសាសនានេះ បានរក្សានូវឧបោសថប្រកបដោយអង្គ៨ ដល់ធ្វើមរណៈកាលទម្លាយកាយទៅ រមែងបានចូលទៅកើតជាមួយនឹងទេវតាទាំងឡាយជាន់យាមា ។ ម្នាលនាងវិសាខា អាស្រ័យហេតុនេះឯង បានជាតថាគតពោលថា រាជសម្បត្តិរបស់មនុស្ស បើលើកយកទៅប្រៀបនឹងសេចក្តីសុខទិព្វឃើញថា គ្រមោចគួរឱ្យអាណិត ម្នាលនាងវិសាខា ៤០០ ឆ្នាំ របស់មនុស្ស បានតែយប់ ១ ថ្ងៃ ១ ទិព្វរពស់ទេវតាជាន់តុសិត យប់ថ្ងៃទិព្វ ៣០ ត្រូវជា ១ ខែទិព្វ ១២ ខែទិព្វ ត្រូវជា ១ ឆ្នាំ ទិព្វ ៤០០០ ឆ្នាំទិព្វ ជាអាយុប្បមាណនៃទេវតាទាំងឡាយជាន់តុសិត រឿងនេះជាភ័ស្តុតាង ១ ។

ម្នាលនាងវិសាខា ស្ត្រីក្តី បុរសក្តី ក្នុងសាសនានេះ បានរក្សានូវឧបោសថប្រកបដោយអង្គ ៨ ដល់ធ្វើមរណកាលទម្លាយកាយទៅ រមែងបានចូលទៅកើតជាមួយនឹង ទេវតាទាំងឡាយជាន់តុសិត ។

ម្នាលនាងវិសាខា អាស្រ័យហេតុនេះឯង បានជាតថាគតពោលថារាជសម្បត្តិរបស់មនុស្ស បើលើកយកទៅប្រៀបនឹងសេចក្តីសុខទិព្វឃើញថាគ្រមោចគួរឱ្យអាណិត ម្នាលនាងវិសាខា ៨០០ ឆ្នាំរបស់មនុស្ស បានតែយប់ ១ ថ្ងៃ ១ ទិព្វរបស់ ទេវតាជាន់និម្មានរតី យប់ថ្ងៃទិព្វ ៣០ ត្រូវជា ១ ខែទិព្វ ១២ ខែទិព្វ

ត្រូវជា ១ ឆ្នាំទិព្វ ៨០០០ ឆ្នាំទិព្វ ជាអយុប្បមាណនៃទេវតាទាំងឡាយ ក្នុងជាន់និម្មានរតី រឿងនេះជាភស្ដុតាង ១ ។

ម្នាលនាងវិសាខា ស្ដ្រីក្ដី បុរសក្ដី ក្នុងសាសនានេះបានរក្សានូវឧបោសថ ប្រកបដោយអង្គ ៨ ដល់មរណកាល ទម្លាយកាយទៅ រមែងបានចូលទៅកើតជាមួយនឹងទេវតាទាំងឡាយ ក្នុងជាន់និម្មានរតី ម្នាលនាងវិសាខា អាស្រ័យហេតុនេះឯង បានជាតថាគតពោលថា រាជសម្បត្តិរបស់មនុស្ស បើលើកយកទៅប្រៀបនឹងសេចក្ដីសុខទិព្វ ឃើញថាត្រមោចគួរឱ្យអាណិត ម្នាលនាងវិសាខា ១៦០០ ឆ្នាំមនុស្ស បានតែយប់១ ថ្ងៃ១ ទិព្វរបស់ទេវតាទាំងលាយជាន់បរនិម្មិតវសវតី យប់ថ្ងៃទិព្វ ៣០ ត្រូវជា ១ ខែទិព្វ ត្រូវជា១ឆ្នាំ ទិព្វ ១៦០០០ ឆ្នាំទិព្វ ជាអយុកប្បមាណ នៃទេវតាទាំងឡាយ ក្នុងជាន់បរនិម្មិតវសវតី រឿងនេះជាភស្ដុតាង ១ ។

ម្នាលនាងវិសាខា ស្ដ្រីក្ដី បុរសក្ដី ក្នុងសាសនានេះ បានរក្សានូវឧបោសថ ប្រកបដោយអង្គ ៨ ដល់ធ្វើមរណៈកាលទម្លាយកាយទៅរមែងបានចូល ទៅកើតជាមួយ នឹងទេវតាទាំងឡាយក្នុងជាន់បរនិម្មិតវសវតី ម្នាលនាងវិសាខា អាស្រ័យហេតុនេះឯង បានជាតថាគតពោលថា រាជសម្បត្តិរបស់មនុស្ស បើលើកយកទៅប្រៀបនឹងសេចក្ដីសុខទិព្វថា ត្រមោចគួរឱ្យអាណិត ។

**ឧបោសថសុត្រចប់តែប៉ុណ្ណេះ**

## កំណើតនមោ

បុ ចុះបទថា នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស នេះតើអ្នកណាពោលជាដំបូង អ្នកនោះឈ្មោះអ្វីខ្លះ ?

វិ- ឈ្មោះអ្នកពោលនូវបទថា នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ជាដំបូងបង្អស់នោះដូចតទៅនេះ :

នមោ សាតាគិរីយក្ខោ តស្ស អសុរិន្ទោ បវុច្ចតិ ភគវតោ ចាតុមហារាជិកា អរហតោ សក្កោ តថា សម្មាសម្ពុទ្ធស្សាតិ មហាព្រហ្មេហិ បវុច្ចតិ ឥតិ ឯវំ បញ្ច ទេវេហិ បតិដ្ឋិតាតិ ។

១-នមោ សាតាគិរីយក្សពោលនមស្ការ .

២-តស្ស អសុរិន្ទរាហូនមស្ការ .

៣-ភគវតោ ស្តេចចាតុមហារាជពោលនមស្ការ .

៤-អរហតោ សម្តេចទេវរាជពោលនមស្ការ .

៥-សម្មាសម្ពុទ្ធស្ស មហាព្រហ្មពោលនមស្ការ ។

ទេវតាទាំង ៥ ព្រះអង្គនេះ ជាអ្នកពោលនមស្ការមួយអង្គមួយបទៗ រៀងខ្លួន ។

ប៉ុ. ចុះបទថា នមោ នេះមានន័យសំដែងដូចម្តេចខ្លះ ?

វិ. បទថា នមោ នេះមានន័យនៅក្នុងសុត្តន្តបិដកសំដែងខ្លះៗ នឹងសេចក្តីដែលគួរចូលចិត្តបាន ដូចតទៅនេះ :

១- នមោ ដែលមានក្នុងសក្កបញ្ហសូត្រមានរឿងដំណាលថា:

កាលនោះស្តេចអមរិន្ទ មានទេពបំណងនឹងស្តេចទៅគាល់ព្រះសាស្តា ទើបបានទ្រង់តាំងគន្ធព្វទេវបុត្រឱ្យជាមគ្គុទេសក៍ នាំផ្លូវព្រះអង្គព្រមដោយទេវបរិវារមកកាន់សំណាក់ព្រះបរមសាស្តា តែក្នុងវេលានោះព្រះអង្គនៅនាសម្បណ្ណគុហាជិតភ្នំវេទយិកាបពិតក្នុងតំបន់អម្ពសណ្ឌ ក្នុងដែនរាជគ្រឹះ ទ្រង់ចូលសន្ទនាការប្រាស្រ័យជាមួយនឹងព្រះសម្ពុទ្ធបរមគ្រូល្មមសមគួរហើយ ទើបទូលបញ្ហាកម្មផ្សេងៗ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ឆ្លើយដោះស្រាយជំរាបដល់ព្រះអង្គអស់សេចក្តីសង្ស័យ ហើយទ្រង់ប្រកាសនូវសេចក្តីរីករាយសាទរយ៉ាងក្រៃលែង ក្នុងកាលដែរបានទទួលក្រេបរសធម៌ទេសនាជាដើមថា ព្រះអង្គនឹងបានចម្រើនព្រះជន្មាយុយឺនយូរ ។

ប្រសិនបើច្យុតិចាកទេវលោកក៏គង់មិនបានទៅកាន់អបាយភូមិទៀត ព្រះអង្គត្រាស់ស្រេចហើយទើបមាន ទេវបញ្ជានឹងគន្ធព្វទេវបុត្រថាលោកមានឧបការៈច្រើនដល់យើង ដែលញ៉ាំងព្រះសាស្តា ឱ្យជ្រះថ្លាជាដំបូង ហើយនាំយើងចូលទៅកាន់សំណាក់ព្រះអង្គក្នុងពេលខាងក្រោយ ណ្ហើយចុះ យើងនឹងឱ្យលោកបានដំណែង

ជាគន្ធព្វទេវរាជ ។ ក្នុងទីបំផុតស្តេចអមរិន្ទឥន្ទកោសិយ ទ្រង់យកព្រះហស្តចាប់ពាល់ផែនដី ហើយបន្លឺព្រះឧទានវាចាដោយសេចក្តីត្រេកអររីករាយក្នុងព្រះទ័យថា:

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។ (ដូច្នេះចំនួន ៣ ដង) ។

២- នមោ ដែលមានមកក្នុងបិយជាតិសូត្រមានរឿងពោលទុកថា គហបតីម្នាក់ មានកូនប្រុសមួយជាទីស្រឡាញ់ពេញចិត្ត កូននោះអនិច្ចកម្មទៅ ចំណែកគហបតីជាបិតាមានសេចក្តីយំសោក ខ្សឹកខ្សួលអាឡោះអាល័យស្តាយបុត្រពន់ប្រមាណ ដរាបដល់ឈប់ធ្វើការងារចិញ្ចឹមជីវិត គិតតែដេកសម្ងំនិងយំកន្ទក់កន្ទេញបម្រះនន្ទៀលរៀបរាប់ដោយប្រការផ្សេងៗ ថ្ងៃមួយគាត់បានចូលទៅគាល់ព្រះសាស្តាៗត្រាស់បង្គាប់ឱ្យសួររឿងហេតុរួចហើយ ទើបត្រាស់ថាម្នាលគហបតី សេចក្តីសោយសោកអាពោះអាល័យ និងទុក្ខទោមនស្សទាំងឡាយនេះ សុទ្ធតែកើតឡើងអំពីសេចក្តីស្រឡាញ់មាន របស់ស្រឡាញ់ជាដែនកើតទាំងអស់។ គាត់ក៏មិនត្រេកអរ មិនជំទាស់តិះដៀលពុទ្ធភាសិត គ្រាន់តែក្រោកអំពីទីអង្គុយហើយដើរចៀសចេញទៅ ហើយទៅពោលពណ៌នារឿងនោះ ប្រាប់ឱ្យអ្នកផងស្តាប់ដំណឹងព្រះពុទ្ធភាសិតនេះ បានឮផ្សាយទៅដល់ព្រះមរមករាជវាំង ។ ព្រះបាទបសេនទិកោសលទើបទ្រង់ត្រាស់សួរនាងមល្លិកាថា ព្រះសមណគោតមពោលដូច្នោះមែន ឬមល្លិកា ។ មែនហើយព្រះអង្គ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់កែសេចក្តីតែម៉្យាងប៉ុណ្ណោះ សូមទ្រង់មេត្តាប្រោស ។ ព្រះរាជាទ្រង់ជឿហើយមានបន្ទូលថា

មល្លិកានេះ ឱ្យតែព្រះសមណគោតមពោលថាដូចម៉េច១ ចេះតែយល់ឃើញថាពិត១ ទាំងអស់ ប្រហែលគ្នាសិស្សនិងអាចារ្យនិយាយអ្វី១ ក៏និយាយតាមគ្នាទៅ ហើយក៏បណ្ដេញព្រះនាងឱ្យចេញទៅ ។

ថ្ងៃមួយខាងក្រោយ ព្រះនាងចូលទៅគាល់ព្រះរាជា ហើយទូលអធិប្បាយព្រះពុទ្ធភាសិតនោះដោយពិស្តារ តែក្នុងទីនេះនឹងច្បិចលើកយក ចំពោះតែសេចក្ដីសំខាន់មកសំដែងឱ្យឃើញថាព្រះនាងទូលសួរព្រះមហាក្សត្រថា បពិត្រមហារាជ វជិរីកុមារីរាជធិតារបស់ព្រះអង្គក្ដី ព្រះនាងវាសភខត្តិយាក្ដី វិឌូឌភសេនាបតីក្ដី ខ្លួនព្រះនាងខ្ញុំជាម្ចាស់ក្ដី ដែលកាសី និងកោសលក្ដី ទាំងអម្បាលនេះជារបស់ស្រឡាញ់ពេញព្រះទ័យខ្លះឬទេ? ព្រះរាជាតបថា ចាំបាច់និយាយទៅថ្វីមល្លិការបស់ទាំងនេះសូម្បីតែមួយមុខ១នេះ ក៏យើងនៅតែស្រឡាញ់ពេញចិត្តទាំងអស់ ។

ចុះបើរបស់ទាំងនោះ វិនាសព្រាត់ប្រាសឬប្រែប្រួលទៅដោយប្រការផ្សេង១ ព្រះអង្គនឹងទ្រង់ទោមនស្សខ្លះដែរឬទេ ? ណ្ហើយចុះមល្លិកាសូម្បីតែខ្លួនយើងក៏គង់ដឹងជាក់ថាជាសេចក្ដីទុក្ខយ៉ាងធំ ព្រះនាងចេះតែទទូចទូលថាហ្នឹងហើយ មហាបពិត្រសេចក្ដីនេះ សមដូចពុទ្ធភាសិតដែលព្រះមានព្រះភាគត្រាស់មិនមែនឬព្រះមានព្រះភាគជាព្រះអរហន្តត្រាស់ដឹងប្រពៃដោយព្រះអង្គឯង ទ្រង់បំណងយកសេចក្ដីនេះ ទើបទ្រង់ត្រាស់ថា« សេចក្ដីសោកសង្រេងសង្រែ អាឡោះអាល័យនិងទុក្ខទោមនស្សទាំងឡាយសុទ្ធតែកើតមានឡើង មកអំពីសេចក្ដីស្រឡាញ់មានរបស់ស្រឡាញ់ជាដែនកើតមុនដូច្នេះ ។

មែនពិត មល្លិកា គួរអស្ចារ្យណាស់ ហ្ន៎ មិនធ្លាប់មានមកពីមុនឡើយ ប្រាកដជាព្រះមានព្រះភាគទ្រង់ចាក់ធ្លុះចំពោះដោយប្រាជ្ញាញាណ ទើបបានទ្រង់ឃើញនូវហេតុយ៉ាងនេះយ៉ាងច្បាស់លាស់ ។ ព្រះរាជាទ្រង់ពេញព្រះទ័យ ជរាប ដោយក្រោកឡើងពីអាសនៈ ទ្រង់ពានាព្រះភូសាឆៀងព្រះអង្សាខាងស្តាំ ហើយទ្រង់បន្លឺឧទានវាចាដោយសេចក្តីជ្រះថ្លាថា:

នមោ តស្ស ភគវតោ អរហតោ សម្មា-សម្ពុទ្ធស្ស ។ (ដូច្នេះ ៣ ដង) ។

៣- នមោ ដែលមានមកក្នុងព្រហ្មាយុសូត្រនោះ មានរឿងដំណាលទុកថា មានព្រាហ្មណ៍ចាស់ម្នាក់ ជាគណាចារ្យយ៉ាងធំឈ្មោះព្រហ្មាយុ មានអាយុ ១២០ ឆ្នាំ បានជ្រាបព្រះកិត្តិយសសំដែងលាន់ឮរន្ទឺ ល្បីមកថា ព្រះសមណគោតម ព្រះអង្គស្តេចចេញព្រះផ្នួសអំពីសក្យៈត្រកូល ហើយបានត្រាស់ដឹងធម៌ពិសេសទាំងពួង ដោយប្រពៃចំពោះព្រះអង្គឯង ជាព្រះអរហន្តឯកក្នុងលោករកបុគ្គលណាមួយ ទៅប្រៀបផ្ទឹមពុំបាន ឥឡូវនេះព្រះអង្គទ្រង់សំដែងធម៌ប្រោសប្រដៅមហាជន មានកិត្តិស័ព្ទល្បីល្បាញខ្ចរខ្ចាយពួសាយសុសសព្វពសុធា ព្រាហ្មណ៍មានបំណងប៉ងប្រាថ្នាចង់ដឹងនូវសេចក្តីពិត ដូចអ្នកផងគេនិយាយមែនឬទេ ទើបហាមាត់ហៅឧត្តរមាណពដែលជាសិស្សសំណប់ចិត្តតែមួយ ឱ្យទៅជួយស៊ើបសួររកសេចក្តីពិត ។

ឧត្តរមាណពទទួលយ៉ាងឆាប់នូវពាក្យបង្គាប់លោកអាចារ្យហើយ បាន ត្រាច់រង្គាត់សង្វាតរកតាមលំដាប់ រហូតចូលទៅដល់ទីដែនវិទេហៈដែលព្រះសាស្ដា ស្ដេចគង់នៅ គាត់ចូលទៅជិតគាល់ព្រះអង្គ ទើបក្រាបទូលសន្ទនាប្រាស្រ័យ លុះល្មមសមគួរហើយ ទើបលុតជង្គង់អង្គុយចុះ។ គាត់បានគន់គូរពិចារណាមើល មាហាបុរសលក្ខណៈ ៣២ ប្រការ មានក្នុងព្រះកាយរបស់ព្រះសាស្ដា ឃើញ សព្វគ្រប់បរិបូណ៌ គាត់មានសេចក្ដីត្រេកអរសោមនស្សយ៉ាងចំហុត តែមានបំណង ចង់ដឹងឱ្យក្រៃលែងតទៅទៀត ទើបឃ្លាំចាំមើលជាប់តាមព្រះព្រះអង្គគ្រប់ ឥរិយាបថ ដូចស្រមោលទៅតាមខ្លួនអស់វារៈ ៧ ខែ ទើបបានដឹងច្បាស់ ។ លុះអស់សេចក្ដីសង្ស័យហើយ ទើបគាត់ប្រញាប់ប្រញាល់វិលត្រឡប់មកកាន់ក្រុង មិថិលាវិញ ចូលទៅកាន់សំណាក់អាចារ្យ និយាយរៀបរាប់អំពីរឿងរាវផ្សេងៗ តាំងតែអំពីខាងដើម រហូតដល់ចប់ឱ្យព្រាហ្មាយុព្រាហ្មណ៍ជាអាចារ្យស្ដាប់ ។ ព្រាហ្មាយុ ព្រាហ្មណ៍ចាស់ជរាក៏ពេញប្រៀបទៅដោយប្រីតាប្រាមោទ្យ បន្លឺនូវឧទាន វាចាដោយសេចក្ដីត្រេកអរីករាយនៃចិត្តថា :

នមោ តស្ស ភគវតោ អរហតោ សម្មា-សម្ពុទ្ធស្ស ។ (ដូច្នេះ ៣ ដង) ។

៤-នមោ ដែលមានមកក្នុងគារវសូត្រ មាននិទានលោកពោលទុកថា ក្នុងដែនកោសលមាននាងព្រាហ្មណីម្នាក់ឈ្មោះធនញ្ជានី ជាស្ត្រីមានសេចក្ដីជ្រះថ្លា

យ៉ាងក្រៃលែងក្នុងពុទ្ធសាសនា អាស្រ័យនៅក្នុងស្រុកឈ្មោះអចលកប្បៈ បាន ជាភរិយានៃភារទ្វាជព្រាហ្ម៍ ដែលត្រូវជាបងប្រុសអក្កោសកភារទ្វាជព្រាហ្មណ៍ នាងជាព្រះសោតាបន្នបុគ្គល នាងនោះកណ្ដាស់ក្ដី ក្អកក្ដី ភ្លាំងភ្លាត់រអិលជំពប់ក្ដី នាងច្រើនតែភ្ញាក់លាន់មាត់បន្លឺឧទានវាចាថា :

នមោ តស្ស ភគវតោ អរហតោ សម្មា-សម្ពុទ្ធស្ស ។ (ដូច្នេះជានិច្ចកាល) ។

បុ. ការពោល នមោ មានប្រយោជន៍ដូចម្ដេច ?

វិ. ការពោលនមោ មានប្រយោជន៍ដូចតទៅនេះ :

១- ដើម្បីឱ្យអ្នកប្រាជ្ញទាំងឡាយជ្រាបថា ការប្រព្រឹត្តយ៉ាងនេះជិតចំពោះវង្ស នៃព្រះអរិយជាម្ចាស់ .

២-ដើម្បីការពារសព្វន្តរាយ .

៣-ដើម្បីនឹងជម្រះសន្ដានចិត្តឱ្យបរិសុទ្ធ.

៤-ដើម្បីនឹងឱ្យជីវិតិន្ទ្រីយ៍មានខ្លឹមសារ ។

**ចប់កំណើតនមោតែប៉ុណ្ណេះ**

## កំណើតបរិត្ត

បុ. បរិត្តនេះកើតពីត្រឹមណាមក ? លោកណាសំដែង ?

វិ. បរិត្តនេះមានយូរហើយ ក្នុងចន្លោះសាសនា កើតពីព្រះពោធិសត្វ កាលព្រះកើតជាសត្វក្ងោក ក្នុងពុទ្ធសាសនាព្រះអង្គសំដែងរឿយអាយុវឌ្ឍនកុមារ ដូចមានក្នុងរឿង ចម្រើនព្រះជន្មស្រោប ។

បុ. ចូរនាំរឿងមោរជាតកមកមើល ?

វិ. មោជាតក ដូចមានរឿងតទៅនេះ :

## មោរជាតក

ឧទេតយញ្ចក្ខុមាតិ ឥទំ សត្ថាជេតវនេ វិហរន្តោ ឯកំ ឧក្កណ្ឋិតភិក្ខុំ អារព្ភ កថេសិ ។

សត្ថា កាលសម្ដេចព្រះបរមត្រៃលោកនាថសាស្ដាចារ្យ ស្ដេចប្រថាប់គង់នៅក្នុងជេតពនមហាវិហារ ព្រះអង្គទ្រង់ប្រារព្ធភិក្ខុមានសេចក្ដីអផ្សុកមួយរូបឱ្យជាហេតុ ត្រាស់ទេសនាមោរជាតកនេះ មានពាក្យថា ឧទេតយញ្ចក្ខុមា ជាដើម ។

ឯភិក្ខុអផ្សុកនោះ ភិក្ខុទាំងឡាយបាននាំទៅកាន់ព្រះដ៏បុណ្យ ព្រះអង្គមានពុទ្ធដីកាត្រាស់សួរថា ម្នាលភិក្ខុ! អ្នកមានសេចក្ដីអផ្សុកមែនឬ ? ភិក្ខុនោះ

ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពិតមែន ។ ព្រះអង្គត្រាស់សួរតទៅទៀតថា លោកឃើញអ្វីបានជាកើតសេចក្តីអផ្សុក ?

សូមទ្រង់មេត្តាប្រោស! ខ្ញុំព្រះអង្គឃើញមាតុគ្រាមមួយនាក់ មានរូបល្អតែងតួល្អណាស់ និម្មិតតែបានឃើញភ្លាម ខ្ញុំព្រះអង្គក៏គិតវិលវល់តែម្តង ។ មានព្រះពុទ្ធដីកាថា ចិត្តរបស់មនុស្សទាំងឡាយយ៉ាងអ្នកនេះ ថ្វីក៏មាតុគ្រាមធ្វើកករល្អក់មិនបានអម្បាលអ្នកប្រាជ្ញពីបុរាណមានល្អជាងអ្នកទៅទៀត ម្តេចក៏បានស្តាប់សម្លេងហើយ កិលេសដែលមិនធ្លាប់ពុះពោរដល់ប្រាំពីររយឆ្នាំ គង់កើតឡើងគ្របសង្កត់ចិត្តបាន ក្នុងខណៈនោះសត្វទាំងឡាយជាអ្នកបរិសុទ្ធ ក៏សៅហ្មង អ្នកបរិបូណ៌ដោយយសយ៉ាងខ្ពង់ខ្ពស់ ក៏ដល់នូវសេចក្តីសាបសូន្យយស ចាំបាច់និយាយថ្វីដល់អ្នកដែលមិនបរិសុទ្ធនេះ ទ្រង់ត្រាស់ដូច្នេះហើយ ភិក្ខុទាំងឡាយក្រាបទូលអារាធនា ទើបទ្រង់នាំអតីតនិទានមកសំដែងដូចតទៅនេះ :

អតីតេ ពារាណសិយំ ព្រហ្មទត្តេ រជ្ជំ ការេន្តេ

ក្នុងកាលកន្លងវិលងទៅយូរហើយ នាកាលព្រះបាទព្រហ្មទត្តទ្រង់សោយរាជ្យសម្បត្តិក្រុងពារាណសី ព្រះពោធិសត្វកើតជាក្ងោកមានសម្បុរដូចមាសឆ្អិនបញ្ចុះថ្នាំពណ៌គួរពិតពិលរមើលមើល ។ មយុរពោធិសត្វនោះ មានបំណងនិងរក្សាជីវិតឱ្យយឺនយូរ ទើបលះបង់ភ្នំខាងក្រៅ ៣ ជាន់ ទៅអាស្រ័យនៅលើទណ្ឌកហិរញ្ញបពិត(១) មានក្នុងជាន់ទី៤ខាងក្នុង ដល់វេលាព្រឹកព្រាងស្វាងឡើង ក៏ហើរឡើងទៅឈរលើកំពូលភ្នំ សម្លឹងមើលព្រះអាទិត្យឧទ័យ( អរុណរះ) ឡើង កាលនឹង

(១) -ភ្នំមានកំទេចប្រាក់ ដូចកំណាត់ឈើ ។

ចង់ព្រហ្មមន្តគាថា ដើម្បីនឹងរក្សាការពារខ្លួនឱ្យរួចអំពីភ័យនៅវេលាស្វែងរកអាហារ ទើបពោលពាក្យនមស្សការព្រះអាទិត្យឧទ័យដោយវចនៈប្រព័ន្ធបឋមឆន្ទគាថាថា:

ឧទេតយញ្ចក្ខុមា ឯករាជា ហរិស្សវណ្ណោ
បឋវិប្បភាសោ តំ តំ នមស្សាមិ ហរិស្សវណ្ណំ
បឋវិប្បភាសំ តយជ្ជគុត្តា វិហរេ មុទិវសំ ។

សេចក្តីថា: ព្រះសុរិយាទេវបុត្រ ដ៏ប្រសើរអង្គឯណា មានចក្ខុព្រះរាជាឯកមានសម្បុរដូចមាស ធ្វើផែនដីភ្លឺស្វាងរះឡើង ខាងបាចីលោកធាតុខ្ញុំសូមអភិវាទក្រាបថ្វាយបង្គំនូវ ព្រះសុរិយាទេវបុត្រ ដ៏មានសម្បុរដូចមាសធ្វើផែនដីឱ្យភ្លឺស្វាង អង្គនោះ សូមព្រះអង្គជួយឃុំគ្រងការពារសេចក្តីអន្តរាយខ្ញុំព្រះអង្គ ឱ្យនៅជាសុខរហូតអស់១ថ្ងៃក្នុងថ្ងៃនេះ។ មយុរៈពោធិសត្វនមស្សការព្រះសុរិយ ទេវបុត្ត ដោយបឋមគាថាដូច្នេះហើយ ក៏នមស្សការព្រះពុទ្ធជាម្ចាស់ទាំងឡាយ ព្រមទាំង ព្រះពុទ្ធគុណដោយទុតិយគាថា:

យេ ព្រាហ្មណា វេទគុ សព្វធមេ តេមេ
នមោ តេ ច មំ បាលយន្តុ នមត្ថុ ពុទ្ធានំ នមត្ថុ
ពោធិយា នមោ វិមុត្តានំ នមោ វិមុត្តិយា ។

សេចក្ដីថា : ព្រះពុទ្ធជាម្ចាស់ទាំងឡាយឯណា ដែលឈ្មោះថាព្រាហ្មណ៍ ដោយសេចក្ដីថា ជាអ្នកមានបាបធម៌បណ្ដែតចេញអស់ហើយ ជាអ្នកដឹងនូវវេទ សេចក្ដី ច្បាស់នូវធម៌ទាំងពួង ខ្ញុំព្រះករុណាសូមថ្វាយបង្គំចំពោះព្រះជាម្ចាស់ទាំងឡាយនោះ បីបាច់ថែរក្សាខ្ញុំព្រះករុណាផង សូមថ្វាយបង្គំចំពោះអ្នកត្រាស់ដឹងទាំងឡាយ ខ្ញុំសូមថ្វាយបង្គំចំពោះបញ្ញាជាគ្រឿងត្រាស់ដឹងទាំងឡាយ ខ្ញុំសូមថ្វាយបង្គំចំពោះ អ្នករួចចាកកិលេសទាំងឡាយ ខ្ញុំសូមថ្វាយបង្គំចំពោះគុណជាតិជាគ្រឿងរួចចាកកិលេស ។

សម្ដេចព្រះត្រៃលោកនាថសាស្ដាចារ្យ កាលទ្រង់នាំអតីតនិទានមកសម្ដែង ដូច្នេះហើយ ព្រះអង្គជាតិសម្ពុទ្ធបុគ្គលបានត្រាស់បំពេញព្រះពុទ្ធសុភាសិតខាងចុងព្រហ្មមន្តបរិត្តគាថាថា :

ឥមំ សោ បរិត្តំ កត្វា មោរោ ចរតិ ឯសនា

សេចក្ដីថា: មោរពោធិសត្វនោះ ធ្វើពាក្យនមស្សការនេះឱ្យជាគ្រឿងការពាររក្សាភយន្តរាយហើយ ទើបត្រេចទៅស្វែងរកអាហារ ។

(តលំដាប់រឿងនិទានថា) មយុរពោធិសត្វនោះ ត្រេចទៅស្វែងរកអាហារអស់ ១ ថ្ងៃទល់ព្រលប់ ហើយក៏ត្រឡប់មកកាន់ទ្រនំលើកំពូលភ្នំវិញ ឃើញព្រះអាទិត្យទៀបអស្ដង្គតទៅ កាលនឹងទ្រង់រំពឹងដល់ព្រះពុទ្ធគុណហើយចងព្រហ្មមន្តដើម្បីរក្សាការពារខ្លួនក្នុងលំនៅទៀត ទើបពោលគាថា ២ គាថា ថា :

អបេតយញ្ចក្ខុមា ឯករាជា ហរិស្សវណ្ណោ

បថវិប្បភាសោ តំ តំ នមស្សាមិ ហរិស្សវណ្ណំ
បថវិប្បភាសំ តយជ្ជ គុត្តា វិហរេ
មុរត្តិ យេ ព្រាហ្មណា វេទគុ សព្វធម្មេ តេ
មេ នមោ តេ ច មំ បាលយន្តុ
នមត្ថុ ពុទ្ធានំ នមត្ថុ ពោធិយា
នមោ វិមុត្តានំ នមោ វិមុត្តិយា ។

សេចក្ដីនៃព្រហ្មមន្តបរិត្តគាថាវេលាល្ងាចនេះ មានពាក្យប្លែកពីគាថាវេលាព្រឹក ពីរម៉ាត់ គឺវេលាព្រឹកថា ឧទេតិ ប្រែថារះឡើងមក វេលាល្ងាចថា អបេតិ ប្រែថាលិចទៅ និងវេលាព្រឹកថា ទិវសំ ប្រែថារហូតអស់ ១ ថ្ងៃ វេលាល្ងាចថា រត្តិំ ប្រែថា រហូតអស់ ១ យប់ ក្រៅពីនោះ មានសេចក្ដីដូចគ្នាទាំងអស់ ក្នុងទីបំផុតក៏ជាពុទ្ធភាសិត សម្ដេចព្រះសម្មាសម្ពុទ្ធត្រាស់បំពេញថា :

ឥមំ សោ បរិត្តំ កត្វា
មោរោ វាសមកប្បយីតិ ។

មោរពោធិសត្វធ្វើពាក្យនមស្សការនេះ ឱ្យជាគ្រឿងរក្សាការពារភយន្តរាយ ហើយ ក៏សម្រេចការនៅជាសុខទៅ ។ មយុរពោធិសត្វប្រព្រឹត្តខ្លួនដូចពោលមកនេះ ជាប្រក្រតីតាមធម្មតា ។

គ្រានោះ ក្នុងទីមិនឆ្ងាយប៉ុន្មានអំពីពារាណសី មានតំបន់មួយនៅស្រុករបស់ព្រាន ក្នុងពួកស្រុកនោះមានព្រានម្នាក់ត្រេចទៅក្នុងប្រទេសហេមពាន្ត ឃើញក្ងោកពោធិសត្វចាប់ទ្រនំទំនៅលើកំពូលភ្នំទណ្ឌកហិរញ្ញបពត ។ លុះព្រាននោះត្រឡប់មកដល់ផ្ទះ ក៏ដំណាលរឿងនោះឱ្យកូនស្តាប់ ។ វេលាថ្ងៃមួយព្រះនាងខេមារាជទេវី អគ្គមហេសីរបស់ព្រះព្រហ្មទត្ត ទ្រង់ព្រះសុបិនថា បានឃើញក្ងោកមាសកំពង់សំដែងធម៌ មិនទាន់ស្តាប់ មិនទាន់ស្តាប់ធម៌ក៏ភ្ញាក់ឡើង ទើបព្រះនាងទូលសេចក្តីតាមព្រះសុបិនសុភនិមិត្ត ហើយមានបំណងនឹងទ្រង់ស្តាប់ធម្មទេសនារបស់ស្តេចក្ងោកមាសឱ្យត្រាតែបាន ។

សម្តេចព្រះបរមបពិត្រផ្ទៃក្រោម ជារាជស្វាមី មានព្រះតម្រាស់ត្រាស់សួរអាមាត្យថា ក្ងោកមាសមាននៅក្នុងទីឯណាខ្លះ ? ពួកអាមាត្យក្រាបទូលថា ព្រាហ្មណ៍ទាំងឡាយទើបជ្រាបដឹង ។ កាលត្រាស់សួរពួកព្រាហ្មណ៍ៗក៏ក្រាបទូលថា ក្ងោកមាសមានជាប្រាកដ តែមិនដឹងជានៅក្នុងទីណា ។ ពួកព្រានព្រៃទើបដឹងរឿងនេះ ទើបមានព្រះរាជឱង្ការឱ្យព្រានព្រៃមកប្រជុំហើយត្រាស់សួរ ។ កូនប្រុសរបស់ព្រាននោះក្រាបបង្គំទូលថា បិតារបស់ទូលព្រះបង្គំដំណាលឱ្យស្តាប់ថា ក្នុងប្រទេសហេមពាន្ត មានភ្នំមួយឈ្មោះហិរញ្ញបពត ភ្នំនោះជាទីនៅរបស់ សត្វក្ងោកមាស ហើយត្រាស់ឱ្យទុកសុវណ្ណប័ដនោះក្នុងហិបមាសក្នុងព្រះរាជនិវេសន៍ ។

កាលសម្តេចព្រះបរមក្សត្រអង្គនោះ សុគតកន្លងទៅហើយក្សត្រអង្គដទៃឡើងគ្រងរាជសម្បត្តិ បានទ្រង់អានព្រះអក្សរក្នុងផែនមាសនោះហើយ ក៏ត្រាស់ឱ្យនាយនេសាទ ( ព្រានព្រៃ ) ម្នាក់ទៅ ដើម្បីចាប់ ។

ព្រះរាជាទ្រង់ព្រះសណ្ដាប់ ក៏ទ្រង់ព្រះសោមនស្ស ត្រាស់បង្គាប់ឱ្យបុត្រព្រានព្រៃនោះទៅចាប់ក្ងោកមាសនោះនាំមកឱ្យត្រាតែបាន ។

បុត្រព្រានព្រៃនោះទទួលព្រះរាជឱង្ការហើយ ក៏ទៅចាត់ចែងគ្រឿងប្រដាប់ស្បៀងអាហារ យាត្រាចាកផ្ទះ ដើរលេចវាលចូលព្រៃ ដរាបដល់គោចរភូមិឋាន (ទីស្វែងរកអាហារ) របស់មយុរពោធិសត្វ គយឃ្លាំចាំសង្កេតមើលត្រាតែឃើញច្បាស់ថា ធ្លាប់ត្រាច់ទៅស្វែងរកអាហារក្នុងទីនោះ ក៏ទៅដាក់អន្ទាក់ក្នុងទីនោះដោយអំណាចព្រះបរិត្តមន្តឃុំគ្រងរក្សាការពារអន្ទាក់មិនថ្លោះ មិនវាត់មិនជាប់ក្ងោកមាសដល់ម្ដងឡើយ ។ ព្រាននោះទៅនៅក្នុងព្រៃនោះចាំទាក់ មយុរពោធិសត្តអស់ ៧ ឆ្នាំ មិនអាចចាប់បាន ទាល់តែដល់កិរិយា ស្លាប់ក្នុងព្រៃនោះទៅ ។

ចំណែកព្រះនាងខេមាទេវី កាលបើមិនបានសមតាមសេចក្ដីប្រាថ្នា ក៏ក្រៀមក្រំព្រះហឫទ័យដល់ទីវង្គត ។ សម្ដេចព្រះបរមក្សត្រទ្រង់ព្រះពិរោធថា ពីព្រោះតែក្ងោកមាសនោះឯង បានជាព្រះរាជទេវីទីវង្គត ព្រះអង្គមានព្រះរាជបញ្ជាបង្គាប់ឱ្យចារឹកអក្សរទុកក្នុងផែនមាសដាក់សេចក្ដីថា នៅប្រទេសហេមពាន្តមាន ភ្នំ ១ ឈ្មោះទណ្ឌកហិរញ្ញបពិត នៅទីនោះមានក្ងោកមាសអាស្រ័យនៅ អ្នកណាបានស៊ីសាច់ក្ងោកមាសនោះ អ្នកនោះមានអាយុយឺនយូរមិនចាស់មិនស្លាប់ឡើយ ហើយត្រាស់ឱ្យទុកសុវណ្ណប័ដក្នុងហិបមាសក្នុងព្រះរាជនិវេសន៍ ។

កាលសម្ដេចព្រះបរមក្សត្រអង្គនោះសុគតកន្លងទៅ ក្សត្រអង្គដទៃទៀតឡើងគ្រងរាជសម្បត្តិ បានទ្រង់អានអក្សរក្នុងផែនមាសនេះហើយ ក៏ទ្រង់ឱ្យនាយនេសាទ (ព្រានព្រៃ) ម្នាក់ទៅដើម្បីចាប់ក្ងោកមាស ព្រានព្រៃនោះទៅនៅក្នុង

ព្រៃចាប់ចាំក្ងោកមាសនោះ យូរប៉ុន្មាន ក៏មិនអាចចាប់មយុរពោធិសត្តបាន ។ គ្រាន់តែព្រះរាជាក្រុងពារាណសីប្រើព្រាណព្រៃ ឱ្យទៅចាប់មយុរពោធិសត្ត ដោយចំនងនេះអស់ ៦ រជ្ជកាលក៏ចាប់ពុំបាន ។ ស្តេចជាគំរប់ ៧ ក៏ទ្រង់បញ្ជូនព្រានព្រៃម្នាក់ទៅទៀត ។

ព្រានព្រៃនោះជាមនុស្សឈ្លាស កាលយកអន្ទាក់ទៅដាក់ហើយ អន្ទាក់ក៏មិនថ្ពោះដូច្នេះ ក៏តាមទៅលបសង្កេតមើលកិរិយាក្ងោកមាសនោះគ្រប់ពេល ក៏ដឹងថាក្ងោកមាសមានប្រក្រតីស្វាធ្យាយបរិត្តមន្តរាល់ព្រឹក-ល្ងាច បានជាការពារអន្តរាយបាន បើដូច្នេះត្រូវរកឧបាយធ្វើឱ្យវង្វេងភ្លេចកុំឱ្យចំរើនបរិត្តមន្តបាននេះឯងទើបសមតាមប្រាថ្នា លុះគិតឃើញដូច្នេះហើយ ក៏ត្រាច់ស្វែងរកមេក្ងោកមកចិញ្ចឹមទុក បង្ហាត់ឱ្យចេះធ្វើតាមសញ្ញា គឺគ្រាន់តែបានឮសំឡេងផ្ទាត់ដៃ ក៏ពេនពង់រំសាយកន្ទុយ បានឮសំឡេងទះដៃក៏ស្រែកយំ លុះបង្ហាត់បានស្ទាត់ជំនាញហើយ ក៏នាំទៅកាន់គោចរភូមិទីស្វែងរកអាហាររបស់មោរពោធិសត្ត ប្រញាប់ទៅឱ្យបានមុនពេលព្រឹកដែលជាពេលចំរើនព្រះបរិត្តមន្តដាក់អន្ទាក់រួចហើយ ក៏ផ្ទាត់ម្រាមដៃឱ្យមេក្ងោកស្រែកយំឡើង ។

ឯព្រះពោធិសត្វបានឮសម្លេង មាតុគ្រាមជាវិសភាគារម្មណ៍ ក៏កើតសេចក្តីរោលរាលដោយអំណាចកិលេសកាម មិនទាន់បានធ្វើការស្វាធ្យាយបរិត្តមន្ត ក៏ហើរទៅដោយរហ័ស ចុះចំអន្ទាក់របស់ព្រានព្រៃ។ ព្រានព្រៃនោះក៏ស្ទុះមកចាប់បានទៅថ្វាយព្រះបាទពារាណសី។ ព្រះរាជាបានទតព្រះនេត្រឃើញរូបសិរីវិសាលរបស់មយុរពោធិសត្វ ក៏ទ្រង់សោមនស្សប្រើគាប្រារមោទ្យ ត្រាស់ឱ្យព្រះរាជទានអាសនៈ ។

ព្រះពោធិសត្វចុះឈរស្ថិតលើអសនៈនោះ ហើយក្រាបបង្គំទូលសួរព្រះរាជាថា សូមព្រះរាជទានអភ័យទោស ដែលសម្តេចព្រះបរមបពិត្រឱ្យព្រានចាប់ខ្ញុំព្រះអង្គមកនេះ តើទ្រង់ប្រាថ្នាដូចម្តេច ? ព្រះរាជឱង្ការតបថា ដោយមានពោលពាក្យមាំមួនថា អ្នកណាបានស៊ីសាច់របស់អ្នក អ្នកនោះមិនចាស់មិនស្លាប់ បានជាយើងឱ្យចាប់អ្នកមក ដើម្បីស៊ីសាច់អ្នកកុំឱ្យចាស់កុំឱ្យស្លាប់នោះឯង ។ សូមទ្រង់មេត្តាប្រោស ខដែលថាអ្នកណាបានស៊ីសាច់របស់ទូលបង្គំ នឹងមិនចាស់មិនស្លាប់នោះ សូមលើកទុកសិន តែឮព្រះបង្គំនេះនឹងស្លាប់ឬទេ ? អើ ! ឮអ្នកថាក៏មិនស្លាប់សូមទ្រង់មេត្តាប្រោស! កាលទូលព្រះបង្គំស្លាប់ហើយ សាច់របស់ទូលបង្គំនិងគុណវិសេសឱ្យអ្នកស៊ីមិនស្លាប់ដូចម្តេចនឹងបាន ? ដោយហេតុដែលមានអ្នកសម្បុរដូចមាសទឹកដប់នេះឯង ទើបសាច់របស់អ្នកមានគុណវិសេសល្អ ។ សូមទ្រង់ព្រះមេត្តាប្រោស !. ដែលទូលបង្គំមានសម្បុរល្អដូចមាសទឹកដប់នេះ ដោយឥតហេតុក៏ទេ គឺដោយជាតិមុនទូលព្រះបង្គំកើតជាបរមក្សត្រចក្រពត្តិរាជ នៅក្នុងព្រះនគរនេះ បានរក្សាសីលបរិសុទ្ធ នឹងបានប្រៀនប្រដៅប្រជាជនទូទៅទាំងមណ្ឌលចក្រវាឡឱ្យរក្សាសីល៥ដូចគ្នាទាំងអស់ គ្រាទូលព្រះបង្គំអស់ជន្មាយុហើយក៏បានកើតក្នុងតាវតិំស្សពិភព នៅតាវតិំស្សពិភពនោះរហូតអស់ជន្មាយុ ហើយចុះមកកើតជាក្ងោក ដោយផលអកុសលកម្មមួយយ៉ាង ជាចំណែកដទៃដែលបានធ្វើ តែអានុភាពផលនៃកុសលដែលបានរក្សាសីលគ្រាមុននោះ គាក់តែងឱ្យទូលព្រះបង្គំមានសម្បុរដូចមាសទឹកដប់ធម្មជាតិ ។ អើ! ក៏ពាក្យដូចអ្នកពោលថា ខ្លួនអ្នកបានជាបរមក្សត្រចក្រពត្តិរាជ បានរក្សាសីល៥ ទើបមានសម្បុរល្អដូចមាស ដោយសីល ៥ នោះខនេះយើងគួរជឿបាន ដោយមានអ្វីជាបន្ទាល់អ្នកខ្លះ ? សូមទ្រង់ព្រះ

មេត្តាប្រោស បន្ទាល់មានទូលព្រះបង្គំកាលកើតជាស្តេចចក្រពត្តិរាជនោះ អង្គុយក្នុងរថធ្វើកែវ ៧ ប្រការត្រាច់ទៅក្នុងអាកាសរថនោះឯង ទូលព្រះបង្គំឱ្យកប់ជាកំណប់ទុកក្នុងផែនដី ត្រង់ផ្ទៃស្រះបោក្ខរណី សូមព្រះអង្គឱ្យជីកគាស់ឡើងមកចុះនោះហើយនឹង បានជាបន្ទាល់ឱ្យទ្រង់ឃើញពិត ។ ព្រះរាជាទ្រង់ទទួលថាសាធុ ! ហើយមានព្រះ រាជឱង្ការចាត់ឱ្យរាជបុរសចាត់ការបង្ហូរទឹកស្រះបោក្ខរណីនោះឱ្យរីងស្ងួតហើយជីកគាស់ចុះទៅក្នុងផ្ទៃស្រះ បានរាជរថកែវសំមពិតដូចពាក្យមយុរពោធិសត្វ ។

. លំដាប់នោះ ទើបមយុរពោធិសត្វទូលសេចក្តីថា សូមទ្រង់ព្រះមេត្តាប្រោស ! បណ្តាសង្ខតធម៌ដែលបច្ច័យតាក់តែងទាំងពួង វៀរលែងតែព្រះអមតមហានិព្វាន ដែលជាអសង្ខតធម៌ចេញក្រៅពីនោះសុទ្ធតែអនិច្ចំមិនទៀត ៉ មានសេចក្តី សាបសូន្យទៅជាធម្មតា ព្រោះសេចក្តីកើតមានហើយ ក៏មានសេចក្តីវិនាសទៅវិញជាទីបំផុត ចំណែកវត្ថុណាដែលកើតហើយ គង់នៅបានមិនវិនាសវត្ថុនោះអ្នកណា១ ក៏រកមិនបានឡើយ ទូលប៉ុណ្ណេះហើយក៏សម្តែងធម្មទេសនាឱ្យសម្តេចបរមក្សត្រទ្រង់ប្រតិស្ឋានក្នុងបញ្ចង្គិកសីល ។ ព្រះរាជាបានទ្រង់ព្រះសណ្តាប់ហើយក៏ទ្រង់មានសេចក្តីសោមនស្សបូជាព្រះពោធិសត្វដោយរាជសម្បត្តិទាំងពួង ។ ព្រះពោធិសត្វទូលថ្វាយសម្បត្តិចំពោះព្រះរាជាវិញ ក៏ទូន្មានដាស់តឿនព្រះសតិដើម្បីមិនឱ្យប្រមាទក្នុងព្រះរាជកុសល ហើយហើរឡើងកាន់អាកាសត្រឡប់ទៅព្រៃហេមពាន្ត ជានិវេសនដ្ឋានរបស់ខ្លួនវិញ ។

ចំណែកខាងព្រះបរមក្សត្រព្រះបាទក្រុងពារាណសីនោះ ទ្រង់ព្រះស្ថិតនៅក្នុងឱវាទរបស់ព្រះពោធិសត្វ បំពេញព្រះរាជកុសលមានទានជាដើម ដល់កាលជាទីបំផុតព្រះជន្ម ក៏ស្ដេចទៅឧប្បត្តិតាមគួរដល់កម្ម។

ចប់គំរណីតបរិត្តវែតប៉ុរណ្ណះ

## កំណើតកឋិន

ខាងដើមនេះនឹងពណ៌នាអំពីដំណើរហេតុដែលឱ្យកើតកឋិនឡើង ក្នុងពុទ្ធសាសនាជាដំបូង តាមលំអានដែលមានមកក្នុងគម្ពីរមហាវគ្គដោយត្រង់ ៗ ។

ដំណាលដើមថា : ព្រះបរមសាស្ដានៃយើងទាំងឡាយ ទ្រង់បានត្រាស់ដឹងក្នុងលោក រាប់បានចំនួន ៥ វស្សា. ព្រះអង្គបានជម្រះពុទ្ធកិច្ចសព្វគ្រប់ហើយទ្រង់បរិនិព្វានទៅ ។ ក៏ក្នុងរវាង ៤៥ វស្សា ដែលព្រះអង្គទ្រង់បានត្រាស់ បើចែកចេញជាកាលមាន ៣ គឺ : រាប់ពីវស្សាទី ១ ដល់វស្សាទី ១៥ ចាត់ជាកាលទី ១ ឈ្មោះបឋមកាល . អំពីវស្សាទី ១៦ ដល់វស្សាទី ៣០ ចាត់ជាកាលទី ២ ឈ្មោះមជ្ឈិមពោធិកាល . អំពីវស្សាទី ៣១ ដល់វស្សាទី ៤៥ ដែលព្រះអង្គទ្រង់បរិនិព្វាននោះចាត់ជាកាលទី ៣ ឈ្មោះបច្ឆិមពោធិកាល កំណត់ ១៥ វស្សាជាពោធិកាល ១ ។

សម័យមួយនោះ នៅក្នុងរវាងមជ្ឈិមពោធិកាល ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ដែលអនាថបិណ្ឌិកសេដ្ឋីសាងថ្វាយទៀបក្រុងសាវត្ថី ។ គ្រានោះមានភិក្ខុ ៣០ អង្គនៅក្នុងដែនបាវេយ្យ ជាអ្នកប្រព្រឹត្តព្រៃ. ប្រព្រឹត្តដើរបិណ្ឌបាត. ប្រព្រឹត្តប្រើសំពត់បង្សុកូល. ប្រព្រឹត្តតែចីវរ ៣ ទាំងអស់. នាំគ្នាចេញអំពីនោះមកកាន់ក្រុងសាវត្ថី ដើម្បីគាល់បម្រើព្រះមានព្រះភាគ ទើបតែមកដល់ពាក់កណ្ដាលផ្លូវ គាប់ជួនជាដល់ថ្ងៃចូលវស្សា នឹងស្រូតុមកទៀតមិនទាន់ ក៏នាំគ្នាស្វែងរកទីសេនាសនៈនៅចាំវស្សាទៀបក្រុងសាកេត នាពាក់កណ្ដាលផ្លូវនោះទៅ ។ ដល់ក្នុងរវាងវស្សាភិក្ខុទាំងនោះមានសេចក្ដីអផ្សុកជាខ្លាំង ដោយគិតឃើញថាព្រះមានព្រះភាគទ្រង់គង់នៅក្នុងទីជិតចម្ងាយ ៦ យោជន៍ទៀតសោះ មិនសម

បើយើងទាំងឡាយស្អុនដំណើរ មិនបានទៅគាល់បម្រើព្រះអង្គ ។ លុះដល់ថ្ងៃចេញវស្សាបវារណាហើយស្រេច លោកក៏នាំគ្នាស្រូតចេញអំពីទីនោះមកទៀត ឲ្យទូលរដូវនោះនៅមានភ្លៀងរលឹមជោកជាំនៅឡើយ តាមផ្លូវដែលទៅមក ពោរពេញទៅដោយទឹកនិងភក់រអិលបបុិចបប៉ាច់ ។ លោកទាំងនោះក៏មានត្រៃចីវរទទឹកស្រកុកបានសេចក្តីលំបាកជាយ៉ាងខ្លាំង. លុះបានមកដល់ក្រុងសាវត្ថីហើយ ក៏ចូលទៅកាន់វត្តជេតពន ដែលព្រះមានព្រះភាគទ្រង់គង់នៅ ក្រាបបង្គំព្រះមានព្រះភាគរួចហើយ អង្គុយនៅក្នុងទីដ៏សមគួរ ។

លំដាប់នោះ ព្រះមានព្រះភាគទ្រង់មានព្រះបន្ទូលរាក់ទាក់ទៅរកភិក្ខុទាំងនោះថា : ម្នាលភិក្ខុទាំងឡាយ សរីរយន្តរបស់អ្នកទាំងឡាយល្មមអត់សង្កត់បានឬទេ ? ល្មមឱ្យប្រព្រឹត្តទៅបានឬទេ ? អ្នកនៅចាំវស្សាសោតស្រួលបួលមិនលំបាកដោយអាហារបិណ្ឌបាតឬទេ ? ភិក្ខុទាំងនោះក្រាបបង្គំទូលតាមដំណើរថា : បពិត្រព្រះអង្គដ៏ចម្រើន សរីរយន្តរបស់ខ្ញុំព្រះអង្គទាំងអស់គ្នា មានសេចក្តីព្រមព្រៀងដោយស្មោះស្មើ ឥតមានវិវាទទាស់ទែងគ្នាទេ ទាំងនៅចាំវស្សាសោតក៏ស្រួលបួលដែរ មិនបានលំបាកដោយអាហារបិណ្ឌបាតទេ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលស្នងព្រះពុទ្ធដីកាដូច្នោះរួចហើយ ក៏ក្រាបបង្គំទូលអំពីសេចក្តីលំបាករបស់ខ្លួនដែលមកតាមផ្លូវដោយសព្វគ្រប់តាមដំណើរ ។

លំដាប់នោះព្រះមានព្រះភាគ ទ្រង់សំដែងនូវធម្មីកថាប្រារព្ធអំពីសំសារវដ្តមិនមានទីបំផុត ប្រោសប្រទានភិក្ខុទាំងនោះ លុះចប់ហើយ ភិក្ខុទាំងនោះក៏បានលុះព្រះអរហត្តទាំងអស់អង្គ ហើយនាំគ្នាហោះតាមអាកាសទៅកាន់លំនៅរបស់ខ្លួន

អស់ទៅ ។ បន្ទាប់អំពីនោះមក ព្រះមានព្រះភាគទ្រង់ព្រះតម្រិះថា បើប្រសិនជាតថាគតបានតែងតាំងកឋិនត្ថារកិច្ចទុកអំពីគ្រាមុន ម្ល៉េះសមភិក្ខុទាំងឡាយនុំះនឹងបានលះចីវរ ១ ទុកនៅទីកន្លែង ជាប់មកតែស្បង់និងចីវរប៉ុណ្ណោះ នឹងមានអត្តភាពស្រាលមិនលំបាកយ៉ាងនេះសោះឡើយ ហើយកឋិនត្ថារកិច្ចនេះសោតព្រះពុទ្ធទាំងឡាយរាល់ព្រះអង្គ ក៏តែងតែទ្រង់អនុញ្ញាតដល់សាវក មិនដែលលះបង់ផង ។ ព្រះមានជោគទ្រង់ព្រះតម្រិះយ៉ាងនេះហើយ ទើបត្រាស់ហៅភិក្ខុទាំងឡាយមកទ្រង់អនុញ្ញាតកឋិនត្ថារកិច្ចដោយពុទ្ធដីកាថា :

អនុជានាមិ ភិក្ខវេ វិស្សំ វុដ្ឋានំ ភិក្ខូនំ កឋិនំ អត្ថរិតុំ អត្ថតកឋិនានំ វោ ភិក្ខវេ បញ្ច កប្បិស្សន្តិ

សេចក្តីថា : ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុទាំងឡាយដែលនៅចាំវស្សារួចហើយ ទទួលក្រាលកឋិន. ម្នាលភិក្ខុទាំងឡាយកាលបើភិក្ខុទាំងឡាយក្រាលកឋិនរួចហើយ នឹងបានសម្រេចអានិសង្សគុណ ៥ ប្រការ ។

ដំណើរដើមដែលនាំឱ្យកើតមានកឋិនឡើងក្នុងសាសនា ដូចន័យដែលបានពណ៌នានេះឯង ។

ឯកំណើតកឋិនទាន ដែលទាយកផ្តើមធ្វើជាដំបូងនោះគឺ ព្រះបាទបសេនទិកោសល ដូចមានរឿងដំណាលដូចតទៅនេះ :

កាលព្រះបាទបសេនទិកោសល មានអង្គព្រះកច្ចាយនត្ថេរ ជាប្រធាន ។ ព្រះកច្ចាយនត្ថេរទទួលគ្រងតាមគន្លងកឋិនត្ថារកិច្ចសម្រេចសព្វប្រការ គ្រានោះព្រះបរមសាស្តា ក៏ទ្រង់ទេសនាសរសើរ កុសលផលបុណ្យកឋិនទាននៃព្រះបាទបសេនទិកោសលរាជ ដោយអនេកបរិយាយ ហើយទ្រង់ត្រាស់នាំអតីតនិទាននៃព្រះអង្គ កាលអន្ទោលជាតិជានរជីវទុគ្គតបរមពោធិសត្វ បានជួយខ្វាយខ្វល់ចាត់ការកឋិនទាននៃកុដុម្ពិក៍ នាំទៅថ្វាយព្រះចមមុនី គឺព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមបទុមុត្តរៈ ព្រះអង្គទ្រង់ប្រោសប្រទានឱ្យព្រះសុជាតត្ថេរជាអគ្គសាវកនៃព្រះអង្គគ្រងក្នុងទីនោះ ឯព្រះបរមសាស្តាជាម្ចាស់នៃយើងនេះ ព្រះអង្គក៏មានពុទ្ធព្យាករណ៍ទំនាយអំពីសំណាក់ព្រះសម្មាសម្ពុទ្ធបទុមុត្តរៈពីកាលនោះមក លុះព្រះអង្គបានត្រាស់ហើយ ទើបទ្រង់ត្រាស់សំដែងព្រះសទ្ធម្មវិសេសទេសនាបានប្រារព្ធនូវបុព្វចរិយានៃព្រះអង្គ កាលព្រះអង្គកើតជានរជីវទុគ្គតពោធិសត្វ ក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធបទុមុត្តរៈ មកនោះស្រេចហើយ ព្រះអង្គទ្រង់អនុញ្ញាតសំពត់កឋិនដល់ភិក្ខុទាំងឡាយដែលមានត្រៃចីវរទុព្វលភាព ហើយទ្រង់បញ្ញត្តនូវសិក្ខាបទ ដែលព្រះសង្គីតិកាចារ្យ បានពោលទុកក្នុងគម្ពីរមហាវគ្គដោយពិស្តារ ហើយទ្រង់ទេសនាសរសើរផលានិសង្សកឋិនទាននេះថា មានផលវិសេសលើសលន់ពន់ប្រមាណណាស់ ។

លំដាប់នោះ មានព្រះថេរៈ ១ ព្រះអង្គព្រះនាមនារទត្ថេរ បានស្តាប់ព្រះទេសនាកឋិនានិសង្សដូច្នោះហើយ

ទើបលោកមានហឫទ័យដ៏ពេញទៅដោយបីតិជ្រះថ្លាគិតថា "កឋិនទានមានផលានិសង្សអស្ចារ្យយ៉ាងនេះ គួរអាត្មានឹងសាងប្រគេនដល់ជំនុំសង្ឃម្តងចុះ . កាលព្រះនារទត្ថេរ លោកគិតដូច្នោះ ទើបលោកទៅកាន់ត្រកូលញាតិ ហើយលោកបបួលពពួកញាតិឱ្យជួយក្នុងកឋិនទាន លុះបានគ្រប់គ្រឿងកឋិនហើយ លោកនាំអង្គកឋិននោះទៅកាន់អារាមមួយអន្លើដោយពពួកញាតិជាបរិវារ ។ លុះបានដល់អារាមហើយ ព្រះនារទត្ថេរក៏យកសំពត់កឋិននោះ ដឹកល់ទៀបព្រះបាទយុគលនៃព្រះតថាគត ហើយសូត្រថ្វាយដោយបាលីថា :

ភន្តេ ឥមានិ ចីវរានិ ពុទ្ធប្បមុខស្ស ភិក្ខុសង្ឃស្ស កឋិនត្ថាយ ទស្សាមិ ។

ប្រែថា: បពិត្រព្រះអង្គ ដ៏ចម្រើន ខ្ញុំព្រះករុណាសូមថ្វាយនូវចីវរទាំងឡាយនេះដល់ភិក្ខុសង្ឃ មានព្រះសម្មាសម្ពុទ្ធជាប្រធាន ដើម្បីក្រាលជាកឋិនក្នុងឥឡូវនេះ ។

គ្រាកាលនោះ ព្រះមានព្រះភាគជាម្ចាស់ ព្រះអង្គក៏ប្រជុំភិក្ខុទាំងឡាយ ៥០០រូប ហើយញុំាងកិច្ចទាំងឡាយ មានការដេរនូវចីវរកឋិនជាដើម ឱ្យសម្រេចសព្វគ្រប់ប្រការ កាលនោះឯង ។

សាធវោ សាធុសប្បុរសទាំងឡាយ ! ឯកិរិយាដែលព្រះនារទត្ថេរធ្វើកឋិនដើម្បីភិក្ខុសង្ឃ មានអង្គព្រះពុទ្ធជាប្រធាននោះ ក៏កើតជាអស្ចារ្យដល់ជំនុំសង្ឃ សឹងនាំគ្នាសរសើរកុសលផលបុណ្យនៃព្រះនារតត្ថេរជាអនេកបរិយាយ កាលនោះសម្តេចព្រះឈ្មះមារ ក៏ទ្រង់នាំអតីតនិទាននៃព្រះអង្គ កាលដើមជាស្តេច

ចក្រពត្រាធិរាជ១ព្រះអង្គ ទ្រង់ព្រះនាមបរមចក្កវិជិតរាជ ប្រកបដោយអំណាចធំ ក្នុងទ្វីបទាំង៤មានទ្វីបតូច២០០០ជាបរិវារ ព្រះអង្គបានសាងកឋិនទានថ្វាយព្រះពុទ្ធទ្រង់ព្រះនាមកោណ្ឌញ្ញសម្មាសម្ពុទ្ធ ដែលត្រាស់ដឹងក្នុងសារកប្ប ជាកប្បកន្លងយូរទៅហើយនោះ នាំមកសម្ដែងជាសណ្ដាប់ដល់ភិក្ខុទាំងឡាយ ក្នុងព្រះពុទ្ធសាសនាដោយពិស្ដារ ជាអនេកបរិយាយក្នុងទីនេះជាសេចក្ដីខ្លី១ នាំមកឱ្យឃើញបុគ្គលអ្នកធ្វើមុនគេ គឺព្រះបាទបសេនទិកោសលរាជ ជាបច្ចុប្បន្ននិទានព្រះនរជីទុត្តតពោធិសត្វ និងនាយក្ដុម្ពីកំនោះក្ដី ការនិទាននេះជាអតីតនិទាន ចំណែកខាងព្រះសង្ឃអ្នកធ្វើសោត គឺព្រះនារទត្ថេរជាបច្ចុប្បន្ននិទាន និទានព្រះនារទត្ថេរធ្វើកឋិននោះគួរយកជាបែបយ៉ាងបាន ហេតុនេះទើបឃើញបព្វជិតទាំងឡាយពីបុរាណក ធ្វើកឋិន ត ៗ គ្នាមក ព្រោះអាស្រ័យនារទត្ថេរនេះឯង ។

កឋិនទានដែលបានបុណ្យជាងគេនោះ ប្រកបដោយហេតុ ៥ យ៉ាងគឺ :

១- កឋិននេះមានតែក្នុងពុទ្ធកាល .

២- កឋិនទានមានតែ ១ ខែ គឺចាប់ពីថ្ងៃ ១ រោច ខែអស្សុជ ទៅទល់ពេញបូរមីខែកត្ដិក .

៣- កឋិននេះមានកើតដោយសង្ឃ .

៤- កឋិននេះញាណសម្បយុត្ត .

៥- កឋិននេះបានអានិសង្សទាំងសង្ខាង ទាំងអ្នកឱ្យទាំងអ្នកទទួល ។

(រឿងទាំងអស់នេះមានក្នុងបញ្ញាសជាតក)

**គំរូណិតកឋិនសមុខបរិតបុះណ្ណះ**

## បុណ្យចំរើនព្រះជន្ម

បុណ្យចំរើនព្រះជន្មនេះ បើតម្រូវឱ្យឃើញអំពីកិច្ចដែលត្រូវធ្វើនោះ ចែកចេញជា ៣ ប្រភេទដូច្នេះគឺ :

១- ជីវិតមហាកម្ម អំពើដែលគេធ្វើដើម្បីអប់រំអបស្មបជប់លៀងនូវជីវិតសង្ខារបង្ការទុកឱ្យហើយ ព្រោះខ្លួនបិតនៅក្នុងលោកនេះមិនមានខ្លឹមសាររស់នៅទទេរៗ មិនបានផលប្រយោជន៍សម្រាប់ទៅបរលោកនាយ គិតឃើញដូច្នេះហើយ ត្រូវបំពេញកុសលមានទានសីលជាដើម .

២- អាយុវឌ្ឍនកម្ម អំពើដែលគេធ្វើទៅដើម្បីចំរើនអាយុសង្ខារឱ្យឋិតថេរទៅតាមអាយុខ័យ ដោយគុណានុភាព នៃព្រះធម្មរតនៈ មានការចំរើននូវព្រះបរិត្តជាដើម ឧទាហរណ៍ដូចអាយុវឌ្ឍនកុមារ .

សេចក្ដីដំណាលថា មានព្រាហ្មណ៍ពីរនាក់ជាសំឡាញ់នឹងគ្នា នៅក្នុងទីក្រុងទីឃលម្ពិកៈ បួសជាតាបសឫសីក្រៅព្រះពុទ្ធសាសនា ប្រព្រឹត្តនូវតបធម៌អស់ ៤៨ ឆ្នាំ បណ្ដាតាបសទាំងពីរនាក់នោះតាបសម្នាក់គិតថា : បើអញនឹងបួសមួយជីវិតមុខជានឹងផុតពូជ . អញត្រូវសិក្ខ គិតដូច្នេះហើយក៏សឹកទៅ រករបរចិញ្ចឹមជីវិតលក់គ្រឿងបរិក្ខារ ហើយក៏បានប្រពន្ធ យូរបន្តិចមកក៏បានកូនប្រុសមួយ ក៏នាំកូនទៅថ្វាយបង្គំតាបសជាសំឡាញ់ លុះទៅដល់ដាក់កូនឱ្យដេករួចថ្វាយបង្គំទាំងប្ដីប្រពន្ធ តាបសជាសំឡាញ់នោះឱ្យពរថា ទិឃាយុកោ ហោថ សូមអ្នកទាំងឡាយមានអាយុវែង។ ហើយលើកកូនឱ្យថ្វាយបង្គំតាបសនោះទៀត តាបសគង់នៅស្ងៀម

ឥតមានឱ្យពរដូចកាលម្ដាយឪពុកថ្វាយបង្គំនោះឡើយ ។ ឪពុករបស់កូននោះសួរថា :' ហេតុដូចម្ដេចបានជាលោកម្ចាស់មិនឱ្យពរដល់កូនរបស់ខ្ញុំព្រះករុណា តាបសឆ្លើយថា ម្នាលព្រាហ្មណ៍ បានជាអាត្មាមិនឱ្យពរ ព្រោះមានសេចក្ដីអន្តរាយដល់កុមារនោះ ។ លោកម្ចាស់អន្តរាយដូចម្ដេច ? ម្នាលព្រាហ្មណ៍ កូននេះរស់នៅតែមួយសប្ដាហ៍ទៀតទេ ។ លោកម្ចាស់មានអ្វីជាគ្រឿងការពារកូននេះទេ ? អាត្មាមិនចេះពិធីការពារនូវជីវិតកូននេះទេ ។ មានអ្នកណាចេះទេព្រះតេជគុណ ? ព្រះសមណគោតម ទើបព្រះអង្គចេះពិធីនេះ ចូរអ្នកឯងទៅសួរព្រះអង្គចុះ ។ ខ្ញុំព្រះករុណាមិនហ៊ានទៅទេខ្លាចសាបសូន្យតបៈ ។ អ្នកឯងស្រឡាញ់តបៈជាងកូនឬ ? បើស្រឡាញ់កូនជាងតបៈត្រូវចូលទៅរកព្រះអង្គ ។ ព្រាហ្មណ៍និងប្រពន្ធនោះក៏ព្រមចូលទៅថ្វាយបង្គំព្រះសាស្ដាតាមតាបស ។ ព្រះសាស្ដាឱ្យពរថា : ទីឃាយុកោ ហោហិ ចូរអ្នកមានអាយុវែង ។ ក្នុងពេលដែលកូនថ្វាយបង្គំ ព្រះអង្គគង់នៅស្ងៀម ។ ព្រាហ្មណ៍ទូលសួរថា ហេតុដូចម្ដេចបានជាព្រះអង្គមិនឱ្យពរដល់កូនខ្ញុំព្រះអង្គ ? ព្រះលោកនាថក៏ទ្រង់ព្យាករណ៍ដូចតាបសដែរ ។ ព្រាហ្មណ៍ទូលសួរព្រះសាស្ដាថា បពិត្រព្រះអង្គ ព្រះអង្គមានឧបាយជាគ្រឿងការពារនូវជីវិតកូននេះបានដែរឬ ? ព្រះអង្គមានពុទ្ធដិកាថា មាន បើអ្នកចង់ឱ្យកូននេះរស់ គប្បីធ្វើមណ្ឌលត្រង់ទ្វារនៃផ្ទះខ្លួន រៀបធ្វើគ្រឿងតាំងកណ្ដាលមណ្ឌលនោះ និងធ្វើរបងព័ទ្ធជុំវិញមណ្ឌលនោះ រួចក្រាលអាសនៈ ៨ ក៏បាន ១៦ ក៏បាន រួចនិមន្តសាវកតថាគតឱ្យអង្គុយលើអាសនៈនោះ បើអ្នកអាចធ្វើឱ្យសាវករបស់តថាគតសូត្រ ព្រះបរិត្តអស់មួយសប្ដាហ៍ កូននេះបានរស់តរៀងទៅ ។ ព្រាហ្មណ៍នោះធ្វើតាមបង្គាប់ព្រះសាស្ដា

ហើយទូលសួរថា ធ្វើដូចម្ដេចបានសាវ័ករបស់ព្រះអង្គ ? ព្រះមានព្រះភាគក៏បញ្ជូនសាវ័ករបស់ព្រះអង្គទៅឱ្យព្រាហ្មណ៍នោះ ភិក្ខុទាំងឡាយបានទៅគង់កន្លែងនោះ ព្រាហ្មណ៍និងព្រាហ្មណី យកកូនមកដាក់នៅលើតាំង ចំពោះមុខព្រះភិក្ខុសង្ឃ ។ ពួកភិក្ខុស្វាធ្យាយនូវព្រះបរិត្តអស់ ៧ យប់ ៧ ថ្ងៃមិនដាច់ ក្នុងថ្ងៃជាគំរប់ ៧ ព្រះបរមសាស្ដាស្ដេចយាងដោយព្រះអង្គឯង ។ ទេវតាមួយម៉ឺនចក្រវាឡដែលមានស័ក្តិធំៗ ក៏មកគាល់ព្រះក្នុងទីនោះ ចំណែកឯទេវតាស័ក្តិតូចៗទាំងឡាយមានអវរុទ្ធយក្ស រួចពីការបំរើស្ដេចវេស្សវ័ណអស់ ១២ ឆ្នាំ បាននូវពរអំពីសំណាក់ស្ដេចវេស្សវ័ណ ថាត្រូវបានចាប់ទារកនេះស៊ីក្នុងថ្ងៃជាគំរប់ ៧ ត្រូវនឹងថ្ងៃដែលព្រះអង្គយាងមក យក្សនោះក៏ចៀសចេញទៅ ដោយអំណាចខ្លាចទេវតាមានស័ក្តិធំក៏ខានស៊ីទារកនោះទៅ ។ លុះដល់ថ្ងៃទី ៨ រះឡើង ក៏នាំទារកនោះទៅថ្វាយបង្គំព្រះសាស្ដា ព្រះអង្គឱ្យពរថា ទិឃាយុកោ ហោហិ ថែមទាំងព្យាករណ៍ថាទារកនេះបានអាយុ ១២០ ឆ្នាំ ចាប់តាំងពីថ្ងៃនោះមក គេក៏ហៅទារកនោះថា "អាយុវឌ្ឍនកុមា" ។ អាយុវឌ្ឍន៍កុមារនេះ លុះចំរើនវ័យធំឡើងត្រាច់ទៅទីណាមកណា មានឧបាសក ៥០០ ជាបរិវារ ។

ថ្ងៃមួយជាខាងក្រោយមក ភិក្ខុជំនុំគ្នាក្នុងធម្មសភាថា : ម្នាលអាវុសោ អាយុវឌ្ឍនកុមារ ដែលត្រូវស្លាប់ក្នុងថ្ងៃគំរប់ ៧ ឥឡូវបែរជាព្រះអង្គព្យាករណ៍ថាបានអាយុ ១២០ ទៅវិញ ថែមទាំងមានបរិវារ ៥០០ ទៀតផង ដូច្នេះប្រហែលជាមានដំណើរធ្វើនូវសត្វឱ្យមានអាយុវែង ។ ក្នុងពេលនោះ ព្រះបរមសាស្ដាចាប់ព្រះអង្គយាងមកសួរភិក្ខុទាំងឡាយនោះថា ជំនុំគ្នារឿងអ្វី ? ពួកភិក្ខុក៏ក្រាបទូល

តាមដំណើរនោះ ព្រះអង្គទ្រង់សំដែងថា ម្នាលភិក្ខុទាំងឡាយ ការរីកចំរើននូវអាយុសត្វទាំងឡាយ មិនមែនមានត្រឹមតែថ្វាយបង្គំនូវអ្នកមានគុណប៉ុណ្ណោះទេ មានហេតុ ៤ យ៉ាងទៀតជាគ្រឿងធ្វើឱ្យរួចនូវសេចក្ដីអន្តរាយ ហើយក៏ព្រះអង្គសំដែងនូវគាថាបញ្ជាក់ថា :

អភិវាទនសីលិស្ស និច្ចំ វុឌ្ឍាបចាយិនោ
ចត្តារោ ធម្មា វឌ្ឍន្តិ អាយុ វណ្ណោ សុខំ ពលំ ។

ពរ ៤ ប្រការគឺ អាយុ ១. ពណ៌សម្បុរ១. សេចក្ដីសុខ ១. កំលាំង ១. រមែងចំរើនដល់បុគ្គល **និង**មានកិរិយាថ្វាយបង្គំដល់ព្រះរតនត្រ័យជាប្រក្រតី និងអ្នកមានសេចក្ដីគោរពកោតក្រែងជានិច្ចដល់ចាស់ព្រឹទ្ធាចារ្យ ។

**ឬ**- រឿងនេះគួរសង្ស័យណាស់ចំពោះអាយុវឌ្ឍន៍កុមារ ដែលថាដល់ថ្ងៃទី ៧ នឹងត្រូវស្លាប់ ហេតុដូចម្ដេចបានជាមិនស្លាប់ ? ព្រោះថា ព្រះពុទ្ធមិនមែនមានពុទ្ធដីកាពីរ ដូចយ៉ាងព្យាករណ៍សុប្បពុទ្ធថានឹងដល់ថ្ងៃទី ៧ នឹងត្រូវព្រះធរណីស្រូប ហើយត្រូវស្រូបមែន ។

**វិ**- រឿងសុប្បពុទ្ធ និង អាយុវឌ្ឍន៍ទាំងពីរនេះខុសគ្នា ចំណែកសុប្បពុទ្ធមានកម្មជាទម្ងន់ ទុកជាការពារយ៉ាងម៉េចក៏មិនផុត ចំណែកអាយុវឌ្ឍន៍កុមារគ្មានពៀរវេរាអ្វីនឹងយក្សនោះទេ ហើយអាយុវឌ្ឍនកុមារនេះ គ្មានបាបជាទម្ងន់ផងអាយុខេយ្យក៏ពុំទាន់ដល់ទៀត ។

ម្យ៉ាងទៀត នយោបាយរបស់ព្រះដើម្បីនឹងឱ្យព្រាហ្មណ៍លះបង់នូវតបៈ ដែលជាខាងក្រៅពុទ្ធសាសនា ។

រឿងចំរើនព្រះជន្មនេះ មានអាយុវឌ្ឍនកុមារមានជាអាទិ រឿងនេះជាប់មកដល់សូត្រភាណយក្សសព្វថ្ងៃនេះ ។

៣- អនុប្បទាន អំពីដែលគេធ្វើដើម្បីអនុគ្រោះដោះទុក្ខទោសសត្វដែលជួបប្រទះនឹងគ្រោះថ្នាក់ផ្សេងៗ ដូចរឿងអភយទាន ដែលដោះជីវិតសត្វឱ្យផុតអំពីសេចក្ដីស្លាប់ ។

បុណ្យចំរើនព្រះជន្ម នេះ ឥឡូវនេះ គេច្រើនធ្វើកតញ្ញូកតវេទី ចំពោះបុព្វការី មានមាតាបិតាជាដើម ។

**បុណ្យចំរើនព្រះជន្មសេះខួបកំណើត**

# កំណើតបង្សុកូល

បង្សុកូលនោះ គឺសំពត់ដែលគេចោលដោយគំនរសម្រាម ជាសំពត់ដែលគេដាច់អាល័យ ដូចជារយាលចាប-សេក សំពត់នៅដោយកាន សំពត់រុំខ្មោច សំពត់ទាំងនេះឯង ព្រះអង្គទ្រង់អនុញ្ញាតឱ្យរើសយកមកប្រើប្រាស់តាមសេចក្តីត្រូវការ ចំពោះអ្នកមានសទ្ធា លុះបានឃើញដូច្នោះហើយ ក៏នាំយកសំពត់ថ្មីទៅចោលនឹងអសុភទីបាឆាហៅថាសំពត់បង្សុកូល ។ លុះកន្លងកាលដ៏យូរមក អ្នកមានសទ្ធាបានឃើញថា ធ្វើដូច្នេះទើបជាទីបដិកូល ទើបយកសំពត់ទៅគ្របលើម្ឈូសខ្មោច ឬ ទាញខ្សែអំពីខ្មោច ហើយដាក់សំពត់លើខ្សែ ភិក្ខុអ្នកបង្សុកូលពិចារណាដោយគាថាថា: អនិច្ចា វត សង្ខារា ជាអាទិ ហើយនាំយកសំពត់នោះមកបានជាគាថានេះសម្រាប់ពិចារណាសង្ខារធម៌ ។

និទានរឿងហេតុដើមឱ្យឃើញថា កាលកន្លងទៅហើយ មានភិក្ខុមួយអង្គឈ្មោះមហាកាល លោកចូលចិត្តពិចារណានូវអសុភកម្មដ្ឋានក្នុងទីបាឆា ។ ថ្ងៃមួយមានគេនាំយកខ្មោចស្រីម្នាក់ មានរូបល្អស្អាតសោភា ទើបតែធ្វើកាលកិរិយាថ្មីៗ ទៅធ្វើឈាបនកិច្ចក្នុងទីបាឆានោះ ។ មហាកាលភិក្ខុលោកបានពិចារណានូវសង្ខារធម៌ដោយគាថាថា :

អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ

ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោ ។

ប្រែថា: សង្ខារធម៌ទាំងឡាយមិនទៀងមែនពិត មានកិរិយាកើតឡើងនិងវិនាសទៅវិញជាធម្មតា តែបើកើតឡើងហើយ តែងរលត់ទៅវិញ លុះរលត់នូវសង្ខារទាំងឡាយនោះបាន ទើបនាំមកនូវសេចក្តីសុខគ្រប់យ៉ាង ។

លោកពិចារណាធម៌នេះ ដោយយោនិសោមនសិការៈ ក៏បានសម្រេចអរហត្តផល ព្រមទាំងចតុប្បដិសម្ភិទាញាណ ។ ហេតុនេះបានជាគាថានេះ ជាទំនៀមទំលាប់សម្រាប់ពិចារណានូវសង្ខារធម៌ ។

**ឬ**. ចុះកិច្ចបង្សុកូលនេះ ជាកិច្ចរបស់លោកធុតង្គ ដែលលោកសមាទានបង្សុកូលិកង្គទេ ហេតុអ្វីក៏យើងកាលក្លាយកមុកប្រើខែចូលឆ្នាំ ខែភ្ជុំបិណ្ឌនិមន្តលោកបង្សុកូល ?

**វិ**- រឿងនេះជាប់ទំនៀមទំលាប់ពីមហាកាល ដែលលោកបានពិចារណាហើយ ឆាកយកសំពត់ស្រ្តីម្នាក់ ដល់មកខាងក្រោយ តែអ្នកណាមានម្តាយឬឪពុកស្លាប់ និមន្តលោកមកឆាកយកស្លបសន្មត់ថាបង្សុកូលបានជាជាប់ធម៌អនិច្ចាតរៀងមកដល់សព្វថ្ងៃនេះ ។

**ឬ**- ចុះលោកសូត្រអភិធម្ម. អវិជ្ជា និងករណីប្រយោជន៍អ្វី ?

**វិ**- បានជាកើតលោកសូត្រ លោកអ្នកប្រាជ្ញយល់ថា អ្នកដែលនិមន្តលោកទៅបង្សុកូលនេះ ច្រើនលើមាតាបិតាស្លាប់ យកធម៌អភិធម្មទៅសងគុណ. ត្រង់សូត្រអវិជ្ជានោះរកកំណើតជាទីកើតទីរលត់ ដែលសូត្រធម៌ករណីនោះ ដើម្បី

បណ្តេញបិសាចដែលនៅស៊ីសាកសុភ ព្រោះមានរឿងដំណាល កាលនោះមានភិក្ខុមួយអង្គទៅឆាកយកសំពត់ស្លប អមនុស្សទៅហួងហែងសាកអសុភនោះ វាចូលក្នុង សាកអសុភដេញបន្ទាចលោក រឿងនេះជ្រាបដល់ព្រះ១ បញ្ញត្តមិនឱ្យឆាកយកសំពត់អសុភស្រស់ ដល់ថ្ងៃទី ៨ បានឆាកយកបាន ។

រឿងនេះជំនាន់ដើម គេច្រើនតែនិមន្តលោកបង្សុកូលប្រគេនសំពត់ស ដល់មកក្រោយក្លាយទៅជាប្រគេនលុយវិញ ។

**ចប់រឿងបង្សុកូលតែប៉ុណ្ណោះ**

# បុណ្យភ្ជុំបិណ្ឌ

បុណ្យភ្ជុំបិណ្ឌនេះ ដែលយើងបានទាក់ទងតៗ គ្នា រហូតដល់មកសព្វថ្ងៃនេះ ហើយគួរឱ្យយកជាប្រមាណក្នុងកិច្ចកុសលទៅកើត មកពីមាននិទានរឿង ១ ជាអាទិ ដូចពោលតទៅ :

សេចក្ដី មានពួកញាតិរបស់ព្រះបាទពិម្ពិសារ ១ ក្រុម បានបំពេញទានមានវត្ថុមិនបរិសុទ្ធល្អ (ស៊ីបាយមុនលោក) (១) លុះលះលោកនេះទៅកាន់លោកខាងមុខ ក៏ទៅកាន់កំណើតជាបេត្តិវិស័យសោយទុក្ខវេទនាជាយូរអង្វែងតទៅ លុះដល់ព្រះពុទ្ធទ្រង់ព្រះនាមកុក្កុសន្ធោបានត្រាស់ឡើងក្នុងលោក ពួកប្រេតនោះក៏នាំគ្នាទៅសួរថា បពិត្រព្រះអង្គដ៏ចម្រើន ចុះខ្ញុំព្រះអង្គកាលណានឹងបានអាហារបរិភោគ ព្រះអង្គប្រាប់ថា ចាំសួរព្រះពុទ្ធខាងក្រោយចុះក្នុងសាសនាតថាគតនេះ អ្នកទាំងឡាយមិនមានអាហារបរិភោគទេ លុះតែផែនដីដុះបាន ១ យោជន៍ឡើង ព្រះពុទ្ធព្រះនាមកោនាគមនៈ បានត្រាស់មកទៀតពួកប្រេតនោះក៏នាំគ្នាមកសួរ ក៏ប្រាប់ដូចមុនទៀត លុះផែនដីដុះបានមួយយោជន៍ទើបព្រះពុទ្ធនាមគោត្តមកើតឡើង ពួកប្រេតទាំងឡាយនាំគ្នាមកសួរព្រះអង្គៗទ្រង់ត្រាស់ថា ចាំមើលព្រះបាទពិម្ពិសារជាញាតិរបស់អ្នកទាំងឡាយ ទ្រង់ឱ្យនូវទានដល់តថាគត នឹងញ៉ាំងអាហារឱ្យសម្រេចដល់អ្នកទាំងឡាយ ៗ នឹងបាននូវអាហារក្នុងពេលនោះ លុះព្រះបាទពិម្ពិសារថ្វាយទានក្នុងថ្ងៃដំបូងហើយ មិនបានផ្សាយផលទៅឱ្យពួកញាតិ ក៏ស្រាប់តែពួកប្រេតជាញាតិទាំងឡាយនោះ យំស្រែកទ្រហោអឺងអាប់ក្នុងរត្តិសម័យ លុះព្រះបាទ

(១) ស៊ីមុនលោក គឺស៊ីហើយសល់យកទៅប្រគេនលោក

ពិម្ពិសារទៅកាន់វត្តវេឡុវ័ន ហើយបានសួរព្រះសម្មាសម្ពុទ្ធ ព្រះអង្គត្រាស់ថាពួកប្រេតជាញាតិរបស់ផងទ្រង់យំស្រែកទ្រហោទ្រហឹងរកអាហារនេះតើ ពួកប្រេតទាំងនោះ បានជាពួកប្រេតនោះចេះតែយំស្រែកបែបនេះ ព្រះរាជាបានយល់ហេតុដូច្នោះហើយ ក៏បានធ្វើទានមានបាយចំណីសំពត់អាវជាដើម ដល់ព្រះសង្ឃមានព្រះសម្មាសម្ពុទ្ធជាប្រធាន ព្រះអង្គក៏អនុមោទនា ដោយធម្មិតិរោកុឌ្ឌសូត្រស្រេចហើយក៏ពួកប្រេតទាំងនោះ ទៅកើតក្នុងទិព្វវិមាន ជាស្ថានប្រកបដោយសុខភាពរៀងរាបតទៅ ។

បុ- មានអ្នកខ្លះថាដល់ថ្ងៃ ១៥ កេច ខែភទ្របទ ពួកយមរាជលែងពួកនរកប្រេត ឱ្យមកទទួលផល រឿងនេះពិត ឬ មិនពិត ?

វិ- រឿងនេះពិតខ្លះ មិនពិតខ្លះ ដែលពិតនោះ ដូចជាពួកប្រេតបរទត្តូបជីវី ដែលត្រូវទទួលផលបាន ក៏ត្រូវដើរស្វែងរកព្រះញាតិណាដែលធ្វើបុណ្យឱ្យទានឧទ្ទិសផលឱ្យទៅ ។ ពួកប្រេត ១ ដែលទទួលផលបាននោះ ត្រូវប្រកបដោយអង្គ ៣ គឺ :

១- ញាតិសន្តានបានឧទ្ទិសផលឱ្យទៅ .

២- តម្កល់ចំពោះសង្ឃ .

៣- ប្រេតបានអនុមោទនា ។

លុះតែប្រកបដោយអង្គ ៣ នេះទើបទទួលផលបាន ដែលថា មិនពិតនោះគឺ យមរាជលែងមកនោះមិនមែនទេ សត្វប្រេតដែលនឹងរួចមកបាន

លុះតែរួចដោះផលកម្ម បានមកទទួលបាន ដូចប្រេតព្រះញាតិព្រះបាទពិម្ពាសារជាដើម ។

ឬ- ខែភ្ជុំបិណ្ឌនេះ ហេតុអ្វី ក៏ធ្វើបានតែខែភទ្របទ ខែដទៃៗ ក៏មិនធ្វើផង ?

វិ- បានតែខែភទ្របទ ព្រោះរដូវនេះជារដូវលោកចាំវស្សាជួបជុំលោក ហើយឧបាសកឧបាសិកា ក៏ទើបនឹងរួចពីការស្ទូងដក ទំនេរល្មមនឹងច្រៀតមកធ្វើរវាង ១៥ ថ្ងៃ ខែនេះបាន ។

ឬ- ចុះដូចយ៉ាងជនាន់ដើម មានបាយបិណ្ឌ លុះភ្ជុំរួចយកទៅចោលក្នុងស្រែ ឬ បណ្ដែតតាមទឹកនេះជាលទ្ធិអ្វី ?

វិ- ត្រង់ដែលមានធ្វើកន្ទោង ឬ បាយបិណ្ឌយកទៅដាក់ចោលក្នុង ស្រែត្រង់នេះជាលិទ្ធិសាសនាព្រាហ្មណ៍ សាសនាព្រាហ្មណ៍គេធ្វើបុណ្យបញ្ជូនទៅមាតាបិតា គេអញ្ជើញពួកព្រាហ្មណ៍ចាស់ៗមកទទួលអាហារ ហើយគេចាប់យកចំណីអាហារដាក់ក្នុងកន្ទោងមួយ គេឧទ្ទិសទៅឱ្យមាតាបិតាគេ គឺគេយកកន្ទោងទៅដាក់ក្នុងទីណាមួយហើយគេចាំមើល បើឃើញគោមកស៊ី គេសំគាល់ថាមាតាបិតាគេឡើងស្ថានសួគ៌ ព្រោះគោជាជំនិះព្រះឥសូរ បាយនេះឈ្មោះសុបិណ្ឌៈ បានជាប់កន្ទោងមកដល់យើងសព្វថ្ងៃនេះ ដូចយ៉ាងធ្វើបុណ្យដារ ពេលរាប់បាត្រមានដាក់កន្ទោង នៅបន្ទាប់ពីចុងបាត្រនេះជាភស្តុតាង ហៅថា កន្ទោងបាយដារ ។

បុ- បុណ្យនេះអ្នកណាធ្វើមុនគេ ?

វិ- ធ្វើមុនគេបង្អស់ព្រះបាទពិម្ពិសារ បន្ទាប់មកនាងឧត្តរានៅ ស្រុកខ្មែរយើងនេះ តាមដែលខ្ញុំដឹង ព្រះករុណាអង្គឌួង ព្រះអង្គចេះកម្មដ្ឋាន ព្រះត្រៃបិដក ព្រះអង្គជ្រះថ្លាក៏ទ្រង់នាំបណ្ដារាស្ត្រធ្វើជាប់មក ដល់មកខាងក្រោយទៀត អាចារ្យក៏នាំធ្វើផ្សេង១ពីគ្នា តាមលទ្ធិអាចារ្យ បានជាយករឿងប្រេតព្រះញាតិព្រះបាទពិម្ពិសារជាភស្តុតាង ព្រោះយើងក្រែងពានញាតិសន្ដាន ដែលធ្វើកាលកិរិយាទៅលោកខាងមុខ កើតជាប្រេតហើយស្វែងមករកញាតិ បានជាយើងខំខ្នះខ្នែង ធ្វើបុណ្យក្នុងថ្ងៃ ១៥ រោច ខែភទ្របទនេះ ដោយថ្ងៃនេះជាថ្ងៃអភ័យដល់សត្វ សូម្បីតែក្របី គោ ក៏គេលែងប្រើប្រាស់ ហើយលាបប្រេងម្សៅឱ្យ រហូតដល់រាជការសព្វថ្ងៃក៏ឈប់ធ្វើការងារដែរ គួរសន្មត់ថ្ងៃខែនេះជានក្ខត្តឫក្សដ៏ល្អ សមនឹងពុទ្ធភាសិតមួយកន្លែងសំដែងថា យំ កិញ្ចារម្មណំ កត្វា ទជ្ជា ទានមមច្ឆរី ធ្វើនូវហេតុណាមួយឱ្យជាអារម្មណ៍ ហើយលះបង់នូវកំណាញ់ ។

រឿងដែលបានអាងមកទាំងប៉ុន្មាននេះ អ្នកកាន់ព្រះពុទ្ធសាសនាក៏ល្មមកាន់យកជាគតិបាន ។

**ចប់គំរោងគម្ពីរបិណ្ឌវេតបុណ្ណះ**

## បុណ្យបូជាព្រះចន្ទ

បុណ្យបូជាព្រះចន្ទនេះជាពិធីមួយយ៉ាងសំខាន់ របស់ពួកជនអ្នកកាន់ព្រះពុទ្ធសាសនា តែងនាំគ្នាធ្វើក្នុងថ្ងៃ ១៥ កើតខែកត្តិក ពួកជនខ្លះបានធ្វើតាមដឹងដោយការពិតទៅក៏មាន ខ្លះធ្វើតៗគ្នាទៅក៏មាន ជនដែលដឹងពិត រមែងបានផលសម្បត្តិ លទ្ធប្រយោជន៍ដោយច្រើនទៅអ្នកដែលមិនដឹងសោះរមែងទៅជាខុសតាមលិទ្ធិសាសនាដទៃ មានសាសនាព្រាហ្មណ៍ជាដើម រមែងសៅហ្មងសរណគមន៍ក៏មាន ហេតុនេះ ពុទ្ធបរិស័ទត្រូវប្រព្រឹត្តដូច្នេះទៅចុះ ព្រោះថា សំពះព្រះខែនេះបើតាមលិទ្ធិព្រះពុទ្ធសាសនា ដែលមានមកក្នុងចរិយាបិដកថា គេធ្វើដើម្បីរំលឹកដល់ព្រះពោធិសត្វ កាលដែលយោនយកកំណើតទៅកើតជាសត្វទន្សាយ ដល់ថ្ងៃពេញបូរមីព្រះចន្ទពេញវង់ មានពន្លឺល្អសោភា ក៏ទ្រង់ក្រឡេកមើលទៅព្រះចន្ទ ហើយមានសេចក្ដីជ្រះថ្លា ប្រកបដោយករុណាចិត្តគិតដូច្នេះថា បើអ្នកណាត្រូវការសាច់របស់អាត្មាអញជាអាហារ អាត្មាអញនឹងបំពេញជីវិតទានក្នុងកាលឥឡូវនេះ ។

សត្វ ៤ ពួក ទន្សាយ. ស្វា. ភេ. ចចក សត្វទាំង ៤ ពួកនេះ ជិតដល់ថ្ងៃពេញបូណ៌មីនិងសមាទានឧបោសថ ចំណែកសត្វស្វា ក៏ស្វែងរកបានផ្លែស្វាយយកមកទុកជាអាហារ សត្វចចកទៅបានសាច់ដែលគេអាំងទុកនឹងខ្ទមវាលស្រែ ស្រែកសូមគេយកមក. សត្វភេដើរតាមដងស្ទឹង ក៏ឃើញត្រីថ្កិនដែលគេកប់ទុក ក៏ស្រែកសូមគេមករៀងៗខ្លួន ចំណែកសត្វទន្សាយមិនបាច់ស្វែងរកអាហារ គ្រាន់តែនឹកប៉ុណ្ណោះ ក៏ក្ដៅអសនៈរបស់ព្រះឥន្ទស្ដេចក៏ទ្រង់អាវជ្ជនាការ ឃើញទន្សាយព្រះពោធិសត្វ មានករុណាជ្រះថ្លាចង់បំពេញទាន ក៏ហោះចុះមកក្លែងខ្លួន ធ្វើជា

ព្រាហ្មណ៍ចាស់ម្នាក់ ដើរមកកាន់សំណាក់ស្វា ក៏ពោលថា ខ្ញុំដើរផ្លូវឆ្ងាយអត់ឃ្លាន គ្មានអាហារ គ្មានអាហារបរិភោគយូរថ្ងៃហើយ ជីវិតរបស់ខ្ញុំនឹងក្ស័យក្នុងថ្ងៃនេះ មិនខានឡើយ ធ្វើម្ដេចនឹងបានអាហារបរិភោគអេះ ។ ស្វាក៏ឱ្យផ្លែស្វាយទៅព្រាហ្មណ៍ចាស់ ស៊ូអត់ខ្លួនឯង ហើយដើរទៅចចកទៀត ចចកក៏ឱ្យសាច់អាំង រួចទៅរកភេ ៗ ក៏ឱ្យត្រីថ្កិនទៀត រហូតដល់ទន្សាយ ៗ ប្រាប់ថា ខ្ញុំមានតែសាច់និងឈាមរបស់ខ្ញុំ ត្រូវការឱ្យជាទាន បើអ្នកត្រូវការ ចូរឱសបង្កាត់ភ្លើងឱ្យឆេះទៅចុះ ខ្ញុំនឹងលោតចូលក្នុងភ្លើង អ្នកនឹងបរិភោគនូវសាច់របស់ខ្ញុំ ព្រាហ្មណ៍ចាស់តបថា ខ្ញុំអរគុណណាស់ បើដូច្នេះហើយរកឧសបង្កាត់ភ្លើងមួយភ្លក់យ៉ាងធំ ទន្សាយពោធិសត្វ រលាស់ខ្លួនយ៉ាងស្អាតហើយ ក៏លោតចូលទៅក្នុងភ្លក់ភ្លើង ស្រាប់តែភ្លើងនោះរលត់អស់ទៅ ។

សេចក្ដីអស្ចារ្យប៉ុណ្ណេះជាដើម ដែលនាំឱ្យព្រាហ្មណ៍ចាស់ស្ងើចសរសើរ ស្ដេចព្រះឥន្ទនោះក៏ហោះទៅយកថ្មកែវ មនោសិលាមួយដុំ ទៅគូរវាសរូបទន្សាយភ្ជាប់ក្នុងវង្វង់ព្រះចន្ទទៅ ។ បានជាយើងមើលឃើញរូបទន្សាយនៅក្នុងវង្វង់ព្រះចន្ទសព្វថ្ងៃនេះ ។ ដំណើពីត្រឹមនោះមក បានជាយើងសព្វថ្ងៃនាំគ្នាគោរពបូជាសំពះព្រះខែជាប់មកដល់សព្វថ្ងៃនេះ ។

កាលនោះស្វាគឺព្រះសារីបុត្រ, ចចកគឺព្រះអានន្ទ, ភេគឺព្រះមោគ្គលាន, ទន្សាយគឺព្រះសមណគោតមហ្នឹងឯង ។ រឿងប៉ុណ្ណេះជាដើម ជាឧទាហរណ៍ដើម្បីជាវត្តប្រតិបត្តិក្នុងកិច្ចបុណ្យសំពះព្រះខែ ។ រឿងនេះមានក្នុងសសៈជាតក គម្ពីរតិក្កនិបាត ។

**ចប់បុណ្យបុជាព្រះចន្ទខែម៉ុរណ្ណ**

# កំណើតបុណ្យផ្កាប្រាក់

រឿងសង្ខេបក្នុងវិនយដ្ឋកថាឈ្មោះ សមន្តបាសាទិកា ត្រង់មហាវិភង្គវណ្ណនា ឈ្មោះតតិយបារាជិកវណ្ណនា នាភេសជ្ជបដិបត្តិកថា ។

សេចក្តីថា ព្រះថេរព្រះនាម មហាបទុម កាលនោះ រោគកើតឡើងដល់ព្រះរាជទេពីរបស់ព្រះ វសភៈ ស្តេចក៏មានព្រះរាជឱង្ការប្រើស្រីស្នំឱ្យទៅសួរថ្នាំនិងមហាបទុមត្ថេរ ។ លោកមិនបានឆ្លើយថាមិនដឹង ហើយលោកបានសំណេះសំណាលជាមួយនឹងភិក្ខុដទៃថា ម្នាលលោកទាំងឡាយ កាលដែលរោគនេះ កើតឡើងដល់ភិក្ខុឈ្មោះឯណោះ ពួកគេបានធ្វើថ្នាំយ៉ាងណា ? ពួកភិក្ខុបានទូលថា បពិត្រព្រះតេជគុណជាទីគោរព ពួកគេបានធ្វើថ្នាំនេះផង ។ អ្នកបំរើស្តេចបានឮដំណឹងនោះហើយ បានធ្វើថ្នាំដល់ព្រះរាជទេពី ។ រោគនោះក៏ជាសះស្បើយ ពួកគេបានញ៉ាំងប្រអប់ឱ្យពេញដោយថ្នាំរោគ ព្រមទាំងចីវរមួយត្រៃ ប្រាក់ ៣០០ កហាបណៈ ហើយហែមកដាក់ក្នុងទីជិតព្រះបាទព្រះថេរៈរួចបានទូលថា បពិត្រព្រះតេជគុណធ្វើនូវវត្ថុទាំងនេះ ឱ្យជាបុប្ផបូជាឱ្យទាន ។ ព្រះថេរៈបានគិតថា បុប្ផបូជានេះ ហៅថាចំណែករបស់អាចារ្យហើយ បានញ៉ាំងកប្បិយការកៈឱ្យទទួលតាមអំណាចកប្បិយវត្ថុ រួចបានធ្វើវត្ថុទាំងនោះឱ្យជាបុប្ផបូជាហើយ ។ បានជាមានបុណ្យផ្កាប្រាក់នេះ ដរាបមកដល់សព្វថ្ងៃនេះ ព្រោះមានរឿងនេះជាអាទិ ។ ឥឡូវនេះធ្វើកិច្ចអ្វីៗ ក៏យកឈ្មោះបុណ្យផ្កានេះដែរ តែជំនាន់ដើមគេធ្វើបូជាចំពោះព្រះរតនត្រ័យទាំងបី បើក្រៅពីព្រះរតនត្រ័យក៏ធ្វើចុះកុំឱ្យតែយក

ឈ្មោះព្រះសង្ឃទៅអាង ហើយវេរចំពោះសង្ឃហើយយកមកធ្វើក្រៅអាវាមវិញ ធ្វើដូច្នេះមិនគួរទេ ។

### ចប់គំរណីតបុណ្យផ្កាប្រាក់តែប៉ុណ្ណេះ

# បុណ្យចូលឆ្នាំ

បុណ្យចូលឆ្នាំនេះ គេច្រើននិយាយមកតាមវិធីច្រើនសណ្ឋានគឺ ពិធីលេងល្បែងផ្សេងៗ មានលេងឈូង អន្ទាក់ក្លាច់ ស្តេចចង់ ជាដើម ហៅថា លេងបុណ្យនក្ខត្តឫក្ស និងថ្ងៃទីបំផុតត្រូវស្រង់ទឹកព្រះជម្រុះមន្ទិល ហើយខំធ្វើបុណ្យទានរក្សាសីលដើម្បីផ្លាស់ចិត្តគំនិត អធ្យាស្រ័យឱ្យបានជ្រះថ្លាផូរផង់ ទើបបានទទួលយកសិរីសួស្តី និងសេចក្តីសុខចំរើន ដែលកើតមានឡើងដោយអំណាចនៃទេវតាដែលចុះមករក្សាសត្វលោកក្នុងឆ្នាំនេះជាដើម ។

ហេតុនេះ បុណ្យចូលឆ្នាំថ្មី បើគិតទៅតាមលំអានរបស់ខ្មែរអ្នកកាន់ព្រះពុទ្ធសាសនាបានប្រតិបត្តិការតាមយោបល់នៃវិចារណ៍កថានេះទៅថា ពីជាន់ពុទ្ធសម័យក៏មានន័យដូច្នេះដែរ បើដូច្នេះពុទ្ធសាសនិកជន ត្រូវត្រិះរិះបំពេញកុសលឱ្យសមតាមវិធានការណ៍នេះ បុណ្យចូលឆ្នាំថ្មី ដូចបានរៀបរាប់មកខាងលើនេះឱ្យបានឋិតក្នុងបំណងរៀងៗខ្លួនកុំខាន ហើយត្រូវខំបំពេញកុសលមានការឱ្យទានរក្សាសីលចំរើនមេត្តា ភាវនា តាមសមគួរ តាមយថាកាល និងសមត្ថភាព ។

**បុ**- បុណ្យចូលឆ្នាំនេះ ហេតុអ្វីក៏ចូលខែចេត្រ ខែដទៃទៀត ក៏មិនធ្វើផង ?

**វិ**- បានជាចូលតែខែចេត្រនេះ ចូលតាមរបៀបសុរិយគតិ ១ មកខែមេសាជាខែទី ១ ខែមេសាត្រូវនឹងខែចេត្រ យើងប្រើខែថ្ងៃជា ៤ ផ្នែកគឺ :

១- ចន្ទគតិ មិគសិរ ខែទី១ មានខ្មែរ នោច កិច្ចព្រះពុទ្ធសាសនា អនុវត្តទៅតាមចន្ទគតិ មានថ្ងៃឧបោសថជាដើម .

២- សុរិយគតិ ខែមេសាជាខែទី ១ រាប់ថ្ងៃ មួយ ពីរ បី តទៅ ខែនេះត្រូវនឹងខែអីរុប .

៣- អីរុបគតិ យកខែមករា [១] ជាខែទី១០ នៃសុរិយគតិ ដាក់ជាខែទី១ ត្រូវនឹងអីរុបយើងប្រើសព្វថ្ងៃនេះ .

៤- ពុទ្ធគតិ យក ១ រោច ខែពិសាខ ទៅទល់ ១ រោច ខែជេស្ឋជាខែទី ១ សំរាប់បកសករាជ នេះតាមព្រះពុទ្ធនិព្វាន ។

បានជាយើងចូលឆ្នាំខែចេត្រនេះ ត្រូវនឹងដាច់ឆ្នាំចាស់ចូលឆ្នាំថ្មី ។ ដាច់ឆ្នាំចាស់ខែមិនា ចូលឆ្នាំថ្មីខែមេសា ។

ប៉ុ- ចុះបុណ្យដទៃ ៗ ក៏មិនមានលេងល្បែង បុណ្យនេះក៏មានលេងល្បែង ?

វិ- ចូលឆ្នាំនេះ មិនមែនមានតែជាតិអ្នកកាន់ព្រះពុទ្ធសាសនាទេ សូម្បីតែជាតិអ្នកកាន់សាសនាដទៃ ក៏គេចូលឆ្នាំដែរ ។ ចូលឆ្នាំនេះ មិនមែនទើបនឹងមានពុទ្ធកាលនេះទេ មានតាំងពីមុនព្រះពុទ្ធបានត្រាស់ បានជាកើតមានល្បែងផ្សេងៗ ជាយូរមកហើយ តែអ្នកកាន់ព្រះពុទ្ធសាសនា យល់ឃើញថា ចូលឆ្នាំទាំង

(១) មករាជាខែទី ១០ នៃសុរិយគតិ ដាក់ជាខែទី១ ត្រូវនឹងអីរុប នេះ កើតមានប្រើត្រឹមគណៈបក្សប្រជាធិបតេយ្យកើតឡើង ។

៣ ថ្ងៃនេះកុំឱ្យខាតប្រយោជន៍ ត្រូវគិតធ្វើបុណ្យ ។ ថ្ងៃទី ១ និមន្តលោកសូត្រមន្តទេសនា ព្រឹកឡើងនិមន្តលោកឆាន់ ប្រគេនសាដកនិមន្តលោកស្រង់ទឹក មានពូនភ្នំខ្សាច់[១] ស្រុកខ្លះមានពូនភ្នំស្រូវដល់ថ្ងៃទី៣ និមន្តលោកសូត្រ ពហូ ទេវា ជាកិច្ចបង្ហើយបុណ្យ ។

បុណ្យចូលឆ្នាំនេះ ស្រេចតែអាចារ្យចេះលៃលកឱ្យសមគួរទៅតាមកាលៈទេសៈ ។

តាមទំនៀមទំលាប់ការចូលឆ្នាំក្នុងថ្ងៃទី ១៣ ១៤ ខែមេសា គឺ ខែចេត្រ តាមចន្ទគតិ ក៏កើតមានឡើងក្នុងសម័យដែលចុងសកភាជនេះ ។

---

(១)- ការពូនភ្នំខ្សាច់ គឺធ្វើតាមទំនៀមទម្លាប់វាលុកចេតីយ. យកវាលុកចេតិយជាហេតុ ដើម្បីឧទ្ទិសចំពោះព្រះរតនត្រ័យ ។ មតិអាចារ្យខ្លះ គេនាំពូនភ្នំស្រូវ ដើម្បីឱ្យចំរើនដល់វត្តអារាម ។

**ចប់បុណ្យចូលឆ្នាំប៉ុណ្ណេះ**

## កំណើតសំពត់សាដក

សំពត់សាដកនេះកើតពីនាងវិសាខា កាលព្រះសាស្ដាគង់នៅក្នុងវត្តជេតពន ពេលនោះជាវស្សានរដូវ (គឺជារដូវភ្លៀង) នាងវិសាខា បានចាត់ប្រើនាងទាសីឱ្យទៅនិមន្តភិក្ខុសង្ឃដើម្បីទទួលចង្ហាន់ ។

នាងទាសីទៅនិមន្ត ឃើញតែបុគ្គលអាក្រាតកំពុងងូតទឹក រកតែភិក្ខុមួយអង្គគ្មាន ។ ទើបនាងទាសីត្រឡប់មកជម្រាបដល់នាងវិសាខាវិញ នាងវិសាខាបានដឹងហេតុដូច្នេះ ក៏ទៅទូលសុំពរ ៨ ប្រការ អំពីព្រះសម្មាសម្ពុទ្ធ ។

## ពរ៨ប្រការ

១-សូមប្រគេនវស្សិកសាដក សំពត់សំរាប់ងូតទឹក ភ្លៀង.

២-សូមប្រគេនអាគន្តុកភត្ត ភត្តសម្រាប់ភិក្ខុទើបមកដល់ថ្មី .

៣-សូមប្រគេនគមិកភត្ត ភត្តសម្រាប់ភិក្ខុមានដំណើរទៅ .

៤-សូមប្រគេនគិលានភត្ត ភត្តសម្រាប់ភិក្ខុមានជម្ងឺ .

៥-សូមប្រគេនគិលានុបដ្ឋាកភត្ត ភត្តសម្រាប់ភិក្ខុអ្នកបម្រើភិក្ខុមានជម្ងឺ .

៦-សូមប្រគេនគិលានភេសជ្ជៈ ថ្នាំសម្រាប់ភិក្ខុមានជម្ងឺ.

៧-សូមប្រគេនធុវយាគូ បបរជានិច្ច .

៨-សូមប្រគេនឧទកសាដក (សំពត់សម្រាប់ ងូតទឹក) ដល់ភិក្ខុនីសង្ឃជាបដល់អស់ជីវិត ។

## អានិសង្សសំពត់សាដកដូចមានរឿងតទៅនេះ :

បើជាបុរសដល់បច្ឆិមជាតិ បានសម្រេចជាឯហិភិក្ខុ ត្រៃចីវរកើតឡើង បើជាស្ត្រីនឹងបានសម្រេចគ្រឿងលតាមហាបាសាធន៍ បើមិនទាន់បានសម្រេចព្រះនិព្វានទេ ទៅកើតនៅភពណាៗ មានពណ៌សម្បុរល្អ នឹងសម្រេចបាននូវសំពត់ទិព្វ ដូចមាននិទានតទៅនេះ :

សេចក្ដីថា: កាលដ៏កន្លងទៅហើយ មានក្មេងកំព្រាម្នាក់នៅក្នុងក្រុងពារាណសី ចូលទៅក្នុងព្រៃ បានឃើញព្រះបច្ចេកពុទ្ធធ្វើចីវរមិនទាន់ហើយ ខ្វះអនុវាត បានប្រគេនសំពត់បង់របស់ខ្លួនទៅព្រះបច្ចេកពុទ្ធ (លុះច្យុតចាកអត្តភាព) នេះ បានទៅកើតក្នុងស្ថានតាវតិង្ស ដោយកុសលកម្មដែលខ្លួនបានប្រគេនសំពត់ដល់ព្រះបច្ចេកពុទ្ធនោះ ។ លុះច្យុតចាកស្ថានតាវតិង្សមក បានទៅកើតជាអាមាត្យមានលំនៅចម្ងាយពីក្រុងពារាណសី ១ យោជន៍ លុះមានវ័យចំរើនឡើងហើយ និយាយនឹងម្ដាយថា បពិត្រលោកម្ដាយ សូមឱ្យសំពត់សាដកមកខ្ញុំ ១ នឹងទៅលេងនក្ខត្តឫក្សនឹងគេ ម្ដាយក៏ឱ្យសំពត់ដែលបោកទឹករួចហើយមកឱ្យកូន ១ នោះ ប្រកែកថា សំពត់នេះគ្រាស់ណាស់ ម្ដាយក៏បានប្ដូរឱ្យសំពត់ដទៃវិញ ក៏នៅតែប្រកែកមិនព្រមយក ។ ម្ដាយប្រាប់ថាគ្មានសំពត់សាច់ល្អិតជាងនេះទេកូន កូននោះតបថា បើគ្មានខ្ញុំនឹងស្វែងរកត្រាតែបាន. ម្ដាយក៏ឆ្លើយ អាងយកប្រមាណព្រហ្ម

វិហាររបស់ខ្លួនថា អើកូនអញប្រាថ្នាឱ្យឯងសោយរាជ្យក្នុងនគរពារាណសីនៅថ្ងៃនេះផង មិនតែចង់ឱ្យឯងបានសំពត់ល្អប៉ុណ្ណោះទេ កុមារនោះបានទទួលមធុរវាចាមាតាថាសាធុៗ ហើយបង្គំលាត្រាច់ទៅក្រុងពារាណសី ដោយគំនរបុណ្យដាស់តឿនកុមារក៏ចូលទៅក្នុងឧទ្យានដេកទទូរក្បាលលើផែនថ្មមង្គល ។ ជួនថ្ងៃនោះជាថ្ងៃគំរប់ ៧ ដែលស្ដេចក្រុងពារាណសីទទួលទីវង្គតទៅ ពួកឥស្សរជនទាំងឡាយម៉ានអាមាត្យជាដើម បានធ្វើសរីរកិច្ចរាជារួចហើយ ក៏ប្រឹក្សាគ្នាថា ព្រះរាជាមានតែព្រះរាជធីតា ១ ព្រះអង្គ ឥតមានរាជបុត្រទេ តពីនេះទៅ មិនមានស្ដេចសោយរាជ្យជាតំណវង្សតទៅទៀតទេ រាជសម្បត្តិ មុខជានឹងវិនាសសាបសូន្យពុំខានឡើយ ។ ហើយក៏ផ្សងបុស្សរថ ដែលទឹមដោយសេះសិន្ធវៈ ៤ ដាក់គ្រឿងបញ្ចកកុធភណ្ឌលើរថ ១ ក៏ចេញទៅតាមទ្វារខាងកើត ចូលទៅកាន់ឧទ្យានប្រទក្សិណកុមារហើយធ្វើអាការហាក់ដូចជា លើកដាក់លើរថ បុរោហិតបើកជាយសំពត់ដណ្ដប់ក្រឡេកមើលឃើញផ្ទៃបាត់ជើងកុមារនោះ ក៏ប្រកាសប្រាប់ថា បុរសនេះគួរសោយរាជ្យហើយ បង្គាប់ឱ្យប្រគុំដូរ្យដន្ត្រី ៣ បទ ខណៈនោះកុមារបើកមុខឡើង ហើយសួរថា អ្នករាល់គ្នាធ្វើអ្វីហ្នឹង ? ពួកឥស្សរៈជនទាំងនោះក្រាបទូលថា បពិត្រព្រះធម្មតិទេព ព្រះអង្គត្រូវទទួលគ្រងរាជសម្បត្តិក្នុងក្រុងពារាណសីនេះ ហើយក៏ក្រាបទូលអំពីការផ្សងរកស្ដេចតាមដំណើរសេចក្ដីតាំងអំពីដើមរហូតមក ។

កុមារក៏ព្រមទទួល ទើបរាជបុរសទាំងនោះ តាក់តែងមណ្ឌបអភិសេក ហើយបង្ហានសំពត់មានតម្លៃ ១ ពាន់កហាបណៈថ្វាយ ក្នុងខណៈនោះភ្លាម ព្រះរាជាអង្គនោះមានព្រះរាជបន្ទូលថា សំពត់សាដកក្រាស់នេះ អ្នករាល់គ្នាត្រូវយកកណ្ដឹមកឱ្យយើង ទើបនឹងបានសំពត់ល្អ រួចក្រោកឡើងកាន់ទឹកច្រូចទៅទិសទាំង ៤ ខណៈនោះស្រាប់តែដើមកល្បព្រឹក្សប្រាំបី ៦ ដើម ទំលាយផែនដីផុះឡើង ក្នុងទិសខាងកើត, ខាងត្បូង, ខាងលិច, ខាងជើង ។

ព្រះរាជាទ្រង់យកសំពត់ទិព្វនោះមកស្លៀក១ ដណ្ដប់ ១ ហើយទ្រង់បង្គាប់ហាមមិនឱ្យពួកស្ត្រី ក្នុងដែននន្ទរាជការសូត្រត្បាញសំពត់តទៅទៀត ហើយទ្រង់ប្រថាប់លើសីវិយាងចូលកាន់នគរ ឡើងកាន់ប្រាសាទសោយរាជ្យនូវមហាសម្បត្តិ រួចហើយធ្វើដែនដីរបស់ព្រះអង្គទាំងមូល ឱ្យដូចឧត្តរកុរុទ្វីប ទ្រង់ប្រទានសំពត់ទិព្វដល់ពួកមនុស្សដែលមកដល់ ក្រោយមកទ្រង់បព្វជ្ជាជាមួយនឹងនាងទេវីនៅក្នុងឧទ្យាន ញ៉ាំងឈានឱ្យកើតឡើង ហើយធ្វើមិនឱ្យសាបសូន្យទៅវិញ (លុះច្យុតចាកអត្តភាព) បានទៅកើតក្នុងព្រហ្មលោក។ ព្រះបាទនន្ទរាជនោះ គឺព្រះមហាកស្សបត្ថេរក្នុងកាលឥឡូវនេះ ព្រះនាងទេវីបានមកជាភទ្ទាកាបិលានីនេះឯង ។

២-ក្នុងកាលកន្លងទៅហើយ នៅក្រុងពារាណសីមានស្ត្រីកំសត់ម្នាក់ បានឃើញពួកស្ត្រីបរិបូណ៌ដោយបុណ្យ ស្លៀកដណ្ដប់សំពត់មានពណ៌ក្រហមដូចផ្កាសិរមាន់ ដើរលេងក្នុងថ្ងៃមហោស្រព ក៏ចង់ស្លៀកសំពត់បែបនោះលេងនឹងគេ ក៏រំអុកប្រាប់មាតាបិតាៗ ថានាងអើយ យើងជាអ្នកកំសត់ តើនឹងបានសំពត់បែប

នេះមកពីណា ? នាងធិតាថាបើដូច្នោះ ខ្ញុំនឹងទៅធ្វើការឈ្នួលឱ្យអ្នកស្តុកស្តម្ភម្នាក់ គេនឹងឱ្យសំពត់ដល់ខ្ញុំ ថាហើយក៏ដើរទៅរកត្រកូល ១ ខំធ្វើការឈ្នួលដើម្បីយកសំពត់នោះ ត្រកូលគេប្រាប់ថា នាងចូរធ្វើការគ្រប់ ៣ ឆ្នាំ ទើបយើងឱ្យ នាងទទួលព្រមហើយក៏ខំធ្វើការយកចិត្តទុកដាក់ ។ លុះគំរប់ ៣ ឆ្នាំ ត្រកូលនោះបានឱ្យសំពត់មានពណ៌ក្រហមដូចផ្កាសិរមាន់ ថែមទាំងសំពត់ដទៃដល់នាងទៀត លុះបានហើយនាងយកទៅដាក់ក្បែរឆ្នេរស្ទឹងទុកសិន ហើយចុះងូតទឹក ។

ខណៈនោះសាវ័ករបស់ព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបៈមួយអង្គ ចោរលួចចីវរអស់ បិទបាំងអវយវៈតែដោយមែកឈើ នៅនាប្រទេសនោះ នាងឃើញហើយគិតថា លោកម្ចាស់អង្គនេះ ពិតជាចោរលួចចីវរ ចំណែកអាត្មាអញរកសំពត់ស្លៀកដោយកម្រណាស់ ព្រោះកាលពីដើមអញលួចសំពត់អ្នកដទៃ គិតដូច្នោះហើយហែកសំពត់របស់ខ្លួនពាក់កណ្តាល ប្រគេន ១ ចំណែកទៅលោក ៗ ឈរក្នុងទីកំបាំងហើយ បោលមែកឈើ ស្លៀកដាយសំពត់ម្ខាង ដណ្តប់ម្ខាងនិមន្តចេញទៅ ។ គ្រានោះសរីរៈទាំងអស់របស់ព្រះថេរៈ មានពន្លឺតែ ១ ហាក់ដូចជាព្រះអាទិត្យទើបរះឡើង ដោយអនុភាពនៃសំពត់នោះនាងឃើញហើយគិតថា លោកម្ចាស់អញពីដើមមិនស្អាតសមរម្យទេ ឥឡូវរុងរឿងដូចជាព្រះអាទិត្យ ដូច្នេះអញនឹងប្រគេនសំពត់ចំណែកទីពីរនេះទៀត គិតហើយប្រគេនភ្លាម រួចតាំងសេចក្តីប្រាថ្នាថា បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំនៅអន្ទោលទៅក្នុងភពសូមឱ្យមានរូបល្អ បុរសណាមួយឃើញខ្ញុំហើយ កុំឱ្យទប់សេចក្តីស្នេហាបាន

ឈ្មោះជាស្ត្រីល្អលើសលែង ឥតមានស្ត្រីដទៃប្រៀបផ្ទឹមបាន ព្រះថេរធ្វើអនុមោទនា ហើយនិមន្តចៀសចេញទៅ ។ ធីតានោះអន្ទោលទៅក្នុងទេវលោក លុះច្យុតចាកទេវលោកមកកើតជាធីតាសេដ្ឋីឈ្មោះ តិរិដិវច្ឆៈ មានសម្បត្តិ ៨ កោដិ ក្នុងដែនអរិដ្ឋបុរីដែនសិវៈ ធីតានោះមានរូបឆោមលោមពណ៌ល្អលើសលែងស្រីក្នុងនគរ បុរសណាឃើញហើយ ទៅជាវង្វេងភ្លេចស្មារតី គិតអ្វីពុំឃើញបានជាគេហៅនាងថា (ឧម្មាទន្តី) នាងមានអាយុ ១៥ ឆ្នាំ មានពណ៌សម្បុរល្អជាងមនុស្សទាំងអស់ ហាក់ដូចស្ត្រីទេពអប្សរ ពួកមនុស្សបុថុជ្ជនណាឃើញនាងហើយ មិនអាចទប់ទល់ស្មារតីឱ្យតាំងនៅប្រក្រតីបានឡើយ ហេតុតែស្រវឹងវង្វេងភ្លេចដោយកិលេសដូចជាអ្នកស្រវឹងស្រា ។

តិរិដិវច្ឆសេដ្ឋី ចូលទៅគាល់ព្រះបាទសិវិរាជ ហើយក្រាបទូលថា បពិត្រព្រះធម្មតិទេព ក្នុងផ្ទះរបស់ខ្ញុំព្រះអង្គ មានឥត្ថីរតន៍កើតឡើងហើយ សូមព្រះអង្គត្រាស់បង្គាប់ឱ្យហោរាទាយលក្ខណៈ ពិនិត្យមើលឥត្ថីរតន៍នោះសមគួរដល់ព្រះរាជាទេ ? ព្រះរាជាទ្រង់ត្រាស់ប្រើពួកព្រាហ្មណ៍ឱ្យទៅមើល ។

ខណៈនោះ នាងឧម្មាទន្តីទៅកាន់សំណាក់ព្រាហ្មណ៍ៗទាំងនោះ ឃើញនាងហើយ ក៏ភាន់ភាំងស្មារតី ហេតុតែស្រវឹងដោយកិលេសលែងដឹងខ្លួន ទៅជាបាចសាចភោជន ឱ្យរាត់រាយពាសពេញនៅទីនោះ អ្នកខ្លះកាន់ពំនូតបាយដាក់លើក្បាលសំគាល់ថាដាក់ក្នុងមាត់ហើយបរិភោគ ខ្លះប្រហារជញ្ជាំង ខ្លះដាក់បាយត្រង់ចន្លោះក្លៀក ទៅជាឆ្កួតទាំងអស់គ្នា ឥតមានសល់ម្នាក់ នាងឃើញប្រុសទាំងអស់នោះធ្វើ

ដូច្នោះហើយគិតថា ព្រាហ្មណ៍ក្រែងមកមើលលក្ខណៈអញ (ម្តេចមកធ្វើកិរិយាដូច្នោះ) ហើយបង្គាប់ឱ្យទាសកម្មករចាប់កញ្ចឹងកអូសចេញទៅខាងក្រៅ ពួកព្រាហ្មណ៍ទាំងអស់នោះអៀនខ្មាស់ ក៏ក្រាបទូលព្រះរាជាដោយពាក្យមិនពិតថា នាងឧម្មាទន្តីនោះ ជាស្រ្តីកាឡកណ្ណីដូច្នោះ ក៏អាក់ខានពុំបានឱ្យនាំមក ចំណែកនាងឧម្មាទន្តីបានពតិមាននោះហើយ បានចងគំនុំចំពោះព្រះរាជា ។

កាលជាខាងក្រោយ សេដ្ឋីបានឱ្យនាងឧម្មាទន្តី ទៅសេនាបតីឈ្មោះអភិបារកៈ ជាសំឡាញ់នឹងព្រះរាជា ថ្ងៃមួយមករៀបដំណើរទៅកាន់ការងាររបស់ខ្លួនផ្តាំភរិយា នែប្អូនដ៏ចម្រើនថ្ងៃពេញបូណ៌ខែកត្តិកនេះ ព្រះរាជាទ្រង់ធ្វើប្រទក្សិណនគរ នឹងយាងមកតាមទ្វារផ្ទះយើងនេះជាដំបូង នាងកុំបង្ហាញខ្លួនឱ្យព្រះអង្គឃើញឡើយ ព្រោះថាបើស្តេចទតឃើញប្អូនឯងហើយ មុខជាភាន់ភាំងស្មារតីពុំខាន ។ លុះដល់ព្រះអាទិត្យអស្តង្គតហើយ ព្រះចន្ទពេញវង់រះឡើង ព្រះរាជាទ្រង់ធ្វើប្រទក្សិណនគរដោយមហន្តយស ដំបូងឡើយទ្រង់យាងចេញតាមទ្វារ សេនាបតីទ្រង់ទតឃើញនាងឧម្មាទន្តី ស្ថិតនៅត្រង់បង្អួចស្រោប់តែវង្វេងដោយកិលេស ភ្លេចស្មារតីលែងនឹកនាការធ្វើប្រទក្សិណនគរ ឈប់ត្រឡប់ឡើងអំពីទីនោះឡើងទៅកាន់ប្រាសាទ ទ្រង់ផ្ទុំប្រារព្ធនឹងនាងឧម្មាទន្តីរវើរវាយដោយប្រការផ្សេងៗ សេនាបតីដឹងហេតុថាព្រះរាជាមានហឫទ័យប្រតិព័ទ្ធចំពោះនាងឧម្មាទន្តីហើយ បើព្រះអង្គមិនបាននាងទេមុខជានឹងទីវង្គតគួរអាត្មាអញថ្វាយជីវិតឱ្យព្រះអង្គចុះ ហើយបង្គាប់បម្រើម្នាក់ថា ឯងចូលទៅឯចេតិយព្រឹក្សមានប្រហោងឯណោះ ហើយអង្គុយក្នុង

ប្រហោងឈើនោះ កុំឱ្យអ្នកណាមួយដឹងឱ្យសោះ អញនឹងនៅកន្លែងនោះ ធ្វើពលីកម្មនិយាយយ៉ាងនេះ ឯងចូរនិយាយយ៉ាងនេះមក បុរសនោះបានទទួលពាក្យហើយ ទៅធ្វើដូច្នោះភ្លាម លុះព្រឹកឡើងសេនាបតីទៅឯចេតិយព្រឹក្សធ្វើពលីកម្មតាំងបន់ស្រន់សួរថា ព្រះរាជារបស់យើង ហេតុអ្វីបានជាមិនទ្រង់ក្រសាលមហោស្រព ? ហើយផ្ទុំវើរវាយប្លែកម្ល៉េះ ? អ្នកបម្រើក៏ឆ្លើយតបពីប្រហោងឈើថា សេនាបតី ! ព្រះរាជារបស់អ្នកមានព្រះទ័យប្រតិព័ទ្ធនិងនាងឧម្មាទន្តី ជាភរិយាអ្នកឯង ប្រសិនបើព្រះអង្គបាននាងនោះមិនទិវង្គតទេ បើមិនបាននាងទេមុខជាទិវង្គតហើយ ហេតុនេះត្រូវថ្វាយនាងឧម្មាទន្តីទៅព្រះរាជាទៅ សេនាបតីឆ្លើយថាស្រួលប្រពៃហើយលោក រួចចូលទៅគាល់ព្រះរាជា ក្រាបទូលដំណើរនោះថា បពិត្រព្រះធម្មតិទេព ខ្ញុំព្រះអង្គថ្វាយនាងឧម្មាទន្តីដល់ព្រះអង្គ ព្រះរាជាសួរបញ្ជាក់ថា នែអភិបារកៈ សម្លាញ់អ្នកដឹងថា យើងវើរវាយព្រោះមានចិត្តប្រតិព័ទ្ធនឹងនាងឧម្មាទន្តីមែនឬមែនឬ ? សេនាបតីក្រាបទូលថាៈ បពិត្រព្រះធម្មតិទេព រឿងនេះពិតមែន ព្រះរាជាទ្រង់ពិចារណាថា យីអើ ! អំពើលាមកលោកទាំងមូលដឹងហើយតើ គិតដូច្នោះហើយ ទ្រង់អៀនខ្មាស់ដកលំព្រះទ័យឱ្យឋិតនៅក្នុងធម៌ បន្ទោបង់នូវបដិព័ទ្ធចោលចេញ មិនព្រមទទួលយកនាងឧម្មាទន្តី ដែលអភិបារកសេនាបតីថ្វាយនោះឡើយ ។

និទានទាំងពីរនេះ លើកមកសំដែងដើម្បីសេចក្តីឱ្យឃើញថា អានិសង្ស ចីវទានបុំណ្ណេះជាដើម ។

**ចប់កំណើតសំពត់សាដកតែម៉្យណ្ណោះ**

## កំណើតបុណ្យប្រទីប

ដូចមានរឿងតទៅនេះ :

### គម្ពី អដ្ឋសាលិនី អដ្ឋកថា អភិធម្ម ធម្មសង្គណី

និទានថា: ទំព័រ ៧៤ (អក្សរសៀម) ។

នឹងពណ៌នាអំពីរស្មីនៃព្រះពុទ្ធទ្រង់ព្រះនាមមង្គលៈ ជាសេចក្តីសង្ខេប តាមបែបគម្ពីរខាងលើនេះ ដូចសេចក្តីតទៅថា :

ព្រះមានព្រះភាគព្រះនាមមង្គលៈនោះ មានរស្មីផ្សាយចេញអំពីព្រះកាយ នៃព្រះអង្គ ពុំដូចព្រះពុទ្ធដទៃទេ គឺព្រះអង្គមានរស្មីផ្សាយចេញអំពីសរីរៈ ផ្សាយ ទៅកាន់លោកធាតុ ១ ម៉ឺនហើយតាំងនៅអស់កាលជានិច្ច ។ ឯសុវណ្ណធាតុទាំង ឡាយ មានព្រៃព្រឹក្សា បព្វតា និងសមុទ្រជាដើម ជាធម្មជាតិហាក់ដូចជាស្រោប ហើយដោយតម្បាវមាស ដោយហោចទៅសូម្បីតែវត្ថុទាំងឡាយ មានផ្កាំងបាយជា ដើម ក៏ក្លាយទៅជាពណ៌មាសដៅ ដោយសារពន្លឺរស្មីនៃពុទ្ធអង្គនោះឯង ។ ព្រះអង្គមានជន្មាយុ ៩ ម៉ឺនឆ្នាំ ។ ក្នុងកាលបុំណ្ណេះ ព្រះចន្ទនិងព្រះអាទិត្យ

ទាំងឡាយ ពុំអាចនឹងរុងរឿងដោយពន្លឺរបស់ខ្លួន បានឡើយ ។ ការកំណត់នៅយប់និងថ្ងៃក៏ពុំប្រាកដឡើយ ។ ពួកសត្វទាំងឡាយ ត្រាច់ចរទៅមកដោយសារតែពន្លឺនៃពុទ្ធអង្គនោះ អស់កាលជានិច្ច ដូចគេត្រាច់ទៅដោយសារពន្លឺនៃព្រះអាទិត្យក្នុងវេលាថ្ងៃ ។ សត្វលោកចំណាំបានថា ពេលយប់ថ្ងៃ ដោយអំណាចផ្កាទាំងឡាយរីកក្នុងពេលល្ងាច និងសម្រែកនៃសត្វស្លាបក្នុងពេលព្រឹកប៉ុណ្ណោះ ។ បុច្ឆាសួរថា ចុះព្រះទាំងឡាយដទៃ មិនមានរស្មីបែបនេះទេឬ? វិសជ្ជនា ឆ្លើយថា មិនមែនមិនមានទេ ព្រោះថាបើព្រះពុទ្ធទាំងឡាយនោះព្រះអង្គមានប្រាថ្នានឹងផ្សាយ ក៏អាចផ្សាយពន្លឺរស្មីឱ្យផ្សាយទៅកាន់លោកធាតុ ១ ម៉ឺន ឱ្យក្រៃលែងជាងនោះទៅទៀតក៏បាន ( ប៉ុន្តែបានតែក្នុងពេលធ្វើបាដិហារ្យ ) ។

ឯព្រះមានព្រះភាគព្រះនាមមង្គលវិញ ព្រះអង្គមានពន្លឺរស្មីផ្សាយចេញទៅអំពី សរីរប្បទេសផ្សាយទៅអស់លោកធាតុ ១ ម៉ឺន អស់កាលជានិច្ច បីដូចជាព្រះពុទ្ធទាំងឡាយ ដែលមានរស្មីតែមួយព្យាមអស់កាលជានិច្ចដែរ ដោយសេចក្តីប្រាថ្នាដែលព្រះអង្គតាំងទុកហើយអំពីបុព្វជាតិ ។

## សោ កិរ ពោធិសត្តចរិយកាលេ ។ល។ ទសសហស្សិលោកធាតុំ ចរិត្វា អដ្ឋាសិ ។

មានសេចក្តីដំណាលថា : ព្រះមានព្រះភាគអង្គនោះ កាលនៅជាពោធិសត្វនៅឡើយ ព្រះអង្គស្ថិតនៅក្នុងអត្តភាពដូចព្រះវេស្សន្តរ ព្រះអង្គព្រមដោយបុត្រនិងភរិយា បានគង់នៅនាភ្នំ ប្រាកដស្មើដោយវង្កបពតិដែរ ។

គ្រានោះ មានយក្សមួយឈ្មោះ ខរទាឋិក: ពួថាមហាបុរសពេញ អធ្យាស្រ័យក្នុងទាន ក៏ក្លែងភេទជាព្រាហ្មណ៍ចូលទៅសូមទារកពីរនាក់ អំពីព្រះមហាសត្ត. ព្រះមហាសត្តមានព្រះទ័យរីករាយ ថា អាត្មាអញនឹងឱ្យនូវបុត្រទាំងឡាយដល់ព្រាហ្មណ៍ ហើយក៏ប្រទាននូវទារកពីរ បានញុំាងផែនដីឱ្យញាប់ញ័រដល់ទីបំផុតនៃទឹក ។ យក្ស(លុះបានហើយ) ក៏ទៅឈរផ្អែកនឹងបន្ទះក្តារ ដែលព្យួរត្រង់ទីបំផុតនៃទីចង្រ្កម កាលមហាសត្តកំពុងតែឃើញច្បាស់ ក៏ទំពារស៊ីនូវទារកទាំងពីរ ដូចជាបុគ្គលទំពារនូវដុំដំឡូង ។ មហាបុរសក្រឡេកមើលឃើញយក្ស ទុកជាឃើញនូវមាត់យក្សនោះ កំពុងហូរចេញនូវទរនៃឈាម បីដូចអណ្ដាតនៃភ្លើង ក៏ទ្រង់ពុំមានសេចក្តីទោមនស្សសូម្បីប៉ុនចុងនៃសក់ឡើយ ។ ព្រះអង្គបែរជាមានសេចក្តីត្រិះរិះថាឱ ហ្ន៎! ទានរបស់អញ ១ បានឱ្យល្អហើយ ឯបីតិសោមនស្សយ៉ាងធំក៏កើតឡើងពេញសរីរៈនៃព្រះអង្គ ។ ព្រះមហាបុរសនោះ បានធ្វើនូវសេចក្តីប្រាថ្នាយ៉ាងនេះថា "ដោយអនិសង្សនៃទានរបស់ខ្ញុំនេះ សូមឱ្យរស្មីផ្សាយចេញអំពីសរីរៈតាមទំនងនេះក្នុងកាលជាអនាគត" ។ អាស្រ័យនូវទានបារមីរបស់ព្រះអង្គនោះ លុះព្រះអង្គបានត្រាស់ជាព្រះសម្ពុទ្ធរស្មីទាំងឡាយផ្សាយចេញអំពីសរីរៈនៃព្រះអង្គ ហើយឋិតនៅអស់កាលមានប្រមាណប៉ុណ្ណេះ ។

មាននិទានមួយទៀតថា កាលព្រះអង្គនៅជាពោធិសត្តព្រះអង្គបានឃើញនូវពុទ្ធចេតិយមួយ ហើយទ្រង់ត្រិះរិះថាគួរអាត្មាអញបរិច្ចាគនូវជីវិតបូជានូវព្រះពុទ្ធនេះ ដូច្នេះហើយក៏ទ្រង់រុំសរីរៈទាំងមូលនៃព្រះអង្គ តាមទំនងនៃការរុំចន្លុះ

ហើយញ៉ាំងភាជន៍មានកំពស់ ១ ហត្ថ ដូចមានមកុដមានក្បាច់ ១ សែន ឱ្យពេញដោយសប្បិ (ប្រេងទឹកដោះ) ហើយដាក់ប្រឆេះ ១ ពាន់ ក្នុងសុវណ្ណភាជនៈនោះ ហើយញ៉ាំងភ្លើងឱ្យឆេះរុងរឿង ហើយដើរប្រទក្សិណនូវចេតិយនោះអស់រាត្រីទាំងមូល ។ កាលមហាបុរសធ្វើព្យាយាមយ៉ាងនេះ ដរាបដល់អរុណរះសូម្បី តែរន្ធនៃរោមក៏ពុំមានចំហាយក្តៅឡើយ ។ (ត្រជាក់) ហាក់ដូចជាកាលព្រះអង្គចូលទៅក្នុងសម្បកនៃផ្កាឈូក ។

មានសេចក្តីសរសើរថា នេះហើយធមិ សមដូចពុទ្ធភាសិតថា ។

ធម្មោ ហវេ រក្ខតិ ធម្មចារឹ

ធម្មោ សុចិណ្ណោ សុខមាវហាតិ

ឯសានិសំសោ ធម្មេសុចិណ្ណេ

ន ទុគ្គតឹ គច្ឆតិ ធម្មចារីតិ ។

សេចក្តីថា មានតែធមិប៉ុណ្ណោះទេ តែងរក្សានូវបុគ្គលអ្នកប្រព្រឹត្តធមិ ធមិដែលបុគ្គលសន្សំល្អហើយ តែងនាំសេចក្តីសុខមកឱ្យ នេះជាអានិសង្សនៃធមិដែលបុគ្គសន្សំល្អហើយ បុគ្គលអ្នកប្រព្រឹត្តធមិ រមែងមិនទៅកាន់ទុគ្គតិឡើយ ។

អានិសង្សនៃបុញ្ញកម្មនេះ ពន្លឺនៃរស្មីក៏ផ្សាយចេញអំពីសរីរៈនៃព្រះមានព្រះភាគអង្គនោះផ្សាយទៅកាន់លោកធាតុ ១ ម៉ឺន ដូចសេចក្តីដែលរៀបរាប់មកប៉ុណ្ណោះឯង ។

រឿងមួយទៀតដូចមានក្នុងធម្មបទដ្ឋកថា
ភាគទី៨ទំព័រ ១២១

## រឿង សុមនសាមណេរ

សេចក្ដីដំណាលថា: ក្នុងសម័យនៃព្រះទ្រង់ព្រះនាមបទុមុត្តរ មានកុលបុត្រម្នាក់ បានឃើញព្រះពុទ្ធអង្គនោះ តែងតាំងភិក្ខុមួយរូបក្នុងឋានៈ ជាអ្នកមានទិព្វចក្ខុយ៉ាងប្រសើរ ជាងភិក្ខុអ្នកមានទិព្វចក្ខុផងគ្នា កណ្ដាលចំណោមនៃបរិស័ទទាំង ៤ ហើយក៏ប្រាថ្នានូវសម្បត្តិគឺទិព្វចក្ខុនោះ ដោយបាននិមន្តព្រះសាស្ដា និងប្រគេនទានអស់ ៧ ថ្ងៃ ដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន រួចហើយក៏តាំងដំកល់នូវសេចក្ដីប្រាថ្នាថា : "បពិត្រព្រះអង្គដ៏ចំរើនសូមឱ្យខ្ញុំព្រះអង្គបានចក្ខុទិព្វប្រសើរជាងភិក្ខុអ្នកមានចក្ខុទិព្វទាំងឡាយក្នុងសាសនា នៃព្រះអង្គណាមួយក្នុងកាលជាអនាគត"។ ព្រះសាស្ដាទ្រង់រមិលមើលកាលរាប់ដោយសែនកប្បទ្រង់ជ្រាបថា: "សេចក្ដីប្រាថ្នារបស់កុលបុត្រនេះ នឹងបានសម្រេចជាប្រាកដ ហើយទ្រង់ព្យាករណ៍ថា : កុលបុត្រនេះ នឹងបានឈ្មោះថាអនុរុទ្ធ ជាបុគ្គលប្រសើរជាងភិក្ខុអ្នកមានទិព្វចក្ខុទាំងឡាយ ក្នុងសាសនានៃព្រះពុទ្ធ ព្រះនាមសមណគោតម ក្នុងទីបំផុតនៃសែនកប្បអំពីភទ្ទកប្បនេះ ។ ចំណែកកុលបុត្រនោះលុះព្យាករណ៍ (ទំនាយ) នោះហើយមានសេចក្ដីសំគាល់នូវសម្បត្តិនោះថា ដូចគេគប្បីបានក្នុងថ្ងៃ

ស្លេក កាលដែលព្រះសាស្តាបរិនិព្វានទៅហើយ បានសួរនូវទិព្វចក្ខុបរិកម្ម ក្នុងសំណាក់នៃភិក្ខុទាំងឡាយ ហើយព័ទ្ធព័ទ្ធនូវតូបជាវិការៈនៃមាន ៧ យោជន៍ ហើយបង្គាប់ឱ្យជាងធ្វើចន្ទះមួយពាន់ ដើម្បីបូជាដោយប្រទីបទាំងឡាយនោះ ។ លុះច្យុតអំពីអត្តភាពនោះ ក៏បានទៅកើតក្នុងទេវលោក តែងអន្ទោលទៅមកក្នុងទេវតានិងមនុស្សយ៉ាងនេះ អស់សែនកប្បទាំងឡាយ ក្រោយមកក្នុងកប្បនេះក៏បានមកកើតក្នុងត្រកូលមួយក្នុងពារាណសី ជាអ្នកនាំនូវស្មៅដល់សុមនសេដ្ឋី ដើម្បីយកកម្រៃចិញ្ចឹមជីវិតដោយសារសេដ្ឋីនោះ ។ ដូច្នេះជនទាំងឡាយតែងហៅបុរសនោះថា **អន្នភារៈ** ។

ថ្លែងពីសុមនសេដ្ឋី តែងឱ្យនូវមហាទានអស់កាលជានិច្ចក្នុងនគរនោះ ។ គ្រាក្រោយមក មានព្រះបច្ចេកពុទ្ធមួយអង្គព្រះនាម **ឧបរិដ្ឋៈ** ទ្រង់ចេញពីនិរោធសមាបត្តិលើភ្នំគន្ធមាទន៍ហើយគិតថា "អញធ្វើនូវសេចក្តីអនុគ្រោះដល់អ្នកណា ហ្ន៎ក្នុងថ្ងៃនេះ" ។ លុះគិតដូច្នេះហើយក៏បានជ្រាបថា ក្នុងថ្ងៃនេះ អញគួរធ្វើសេចក្តីអនុគ្រោះ ដល់បុរសឈ្មោះអន្នភារៈ តែឥឡូវនេះ បុរសនោះ កំពុងកាន់យកនូវស្មៅអំពីព្រៃហើយនាំទៅកាន់ផ្ទះ ។ ព្រះបច្ចេកពុទ្ធអង្គនោះ លុះបានជ្រាបដូច្នេះហើយក៏កាន់យកនូវបាត្រនិងចីវរ ហើយហោះទៅដោយឫទ្ធិ ហើយស្ថិតនៅក្នុងទីចំពោះមុខបុរសនោះ ។ អន្នភារៈបុរសនោះ លុះបានឃើញព្រះបច្ចេកពុទ្ធហើយក៏ទូលសួរថា : លោកម្ចាស់ដ៏ចំរើន ចុះលោកម្ចាស់បាននូវភិក្ខាឬទេ ? ។ ព្រះបច្ចេកពុទ្ធឆ្លើយថា : អាត្មានឹងបានដូច្នេះ ។ គាត់ឮដូច្នេះហើយ ក៏ទម្លាក់ចោល

នូវបាច់ស្មៅ រួចពោលថា សូមលោកម្ចាស់បង្អង់សិន គាត់ក៏ទៅកាន់ផ្ទះដោយប្រញាប់ ទៅកាន់ផ្ទះហើយ ក៏សួរប្រពន្ធថា ម្នាលនាងដ៏ចំរើន ភត្តដែលនាងទុកដើម្បីអញមានខ្លះឬទេ ? ។ ប្រពន្ធឆ្លើយថា មាន! ។ គាត់ក៏ត្រឡប់ដោយប្រញាប់ទៅយកបាត្រពីព្រះបច្ចេកពុទ្ធ ហើយកាន់មកផ្ទះវិញដោយគិតថា កាលអញ ចង់ឱ្យទេយ្យធម៌ ក៏មិនមាន. កាលទេយ្យធម៌មាន អញក៏មិនបាននូវបដិគ្គាហក: ប៉ុន្តែក្នុងថ្ងៃនេះ អញបាននូវបដិគ្គាហក:ផងថែមទាំងមានទេយ្យធម៌ផង ។ នេះជាលាភដ៏ប្រសើររបស់អញណាស់តើ ។ រួចគាត់ក៏យកភត្តមកដាក់ក្នុងបាត្រ ហើយនាំទៅប្រគេនព្រះបច្ចេកពុទ្ធវិញ លុះប្រគេនហើយ ក៏ដឹកល់នូវសេចក្ដីប្រាថ្នាថា "ដោយទាននេះ សេចក្ដីទ័លក្រកុំមានដល់ខ្ញុំឡើយ ពាក្យថាគ្មានក៏កុំមានដល់ខ្ញុំ ក្នុងភពតូចនិងភពធំឡើយ" ។

ព្រះបច្ចេកពុទ្ធក៏ធ្វើអនុមោទនាថា "ម្នាលអ្នកមានបុណ្យច្រើនសេចក្ដីប្រាថ្នា ដែលអ្នកប្រាថ្នាហើយ ចូរសម្រេចយ៉ាង នេះចុះ" រួចនិមន្តចៀសចេញទៅ ។

ថ្លែងពីទេវតា ដែលនៅអាស្រ័យលើឆត្រសុមនសេដ្ឋីនោះបានពោលថា ឱ! ទានដែលបុរសនោះបានដឹកល់ហើយដល់ព្រះបច្ចេកពុទ្ធព្រះនាមឧបរិដ្ឋ ជាទានដ៏ប្រសើរក្រៃលែង ទេវតានោះបានឱ្យសាធុការពរ ៣ ដង ។

ក្នុងកាលនោះ សេដ្ឋីពោលនឹងទេវតាថា ម្នាលទេវតា អ្នកមើលឃើញខ្ញុំដែលឱ្យទានអស់កាលមានប៉ុន្មានប៉ុណ្ណោះទេឬ ? ទេវតាឆ្លើយថា ខ្ញុំមិនមែនឱ្យសាធុការពរព្រោះប្រារព្ធទានរបស់អ្នកទេ តែខ្ញុំជ្រះថ្លាក្នុងទានដែលបុរសនេះឱ្យ

ហើយដល់ព្រះបច្ចេកពុទ្ធ ទើបខ្ញុំឱ្យសាធុការពរ សេដ្ឋីនោះគិតថា "ឱ អស្ចារ្យណាស់តើ អញឱ្យទានអស់ច្រើនដល់ម៉្លោះ ក៏មិនអាចញ៉ាំងទេវតាឱ្យសាធុការពរដល់អញបាន ឯអន្នភារៈបុរសនោះរស់នៅដោយសារអញ ក៏អាចញ៉ាំងទេវតាឱ្យសាធុការពរដល់ខ្លួនដោយបិណ្ឌបាត្រតែមួយប៉ុណ្ណោះ" ។ បើដូច្នេះ អញនឹងទិញបិណ្ឌបាតយកអំពីបុរសនោះ រួចហើយក៏ហៅអន្នភារៈបុរសមកសួរ តើអ្នកឱ្យទានដូចម្ដេច ? ក្នុងថ្ងៃនេះ ? ។

អន្នភារៈឆ្លើយថា ខ្ញុំឱ្យបិណ្ឌបាត្រដល់ព្រះបច្ចេកពុទ្ធ សេដ្ឋីពោលថា បើដូច្នោះចូរអ្នកកាន់យកកហាបណៈនេះ ហើយឱ្យបិណ្ឌបាតនោះមកខ្ញុំ អន្នភារៈឆ្លើយថា លោកខ្ញុំមិនឱ្យបិណ្ឌបាតនោះទេ សេដ្ឋីចេះតែតម្លើងថ្លៃដល់ ១០០០កហាបណៈ តែអន្នភារៈនោះមិនព្រមឱ្យដល់សេដ្ឋីនោះឡើយ គ្រានោះសេដ្ឋីពោលទៅទៀតថា បើដូច្នោះអ្នកចូរកាន់យកកហាបនៈ ១០០០នេះ ហើយឱ្យចំណែកបុណ្យមកដល់ខ្ញុំ ។

អន្នភារៈឆ្លើយថា ចាំខ្ញុំប្រឹក្សាជាមួយព្រះបច្ចេកពុទ្ធ អង្គនោះសិន រួចហើយក៏និមន្តព្រះបច្ចេកពុទ្ធឱ្យត្រឡប់មកវិញ ហើយទូលសួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន សុមនសេដ្ឋីបានឱ្យកហាបណៈ ១០០០ ដល់ខ្ញុំ ហើយសុំចែកចំណែកបុណ្យអំពីខ្ញុំ តើគិតធ្វើដូចម្ដេច ? ។

គ្រានោះព្រះបច្ចេកពុទ្ធ នាំមកនូវសេចក្ដីឧបមាដល់បុរសនោះថា ម្នាលបណ្ឌិត ប្រទីបក្នុងផ្ទះមួយអាចឆេះក្នុងស្រុកដែលមានត្រកូល ១០០ បាន គឺថាជន

ឯទៀត ជនឯទៀតផ្សឹមដោយបញ្ចោះនិងប្រេងរបស់ខ្លួន ហើយទៅដុតបញ្ចោះនោះ ហើយយកពន្លឺអំពីប្រទីបមុន តើអ្នកគប្បីឆ្លើយថាបពិត្រលោកម្ចាស់ដ៏ចំរើន ពន្លឺនោះនឹងមានដ៏លើសលុបក្រៃលែង ។ អើម្នាលបណ្ឌិត បបរទោះមួយបោយក្តី ភិក្ខាទោះមួយវែកក្តី ឱ្យដល់ជនមានប៉ុន្មាននាក់ តែងចំរើនប៉ុណ្ណោះដល់ជនអ្នកឱ្យចំណែកបុណ្យក្នុងបិណ្ឌបាត្ររបស់ខ្លួនដល់អ្នកដទៃ មានឧបមាដូច្នោះដែរ ដ្បិតថា: អ្នកឱ្យបិណ្ឌបាតតែមួយទេ តែបិណ្ឌបាត្រមាន២គឺបិណ្ឌបាត្រមួយរបស់អ្នកបិណ្ឌបាត្រមួយរបស់សេដ្ឋី ដោយចំណែកបុណ្យដែលអ្នកឱ្យហើយដល់សេដ្ឋីនោះ ។ បុរសនោះពោលថា បពិត្រលោកម្ចាស់ប្រពៃហើយ លុះពោលហើយក៏ថ្វាយបង្គំព្រះបច្ចេកពុទ្ធ ត្រឡប់ទៅកាន់សំណាក់នៃសេដ្ឋីនោះវិញ លុះទៅដល់ក៏ពោលនឹងសេដ្ឋីថា បពិត្រលោកចៅហ្វាយអើយ សូមលោកកាន់យកនូវចំណែកបុណ្យអំពីខ្ញុំចុះ ។ សេដ្ឋីបានឱ្យកហាបណៈដល់បុរសនោះ តែបុរសនោះប្រកែកថា: ខ្ញុំមិនលក់ បិណ្ឌបាតនេះទេ ខ្ញុំនឹងជូនចំណែកបុណ្យដល់អ្នកដោយសទ្ធា ។ សេដ្ឋីតបថា អ្នកឱ្យ ចំណែកបុណ្យដល់ខ្ញុំដោយសទ្ធា ឯខ្ញុំក៏បូជាដល់អ្នកវិញ ម្នាលអ្នកដ៏ចំរើន ចូរកាន់យកនូវកហាបណៈនេះទៅចុះ ហើយចាប់ផ្តើមអំពីថ្ងៃនេះតទៅ អ្នកឈប់ធ្វើការដោយដៃឯង ចូរអ្នកកសាងផ្ទះមួយនៅក្បែរថ្នល់ ហើយនៅជាសុខក្នុងផ្ទះនោះចុះ ។ បើអ្នកត្រូវការដោយវត្ថុណាចូរកាន់យកនូវវត្ថុនោះអំពីខ្ញុំតែថាបិណ្ឌបាតដែលបុរសនោះឱ្យហើយ ចំពោះព្រះបច្ចេកពុទ្ធដែល

ទើបនឹងចេញអំពីនិរោធ ក៏បាននិ្យនូវវិបាកក្នុងថ្ងៃនោះភ្លាម ព្រោះហេតុនោះ សូម្បីព្រះរាជាឮដំណឹង នោះហើយក៏ទ្រង់ប្រទានដំណែងជាសេដ្ឋីដល់បុរសនោះ ។

ឯអន្នភារៈ បុរសនោះបានជាសម្លាញ់នៃសុមនសេដ្ឋីតែងធ្វើនូវបុណ្យទាំងឡាយ ដរាបដល់អស់ជីវិត លុះច្យុតចាកអំពីអត្តភាពនោះបានទៅកើតក្នុងទេវលោក តែងអន្ទោលទៅមកក្នុងទេវលោកនិងមនុស្សលោក ។ ក្នុងពុទ្ធុប្បាទនេះ ក៏មកចាប់បដិសន្ធិក្នុងផ្ទះនៃសក្យឈ្មោះអមិតោ្តទនៈ ក្នុងនគរឈ្មោះកបិលព័ស្តុ ។ ជនទាំងឡាយឱ្យឈ្មោះថា អនុរុទ្ធ ។ អនុរុទ្ធនោះ ត្រូវជាបងប្អូននៃព្រះសក្យមហានាម នឹងត្រូវជាកូននៃចុល្លបិតារបស់ព្រះសាស្តាយើងហើយ ជាបុគ្គលមានសុខុមាលភាពនិងមានបុណ្យច្រើន ។

**ចប់គំរោគ៏តបុណ្យប្រទីបតែប៉ុណ្ណោះ**

## វិធីឆ្លងបុណ្យ

ពាក្យថាឆ្លងបុណ្យនេះ ហៅផ្ទុយទៅវិញ បើតាមការពិត គេធ្វើសាលា វិហារ ដល់ធ្វើរួចគេធ្វើបុណ្យបង្ហើយ តាមពាក្យអ្នកស្រុកហៅថាឆ្លងបុណ្យៗ នេះមានតាំងពីជំនាន់ដើមមក ជំនាន់ព្រះពុទ្ធទ្រង់ព្រះនាមកស្សបៈ មានសុមនសេដ្ឋី ជាអ្នកបានកសាងវិហារពីរលើក ហើយឆ្លងទាំងពីរលើក ឧទាហរណ៍ដូចមាន រឿងតទៅនេះ :

កស្សបពុទ្ធកាលេ កិរ សុមង្គលសេដ្ឋី នាម សុវណ្ណិដ្ឋិកាហិ ភូមិយំ បត្ថរិត្វា ។ បេ ។ វិបាកាវសេសេន ឥទានិ គិជ្ឈកូដបព្វតេ អជគរបេតោ ហុត្វា បច្ចតីតិ ។

តាមដំណើរបានព្ធមកថា នៅក្នុងកស្សបពុទ្ធកាល មានសេដ្ឋីម្នាក់ ឈ្មោះ សុមង្គលៈ បានរៀបក្រាលឥដ្ឋមាសលើផ្ទៃផែនដី ក្នុងទំហំ ២០ ឧសភៈ ចំណាយទ្រព្យចំនួនប៉ុណ្ណឹងទៀតកសាងព្រះវិហារ រួចធ្វើបុណ្យឆ្លងវិហារនោះ អស់ទ្រព្យចំនួនប៉ុណ្ណោះទៀត ។ ថ្ងៃមួយសេដ្ឋីដើរទៅគាល់ព្រះសាស្តាពីពេលព្រលឹម ឃើញចោរម្នាក់ដើរប្រឡាក់ភក់ស្រមក ដេកទទូរក្បាលលើសាលាមួយក្បែរនគរ ក៏ថាឱ្យវាថា "គាត់នេះជើងភក់ស្រមក បែបរវល់ដើរយប់ ទើបតែមកដេក" ។ ចោរបើកមុខឡើងក្រឡេកមើលសេដ្ឋី ក៏គិតបំផ្ចិចបំផ្លាញ បានលួចដុតស្រែអស់ ៧ ដង លួចកាត់ជើងគោក្នុងក្រោលអស់ ៧ ដង លួចដុតផ្ទះអស់ ៧ ដង ។

មិនតែប៉ុណ្ណោះ នៅមិនអស់កំហឹងវាទៀត វាស៊ើបដឹងថាសេដ្ឋីស្រឡាញ់គន្ធកុដិជាបណ្ដាច់បណ្ដូលចិត្ត ក្នុងកាលព្រះសាស្ដាស្ដេចយាងទៅទ្រង់បាត្រ វាវាយបំបែកពាងសម្រាប់ដាក់ទឹកឆាន់ប្រើប្រាស់ ហើយដុតបំផ្លាញនូវគន្ធកុដិ ។ សេដ្ឋីមកឃើញញញឹមពព្រាយសប្បាយចិត្តទះដៃសើច ។ ជនទាំងអស់ដែលនៅឈរជិតខាងនឹកឆ្ងល់ណាស់សួរចំពោះសេដ្ឋី១ អធិប្បាយថា ខ្ញុំបានធ្វើបុណ្យទាំងប៉ុណ្ណេះឈ្មោះថាកប់ទ្រព្យទុកក្នុងព្រះពុទ្ធសាសនា មិនមែនអន្តរាយមានភ្លើងជាដើមដណ្ដើមយកបានទេ ឥឡូវជាភព្វសំណាងបានកសាងម្ដងទៀតហើយ ។ កាលសេដ្ឋីសាងគន្ធកុដិជាថ្មីរួចហើយ ថ្វាយទានដល់ព្រះសាស្ដា ព្រមទាំងភិក្ខុជាបរិវារ ២ ហ្មឺនអង្គចំនួន ៧ ថ្ងៃ ។ ចោរនោះស្ទៀតកាំបិតស្ទៀតនៅចង្កេះ ដើរចុះឡើងក្នុងវត្តរកឱកាសសម្លាប់សេដ្ឋីនោះពុំបាន ។ លុះដល់ថ្ងៃទី ៧ សេដ្ឋីថ្វាយទានរួចហើយចូលទៅថ្វាយបង្គំព្រះជាគ្រូ ពោលពាក្យថា "បពិត្រព្រះអង្គដ៏ចម្រើន! ខ្ញុំព្រះអង្គសូមឧទ្ទិសនូវចំណែកបុណ្យជាប្រថមក្នុងទាននេះ ដល់ចោរដែលបំផ្លិចបំផ្លាញនោះ" ។

ចោរឮដូច្នោះភិតភ័យតក្កមា ដឹងច្បាស់ថាខ្លួនខុសធ្ងន់ លូនក្រាបទៀបបាទមូលសេដ្ឋី សូមខមាទោសខុសកន្លងគ្រប់យ៉ាង ហើយសូមប្រគល់ខ្លួនទាំងកូនទាំងប្រពន្ធធ្វើជាខ្ញុំបម្រើក្នុងផ្ទះ ។ តែសេដ្ឋីបដិសេធ ពុំព្រមទទួលយកជាខ្ញុំកំដរឡើយ ។ ឯចោរនោះលុះក្ស័យជីវិតទៅកើតក្នុងអវីចិមហានរកអស់កាលជាអង្វែង

ដោយនូវសេសសល់វិបាក ទើបបានមកកើតជាអជគរប្រេតរងទុក្ខនៅលើកំពូលភ្នំគិជ្ឈកូដ ក្នុងគ្រានោះឯង ។

រឿងនេះគួរយកជាគតិបាន ។

ក្នុងសាសនារបស់ព្រះពុទ្ធទ្រង់ព្រះនាមគោតម មាននាងវិសាខាបានកសាងវិហារបុព្វារាម រួចហើយនាងបានថ្វាយទានដល់ព្រះភិក្ខុសង្ឃក្នុងវត្តអស់ ៤ ខែ ក្នុងថ្ងៃទីបំផុតនាងថ្វាយនូវចីវរសាដកដល់ភិក្ខុសង្ឃថែមទៀត រួចហើយនាងបានប្រគេនភេសជ្ជៈ ១ បាត្រ១ រាល់១អង្គ ។ ក្នុងការបរិច្ចាគទាននេះចំណាយទ្រព្យអស់ ៩ កោដិ ថ្លៃដីដែលនាងទិញអស់ ៩ កោដិ. កសាងកុដិសាលាអស់ ៩ កោដិ ធ្វើបុណ្យឆ្លង អស់ ៩កោដិ ។ នេះសឱ្យឃើញភស្ដុតាងថា ក្នុងសម័យពុទ្ធកាលក៏មានធ្វើបុណ្យឆ្លង ដូចជារឿងនាងវិសាខាជាដើម ។

**បុ**- ជំនាន់ដើមមានសាស្ត្រាបុរាណមួយច្បាប់ ហៅថាសាស្ត្រាចម្លងបុណ្យមានសេចក្ដីថា អ្នកណាដាំដើមពោធិ ហើយមិនបានឆ្លង ស្លាប់ទៅ១កើតជារាជសីសុីនៅក្រោមដើមពោធិ បើអ្នកជីកស្រះជីកអណ្ដូងមិនបានឆ្លង ស្លាប់ទៅទីណារកទឹកផឹកគ្មាន រឿងនេះពិតឬមិនពិត ?

**វិ**- រឿងនេះមិនពិតទេ បានជាមិនពិតនោះ គឺមិនសមហេតុ-ផល ព្រោះបុណ្យកើតដោយចេតនា ៣ យ៉ាងគឺ :

១- បុព្វចេតនា គ្រេកអរជ្រះថ្លាមុនពេលនឹងឱ្យ .

២- មុញ្ចនចេតនា ឱ្យរួចហើយត្រេកអរជាខាងក្រោយ .

៣- អបរាបរចេតនា ឱ្យហើយនឹកឡើងថ្ងៃក្រោយត្រេកអរ ។

**ឬ-** មិនដូច្នោះទេ ហេតុអ្វីក៏ចាំបាច់ឆ្លង ?

**វិ-** បានជាធ្វើហើយឆ្លង ទៀតនោះ ដើម្បីបន្ថែមកុសលឱ្យរឹងរឹតតែចុំរើន ឡើង ដូចពុទ្ធភាសិតសំដែងថា :

បុញ្ញញ្ចេ បុរិសោ កយិរា កយិរាថេនំ បុនប្បុនំ

តម្ហិ ឆន្ទំ កយិរាថ សុខោ បុញ្ញស្ស ឧច្ចយោ ។

បើបុគ្គលធ្វើនូវបុណ្យ គប្បីធ្វើនូវបុណ្យនោះឱ្យរឿយៗ គប្បីធ្វើនូវសេចក្តីពេញចិត្តក្នុងបុណ្យនោះថែមទៀត ការសន្សំនូវបុណ្យទើបបានសេចក្តីសុខ ។

បានជាគេធ្វើបុណ្យឱ្យរឿយៗនេះ ដើម្បីឱ្យបានបុណ្យនោះញឹកៗ កុំឱ្យបាបមានឱកាសចូលមកជ្រៀតជ្រែកបាន ។

**ឬ-** ឆ្លងបុណ្យហេតុអ្វីបានជាព្រះសង្ឃសូត្រធមិពហូទេវា ?

**វិ-** បានជាសូត្រធមិពហូទេវា ព្រោះធមិនេះសំដែងអំពីមង្គលទាំង៣៨ ប្រការ ដល់មនុស្សទេវតា ដើម្បីនឹងប្រព្រឹត្តទៅ ។

**ឬ-** ចុះដែលគេដាក់ទឹកផ្តិលបិតទៀន ៤ នោះ តើដើម្បីប្រយោជន៍អ្វី ?

វិ- ទឹកផ្ដិលនិងទៀន ៤ នោះ តាមលទ្ធិអាចារ្យខ្លះ ថាទឹកទុកដូចអន្លង់ (ឱឃៈ) [១] ទៀន ៤ ទុកដូចជាធាតុទាំង៤ [១] សេចក្ដី យល់ដូច្នេះ ក៏សមណាស់ដែរ ដូចក្នុងអសីវិសូបមសូត្រសំដែងថា :

មានសេចក្ដីដំណាលថា: មានបុរសម្នាក់ចិញ្ចឹមសត្វពស់ ៤ ពស់មួយចឹកមានពិសរីងខ្លួន, មួយចឹកទៅមានពិសហើមខ្លួន, មួយចឹកទៅមានពិសក្រហល់ក្រហាយ, មួយទៀតចឹកទៅមានពិសដូចជាកាំបិតកោរចូលទៅកាត់ពោះវៀនខាងក្នុង ។ មានបុរសម្នាក់ដើរទៅឃើញ គេស្គាល់ច្បាស់ថាជាពស់មានពិសគេប្រាប់ថា : អ្នកឯងម្ដេចក៏ចិញ្ចឹមពស់មានពិសអញ្ចឹង ! តិចចឹកស្លាប់ បុរសនោះស្ដាប់ឮហើយក៏ភិតភ័យខ្សំរត់ ។ ខណៈនោះនោះពស់ទាំង ៤ ក៏ដេញប្រកិតតាមក្រោយ ។

តពីនោះទៅក៏បានជួបនឹងពួកចោរ ៥ នាក់ លើកដាវងាវបំរុងនឹងប្រហារបុរសនោះគេចពីនោះចូលទៅក្នុងព្រៃ ក៏ជួបនឹងចោរម្នាក់ក្នុងទីដ៏ស្ងាត់បំរុងនឹងសម្លាប់ទៀត ។ លុះចេញផុតពីព្រៃទៅឃើញមានភូមិចាស់មួយ ដែលម្ចាស់គេបោះបង់ចោល បុរសនោះក៏បានទៅស្នាក់អាស្រ័យក្នុងភូមិនោះ ស្រាប់តែមានចោរ ៥០០ មកចោមរោម បុរសនោះឯងក៏គេៀសខ្លួនចេញពីទីនោះទៅទៀត បានឃើញអន្លង់ទាំង៤ គន់មើលទៅត្រើយម្ខាងឃើញមានផ្សារ បុរសនោះគិតថា "បើអាត្មាអញឆ្លងផុតទៅត្រើយម្ខាងនឹងផុតពីអន្តរាយ" គិតស្រេចហើយខំរកឬស្សីវល្លិ៍មក

(១) កាមោឃោ. ភវោឃោ. អវិជ្ជោឃោ. ទិដ្ឋោឃោ ។ (២) ដី. ទឹក. ភ្លើង. ខ្យល់ ។

ចងធ្វើជាក្បូន រួចយកដៃទាំងពីរជើងពីរធ្វើជាជើងចែវ ប្រឹងប្រវែប្រវាទាល់តែដល់ត្រើយម្ខាង រួចអំពីអន្តរាយ ។

រឿងនេះសឱ្យឃើញច្បាស់ថា :

បុរសនោះគឺព្រះយោគាវចរ ដែលបានចំរើននូវវិបស្សនាកម្មដ្ឋាន សត្វទាំង ៤ គឺពស់ទី ១ បានដល់ធាតុដី, ពស់ទី ២ បានដល់ធាតុទឹក, ពស់ទី ៣ បានដល់ធាតុភ្លើង, រីឯពស់ទី ៤ បានដល់ធាតុខ្យល់ ។ ចំណែកខាងបុរសដែលប្រាប់ផ្លូវបានដល់ព្រះសម្មាសម្ពុទ្ធ . ពួកចោរទាំង ៥ នាក់ បានដល់ខន្ធ ៥, ចោរក្នុងទីស្ងាត់បានដល់នន្ទិរាគ, ភូមិចាស់បានដល់អាយតនៈខាងក្នុង ចោរទាំង ៥០០ នាក់ បានដល់អាយតនៈខាងក្រៅ, អន្លង់បានដល់អន្លង់ទាំង ៤, ក្បូនគឺអដ្ឋង្គិកមគ្គ, ដៃ ២ ជើង ២ បានដល់សម្មប្បធាន ៤, ផ្សារគឺ ព្រះនិញ្វន, (បុរសដែលបានដល់ផ្សារ គឺព្រះខីណាស្រព) ។

**ចប់រឿងខ្លួនបុណ្យរ៉ែតប៉ុះណ្ណះ**

## កំណើតឧបាសករក្សាសីល១០

សីល១០នេះហៅថា និយមសីល សីលនេះបើឧបាសក-សិកាកំណត់រក្សាប៉ុន្មានខែ អស់ត្រឹមកាលប៉ុណ្ណោះ បានជាហៅថានិយមសីល ។

សីល១០នេះក្នុងកាលព្រះពុទ្ធទ្រង់ព្រះនាម បុស្សៈ គឺព្រះរាជ បុត្រ ៣ ព្រះអង្គបានរក្សា ។

ក្នុងកាលនៃព្រះពុទ្ធទ្រង់ព្រះនាម កស្សបៈ គឺស្នូនឆ្នាំងឈ្មោះ ឃដិការៈ បានរក្សា ។

ក្នុងកាលនៃព្រះពុទ្ធទ្រង់ព្រះនាមសមណគោត្តម គឺអនុបុព្វសេដ្ឋីបុត្ត បានរក្សា ។

បុ- ចូរនាំរឿងអនុបុព្វសេដ្ឋីបុត្តមានសេចក្ដីដំណាលដូចម្ដេច ?

វិ- សត្ថរិ កិរ សាវត្ថិយំ វិហរន្តេ ឯកោ សេដ្ឋីបុត្តោ ។ល។ អនុបុព្វសេដ្ឋីបុត្តោ នាម ជាតោ ។

កាលព្រះសាស្តា ទ្រង់គង់នៅក្នុងក្រុងសាវត្ថី មានសេដ្ឋីបុត្រម្នាក់ចូលទៅរកព្រះថេរៈជាជីតុនរបស់ខ្លួន និយាយសំណេះសំណាលថា លោកម្ចាស់! ខ្ញុំព្រះករុណាចង់រួចចាកសេចក្ដីទុក្ខ សូមលោកម្ចាស់សំដែងប្រាប់នូវធម៌ជាគ្រឿងរួចចាកសេចក្ដីទុក្ខ សូមលោកម្ចាស់សំដែងប្រាប់នូវធម៌ជាគ្រឿងរួចចាកទុក្ខ ដល់ខ្ញុំព្រះករុណា ។ ព្រះថេរៈឆ្លើយថា ល្អហើយ! បើអ្នកចង់រួចចាកសេចក្ដីទុក្ខ

ចូរអ្នកឱ្យនូវសលាកភត្ត, បក្ខិកភត្ត, វស្សាវាសិកសាដក និងបច្ច័យ ៤ មានចីវរប្បច្ច័យជាដើម ហើយចែកនូវសម្បត្តិរបស់ខ្លួនជា ៣ ចំណែកគឺ មួយចំណែកសំរាប់ប្រកបការងារ, មួយចំណែកសម្រាប់ចិញ្ចឹមប្រពន្ធកូន, មួយចំណែកសំរាប់សម្រាប់កប់ទុកក្នុងព្រះពុទ្ធសាសនា ។ ឯសេដ្ឋីបុត្តនោះ ក៏បានប្រតិបត្តិតាមសព្វគ្រប់រួចហើយ សួរតទៅទៀតថា លោកម្ចាស់ ! បន្ទាប់អំពីនេះទៅ ខ្ញុំព្រះករុណាត្រូវធ្វើអ្វីតទៅទៀត ? ព្រះថេរ ឆ្លើយប្រាប់ថា ចូរអ្នកកាន់យកព្រះត្រៃសរណគមន៍ ៣ រក្សា សីល ៥ សីល ៨ តទៅ ។ សេដ្ឋីបុត្តរក្សាហើយសួរថា ខ្ញុំព្រះករុណាត្រូវធ្វើដូចម្តេច ? ព្រះថេរឆ្លើយថា **តេនហិ ទស សីលានិ គណ្ហាហិ** បើដូច្នោះ ចូរអ្នករក្សាសីល ១០ តទៅទៀត ។ សេដ្ឋី បុត្រនោះបានប្រតិបត្តិតាមបង្គាប់ព្រះថេរៈដោយសព្វគ្រប់តាំងពីពេលនោះមក **សោឯវំ អនុបុព្វេន បុញ្ញកម្មស្ស កតត្តា អនុបុព្វសេដ្ឋីបុត្តោនាម ជាតោ** សេដ្ឋីបុត្រនោះ បានឈ្មោះថា អនុបុព្វសេដ្ឋីបុត្ត ព្រោះគាត់ធ្វើនូវបុណ្យតាមលំដាប់យ៉ាងនេះឯង ។

(គម្ពីរធម្មបទដ្ឋកថា ភាគ២ ទំព័រ ២១៣)

**ប**- សីល ១០ របស់សាមណេរ និងសីល ១០ របស់ឧបាសក ឧបាសិកា មានកិច្ចរក្សាផ្សេង គ្នាដូចម្តេច?

**វ**- មានកិច្ចរក្សាដូចគ្នាខ្លះ ផ្សេងគ្នាខ្លះ ។

បុ- ដែលដូចគ្នានោះដូចម្ដេច ? ផ្សេងគ្នានោះដូចម្ដេច ?

វិ- ផ្សេងគ្នានោះគឺ សាមណេរមានទាសនង្គៈ ទណ្ឌកម្ម និង សេក្ខិយវត្ត. ឧបាសក-ឧបាសិកាមានកិច្ចធុតង្គ ២ គឺ បិណ្ឌបាតិកង្គធុតង្គ ១ អរញ្ញិកង្គធុតង្គ ១ ។ ដូចគ្នានោះគឺ សិក្ខាបទ ១០ រក្សាដូចគ្នា និងវៀរដូចគ្នា ។

បុ- វិធីសុំសីល ១០ នៃសាមណេរ និងឧបាសកឧបាសិកាផ្សេងគ្នា ឬដូចគ្នា ?

វិ- វិធីសុំសីល១០ ផ្សេងគ្នាខ្លះ ដូចគ្នាខ្លះ ។

បុ- ផ្សេងគ្នានោះដូចម្ដេច ? ដូចគ្នានោះដូចម្ដេច ?

វិ- ចំណែកសាមណេរសុំបានតែពីសំណាក់ឧបជ្ឈាយ៍ ឬអាចារ្យដែលជាបព្វជ្ជាចារ្យឈ្លាសប្រតិពលក្នុងអក្ខរវិធី ហៅថាឧភតោសុទ្ធិចំណែកខាងឧបាសក - ឧបាសិកា សុំពីភិក្ខុឬសាមណេរ ឬក៏ឧបាសក ឧបាសិកាដែលបានសមាទានមុននេះចំពោះតែមុនដំបូង ។

**ចប់គំរូឧបាសកក្សាសីល១០តែប៉ុណ្ណេះ**

## កំណើតមហាបង្សុកូល

បុ- មហាបង្សុកូលនេះមានមកពីត្រឹមណាមក ? លោកណាបង្សុកូលមុនគេ ?

វិ- មហាបង្សុកូលនេះមានតាំងពីជំនាន់ព្រះគង់ធរមាននៅឡើយ គឺតួព្រះអង្គឯង បង្សុកូលនាងបុណ្ណទាសី ដូចមានរឿងតទៅនេះ :

សេចក្ដីថា នាងបុណ្ណទាសីជាខ្ញុំបម្រើអនាថបិណ្ឌិកសេដ្ឋី នាងនោះមានសេចក្ដីរិះគិតថា ដល់ស្លាប់ទៅគេនឹងយកខ្លួនទៅចោលដោយគ្មានសំពត់រុំ គេនឹងឃើញកេរ្តិ៍ខ្មាស ហើយក៏ត្បាញសំពត់បម្រុងទុក ហើយផ្ដាំគេថា បើខ្ញុំស្លាប់ទៅឱ្យយកសំពត់នេះរុំខ្ញុំ ។ នៅពេលដែលមានជំងឺស្លាប់ អនាថបិណ្ឌិកសេដ្ឋីក៏យកសំពត់ដទៃទៀតរុំ អ្នកដែលទទួលបណ្ដាំនាងបុណ្ណទាសីប្រាប់ថា នាងបានត្បាញសំពត់បំរុងទុកហើយ សេដ្ឋីក៏យកសំពត់នាងនោះរុំទៅ ហើយក៏យកទៅចោលក្នុងទីឆាំឆា ។ រឿងនេះជ្រាបទៅដល់ព្រះបរមគ្រូ ព្រះអង្គយាងមកបង្សុកូលក្នុងថ្ងៃទី ៧ គិតតាំងពីថ្ងៃដែលនាងស្លាប់ ព្រះអង្គយកសំពត់ស្អុយទៅលាងទឹកគ្រាន់តែជង្គង់ចំនួន ៤ តុំ ។ ខណៈនោះព្រះឥន្ទចុះមកនិម្មិតថ្ម ១ ដុំឱ្យព្រះអង្គគង់លើ លុះលាងរួចហើយ ព្រះឥន្ទ្រក៏និម្មិតជាមែកឈើទៀតដើម្បីឱ្យព្រះអង្គហាល លុះហាលរួចហើយក៏យកមកកាត់ជាចីពរ ហើយយកទៅប្ដូរនឹងព្រះមហាកស្សបៈ គ្រាន់តែរឿងប៉ុណ្ណេះក៏ញាប់ញ័រផែនដីតាំងមូល ។ ក្នុងកាលព្រះសមណគោតមមានតែម្ដងនេះទេ មិនមានតែរាល់បុណ្យទេ ។ ដោយ

មានរឿងដូច្នេះហើយ បានជាអ្នកស្រុកនិយមរាប់អានមហាបង្សុកូលនេះណាស់ ព្រោះបានបុណ្យច្រើនជាងបុណ្យទាំងអស់ ប៉ុន្តែបានបុណ្យច្រើន ចំពោះតែជំនាន់ព្រះទេ ។ ធ្វើជំនាន់ក្រោយនេះ មិនត្រូវតាមមហាបង្សុកូលឡើយ ។

## កំណើតមហាបង្សុកូលចប់តែប៉ុណ្ណេះ

## កំណើតឈាបនកិច្ច

**ឬ**- កិច្ចបូជាសពនេះកើតពីត្រឹមណាមក?

**វិ**- កិច្ចបូជាសពនេះមិនមែនទើបនឹងមានទេ គឺមានតាំងពីអតីត កាលមក ដូចមាននិទានតទៅនេះ :

ជាតកជន ៥៥ នាក់មាន ព្រះយសកុលបុត្តជាប្រមុខ

យសកុលបុត្តប្បមុខា បញ្ចបញ្ញាស ជនា កឹ កម្មំ ករឹសុ ភន្តេ ។បេ។ នាហំ មុខំ ឱលោកេត្វា ភិក្ខូនំ ទម្មីតិ ។

ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ចុះជនទាំងឡាយ ៥៥ នាក់ មានយសកុលបុត្តជាដើម តើបានធ្វើនូវកម្មដូចម្ដេចខ្លះ? ទើបព្រះជាគ្រូទ្រង់ដំណាលរៀបរាប់ថា ជនទាំងឡាយនោះ ធ្លាប់បានធ្វើបុញ្ញកម្មច្រើនប្រការផ្សេង ចិត្តប្រាថ្នាយកព្រះអរហត្តក្នុងសំណាក់នៃព្រះពុទ្ធមួយអង្គដែរ ដល់ចំណេរចិរកាល មកខាងក្រោយជាកាលលង្វែកព្រះពុទ្ធ បានជាសំឡាញ់នឹងគ្នាជាប់បក្សពួកជាមួយគ្នា តែងនាំគ្នាខំធ្វើបុណ្យយកចិត្តទុកដាក់ទំនុកបំរុងសរីរៈ ស្លាប់នៃមនុស្សអនាថា។ មានកាលមួយថ្ងៃ ពួកជនទាំងនោះបានឃើញស្ត្រីមានគភ៌ ធ្វើកាលកិរិយានាំគ្នាយកទៅព្រៃស្មសាន ហើយចាត់ចែងគ្នា ៥ នាក់ឱ្យទៅធ្វើឈាបនកិច្ច ជនក្រៅពីនោះវិលទៅស្រុកវិញ ។ រីឯយសទារកកាលយកឈើស្ទូលរុកចាក់ប្រមៀលសរីរៈនោះ ដុតបានកើតអសុភសញ្ញា ហើយនិយាយពន្យល់ដល់ជនទាំង ៤

នាក់ថា គ្នាយើង អើយ! អ្នកគួរនាំគ្នាមើលពិចារណាសរីរៈនេះរបករបាចស្បែក ដូចគោព្រាលជា របស់អាសោចិ៍ ក្លិនស្អុយខ្មោះខ្មួលអាក្រក់អាក្រី គួរកើតបដិកូល ។ គ្រាកាលជនទាំង ៥ នាក់ ត្រឡប់ទៅស្រុកវិញ បានដំណាលប្រាប់សំឡាញ់ទាំងឡាយអស់អាថ៌សេចក្ដី ។ ឯយសទារកទៅដល់ផ្ទះបានអធិប្បាយប្រាយប្រាប់មាតាបិតានិងភរិយា ។ ក៏បានចំរើនអសុភសញ្ញាគ្រប់ៗគ្នារៀងទៅ ។ នេះហើយជាបុព្វកម្មរបស់ជនទាំងនោះ។ ចំណែកយសទារក បានកើតអសុភសញ្ញាតាំងពីតូចមក តែងសំគាល់នូវផ្ទះ របស់ខ្លួនថាជាព្រៃស្មសាន ។ ឧបនិស្ស័យនេះហើយនាំឱ្យជនអស់ហ្នឹងបានត្រាស់ដឹង នូវគុណវិសេសបានសមតាមបំណង ដែលគេផ្ដងទុកមកយ៉ាងនេះឯង ។ តថាគតមិនឱ្យដោយយល់មុខទេ ។

បុ- ឈាបនកិច្ចនេះប្រកបដោយអង្គប៉ុន្មាន ទើបបានបុណ្យច្រើន ?

វិ- ឈាបនកិច្ចនេះប្រកបដោយអង្គ ៣ គឺ :

១- សតិ មានសេចក្ដីរឭក .

២- ញាណ មានបញ្ញាពិចារណា .

៣- សង្វេគ មានសេចក្ដីតក់ស្លុត ។

ឈាបនកិច្ចលុះតែប្រកបដោយអង្គ ៣ នេះ ទើបបានបុណ្យច្រើនដូចមានរឿងខាងដើមស្រាប់ ។

**ចប់គំរូគតិឈាបនកិច្ចដោយសង្ខេប**

# កំណើតបុណ្យទេសនាមហាជាតក៍

ក្នុងមាលេយ្យសូត្រ មានសេចក្ដីថា ព្រះមាលេយ្យត្ថេរ មាននិមន្តទៅស្ថានត្រៃត្រឹង្ស ដើម្បីថ្វាយបង្គំព្រះចូឡាមណីចេតិយ បានជួបព្រះមេត្តេយ្យពោធិសត្វ ដែលបានកើតជា សន្តុសិតទេវបុត្រ ជាទេវរាជក្នុងឋានតុសិត បានយាងមកឋានត្រៃត្រឹង្ស ដើម្បីថ្វាយបង្គំចូឡាមណីចេតិយដែរ ហើយបានសំណេះសំណាលជាមួយគ្នាសន្តុសិតទេវបុត្របានផ្ដាំថា បើពួកជនណាចង់ជួបនឹងខ្ញុំព្រះករុណា ក្នុងពេលខ្ញុំព្រះករុណាបានត្រាស់ជាព្រះពុទ្ធ ទ្រង់ព្រះនាមស្រីអារ្យមេត្រីយ៍ ពួកជននោះចូរឧស្សាហ៍ស្ដាប់រឿងមហាជាតក៍ បានជាជាប់មានទេសនាមហាជាតក៍ដល់សព្វថ្ងៃនេះ ។

មួយទៀត រឿងជាតកនេះ ជាតួអង្គសាសនាតាមទំនៀមខ្លះគេធ្វើបុណ្យទេសន៍ទសជាតក៍ទាំង ១០ ជាតក៍ ដើម្បីដឹងគោលសាសនា ។ គេកសាងជាព្រះពុទ្ធនោះ លុះតែពេញដោយបារមីទាំង១០ គ្រប់គ្រាន់ទើបបានត្រាស់ដឹងជាព្រះពុទ្ធ ហើយអ្នកស្ដាប់ទៀតដើម្បីឱ្យដឹងចរិយាព្រះកសាងផង ។

ចប់បុណ្យទេសន៍មហាជាតក៍ដោយសង្ខេប

## កំណើតព្រះពុទ្ធរូប

ក្នុងសៀវភៅជំណាលពុទ្ធចេតិយ មានសេចក្ដីថា ក្នុងកាលពុទ្ធសករាជកន្លងទៅបាន ៤០០ ឆ្នាំ មានស្ដេចមួយអង្គព្រះនាមនិស្កៈ ជាតិក្រិក នៅក្នុងប្រទេសឥណ្ឌា បានប្រឹក្សាជាមួយរាជបណ្ឌិត នាម អស្សឃោសៈ ហើយបានកសាងព្រះពុទ្ធរូបឡើង ស្ដេចនិស្កៈនេះ ពីដើមកាន់សាសនាព្រាហ្មណ៍ យកទេវរូបគឺរូបព្រះឥសូរមកតាំងទុកនមស្សការថ្វាយបង្គំ ដល់មកជ្រះថ្លាក្នុងព្រះពុទ្ធសាសនា មកគិតឃើញថា ប៉ុនគេកាន់សាសនាព្រាហ្មណ៍ម៉េចគេយកទេវរូបមកនមស្សការ ចំណង់បើយើងកាន់ព្រះពុទ្ធសាសនា គួរតែធ្វើរូបព្រះពុទ្ធជាជំណាង ដើម្បីភស្ដុតាងដល់ចិត្ត ហើយកសាងព្រះពុទ្ធរូបនេះឡើង ព្រះពុទ្ធរូបនេះ មិនមែនជាពុទ្ធានុញ្ញាតទេ កើតឡើងដោយនិស្កៈជាតិក្រិកទេ ។

**បុ-** ព្រះពុទ្ធមានអនុញ្ញាតកន្លែងណាខ្លះ ដើម្បីឱ្យពុទ្ធបរិស័ទទុកជាទីរលឹក ?

**វិ-** ព្រះអង្គទ្រង់អនុញ្ញាតសង្វេគនីយដ្ឋាន ៤ កន្លែង គឺ :

១- ព្រៃលុម្ពិនីវ័ន កន្លែងដែលព្រះទ្រង់ប្រសូត.

២- ក្រោមដើមពោធិព្រឹក្ស កន្លែងដែលព្រះអង្គបានត្រាស់ .

៣- ព្រៃឥសិបតនមិគទាយវ័ន កន្លែងដែលព្រះអង្គទ្រង់សំដែង ធម្មចក្កប្បវត្តនសូត្រ ប្រោសពួកបញ្ចវគ្គិយ៍ .

៤- ក្រោមដើមរាំងទាំងគូ កន្លែងដែលព្រះអង្គបរិនិព្វាន ។

កន្លែងទាំង ៤ នេះ ដើម្បីឱ្យពុទ្ធបរិស័ទកើតសេចក្ដីជ្រះថ្លានិងសង្វេគ ។

**ឬ**- ចុះបុណ្យអភិសេកព្រះនេះ កើតពីត្រឹមណាមក ?

**វិ**- បុណ្យអភិសេកព្រះនេះ កើតតៗគ្នាមកតាមលិទ្ធិអាចារ្យ និង ជាងរចនា ។

## កំណើតព្រះពុទ្ធរូប

ប្រទេសកម្ពុជាមានព្រះពុទ្ធរូប ៨ បែបគឺ :

១-ព្រះពុទ្ធរូបសមាធិ គង់មានព្រះភ្នែន មានព្រះហស្តស្តាំផ្ងារលើព្រះហស្តឆ្វេង តម្រួតលើព្រះភ្នែន ហៅថា វិតក្កមុទ្រា ។

២- ព្រះពុទ្ធរូបមារវិជ័យ ( កាលផ្ចាញ់មារ ) គង់ពត់ព្រះភ្នែនដូចព្រះពុទ្ធរូបសមាធិដែរ ប៉ុន្តែព្រះហស្តស្តាំផ្កាប់លើព្រះឧរុ ( ភ្លៅ ) ចង្អុលចុះទៅផែនដី ព្រះហស្តឆ្វេងផ្ងាចាក់លើព្រះឧរុ ហៅថា ភូមិស្បសមុទ្រា ។ ព្រះពុទ្ធរូបបែបនេះកាលបើគេគូរនៅជញ្ជាំងវិហារ ឬ លើផ្ទាំងសំពត់ ឃើញសុទ្ធតែមានរូបពួកមារាធិរាជ កាន់អាវុធគ្រប់ដៃ ។

៣-ព្រះពុទ្ធរូបសំដែងធម្មចក្រ គង់ពត់ព្រះភ្នែនមានព្រះហស្តស្តាំ ក្តោបម្រាមធ្វើជារង្វង់មូលដូចជារូបកង់រទេះ
ព្រះហស្តឆ្វេងធ្វើអាការដូចជាព្រះហស្តស្តាំក៏មាន ដាក់លើព្រះឧរុក៏មាន ហៅថាធម្មចក្រមុទ្រា ។ ព្រះពុទ្ធរូបបែបនេះ កាលបើគេគូរតែងតែមានរូបបញ្ចវគ្គិយភិក្ខុកំពុងអង្គុយគោរពស្តាប់ធម្មចកប្បវត្តនសូត្រ ដែលជាបឋមទេសនា ។

៤- ព្រះពុទ្ធរូបប្រទានអភ័យ ជាតំណាងកាលដែលព្រះអង្គសំដែងធម៌ ប្រោសសត្វក្នុងទីណាមួយ មានព្រះកាយឈរក៏មានគង់ពត់ព្រះភ្នែនក៏មាន ព្រះហស្តស្តាំកាចេញទៅមុខ ព្រះហស្តឆ្វេងសំយុងចុះ ហៅថា អភយមុទ្រា ។

៥- ព្រះពុទ្ធរូបប្រទានពរ បាតព្រះហស្តទាំងពីរសំយុងចុះ បែរបាតព្រះហស្តទៅខាងមុខ ទ្រង់គង់ពត់ព្រះភ្នែនក៏មាន ទ្រង់ឈរក៏មាន ជាតំណាងកាលបរិស័ទណាមួយ ចូលមកថ្វាយបង្គំដោយត្រូវការចង់ជួប ចង់ឃើញក្តី ក្រាបទូលសួរធម៌ចំពោះព្រះអង្គក្តី ហៅថា វរមុទ្រា ។

៦- ព្រះពុទ្ធរូបទ្រង់ឈរអោបបាត្រ ជាតំណាងកាលព្រះអង្គទ្រង់និមន្តបិណ្ឌបាត ហៅថា បាត្រាទានមុទ្រា ។

៧-ព្រះពុទ្ធរូបទ្រង់ផ្ទំ ជាតំណាងកាលដែលព្រះអង្គផ្ទំផ្អៀងព្រះកាយទៅខាងស្តាំ ព្រះបាទឆ្វេងត្រួតលើព្រះបាទស្តាំដោយទ្រង់ផ្ទំធម្មតាក្តី ផ្ទំលើមញ្ចាសនជាអនុដ្ឋានសញ្ញាទ្រង់បរិនិព្វានក្តីហៅថា សយនមុទ្រា ។

៨- ព្រះពុទ្ធរូបនាគប្រក់ ជាតំណាងកាលដែលព្រះអង្គគង់ឡើងស្រះមុច្ចលិន្ទ ដែលក្នុងពេលនោះមានភ្លៀងបង្អុរខ្លាំង មាននាគរាជមកពេនព័ទ្ធព្រះអង្គ បើកពពារ គ្របបាំងលើព្រះអង្គ ដើម្បីការពារភ្លៀង ។

ពាក្យថា "មុទ្រា" នេះជាពាក្យសំស្រ្កឹត បាលីថា "មុទ្រា" ប្រែជាខ្មែរថា គ្រឿងសំគាល់ បែបយ៉ាង, អាការ, កាយវិការ, ត្រា, សញ្ញា ។

ព្រះពុទ្ធរូបទាំង ៨ បែបនេះ រូបដែលគេយកថ្មមកឆ្លាក់ក៏មាន យកចម្លាក់ពុម្ពលាយស៊ីម៉ង់ត៍និងខ្សាច់បោះពុម្ពក៏មាន ឥឡូវនេះគេច្រើនតែបោះពុម្ព ។ ព្រះពុទ្ធរូបដែលមានគ្រឿងសំគាល់ផ្សេងៗគ្នានេះ ជាបែបសិល្បៈនៃបុព្វបុរសជាតិខ្មែរ ជាពុទ្ធសាសនិកខាងនិកាយថេរវាទ ដែលគួរគោរពគួរជឿបានដោយពិត ព្រោះជារូបដែលកសាងត្រូវតាមគោលរឿងពុទ្ធប្បវត្តិ ព្រះពុទ្ធរូបទាំង ៨ បែបនេះ នៅប្រទេសខ្មែរយើង គេមិនគ្រាន់តែរចនាដោយឆ្លាក់ឈើថ្ម ឬ បោះពុម្ពដោយស៊ីម៉ង់ត៍ទេ ឃើញគេគូរនៅជញ្ជាំងវិហារក៏មាន គូរលើផ្ទាំងសំពត់ក៏មាន គូរលើកញ្ចក់ក៏មាន គឺគេគូរតាមរឿងពុទ្ធប្បវត្តិ ឬ ទសជាតក៏ . មានរូបមួយបែបទៀត ដែលអ្នកស្រុកហៅថា ព្រះពុទ្ធទ្រង់គ្រឿង ប៉ុន្តែតាមពិតរូបនេះពុំមែនជាពុទ្ធរូបទេ គឺជារូបស្តេចចក្រ ឬ ជារូបមេតេយ្យពោធិសត្វ មានទ្រង់មកុដ សង្វារ ខ្សែសុវង និង ចិញ្ចៀនដូចរូបស្តេចទ្រង់មកុដ ឬ រូបទ្រង់ល្ខោន ។ ព្រះពុទ្ធរូបនាគប្រក់នៅប្រទេសឥណ្ឌាមិនដែលឃើញមានទេ មានតែក្នុងប្រទេសខ្មែរ ដែលកើតឡើងដោយសិល្បៈខ្មែរក្នុងសម័យខាងក្រោយកសាងតាមរឿងពុទ្ធប្បវត្តិ ។

**ចប់កំណើតព្រះពុទ្ធរូបដោយសង្ខេបតែប៉ុណ្ណេះ**

## បត្តិទានគាថា

ពុទ្ធសាសនិកជន ដែលបានធ្វើកុសលឯណាមួយរួចហើយ បើមានប្រាថ្នានឹងឱ្យចំរើនផលានិសង្ស ដល់ខ្លួនដោយច្រើនឡើងទៀត នោះគប្បីឧទ្ទិសផ្សាយផលនៃកុសលនោះដល់សត្វទាំងឡាយ ដោយកុសលចិត្តជាបុញ្ញកិរិយាវត្ថុ ១០ យ៉ាងដែលហៅថា បត្តិទាន គឺកិរិយាឱ្យនូវចំណែកបុណ្យដល់អ្នកដទៃ ដោយបត្តិទានគាថានេះដូច្នេះថា :

យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម កាយេន
វាចាមនសា តិទសេ សុគតំ កតំ យេ សត្តា សញ្ញិនោ
អត្ថិ យេ ច សត្តា អសញ្ញិនោ កតំ បុញ្ញផលំ មយ្ហំ សព្វេ
ភាគី ភវន្តុ តេ យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ
មយា យេ ច តត្ថ ន ជានន្តិ ទេវា គន្ត្វា និវេទយុំ
សព្វេ លោកម្ហិ យេ សត្តា ជីវន្តាហារហេតុកា មនុញ្ញំ
ភោជនំ សព្វេ លភន្តុ មម ចេតសាតិ ។

ប្រែថា យំ កិញ្ចិ កុសល កម្មំ កត្តព្វំ កិរិយំ មម អំពើជាកុសលឯណាមួយ ដែលខ្ញុំគប្បីធ្វើ កាយេន វាចាមនសា ដោយទ្វារទាំង ៣

គឺកាយវាចាចិត្ត តិទសេ សុគតំ កតំ អំពើជាកុសលទាំងអស់នោះ ដែលខ្ញុំបាន ធ្វើហើយ ជាកុសលអាចនឹងនាំឱ្យទៅកើតក្នុងឋានត្រៃត្រឹង្សសួគិបាន យេ សត្តា សញ្ញិនោ អត្ថិ សត្វទាំងឡាយឯណាគឺមនុស្ស ឬ ទេវតា ឬព្រហ្ម ដែលជាសត្វមានសញ្ញាក្តី យេ ច សត្តា អសញ្ញិនោ សត្វទាំងឡាយឯណា ជាអសញ្ញិសត្វ គឺសត្វដែលឥតសញ្ញាក្តី កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ សត្វទាំងឡាយទាំងអស់នោះ ចូរឱ្យបាននូវចំណែកផលនៃបុណ្យ ហើយចូរសោយនូវផលបុណ្យដែលខ្ញុំបានធ្វើ ហើយបានឧទ្ទិសផ្សាយទៅនេះចុះ យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា បុណ្យដែលខ្ញុំបានធ្វើហើយនោះ បើសត្វទាំងឡាយឯណាបានដឹងច្បាស់ហើយ សត្វទាំងឡាយនោះ ចូរឱ្យបានសោយនូវផលនៃបុណ្យដែលខ្ញុំបានឧទ្ទិសឱ្យទៅនោះចុះ យេ ច តត្ថ ន ជានន្តិ ម្យ៉ាងទៀតបណ្តាអស់សត្វទាំងនោះ បើសត្វទាំងឡាយឯណាមិនបានដឹងនូវបុណ្យដែលខ្ញុំបានធ្វើហើយនោះ ទេវា គន្ត្វា និវេទយុំ សូមទេវតាទាំងឡាយ អញ្ជើញទៅឱ្យដំណឹងដល់សត្វទាំងឡាយនោះឱ្យបានដឹងផងថា ជនឯណោះគេបានធ្វើបុណ្យ ហើយគេឧទ្ទិសផ្សាយផលបុណ្យនោះមក ដល់អ្នកទាំងឡាយ ៗ ចូរអនុមោទនាត្រេកអរនឹងបុណ្យគេនោះចុះ សព្វេ លោកម្ហិ យេ សត្តា

ជិវន្តាហារហេតុកា សត្វទាំងឡាយឯណាក្នុងលោកទាំងអស់ ដែលអាស្រ័យនូវអាហារហើយរស់នៅ មនុញ្ញំភោជនំ សព្វេ លភន្តុ មម ចេតសាតិ សត្វទាំងឡាយទាំងអស់នោះ ចូរឱ្យបាននូវភោជនជាទីគាប់ចិត្ត ដែលសម្រេចដោយបុញ្ញឫទ្ធិតាមចិត្ត ដែលខ្ញុំឧទ្ទិសផ្សាយទៅឱ្យនេះចុះ ។

*បត្តិទានគាថានេះ សម្រាប់សូត្របានក្នុងទីទាំងពួងក្នុងកាល*
*ដែលបានធ្វើកុសលអ្វីមួយហើយស្រេច ។*

## បត្តិទានគាថា

*ពាក្យផ្សាយចំណែកបុណ្យ*

យា ទេវតា សន្តិ វិហារវាសិនី ថូបេ
ឃរេ ពោធិឃរេ តហឹ តហឹ តា
ធម្មទានេន ភវន្តុ បូជិតា សោត្ថឹ ករោន្តេធ
វិហារមណ្ឌលេ ថេរា ច មជ្ឈា នវកា ច
ភិក្ខវោ សារាមិកា ទានបតី ឧបាសកា
គាមា ច ទេសា និគមា ច ឥស្សរា
សប្បាណភូតា សុខិតា ភវន្តុ តេ ជលាពុជា
យេបិ ច អណ្ឌសម្ភវា សំសេទជាតា
អថវោបបាតិកា និយ្យានិកំ ធម្មវរំ បដិច្ច តេ
សព្វេបិ ទុក្ខស្ស ករោន្តុ សំខយំ ។

ឋាតុ ចិរំ សតំ ធម្មោ ធម្មធរា ច បុគ្គលា សង្ឃោ
ហោតុ សមគ្គោវ អត្ថាយ ច ហិតាយ ច អម្ហេ

វក្ខតុ សទ្ធម្មោ សព្វេបិ ធម្មចារិនោ វុឌ្ឍឹ សម្បាបុណេយ្យាម ធម្មារិយប្បវេទិតេ ។

ប្រែថា យា ទេវតា សន្តិ វិហារវាសិនី ថូបេ ឃរេ ពោធិឃរេ តហឹ តហឹ ទេវតាទាំងឡាយឯណា មានប្រក្រតីនៅក្នុងទីវត្តជាទីនៅនៃសង្ឃ ព្ធដ៏ខឿនព្រះសថូប ព្ធដ៏ខឿនព្រះពោធិព្រឹក្សក្នុងទីនោះ ៗ តា ធម្មទានេន ភវន្តុ បូជិតា ទេវតាទាំងឡាយនោះ ជាបុគ្គលគឺយើងទាំងឡាយបូជាហើយដោយធម្មទាន សោត្ថឹ កុរោន្តេធ វិហារមណ្ឌលេ ចូរធ្វើនូវសួស្តីក្នុងមណ្ឌលនៃវត្តជាទីនៅនៃសង្ឃនេះ ថេរា ច មជ្ឈានវកា ច ភិក្ខវោ ភិក្ខុទាំងឡាយជាថេរៈក្តី ជាកណ្តាលក្តី ទើបនឹងបួសថ្មីក្តី សារាមិកា ទានបតី ឧបាសកា ឧបាសកនិងឧបាសិកាទាំងឡាយដែលជាម្ចាស់នៃទាន ព្រមទាំងអារាមិកជន គឺញោមវត្តក្តី គាមា ច ទេសា និគមា ច ឥស្សរា ជនទាំងឡាយ ដែលជាអ្នកស្រុកក្តី ជាអ្នកប្រទេសក្តី ជាអ្នកនិគមក្តី ដែលជាឥស្សរៈជាធំក្តី សប្បាណភូតា សុខិតា ភវន្តុ តេ សត្វទាំងឡាយនោះ ៗ ចូរឱ្យបានដលនូវសេចក្តីសុខ ជលាពុជា យេបិ ច អណ្ឌសម្ភវា សំសេទជាតា អថ វោបបាតិកា មួយវិញទៀត

សត្វទាំងឡាយឯណា ដែលជាជលាពុជៈ កំណើតក្ដី ដែលជាអណ្ឌជៈកំណើតក្ដី ដែលជាសំសេទជៈកំណើតក្ដី ដែលជា ឧបបាតិកៈកំណើតក្ដី និយ្យានិកំ ធម្មវរំ បដិច្ច តេ សព្វេបិ ទុក្ខស្ស ករោន្តុ សំខយំ សត្វទាំងឡាយទាំងអស់នោះ កាលបើបានអាស្រ័យនូវធម៌ដ៏ប្រសើរជានិយ្យានិកធម៌ហើយ ចូរធ្វើនូវធម៌ជាគ្រឿងអស់ទៅនៃទុក្ខចុះ ឋាតុ ចិរំ សតំ ធម្មោ សូមឱ្យធម៌របស់សប្បុរសទាំងឡាយស្ថិតនៅអស់កាលយូរអង្វែងទៅ ធម្មធរា ច បុគ្គលា បុគ្គលអ្នកទ្រទ្រង់នូវធម៌ទាំងឡាយ (ចូរស្ថិតនៅអស់កាលយូរអង្វែងទៅ) សង្ឃោ ហោតុ សមគ្គោ វ សូមព្រះសង្ឃព្រមព្រៀងគ្នា អត្ថាយ ច ហិតាយ ច ដើម្បីសេចក្ដីចម្រើនផង ដើម្បីសេចក្ដីសម្រេចផលប្រយោជន៍ផង អម្ហេ រក្ខតុ សទ្ធម្មោ សព្វេបិ ធម្មចារិនោ សូមព្រះសទ្ធម្មរក្សានូវយើងទាំងឡាយ សូមរក្សានូវអ្នកដែលប្រព្រឹត្តធម៌ទាំងឡាយទាំងអស់ផង វុឌ្ឍី សម្បាបុណេយ្យាម ធម្មារិយប្បវេទិតេ សូមឱ្យយើងទាំងឡាយបានដល់នូវសេចក្ដីចម្រើន ក្នុងធម៌ដែលព្រះអរិយៈទាំងឡាយលោកសម្ដែងហើយ ។

*បត្តិទានគាថានេះ សម្រាប់សូត្រចំពោះតែក្នុងទីវត្ត អារាម ក្នុងកាលដែលចប់ធម៌ទេសនា ឬ ក្នុងវេលាដែលសូត្រធម៌ណាចប់ហើយ ។*

## បរិត្តភាសនាយាចនគាថា

*ពាក្យអារាធនាព្រះភិក្ខុសង្ឃសូមឱ្យចម្រើនព្រះបរិត្ត*

វិបត្តិប្បដិពាហាយ សព្វ សម្បត្តិ សិទ្ធិយា
សព្វទុក្ខវិនាសាយ បរិត្តំ ព្រូថ មង្គលំ ។
វិបត្តិប្បដិពាហាយ សព្វសម្បត្តិសិទ្ធិយា
សព្វភយវិនាសាយ បរិត្តំ ព្រូថ មង្គលំ ។
វិបត្តិប្បដិពាហាយ សព្វសម្បត្តិសិទ្ធិយា
សព្វរោគវិនាសាយ បរិត្តំ ព្រូថ មង្គលំ ។

ប្រែថា សូមព្រះករុណាទាំងឡាយ ចម្រើននូវព្រះបរិត្តជាជយមង្គល ដើម្បីនឹងការពារបញ្ចៀសនូវវិបត្តិគឺ សេចក្ដីអន្តរាយទាំងពួង ដើម្បីនឹងឱ្យបាន សម្រេចនូវសម្បត្តិគ្រប់យ៉ាង ដើម្បីនឹងញ៉ាំង ទុក្ខ ភ័យ រោគ ទាំងអស់ ឱ្យវិនាសបាត់ទៅ ។

លុះលោកអាចារ្យអារាធនានិមន្តដូច្នេះហើយ លោកសង្ឃអ្នកចម្រើន ព្រះបរិត្តនោះ ត្រូវសូធ្យ "សគ្គេ កាមេ ។ល។ អយម្ភទន្តា"

ប្រកាសអញ្ជើញពពួក ទេវតារួចហើយ ទើបចម្រើនព្រះបរិត្តជាពុទ្ធមន្ត តាមគួរដល់ពុទ្ធានុញ្ញាតក្នុងខុទ្ទក វត្តក្ខន្ធកៈ ក្នុងព្រះវិន័យ ។

## ទេវតាបការសនគាថា

*ពាក្យប្រកាសអញ្ជើញពពួកទេវតា*

សគ្គេ កាមេ ច រូបេ គិរិសិខរតដេ ចន្តលិក្ខេ វិមានេ ទីបេ រដ្ឋេ ច គាមេ តរុវនគហនេ គេហវត្ថុម្ហិ ខេត្តេ ភុម្មា ចាយន្តុ ទេវា ជលថលវិសមេ យក្ខគន្ធព្វនាគា តិដ្ឋន្តា សន្តិកេ យំ មុនិវរវចនំ សាធវោ មេ សុណន្តុ ។

ធម្មស្សវនកាលោ អយម្ភទន្តា ធម្មស្សវនកាលោ អយម្ភទន្តា ធម្មស្សវនកាលោ អយម្ភទន្តា ។

ប្រែថា ទេវតាទាំងឡាយដែលស្ថិតនៅក្នុងស្ថានសួគ៌ដែលជាកាមភពនិង រូបភពក្តី ភុម្មទេវតាទាំងឡាយដែលស្ថិតនៅក្នុងទិព្វវិមាន គឺលើកំពូលភ្នំ ឬ ភ្នំដែល ដាច់ក្តី ឰដ៏អាកាសក្តី នៅនាកោះ និងដែន និងស្រុកក្តី នៅនាដើមព្រឹក្សានិងព្រៃ ញៀតស្បាត ឬទីស្រែចំការក្តី យក្ខ និងគន្ធព្វ និងនាគទាំងឡាយ ដែលស្ថិតនៅនាទី ទឹកដីគោក ឬទីមិនរាបស្មើ ដែលនៅក្នុងទីជិតនេះក្តី សូមអញ្ជើញមកប្រជុំគ្នា (ក្នុងទីនេះ) ពាក្យឯណា ដែលជាពាក្យព្រះសក្យមុនីដ៏ប្រសើរ (ដែលយើងនឹង

សូធ្យឥឡូវនេះ) លោកអ្នកសប្បុរសទាំងឡាយ ចូរស្ដាប់នូវពាក្យនោះ (ដោយគោរព) ។

ធម្មស្សវនកាលោ អយម្ភទន្តា បពិត្រលោកអ្នកដ៏ចម្រើនទាំងឡាយ ពេលនេះជាវេលាគួរនឹងស្ដាប់នូវព្រះធម៌ (ត្រូវសូធ្យ ៣ ដង)

## ធម្មទេសនាយាចនគាថា

*ពាក្យសូមអារាធនាលោកអ្នកសម្ដែងធម៌*

ព្រហ្មា ច លោកាធិបតី សហម្បតី
កតញ្ជលី អន្ធិវរំ អាយាចថ សន្តីធ
សត្តាប្បរជក្ខជាតិកា ទេសេតុ ធម្មំ
អនុកម្បិមំ បជំ ។ សទ្ធម្មភេរឹ វិនយញ្ច
កាយំ សុត្តញ្ច ពន្ធំ អភិធម្មធម្មំ
អាកោដយន្តោ ចតុសច្ចទណ្ឌំ បញ្ចេធ
នេយ្យេ បរិសាយ មជ្ឈេ ។

ឯវំ សហម្បតី ព្រហ្មា ភគវន្តំ អាយាចថ តុណ្ហី
ភាវេន តំ ពុទ្ធោ ការុញ្ញេនាធិវាសយ តម្ហា
វុដ្ឋាយ បាទេន មិគទាយំ គតោ គតោ
បញ្ចវគ្គិយានំ ទេសេសិ ។ អមំ បាយេសិ ធម្មតោ
តតោ បភូតិ សម្ពុទ្ធោ អន្ធនា ធម្មទេសនំ
មាឃវស្សានិ ទេសេសិ សត្តានំ អត្ថសិទ្ធកំ ។
តេន សាធុ អយ្យោ ភន្តេ ទេសេតុ ធម្មទេសនំ
សព្វាយិធ បរិសាយ អនុកម្បម្បិ កាតវេ ។

គ្រានោះសហម្បតី- ព្រហ្មជាឥស្សរលោកា ចូលគាល់ព្រះសាស្ដា ឈើកហត្ថាសិរោរាប ។ ហើយពោលពាក្យទូលថា សូមព្រះករុណាស្ដេចទ្រង់ជ្រាប ដ្បិតសត្វអន់ទន់ទាបទុព្វលភាពបាបក្រៃក្រាស់ ។ ទន្ទឹមព្រះធម៌ថ្លៃ ជានិស្ស័យបច្ច័យច្បាស់ ឥឡូវទ្រង់បានត្រាស់ ត្រេកអរណាស់ពុំកន្តើយ ។ សត្វខ្លះក្រាស់ដោយកាមមិនយល់តាមត្រៃលក្សណ៍ឡើយ ឥឡូវយល់ខ្លះហើយ ដោយអំណាចព្រះមានបុណ្យ ។ បើបានស្ដាប់ទេសនា បញ្ញាក្លាខ្លាំងលើសមុន សូមព្រះដ៏មានបុណ្យ ទ្រង់និមន្តប្រោសទេសនា ។ ប្រោសសត្វបំបាត់សោក ទាំងរាគរោគរូបតណ្ហា ឯងឹតប្រែជ្រះថ្លា កើតបញ្ញាភិយ្យោយល់ ។ ត្រៃលោកគោកត្រៃលក្សណ៍

សង្សារចក្រវិលមិនដល់ អវិជ្ជាក៏ឫសគល់ ជាបច្ច័យនៃសង្ខារ ។ នាំសត្វឱ្យសោក សៅ លិចលង់នៅក្នុងសង្សារ បញ្ចមាររមោហន្ធការ រឹតរុំហ៊ុមជុំជាប់នៅ ។ ហេតុនោះ សូមព្រះអង្គ ប្រោសស្រោចស្រង់ដាក់សំពៅ ចម្លងសត្វឆ្លោះទៅ កាន់ត្រើយ ត្រាណនិញ្វាននាយ ។ ដូចកលប្រទីបធំ សាយត្រសុំភ្លឺព្រោងព្រាយ បំភ្លឺសត្វទាំងឡាយ ឱ្យសប្បាយក្សាន្តភិរម្យ ។ ព្រះសទ្ធម្មជាស្គរជ័យ ព្រះវិន័យជារាងធំ ព្រះសូត្រជាខ្សែរុំ ព្រះអភិធម្មជាស្បែកដាស ។ អរិយសច្ច ជាអន្ទង សម្រាប់ទូងឱ្យឮច្បាស់ សត្វលោកងោកងុយណាស់ ឮស្គរដាស់ក្រោក ឡើងបាន ។ បរិស័ទ ៤ ជំពូក ដូចផ្កាឈូកក្នុងជលដ្ឋាន ខ្ចះផុសចាំសូរ្យឆាន រះនឹងរីកដោយរស្មី ។ ព្រះធម៌ជាសូរ្យសែង រះឡើងចែងចាំងរង្សី បំភ្លឺលោកទាំងបី ឱ្យយល់ផ្លូវឋានសុខា ។

សហម្បតីព្រហ្ម ខិនបង្គំអារាធនា សម្ដេចព្រះភគវា ដោយគាថាយ៉ាង នេះឯង ។ ព្រះពុទ្ធទ្រង់អនុកូល ព្រមទទួលនិងសម្ដែង ដោយតុណ្ហីភាពថ្លែង តាមភាវៈគុណករុណា ។ ទើបក្រោកចាកទីនោះ ភក្ត្រឆ្ពោះព្រៃមិគទា យាងចេញ ចរលីលា ពីទីនោះដោយព្រះបាទ ។ ញុំាងសត្វចូលពុទ្ធចក្រ មានបញ្ចវគ្គីយ៍ជាអាទិ៍ ឱ្យផឹកអម្រឹតជាតិ រសនិញ្វានតាមធម្មតា ។ ចាប់ដើមពីនោះឯង ទ្រង់សម្ដែងធម៌ទេសនា ធ្វើពុទ្ធកិច្ចា អស់វស្សាសែសិបប្រាំ ។ ពុំថយពុំបន្ធូរ ប្រយោជន៍យូរអង្វែងឆ្នាំ សម្រេចបុញ្ញកម្ម ដល់សព្វសត្វទាំងភពត្រ័យ ។

ហេតុនោះឥឡូវនេះ យើងខ្ញុំនេះសាទរក្រែ បពិត្រព្រះគុណថ្លៃ សូមនិមន្តប្រោសទេសនា ។ អនុគ្រោះពួកបរិស័ទ ដែលជាប់ខាត់ដោយមោហា ឱ្យកើតមានបញ្ញា ប្រាកដនាទីនេះហោង ។

## សម្ដែងអំពីវិធីវេរភត្ត ១៤ ប្រការ

បើឧបាសកឧបាសិកាមានបសាទសទ្ធា គឺជាជំនឿប្រកបដោយសេចក្ដីជ្រះថ្លា កើតឡើងក្នុងសន្ដាន មានប្រាថ្នានឹងវេរនូវភត្តទាំង ១៤ ប្រការ ភត្តណាមួយក៏បានតាមប្រាថ្នា ។

### ឯភត្តទាំង ១៤ នោះ គឺ :

១-សង្ឃភត្តំ វេរនូវភត្តដល់សង្ឃ ។

២-ឧទ្ទេសភត្តំ វេរនូវភត្តដល់ភិក្ខុ ១ អង្គ ឬ ២ អង្គ ឬក៏ ៣ អង្គជាដើម តាមពាក្យដែលសង្ឃសម្ដែងឱ្យ ។

៣-និមន្តនភត្តំ វេរនូវភត្តដល់ភិក្ខុដែលខ្លួននិមន្តមកហើយប្រគេន ។

៤-សលាកភត្តំ វេរនូវភត្តដល់ភិក្ខុទាំងឡាយ ដែលខ្លួនសរសេរឈ្មោះក្នុង ស្លាកហើយចាប់ ។

៥-បក្ខិកភត្តំ វេរនូវភត្តដល់ភិក្ខុសង្ឃក្នុងសុក្កបក្ខ គឺចំណែកខាងខ្នើត ឬកាឡបក្ខ គឺចំណែកខាងរនោច តែក្នុង ១ បក្ខប្រគេនតែ ១ ថ្ងៃ មិនមានកំណត់ ថ្ងៃណា ។

៦-ឧបោសថិកភត្តំ វេរនូវភត្តដល់ភិក្ខុសង្ឃក្នុងថ្ងៃឧបោសថកាល ។

៧-បាដិបទិកភត្តំ វេរនូវភត្តដល់ភិក្ខុសង្ឃក្នុងថ្ងៃ ១ កើត ឬ ១រោច ។

៨-អាគន្តុកភត្តំ វេរនូវភត្តដល់ភិក្ខុសង្ឃដែលទើបមកដល់ថ្មី ។

៩-គមិកភត្តំ វេរនូវភត្តដល់ភិក្ខុសង្ឃដែលមានដំណើរនឹងទៅកាន់ទីណាមួយ ។

១០-គិលានភត្តំ វេរនូវភត្តដល់ភិក្ខុសង្ឃដែលមានជំងឺ ។

១១-គិលានុបដ្ឋាកភត្តំ វេរនូវភត្តដល់ភិក្ខុសង្ឃជាអ្នករក្សាជំងឺភិក្ខុសាមណេរផងគ្នា ។

១២-និច្ចភត្តំ វេរនូវភត្តដែលត្រូវប្រគេនជានិច្ចដល់ភិក្ខុសង្ឃ ។

១៣-កុដិកភត្តំ វេរនូវភត្តដល់ភិក្ខុសង្ឃ នៅទីលំនៅមានកុដិជាដើម (ភត្តនេះហៅបានតាមឈ្មោះទីកន្លែងដែលសង្ឃនៅ) ។

១៤-វារកភត្តំ វេរនូវភត្តដល់ភិក្ខុសង្ឃដោយចាត់ចែងជាវេន ។

ភត្តទាំង១៤ប្រការនេះ បើទាយកប្រាថ្នានឹងវេរភត្តណាមួយត្រូវដាក់ឈ្មោះភត្តនោះ ត្រង់បាលីដែលវង់ក្រចកយ៉ាងនេះ (          ) ទុកនោះចុះ ។

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស (បីចប់) ។ អយំ នោ ភន្តេ បិណ្ឌបាតោ ធម្មិកោ ធម្មលទ្ធោ ធម្មេនេវ ឧប្បាទិតោ មាតាបិតុអាទិកេ គុណវន្តេ ឧទ្ទិស្ស ឥមំ (ឥត្ថន្នាមំ) សបរិក្ខារំ ពុទ្ធប្បមុខស្ស (១) សង្ឃស្សទេម តេ គុណវន្តាទយោ ឥមំ (ឥត្ថន្នាមំ) អត្តនោ សន្តកំ វិយ មញ្ញមានា អនុមោទន្តុ អនុមោទិត្វាន យថិច្ឆិតសម្បត្តីហិ សមិជ្ឈន្តុ សព្វទុក្ខា បមុញ្ចន្តុ ឥមិនា និស្សន្ទេន ។ ទុតិយម្បិ.....។ តតិយម្បិ........ ។

ប្រែថា បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើនឡើយ វីចង្ហាន់បិណ្ឌបាតនៃយើងខ្ញុំទាំងឡាយនេះ ប្រកបដោយធម៌ បានអកដោយធម៌ កើតឡើងដោយធម៌ យើងខ្ញុំទាំងឡាយ សូមឧទ្ទិសចំពោះដល់លោកអ្នកដ៏មានគុណទាំងឡាយមានមាតានិងបិតាជាដើម យើងខ្ញុំទាំងឡាយ វេរ (នូវភត្តមានប្រការនេះជា ឈ្មោះ) នេះថាដូចជារបស់ខ្លួន ហើយសូមអនុមោទនាយកចុះ លុះអនុមោទនារួច ហើយ

១- បើមានរៀបភោជនាហារដោយឡែកផ្សេងជាតង្វាយព្រះពុទ្ធរូបក្នុងទីនោះ ទើបត្រូវ ដាក់បាលីថា "ពុទ្ធប្បមុខស្ស" នេះ បើមិនមានតង្វាយព្រះពុទ្ធរូបទេ កុំដាក់បាលីនេះ ។ ប៉ែកខាងសេចក្ដីប្រែ ក៏ដូចគ្នាដែរ ។

សូមឱ្យរួចរំដោះចាកទុក្ខទាំងពួង ឱ្យបានសម្រេចដោយ សម្បត្តិទាំងឡាយ ៣ ប្រការ គឺសម្បត្តិមនុស្ស ១, សម្បត្តិទេវតា ១ សម្បត្តព្រះនិព្វាន១ ដោយសមគួរតាមសេចក្តីប្រាថ្នា របស់លោកអ្នកដ៏មានគុណទាំងឡាយនោះចុះ ដោយអំណាចផលានិសង្ស ដែលហូរជូនមកមិនដាច់នេះហោង ។ អស់វារៈ២ដង ផង ។ អស់វារៈ ៣ ដងផង ។

ត្រង់បទថា "ឥត្ថន្នាមំ" នោះត្រូវបញ្ចូលឈ្មោះ "ភត្ត" តាមប្រាថ្នាយ៉ាងដូច "សង្ឃភត្ត" បញ្ចូលថា "សង្ឃភត្តំ (នូវសង្ឃភត្ត)" ។

## បើវេរចតុប្បច្ច័យជាសង្ឃទាន ថាដូច្នេះ

មយំ ភន្តេ ឥមេ ចត្តារោ បច្ចយេ ឥធានេត្វា សង្ឃស្ស ទេម-សាធុ' ភន្តេ សង្ឃោ ឥមេ ចត្តារោ បច្ចយេ បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ......។ តតិយម្បិ ។

ប្រែថា បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើន យើងខ្ញុំទាំងឡាយ បាននាំមកនូវបច្ច័យទាំងឡាយ ៤ នេះ មកទម្កល់ទុកក្នុងទីនេះ ហើយវេរប្រគេន ដល់ ព្រះសង្ឃ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃទទួលយកនូវបច្ច័យទាំង ឡាយ ៤ នេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់យើង

ខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។ .......អស់វារៈ ២ ដងផង ។ .......អស់វារៈ ៣ ដងផង ។

### បើវេរចតុប្បច្ច័យដល់ភិក្ខុមួយអង្គ ថាដូច្នេះ

មយំ ភន្តេ ឥមេ ចត្តារោ បច្ចយេ ឥធានេត្វា អាយស្មតោ ទេម សាធុ ភន្តេ អាយស្មា ឥមេ ចត្តារោ បច្ចយេ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ......... ។ តតិយម្បិ ....... ។

ប្រែថា បពិត្រព្រះករុណាដ៏ចម្រើន យើងខ្ញុំទាំងឡាយ បាននាំនូវបច្ច័យទាំងឡាយ ៤ នេះ មកតម្កល់ទុកក្នុងទីនេះ សូមវេរប្រគេនដល់ព្រះករុណាដ៏មានអាយុ បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាទទួលយកនូវបច្ច័យទាំងឡាយ ៤ នេះ ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។ ........អស់វារៈ ២ ដង ផង ។ ........អស់វារៈ ៣ ដងផង ។

### វេរកឋិនទានដល់ព្រះសង្ឃ ថាដូច្នេះ

ឥមំ ទុស្សំ កឋិនចីវរំ សង្ឃស្ស ទេម ។ ទុតិយម្បិ.... ។ តតិយម្បិ...... ។

ប្រែថា បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើនឡើយ យើងខ្ញុំទាំងឡាយ សូមវេរនូវសំពត់នេះ ជាសំពត់ដើម្បីកឋិនចីវរ ប្រគេនដល់ព្រះសង្ឃ ។

.......អស់វារៈ ២ ដងផង ។ ...... អស់វារៈ ៣ ដងផង ។

ឬនឹងវេរថា ឥមំ វត្ថំ កឋិនចីវរំ សង្ឃស្ស ទេម ដូច្នេះក៏បាន. សេចក្តីប្រែដូចគ្នា ។

**វេរគ្រឿងបរិក្ខារជាបរិវារកឋិន ថាដូច្នេះ**

យេនម្ហាកំ កឋិនតំ គហិតំ កឋិនានិសង្សានិ តស្សេវ ទេម ។ ទុតិយម្បិ........។ តតិយម្បិ.........។

ប្រែថា បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើនឡើយ រីកឋិននៃយើងខ្ញុំទាំងឡាយ គឺលោកម្ចាស់អង្គណាបានទទួលកាន់យកហើយ យើងខ្ញុំទាំងឡាយ សូមវេរនូវគ្រឿងបរិក្ខារជាបរិវារនៃកឋិនទាំងឡាយ ប្រគេនដល់លោកម្ចាស់អង្គនោះ ។

.........អស់វារៈ ២ ដងផង ។ .............អស់វារៈ ៣ ដងផង ។

សំពត់ ៧ ប្រការ ដែលព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតទុកឱ្យជាសំពត់សមណបរិក្ខានោះគឺសំពត់ត្រៃចីវរ១ សំពត់សម្រាប់ងូតទឹកភ្លៀង ១ សំពត់សម្រាប់ទ្រាប់អង្គុយ ១ សំពត់សម្រាប់ក្រាលជាកម្រាល ១ សំពត់សម្រាប់គ្របបូសឬគ្របដំបៅ ១ សំពត់សម្រាប់ជូតមុខតឹកន្សែង ១ សំពត់តូច ធំជាងប្រមាណ ហៅថាសំពត់បរិក្ខារចោឡៈ ១ បញ្ចូលសំពត់សម្រាប់ត្រងទឹក ១ សំពត់ចំណាំវស្សា១

និងសំពត់អច្ចេកចីវរ ១ ថែមទៀត ជា ១០ ។

សំពត់ទាំង ១០ប្រការនេះ បើទាយកមានប្រាថ្នានឹងវេរសំពត់ណាមួយដល់សង្ឃ តែសំពត់នោះមានតែ ១ ត្រៃ ឬ ១ ផ្ទត់ ត្រូវដាក់ឈ្មោះសំពត់នោះជាបាលីឯកវចនៈ បញ្ចូលវេរដូចមានសំណៅទុកជាបែបខាងមុខនេះទាំង ១០ ប្រការគឺ:

១- ឥមំ តិចីវរំ នូវត្រៃចីវរនេះ ។

២- ឥមំ វស្សិកសាដកំ នូវសំពត់សម្រាប់ងូតទឹកភ្លៀងនេះ ។

៣-ឱមំ និសីទនំ នូវសំពត់សម្រាប់ទ្រាប់អង្គុយនេះ ។

៤-ឥមំ បច្ចត្ថរណំ នូវសំពត់សម្រាប់ក្រាលនេះ ។

៥-ឥមំ គណ្ឌុប្បដិច្ឆាទិ នូវសំពត់សម្រាប់គ្របបូស ឬ ដំបៅនេះ ។

៦-ឥមំ មុខបុញ្ឆនចោឡំ នូវសំពត់សម្រាប់ជូតមុខតឹកខ្សៀងនេះ ។

៧-ឥមំ បរិក្ខារចោឡំ នូវសំពត់តូច ឬធំជាងប្រមាណជាបរិក្ខានេះ ។

៨-ឥមំ បរិសាវនំ នូវសំពត់សម្រាប់ត្រងទឹកនេះ ។

៩-ឥមំ វស្សាវាសិកំ នូវសំពត់ចំណាំវស្សានេះ ។

១០-ឥមំ អច្ចេកចីវរំ នូវសំពត់អច្ចេកចីវរនេះ ។

សំពត់ទាំង១០ប្រការនេះ បើត្រូវការនឹងវេរប្រគេនណាមួយ ឱ្យយកឈ្មោះសំពត់ដែលមានសំណៅជាបែបទុកនុះ មកដាក់ជាបាលីដែលសម្រាប់សូត្រវេរត្រង់កន្លែង ដែលមានវង់ក្រចកទុកស្រាប់ហើយនោះចុះ ។

**វេរត្រៃចីវរ ថា**

មយំ ភន្តេ ឥមំ (តិចីវរំ) ឥធានេត្វា សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមំ (តិចីវរំ) បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ...... ទុតិយម្បិ ។ .......តតិយម្បិ ។

ប្រែថា បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើនឡើយ យើងខ្ញុំទាំងឡាយបាននាំ (នូវត្រៃចីវរ) នេះ មកតម្កល់ទុកក្នុងទីនេះ សូមវេរប្រគេនដល់ព្រះសង្ឃ បពិត្រព្រះសង្ឃ ដ៏ចម្រើន សូមព្រះសង្ឃទទួលយក(នូវត្រៃចីវរ)នេះ ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខៈដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។ ........អស់វារៈ ២ ដងផង ។ ...............អស់វារៈ ៣ ដងផង ។

សំពត់ទាំង១០ប្រការនេះ បើប្រាថ្នានឹងវេរសំពត់ណាមួយដល់ព្រះសង្ឃ តែសំពត់នោះមានច្រើនត្រៃ ឬ ច្រើនផ្ទត់ ត្រូវឱ្យយកឈ្មោះសំពត់នោះជាបាលីពហុវចនៈមកដាក់បញ្ចូលវេរ ដូចមានសំណៅជាបែបទុកនៅខាងក្រោមនេះស្រាប់ ។

១-ឥមានិ តិចីវរានិ នូវសំពត់ត្រៃចីវរទាំងឡាយនេះ ។

២-ឥមា វិស្សិកសាដិកាយោ នូវសំពត់សម្រាប់ងូតទឹកភ្លៀងទាំងឡាយនេះ ។

៣-ឥមានិ និសីទនានិ នូវសំពត់សម្រាប់ទ្រាប់អង្គុយទាំងឡាយនេះ ។

៤-ឥមានិ បច្ចត្ថរណានិ នូវសំពត់កម្រាលទាំងឡាយនោះ ។

៥-ឥមានិ គណ្ឌុប្បដិច្ឆាទីនិ នូវសំពត់សម្រាប់គ្របបូស ឬ គ្របដំបៅទាំងឡាយនេះ ។

៦-ឥមានិ បរិក្ខារចោឡានិ នូវសំពត់សម្រាប់ជូតមុខទាំងឡាយនេះ ។

៧-ឥមានិ បរិក្ខារចោឡានិ នូវសំពត់បរិក្ខារចោឡៈទាំងឡាយនេះ ។

៨-ឥមានិ បរិសាវនានិ នូវសំពត់សម្រាប់ត្រងទឹកទាំងឡាយនេះ ។

៩-ឥមា វស្សាវាសិកាយោ នូវសំពត់ចំណាំវស្សាទាំងឡាយនេះ ។

១០-ឥមានិ[១] អច្ចេកចីវរានិ នូវសំពត់អច្ចេកចីវរទាំងឡាយនេះ ។

---

១- "ឥមំ" ឬ ឥមា. ឥមានិ ប្រែថា "នេះ" ជាពាក្យចង្អុលរបស់ដែលនៅក្នុងហត្ថបាសនៃទាយកអ្នកវេរ. បើរបស់នៅក្រៅហត្ថបាសទាយកអ្នកវេរ ត្រូវថា "ឯតំ. ឯតា. ឯតានិ" ប្រែថា "នុះ" ។

ឯសំពត់១០ប្រការនេះ បើត្រូវការវេរសំពត់ណាមួយ ឱ្យយកឈ្មោះសំពត់នោះមកដាក់ជាបាលី សម្រាប់សូត្រវេរខាងមុខនោះចុះ ត្រង់កន្លែងដែលមានវង់ក្រចកនេះស្រាប់ ។

**វេរសំពត់សម្រាប់ងូតទឹកភ្លៀង ថា**

មយំ ភន្តេ ឥមា (វស្សិកសាដិកាយោ) ឥធានេត្វា សង្ឃស្ស ទេម . សាធុ ភន្តេ សង្ឃោ ឥមា (វស្សិកសាដិកាយោ) បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ........ ។ តតិយម្បិ........ ។

ប្រែថា បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើនឡើយ យើងខ្ញុំទាំងឡាយ បាននាំ (នូវសំពត់សម្រាប់ងូតភ្លៀងទាំងឡាយ) នេះមកតម្កល់ទុកក្នុងទីនេះ សូមវេរប្រគេនដល់ព្រះសង្ឃ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃទទួលយក (នូវសំពត់សម្រាប់ងូតទឹកភ្លៀងទាំងឡាយ) នេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។ ........ អស់វារៈ ២ ដង ផង ។ ..............អស់វារៈ ៣ ដងផង ។

**វេរសង្ឃទាន ថា**

មយំ ភន្តេ ឥមានិ ខាទនីយភោជនីយាទីនិ សង្ឃេត្វា សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមានិ ខាទនីយ ភោជនីយាទីនិ បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ...... ។ តតិយម្បិ..... ។

ប្រែថា បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើនឡើយ យើងខ្ញុំទាំងឡាយ បានតាក់តែងនូវវត្ថុទាំងឡាយ មានខាទនីយភោជនីយាហារ គឺបង្អែមនិងចម្អាប ជាដើមនេះ ហើយវេរប្រគេនដល់ព្រះសង្ឃ. បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើន សូមព្រះសង្ឃទទួលយកនូវវត្ថុទាំងឡាយ មានបង្អែមនិងចង្អាបជាដើមនេះ ដើម្បី សេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។ ........អស់វារៈ ២ ដងផង ។ .......អស់វារៈ ៣ ដងផង ។

**វេរគណៈទាន ថា**

មយំ ភន្តេ ឥមានិ ខាទនីយភោជនីយាទីនិ សង្ឃេត្វា សីលវន្តានំ ទេម. សាធុ ភន្តេ សីលវន្តោ ឥមានិ ខាទនីយ

ភោជនីយានិ បដិគ្គណ្ហន្តុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ...... ។ តតិយម្បិ..... ។

ប្រែថា បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើនឡើយ យើងខ្ញុំទាំងឡាយ បានតាក់តែងនូវវត្ថុទាំងឡាយ មានខាទនីយភោជនីយាហារ គឺបង្អែមនិងចម្អាប ជាដើមនេះ ហើយវេរប្រគេនដល់លោកម្ចាស់អ្នកមានសីលទាំងឡាយ. បពិត្រព្រះករុណាទាំងឡាយដ៏ចម្រើន សូមលោកម្ចាស់អ្នកមានសីលទាំងឡាយ ទទួលយកនូវវត្ថុទាំងឡាយ មានបង្អែមនិងចម្អាបជាដើមនេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។ ........អស់វារៈ ២ ដងផង ។ .......អស់វារៈ ៣ ដងផង ។

### វេរចាបិបុគ្គលិកទាន ថា

មយំ ភន្តេ ឥមានិ ខាទនីយភោជនីយានិ សជ្ជេត្វា សីលវតោ ទេម. សាធុ ភន្តេ សីលវា ឥមានិ ខាទនីយ ភោជនីយានិ បដិគ្គណ្ហតុ អម្ហាកំ. ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ...... ។ តតិយម្បិ..... ។

ប្រែថា បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើនឡើយ យើងខ្ញុំទាំងឡាយ បានតាក់តែងនូវវត្ថុទាំងឡាយ មានខាទនីយភោជនីយាហារ គឺបង្អែមនិងចម្អាប ជាដើមនេះ ហើយវេរប្រគេនដល់ព្រះករុណា. បពិត្រព្រះករុណាដ៏ចម្រើន

សូមលោកអ្នកមានសីលទទួលយកនូវវត្ថុទាំងឡាយ មានបង្អែមនិងចង្ហាបជាដើមនេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។ ......អស់វារៈ ២ ដងផង ។ .......អស់វារៈ ៣ ដងផង ។

**វេរអង្ករដល់ព្រះសង្ឃ ថា**

មយំ ភន្តេ ឥមានិ តណ្ឌុលានិ ឥធានេត្វា សង្ឃស្ស ទេម. សាធុ ភន្តេ សង្ឃោ ឥមានិ តុណ្ឌុលានិ បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ...... ។ តតិយម្បិ..... ។

ប្រែថា បពិត្រព្រះគម្តែងសង្ឃដ៏ចម្រើនឡើយ យើងខ្ញុំទាំងឡាយ បាននាំមកនូវអង្ករទាំងឡាយនេះ មកតម្កល់ទុកក្នុងទីនេះ ហើយសូមវេរប្រគេនដល់ព្រះសង្ឃ. បពិត្រព្រះគម្តែងសង្ឃដ៏ចម្រើន សូមព្រះសង្ឃទទួលយកនូវអង្ករទាំងឡាយនេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។ ......អស់វារៈ ២ ដងផង ។ .......អស់វារៈ ៣ ដងផង ។

## វេរផ្លែឈើផ្សេងៗ ថា

មយំ ភន្តេ ឥមានិ នានាផលានិ ឥធានេត្វា សង្ឃស្ស ទេម. សាធុ ភន្តេ សង្ឃោ ឥមានិ នានាផលានិ បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ...... ។ តតិយម្បិ..... ។

ប្រែថា បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើនឡើយ យើងខ្ញុំទាំងឡាយ បាននាំនូវផ្លែឈើផ្សេងៗទាំងឡាយនេះ មកតម្កល់ទុកក្នុងទីនេះ សូមវេរប្រគេនដល់ព្រះសង្ឃ. បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើន សូមព្រះសង្ឃទទួលយកនូវផ្លែឈើផ្សេងៗទាំងឡាយនេះ ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។ ......អស់វារៈ ២ ដងផង ។ ......អស់វារៈ ៣ ដងផង ។

## វេរគ្រឿងសេនាសនៈតទៅ

### បើវេររោងឧបោសថ គឺវិហារ ថា

មយំ ភន្តេ ឥមំ (ឧបោសកថាគារំ) ការេត្វា ឧបោសថបវារណាទិសង្ឃកម្មករណត្ថាយ ចាតុទ្ទិសស្ស ភិក្ខុសង្ឃស្ស ទេម សាធុ ភន្តេ ភិក្ខុសង្ឃោ ឥមំ

(ឧបោសកថាគារំ) បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ..... ។ តតិយម្បិ..... ។

ប្រែថា បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើនឡើយ យើងខ្ញុំទាំងឡាយ បានចាត់ចែងធ្វើ(នូវរោងសម្រាប់ធ្វើនូវឧបោសថ)នេះ ហើយវេរប្រគេនដល់ព្រះភិក្ខុសង្ឃ. ដែលមកអំពីទិសទាំង ៤ ដើម្បីប្រយោជន៍ ដល់កិរិយាធ្វើនូវសង្ឃកម្ម មានឧបោសថកម្ម និងបវារណាកម្មជាដើម បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើន សូមព្រះភិក្ខុសង្ឃទទួលយក (នូវរោងសម្រាប់ធ្វើនូវឧបោសថ)នេះ ដើម្បី សេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។ ........អស់វារៈ ២ ដងផង ។ .......អស់វារៈ ៣ ដងផង ។

**បើវេរសាលា ថា**

ឥមំ សាលំ នូវសាលានេះ ។

**វេរកប្បិយកុដិ ថា**

ឥមំ កប្បិយកុដឹ នូវកប្បិយកុដិនេះ ។

**វេរកុដិតូច ឬ តូប ថា**

ឥមំ កុដឹ ទទួលនូវកុដិ ឬ នូវតូបនេះ ។

**បើវេរកុដិធំ**

ឥមំ វិហារំ នូវកុដិធំនេះ ។

**វេរបង្គន់ ថា**

ឥមំ វច្ចកុដឹ នូវបង្គន់នេះ ។

បើក្រាផ្ទាំនឹងវេរសាលាក្ដី កប្បិយកុដិក្ដី កុដិតូចឬតូបក្ដី កុដិធំក្ដី បង្គន់ក្ដី ទាំង ៥ យ៉ាងនេះ នឹងវេររបស់ណាមួយ ឲ្យយកឈ្មោះរបស់នោះ ទាំងបាលីទាំងសម្រាយ មកដាក់ត្រង់កន្លែងដែលវង់ក្រចកនោះ ហើយសូត្រវេរចុះ ។

**វេរគរុភណ្ឌ ថា**

មយំ ភន្តេ ឥមំ គរុភណ្ឌំ ឥធានេត្វា ភិក្ខុសង្ឃស្សទេម សាធុ ភន្តេ ភិក្ខុសង្ឃោ ឥមំ គរុភណ្ឌំ បដិគណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ....... ។ តតិយម្បិ........ ។

ប្រែថា បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើនឡើយ យើងខ្ញុំទាំងឡាយ បាននាំនូវគរុភណ្ឌនេះ មកតម្កល់ទុកក្នុងទីនេះ សូមវេរប្រគេនដល់ព្រះភិក្ខុសង្ឃ បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើន សូមព្រះភិក្ខុសង្ឃ ទទួលយកនូវគរុភណ្ឌនេះ ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខដល់យើងខ្ញុំទាំងឡាយ

អស់កាលជាអង្វែងទៅហោង ។ ...... អស់វារៈ ២ ដងផង។ ........អស់វារៈ ៣ ដងផង

## វិធីវេរគ្រឿងភេសជ្ជៈ

## បើវេរទឹកឃ្មុំ ថា

មយំ ភន្តេ ឥមំ (មធុំ) ឥធានេត្វា ភិក្ខុសង្ឃស្ស ទេម សាធុ ភន្តេ ភិក្ខុសង្ឃោ ឥមំ (មធុំ) បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ. សុខាយ ។ ទុតិយម្បិ....... ។ តតិយម្បិ........ ។

ប្រែថា បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើនឡើយ យើងខ្ញុំទាំងឡាយ បាននាំ(នូវទឹកឃ្មុំ) នេះ មកតម្កល់ទុកក្នុងទីនេះ សូមវេរប្រគេនដល់ព្រះភិក្ខុសង្ឃ បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើន សូមព្រះភិក្ខុសង្ឃ ទទួលយក(នូវទឹកឃ្មុំ) នេះ ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។ ...... អស់វារៈ ២ ដងផង។ ........អស់វារៈ ៣ ដងផង ។

## បើវេរប្រេងថា

ឥមំ តេលំ នូវប្រេងនេះ ។

## បើវេរទឹកអំពៅ ថា

ឥមំ ផាណិតំ នូវទឹកអំពៅនេះ ។

## បើវេរទឹកត្នោតថា

ឥមំ តាលោទកំ នូវទឹកត្នោតនេះ ។

## បើវេរថ្នាំរម្ងាប់រោគថា

ឥមំ គិលានភេសជ្ជំ នូវថ្នាំសម្រាប់រក្សានូវមនុស្ស ឈឺនេះ ។

បើប្រាថ្នានឹងវេរប្រេងក្ដី ទឹកអំពៅក្ដី ទឹកត្នោតក្ដី ថ្នាំរក្សានូវជំងឺក្ដី ទាំង ៤ នេះ របស់ណាមួយ ឱ្យយកឈ្មោះរបស់នោះ ទាំងបាលី ទាំងសម្រាយ មកដាក់ត្រង់កន្លែងដែលវង់ក្រចកនោះ ហើយសូត្រវេរចុះ ។

វិធីវេរបច្ច័យទាំង ៤ ប្រការ ចប់ដោយសង្ខេបតែប៉ុណ្ណេះ

## បាលីវេរដុំថ្មជានិមិត្តសីមា

ឧកាស មយំ ភន្តេ ឥមេ មហន្តេ បាសាណបិណ្ឌេ សីមាយ និមិត្តករណត្ថាយ ភិក្ខុសង្ឃស្ស ទេម សាធុ ភន្តេ ភិក្ខុសង្ឃោ ឥមេ បាសាណបិណ្ឌេ បដិគ្គណ្ហតុ បដិគ្គហេត្វាន ឥមេហិ បាសាណបិណ្ឌេហិ និមិត្តំ កិត្តេត្វា ខណ្ឌសីមំ សម្មន្នតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

សូមគោរព បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើន យើងខ្ញុំទាំងឡាយសូមវេរនូវដុំថ្មទាំងឡាយនេះ ប្រគេនដល់ព្រះភិក្ខុសង្ឃ ដើម្បីប្រយោជន៏ដល់ការធ្វើជានិមិត្តសីមា. បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើន. សូមព្រះសង្ឃទទួលនូវដុំថ្មទាំងឡាយនេះ ហើយសន្មត់នូវខណ្ឌសីមាចុះ. ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៏. ដើម្បីសេចក្តីសុខ. ដល់យើងខ្ញុំទាំងឡាយ អស់កាលជាយូរអង្វែងទៅហោង ។

## បាលីវេររោងឧបោសថ (គីរីហារ)

ឧកាស មយំ ភន្តេ យថាសទ្ធំ ធនំ បរិច្ចជិត្វា ឥមំ ឧបោសថាគារំ ការេត្វា ឧបោសថ បវារណាទិ - សង្ឃកម្ម - ករណត្ថាយ ចាតុទ្ទិសស្ស ភិក្ខុសង្ឃស្ស ឱណោជេម សាធុ

ភន្តេ ភិក្ខុសង្ឃោ ឥមំ ឧបោសថាគារំ បដិគ្គណ្ហតុ បដិគ្គហេត្វាន យថិច្ឆិតំ វលញ្ជតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

សូមគោរព. បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើន. យើងខ្ញុំទាំងឡាយបានបរិច្ចាគនូវទ្រព្យ តាមគួរដល់សទ្ធាហើយ បានចាត់ចែងការសាងសង់នូវឧបោសថាគារ គឺវិហារជារោងឧបោសថនេះ រួចហើយសូមវេរប្រគេនដល់ព្រះភិក្ខុសង្ឃ. ដែលនិមន្តមកអំពីទិសទាំង ៤. ដើម្បីជាប្រយោជន៍ដល់ការធ្វើនូវសង្ឃកម្ម មានឧបោសថកម្ម និង បវារណាកម្មជាដើម បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើន. សូមព្រះសង្ឃទទួលនូវឧបោសថាគារនេះ លុះទទួលរួចហើយសូមប្រើប្រាស់តាមត្រូវការចុះ ដើម្បីសេចក្ដីចម្រើន. ដើម្បីបានជាប្រយោជន៍. ដើម្បីសេចក្ដីសុខ. ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។

## បញ្ហាទាន

ចង់ដឹងបញ្ហានេះ មុនដំបូងត្រូវដឹងថា អ្វីទៅហៅថា **ទាន** មានឈ្មោះម្ដេចខ្លះ ?

**ទាន** ជានាមធម៌ គឺជាតួចេតនារបស់អ្នកឱ្យហៅថា ទានចេតនា មានឈ្មោះបីយ៉ាង ដូចបាលីលោកសម្ដែងទុកថា ទានំ នាម ចាគចេតនា វិរតិ

ទេយ្យធម្មវសេន តិវិធំ ហោតិ ទានមានឈ្មោះ ៣ យ៉ាងគឺ ចាគចេតនា វិរតិ និង ទេយ្យធម៌ :

១- ចាគចេតនា ចេតនាដែលលះ (នូវទេយ្យធម៌ឱ្យដល់អ្នកដទៃ) ។

២-វិរតិ ការវៀរចាកសម្លាប់ជីវិតសព្វសត្វនានា ។

៣-ទេយ្យធម្ម គឺវត្ថុសម្ភារៈផ្សេងៗ ដែលគួរឱ្យ ។

## សេចក្តីពន្យល់

-ចេតនាដែលមានសទ្ធា (ជំនឿ) និងហិរិ (ការអៀនខ្មាស់ខ្ញើមអំពីបាប) ជាកុសលជួយបណ្តុះបណ្តាលឡើង អាស្រ័យដោយហេតុណាមួយ ជួយជំរុញឱ្យលះបង់ ហើយឱ្យនូវ ទេយ្យវត្ថុផ្សេងៗ ហៅថា ចាគចេតនាទាន ។

-ការសមាទានសីលប្រាំ វៀរចាកសម្លាប់ជីវិតគេ ឱ្យអភ័យដល់សព្វសត្វដទៃ ប្រកបដោយមេត្តាជាដើម ហៅថា វិរតិទាន ។

-ការឱ្យនូវរបស់ដែលគួរឱ្យ មានគ្រឿងឧបភោគបរិភោគ ឬ ខាទនីយ ភោជនីយាហារ ជាបច្ច័យសម្រាប់ផ្គត់ផ្គង់ប្រើប្រាស់ ហូប ចុក ជាដើម ហៅថាទេយ្យធម្មទាន ។

ទានមានឈ្មោះបីយ៉ាងនេះ ដែលមានបញ្ញាស្មុគ្រស្មាញជាងគេ គឺទេយ្យធម្មទានហ្នឹងឯង ពីព្រោះទាយកទាយិកាអ្នកធ្វើ ច្រើនទាក់ទងលើបញ្ហា ៣ គឺ បញ្ហាឱ្យ បញ្ហាវេរ និងបញ្ហារកនិមន្តបដិគ្គាហកៈ គឺចំនួនភិក្ខុមកទទួល ។

១-បញ្ញាឱ្យ ត្រូវអាស្រ័យដោយចេតនារបស់អ្នកឱ្យ បើចេតនាតម្កល់ទានចំពោះលើសង្ឃ ហៅថា សង្ឃគតទាន ឬ សង្ឃទាន. បើចេតនាតម្កល់ទានចំពោះបុគ្គល តាមការជ្រើសរើសដោយស្រឡាញ់ពេញចិត្ត ហៅថា បាដិបុគ្គលទាន ។

២-បញ្ញាវេរ ត្រូវអាស្រ័យដោយចំនួនភិក្ខុអ្នកទទួល បើភិក្ខុអ្នកទទួលមានតែ ១ រូប. អាចារ្យត្រូវវេរជាបុគ្គល. បើភិក្ខុអ្នកទទួលមាន ២ រូប ឬ ៣ រូប អាចារ្យត្រូវវេរគណៈ. បើភិក្ខុអ្នកទទួលមានពី ៤ រូបឡើងទៅ អាចារ្យត្រូវវេរជាសង្ឃ ។

៣-បញ្ញាបដិគ្គាហកៈ គឺរកនិមន្តភិក្ខុមកទទួល អាស្រ័យដោយទាយកទាយិកាម្ចាស់ទាន មានការប៉ុនប្រសប់ផងដែរ គឺ ប្រើសម្ដីជាសង្ឃជភាប ។

ក្នុងវិន័យព្រះពុទ្ធសាសនា លោកសម្ដែងអំពីកិច្ចធ្វើទាន មានសេចក្ដីទូលំទូលាយណាស់ សូមលើកយកតែអំពីការធ្វើទានបច្ច័យ ៤ មួយយ៉ាងប៉ុណ្ណោះមកជាតួយ៉ាង (១) ។

## ធ្វើទានបច្ច័យ ៤ ចំពោះសង្ឃ

អ្នកធ្វើបច្ច័យ ៤ បើកាលណាចាត់ចែងទេយ្យទានធម្មទាន បានសព្វគ្រប់បច្ច័យទាំង ៤ ហើយ ទោះបីលទ្ធភាពបានត្រឹមតែ ១ ប្រដាប់ក្ដី ២-៣-៤ ឬលើសពីនេះទៅទៀតក្ដី រួចហើយចូលទៅវត្តអារាមណាមួយ ពិតទូលប្រធានសង្ឃថា សូមព្រះសង្ឃមេត្តាចាត់ភិក្ខុ១រូប ២-៣-៤ ឬ លើស តាមតែអង្គណាក៏

១-សូមពិនិត្យមើលន័យ ក្នុងទក្ខិណាវិភង្គសូត្រ មជ្ឈិមនិកាយបិដក ភាគ ២៨ ខ្ទះ៨៦ ។

បានឱ្យនិមន្តទៅទទួល សង្ឃទាន ឯផ្ទះខ្ញុំព្រះករុណា វេលាព្រឹកនេះឬស្អែកម៉ោងប៉ុណ្ណេះ ។ បើការនិមន្តមានវិធីដូច្នេះ ទោះបីធ្វើតែនឹងភិក្ខុ ១ អង្គ ដែលសង្ឃចាត់មកនោះ ក៏ឈ្មោះថា សង្ឃទាន គឺបានធ្វើចំពោះសង្ឃពេញទី...... ។

ចំពោះទាយកម្ចាស់ទាន កាលណាបើភិក្ខុដែលសង្ឃចាត់ និមន្តមកដល់ផ្ទះហើយ ត្រូវតាំងចិត្តថា សង្ឃ ទទួលបដិសណ្ឋារៈ ជា សង្ឃ តែមួយយ៉ាងទោះបីជាសាមណេរក៏ដោយ ។

## របៀបវេរបច្ច័យ ៤ ជាសង្ឃទាន

ការវេរបច្ច័យ ៤ ត្រូវគិតតាមចំនួនបដិគ្គាហកៈ គឺចំនួនភិក្ខុអ្នកទទួលៈ

១-បើភិក្ខុពី ៤ អង្គឡើងទៅ ត្រូវវេរជាសង្ឃថា មយំ ភន្តេ ឥមេ ចត្តារោ បច្ចយេ ឥធានេត្វា សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមេ ចត្តារោ បច្ចយេ បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ ។ តតិយម្បិ ។

២-បើភិក្ខុមានតែ ២ ឬ ៣ អង្គ ត្រូវវេរជាគណៈថា ៖ មយំ ភន្តេ ឥមេ ចត្តារោ បច្ចយេ ឥធានេត្វា អាយស្មន្តានំ ទេម សាធុ ភន្តេ អាយស្មន្តោ ឥមេ ចត្តារោ បច្ចយេ បដិគ្គណ្ហតុ អម្ហាកំ

ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ ។ តតិយម្បិ ។

បើភិក្ខុមានតែ ១ អង្គ ត្រូវវេរជាបុគ្គលថា : មយំ ភន្តេ ឥមេ ចត្តារោ បច្ចយេ ឥធានេត្វា អាយស្មតោ ទេម សាធុ ភន្តេ អាយស្មា ឥមេ ចត្តារោ បច្ចយេ បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ ។ តតិយម្បិ ។

សូមបញ្ជាក់ថា: ពាក្យថា "វេរ" មានន័យថា ប្រគល់នូវបច្ច័យ ៤ ឬទេយ្យវត្ថុ ចំពោះចំនួនភិក្ខុ ដែលប្រធានសង្ឃចាត់ជាតំណាងសង្ឃ ឱ្យមកទទួលនាំយកទៅប្រគល់ឱ្យសង្ឃនៅឯវត្ត ចាត់ចែងប្រើប្រាស់តាមសមគួរ ។

ន័យនេះ សមនឹងអង្គនៃសង្ឃទាន មាន ពីរយ៉ាងគឺ :

១-ទាយក បានសុំនិមន្តលោកដែលជាបដិគ្គាហក: អំពីសំណាក់សង្ឃ ។

២-កាលណាលោកជាបដិគ្គាហក: និមន្តមកដល់ផ្ទះខ្លួនហើយ ខ្លួនបានតាំងចិត្តចំពោះ លើសង្ឃ ។

## អំពីពាក្យថាសង្ឃ

ពាក្យថា "សង្ឃ" ៗនេះប្រែបានច្រើនយ៉ាង ឧទាហរណ៍ មិគសង្ឃោ ប្រែថា ហ្វូងនៃម្រឹគ ទេវសង្ឃោ ពួកនៃទេវតា ។ល។

សព្ទនេះ បើភ្ជាប់ជាមួយស័ព្ទដទៃណាមួយ ក៏នៅតែរក្សាទុកអានុភាពជាពហុវចនៈទាំងអស់ ។

អំពីព្រះភិក្ខុសង្ឃ ( ពាក្យសាមញ្ញហៅត្រឹមតែព្រះសង្ឃ ) ។

បានពិនិត្យឃើញ ក្នុងគម្ពីរមហាវគ្គ តតិយ សមន្តបាសាទិកាអដ្ឋកថា និងគម្ពីរកង្ខាវិតរណីជាដើម សម្ដែងពន្យល់សេចក្ដីថា ប្រជុំនៃភិក្ខុសង្ឃច្រើនរូបដោយសេចក្ដីមិនប្លែកគ្នា បានឈ្មោះ ថាសង្ឃ ។

## ឯសង្ឃនោះមានពីរពួក គឺ

១-ប្រជុំនៃព្រះអរិយបុគ្គលទាំង ៨ ពួកជាភិក្ខុ ឈ្មោះថាទក្ខិណេយ្យសង្ឃ ។

២-ប្រជុំភិក្ខុជាបុថុជ្ជន ដែលលោកសន្មត់ឈ្មោះថា សម្មតិសង្ឃ ។ ត្រូវជាសង្ឃពីរពួក សម្រាប់ធ្វើសង្ឃកម្ម ។

សង្ឃទាំង ២ ពួកនេះ ចែកចេញជា ៥ ពួកទៀត ដូចតទៅ :

| | | | |
|---|---|---|---|
| ១- ប្រជុំនៃភិក្ខុ | ៤ រូប | ឈ្មោះថា | សង្ឃចតុវគ្គ |
| ២- - ដ - | ៥ រូប | - ដ - | សង្ឃបញ្ចវគ្គ |
| ៣- - ដ - | ១០រូប | - ដ - | សង្ឃទសវគ្គ |
| ៤- - ដ - | ២០រូប | - ដ - | សង្ឃវីសតិវគ្គ |

៥- - ដ - ច្រើនជាង ២០ រូប ឡើងទៅ ឈ្មោះថា សង្ឃអតិរេកវីសតិវគ្គ ។

ក-សង្ឃចតុវគ្គ គួនឹងធ្វើសង្ឃកម្មទាំងអស់បាន វៀរលែងសង្ឃកម្ម ៤ យ៉ាងគឺ ឧបសម្បទាកម្ម ១ បវារណាកម្ម១ កឋិនកម្ម ១ អព្ភានកម្ម ១ ធ្វើពុំបានឡើយ ។

ខ-សង្ឃបញ្ចវគ្គ គួរនឹងធ្វើសង្ឃកម្មទាំងអស់បាន វៀរលែងតែសង្ឃកម្ម ២ យ៉ាងគឺ ឧបសម្បទាកម្ម ក្នុងមជ្ឈិមប្រទេស និងអព្ភានកម្ម ធ្វើពុំបានឡើយ ។

គ-សង្ឃទសវគ្គ គួរនឹងធ្វើសង្ឃកម្មទាំងអស់បាន វៀរលែងតែអព្ភានកម្ម ១ ចេញ ធ្វើពុំបានឡើយ

ឃ-សង្ឃវីសតិវគ្គ គួរនឹងធ្វើសង្ឃកម្មទាំងអស់បាន មានអព្ភានកម្មជាដើម ឥតមានទាស់អ្វីឡើយ ។

ង-សង្ឃអតិរេកវីសតិវគ្គ គួរនឹង ធ្វើសង្ឃកម្មទាំងអស់បានដោយប្រពៃ ។

## ធមស្ការបូជនីយវត្ថុជាទីគោរព

វន្ទាមិ ចេតិយំ សព្វំ សព្វដ្ឋានេសុ បតិដ្ឋិតំ
សារីរិកធាតុមហាពោធិ ពុទ្ធរូបំ សកលំ សទា ។

ខ្ញុំសូមថ្វាយបង្គំ ព្រះបរមចេតិយ ព្រមទាំងព្រះសារីរិកធាតុនៃព្រះពុទ្ធ ។ និងមហាពោធិព្រឹក្ស ដែលគួរនឹកដោយលំអុត លំឱនចិត្តបរិសុទ្ធ លើកកំបង់អញ្ចលី ។ និងព្រះពុទ្ធរូប តំណាងអង្គព្រះមុនី ដែលស្ថិតនៅគ្រប់ទីឋាននានានោះទាំងអស់ ។ ( ដោយតេជៈនៃគុណ ព្រះមានបុណ្យប្រសើរខ្ពស់ ដែលតែងតែរំលស់រំដោះទុក្ខភ័យអន្តរាយ ។ ខ្ញុំសូមឱ្យបានសុខឃ្លាតចាកទុក្ខផងទាំងឡាយ សត្រូវទោះជិតឆ្ងាយ សូមឱ្យក្លាយជាមិត្រ ។ សូមទាន់ព្រះអរិ-យមេត្តេយ្យថ្លៃវិសិដ្ឋ សូមបានឃើញធម៌ពិត សមដូចចិត្តប្រាថ្នាហោង ។

## នមស្ការព្រះរតនត្រ័យ

### ប្រែជាពាក្យកាព្យ

យោ កប្បកោដី - ហិបិ អប្បមេយ្យំ
កាលំ ករោន្តោ អតិទុក្ករានិ
ខេទំ គតោ លោកហិតាយ នាថោ
នមោ មហាការុណិកស្ស តស្ស ។

ព្រះពុទ្ធជាទីពឹង ជាពុំនឹងសព្វសត្វា ព្រះអង្គកាលប្រាថ្នា ធ្វើកសាងអស់កាលយូរ ។ រាប់ដោយកោដិកប្បា ច្រើនគណនាហួសគិតគូរ បានត្រាស់ជាសព្វញ្ញូ ត្រាស់ជាគ្រូលើភពឋាន ។ ធ្វើកម្មជាកម្រ សត្វនិករគ្រាប់ពុំបាន នឿយហត់

លំបាកប្រាណ ព្រោះប្រយោជន៍ដល់សព្វសត្វ ។ ខ្ញុំសូមឱនសិរសាចិត្តប្រាថ្នា បង្គំថ្វាត់ ព្រះពុទ្ធករុណាសត្វ នោះជាទីពឹងសព្វកាល ។

អសម្ពុធំ ពុទ្ធនិសេវិតំ យំ

ភវាភវំ គច្ឆតិ ជីវលោកោ

នមោ អវិជ្ជាទិកិលេសជាលំ

វិទ្ធំសិនោ ធម្មវរស្ស តស្ស ។

សត្វតែងកើតស្លាប់បង់ ព្រោះចំណងកម្មជាគោល ឱ្យវិលវល់អន្ទោល ក្នុងភពតូចនិងភពធំ ។ ហេតុតែមិនដឹងធម៌ បរិសុទ្ធល្អស្អាតសុខុម គឺព្រះពុទ្ធសេព សមចិត្តខ្ញុំសូមនមស្ការ ។ នូវធម៌ប្រពៃពិត វិសេសសុទ្ធនោះឯងណា កាត់បង់នូវ អវិជ្ជា គឺបណ្ដាញកិលេសហើយ ។

គុណេហិ យោ សីលសមាធិបញ្ញា

វិមុត្តិញាណប្បភុតីហិ យុត្តោ

ខេត្តញ្ជនានំ កុសលត្ថិកានំ

តមរិយសង្ឃំ សិរសា នមាមិ ។

ព្រះសង្ឃអង្គសាវ័ក មានសំវរៈស្អាតផូរផង់ គបដោយសីលពេញអង្គ និងសមាធិបញ្ញា ។ ទាំងវិមុត្តិញាណ កិលេសគ្មានក្នុងអាត្មា ជាបុញ្ញក្ខេត្តាជនត្រូវ

ការដោយកុសល ។ ខ្ញុំសូមឱនសិរសី ឆ្ពោះព្រះអរិយបុគ្គល ជាបុត្រព្រះទសពល ជាមង្គលដល់សព្វសត្វ ។

## ចតុរារក្ខកម្មដ្ឋាន

### កម្មដ្ឋាន គួរចម្រើនរឿយៗ ៤ យ៉ាង

ពុទ្ធានុស្សតិ មេត្តា ច អសុភំ មរណស្សតិ
ឥច្ចេតា ចតុរារក្ខា ភាវេតព្វា បុនប្បុនំ ។
វន្ទាមិ ពុទ្ធំ គុណសាគរន្តំ
សត្តា សទា ហោន្តុ សុខី អវេរា
កាយោ ជិគុច្ឆោ សកលោ ទុគន្ធោ
គច្ឆន្តិ សព្វេ មរណំ អហំ ច ។

អារក្ខកម្មដ្ឋាន ៤ យ៉ាងនេះ គឺ ពុទ្ធានុស្សតិ១ មេត្តា ១ អសុភៈ ១ មរណស្សតិ ១ គួរសាធុជនចម្រើនរឿយៗថា ខ្ញុំសូមថ្វាយបង្គំចំពោះព្រះសម្មាសម្ពុទ្ធ ទ្រង់មានព្រះគុណដ៏ធំធេងដូចសាគរ. សូមសត្វទាំងឡាយមានតែសេចក្ដីសុខ មិនមានពៀរនឹងគ្នាសព្វកាល. រាងកាយទាំងមូល(នេះ) មានក្លិនអាក្រក់ គួរខ្ពើម

រអើមក្រៃពេកណាស់ សព្វសត្វទាំងអស់ រមែងដល់នូវសេចក្តីស្លាប់. ទាំងខ្លួនអាត្មាអញក៏ដូច្នោះដែរ ។

វន្ទាមិ ធម្មំ សុគតេន វុត្តំ
សត្តា សទា ហោន្តុ សុខី អវេរា
កាយោ ជិឃុច្ឆោ សកលោ ទុគន្ធោ
គច្ឆន្តិ សព្វេ មរណំ តថាហំ ។

ខ្ញុំសូមថ្វាយបង្គំ ចំពោះព្រះធម៌ ដែលព្រះសុគតទ្រង់ត្រាស់សម្តែងហើយ សូមសត្វទាំងឡាយមានតែសេចក្តីសុខ មិនមានពៀរនឹងគ្នាសព្វកាល. រាងកាយទាំងមូល(នេះ) មានក្លិនអាក្រក់គួរខ្ពើមរអើមក្រៃពេកណាស់. សព្វសត្វទាំងអស់ រមែងដល់នូវសេចក្តីស្លាប់. ទាំងខ្លួនអាត្មាអញក៏ដូច្នោះដែរ ។

វន្ទាមិ សង្ឃំ មុនិរាជបុត្តំ
សត្តា សទា ហោន្តុ សុខី អវេរា
កាយោ ជិឃុច្ឆោ សកលោ ទុគន្ធោ
គច្ឆន្តិ សព្វេ មរណំ តថាហំ ។

ខ្ញុំសូមថ្វាយបង្គំចំពោះព្រះសង្ឃ ដែលជាបុត្រនៃព្រះសម្ពុទ្ធ ជាស្តេចនៃអ្នកប្រាជ្ញ សូមសត្វទាំងឡាយមានតែសេចក្តីសុខ មិនមានពៀរនឹងគ្នាសព្វកាល

រាងកាយទាំងមូល(នេះ) មានក្លិនអាក្រក់ គួរខ្ពើមរអើមក្រៃពេកណាស់ សព្វសត្វទាំងអស់ រមែងដល់នូវសេចក្ដីស្លាប់ ទាំងខ្លួនអាត្មាអញក៏ដូច្នោះដែរ ។

## ពុទ្ធបានឧបគ្គារគាថា

### គាថានមស្ការស្ទាមព្រះបាទព្រះពុទ្ធ

វន្ទាមិ ពុទ្ធំ ភវបារតិណ្ណំ

តិលោកកេតុំ តិភវេកនាថំ

យោ លោកសេដ្ឋោ សកលំ កិលេសំ

ឆេត្វាន ពោធេសិ ជនំ អនន្តំ ។

ព្រះសព្វញ្ញុពុទ្ធ វិសេសផុតត្រៃលោកា គ្មានមនុស្ស ឬទេវតា ព្រហ្មណា ប្រដូចបាន ។ កំចាត់នូវកិលេស គ្មានឱ្យសេសនៅសល់ខាន ញុំាងជនទាំងប៉ុន្មាន ជាអនន្តឱ្យត្រាស់ដឹង ។

ខ្ញុំសូមថ្វាយបង្គំនូវព្រះបរមជាទីពឹង ព្រះអង្គឆ្លងផុតស្ទឹង បានដល់ច្រាំងនៃភពហើយ ។ ព្រះអង្គជាទង់ជ័យ ធំត្រៃឈៃបង្ហាញត្រើយ តែមួយព្រះអង្គហើយ ជាទីពឹងក្នុងត្រៃភព ។ មារព្រហ្មទាំងទេព្តា និងមនុស្សាតែងគោរព ចូលជ្រកក្រោមព្រះម្លប់ ពោធិញ្ញាណបានសុខា ។

យំ នម្មទាយ នទិយា បុលិនេ ច តីរេ

យំ សច្ចពន្ធគិរិកេ សុមនាចលគ្គេ
យំ តត្ថ យោនកបុរេ មុនិនោ ច បាទំ
តំ បាទលញ្ឆនមហំ សិរសា នមាមិ ។

សូមថ្វាយបង្គំ ទសករប្រណម ឆ្ពោះត្រង់ស្នាមព្រះបាទា ដែលព្រះមានជោគ ទ្រង់ព្រះមេត្តា ជាន់ទុកឱ្យជាស្ថានថ្លៃ ។ បាទមួយនៅនា ស្ទឹងនម្មទាត្រង់ឆ្នេរខ្សាច់ប្រសើរក្រៃ. បាទមួយទ្រង់ជាន់ទុកនៅព្ន - ដ៏ភ្នំគិរីសច្ចព័ន្ធ ។ បាទមួយនៅភ្នំ សុមនកូដ រហូតដល់កំពូលដ៏សោភ័ណ ព្រះបាទមួយទៀត ព្រះទ្រង់ជាន់ទុកនៅ នាយោនកបុរី ។ ខ្ញុំសូមបន្ទន់ កាយវាចា និងចិត្តជ្រះថ្លាឱនសិរសីបង្គំព្រះបាទ ព្រះជិនស្រី សូមសុខសួស្តីគ្រប់វេលា ។

សុវណ្ណមាលិកេ សុវណ្ណបព្វតេ សុមនកូដេ
យោនកបុរេ នម្មទាយ នទិយា
បញ្ចបាទវរំ ឋានំ អហំ វន្ទាមិ ទូរតោ ។

ខ្ញុំសូមនមស្ការអំពីចម្ងាយ នូវឋានទាំងឡាយដែលមានព្រះបាទ ទាំងប្រាំកន្លែងដែលព្រះមុនីនាថ ទ្រង់ឈានព្រះបាទលើកំពូលភ្នំ ។ សុវណ្ណមាលិកមួយនោះជាធំ មួយនៅលើភ្នំសុវណ្ណបពតិ មួយនៅលើភ្នំសុមនកូដប្រាកដ មួយនៅរាជវង្ស យោនកបុរី ។ មួយនៅក្បែរស្ទឹងនម្មទាជលធី ទាំងប្រាំនាទីដែលទ្រង់ប្រទានទុកឱ្យសព្វសត្វប្រតិបត្តិជាស្ថាន ដែលព្រះទ្រង់ញាណប្រទានទុកឱ្យ ។

# សុខាភិយាចនគាថា

## គាថាសូមសេចក្ដីសុខ

សូត្រនៅពេលសមាទាន ឬពេលធ្វើកុសលណាមួយហើយ

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវានាគា មហិទ្ធិកា
បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ សាសនំ ។

ទេវតាទាំងឡាយ ស្ថិតនៅព្ធដ៏អាកាសក្ដី ស្ថិតនៅលើផែនដីក្ដី នាគទាំងឡាយ មានឥទ្ធានុភាពច្រើនក្ដី ចូរអនុមោទនាបុណ្យនៃយើងទាំងឡាយ ចូររក្សានូវព្រះពុទ្ធសាសនា (ឱ្យបានសុខចម្រើន) អស់កាលជាយូរអង្វែងទៅ ។

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវានាគា មហិទ្ធិកា
បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ រដ្ឋកេ ។

ទេវតាទាំងឡាយ ស្ថិតនៅព្ធដ៏អាកាសក្ដី ស្ថិតនៅលើផែនដីក្ដី នាគទាំងឡាយ មានឥទ្ធានុភាពច្រើនក្ដី ចូរអនុមោទនាបុណ្យនៃយើងទាំងឡាយ ចូររក្សានូវមហាជនក្នុងរដ្ឋទាំងឡាយ (ឱ្យបានសុខចម្រើន) អស់កាលជាយូរអង្វែងទៅ ។

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវានាគា មហិទ្ធិកា
បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ ញាតយោ ។

ទេវតាទាំងឡាយ ស្ថិតនៅក្នុងអាកាសក្ដី ស្ថិតនៅលើផែនដីក្ដី នាគទាំងឡាយ មានឥទ្ធានុភាពច្រើនក្ដី ចូរអនុមោទនាបុណ្យនៃយើងទាំងឡាយ ចូររក្សានូវ ចូររក្សានូវញាតិទាំងឡាយ (ឱ្យបានសុខចម្រើន) អស់កាលជាយូរអង្វែងទៅ ។

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា

បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ បាណិនោ ។

ទេវតាទាំងឡាយ ស្ថិតនៅក្នុងអាកាសក្ដី ស្ថិតនៅលើផែនដីក្ដី នាគទាំងឡាយ មានឥទ្ធានុភាពច្រើនក្ដី ចូរអនុមោទនាបុណ្យនៃយើងទាំងឡាយ ចូររក្សានូវ ចូររក្សានូវសត្វទាំងឡាយ (ឱ្យបានសុខចម្រើន) អស់កាលជាយូរអង្វែងទៅ ។

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា

បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ នោ សទា ។

ទេវតាទាំងឡាយ ស្ថិតនៅក្នុងអាកាសក្ដី ស្ថិតនៅលើផែនដីក្ដី នាគទាំងឡាយ មានឥទ្ធានុភាពច្រើនក្ដី ចូរអនុមោទនាបុណ្យនៃយើងទាំងឡាយ ចូររក្សានូវ បុណ្យនៃយើងទាំងឡាយគ្រប់កាលទាំងពួង (ឱ្យបានសុខចម្រើន) អស់កាលជាយូរអង្វែងទៅ ។

❀ ❀

❀

## ការឧទ្ទិសផលបុណ្យនិងការប្រាថ្នា

ឥមិនា បុញ្ញកម្មេន ឧបជ្ឈាយា គុណុត្តរា អាចរិយូបការា ច មាតាបិតា បិយា មមំ សុរិយោ ចន្ទិមា រដ្ឋា គុណវន្តា នរាបិច ព្រហ្មា មារា ច ឥន្ទ្រា ច លោកបាលា ច ទេវតា យមោ មិត្តា មនុស្សា ច មជ្ឈត្តា វេរិកាបិច សព្វេ សត្តា សុខី ហោន្តុ បុញ្ញានិ បកតានិ មេ សុខញ្ច តិវិធំ ទេន្តុ ខិប្បំ បាបេថ វោមតំ ។

ដោយបុញ្ញកម្មនេះ ឧបជ្ឈាយ៍ទាំងឡាយ មានគុណដ៏ខ្ពង់ខ្ពស់អាចារ្យទាំងឡាយ មានឧបការៈ មាតាបិតាជាទីស្រឡាញ់នៃខ្ញុំ ព្រះអាទិត្យ. ព្រះចន្ទ. រដ្ឋការ. នរជនអ្នកមានគុណទាំងឡាយ. ព្រះព្រហ្ម. មារាធិរាជ. ព្រះឥន្ទទាំងឡាយ. លោកបាលមហារាជ និងទេវតាទាំងឡាយ. ព្រះយមរាជនិងមនុស្សទាំងឡាយជាមិត្តនឹងគ្នាក្តី មានចិត្តជាកណ្តាលក្តី មានពៀរជាមួយគ្នាក្តី (រួបរួមសេចក្តីថា) សូមឱ្យសព្វសត្វទាំងឡាយ មានសេចក្តីសុខរាល់គ្នា បុណ្យទាំងឡាយ ដែលខ្ញុំបានកសាងសន្សំហើយ ចូរឱ្យនូវសេចក្តីសុខទាំង ៣ ប្រការ សូមឱ្យអ្នក ទាំងឡាយបានដល់នូវអមតមហានិព្វាន ឱ្យបានឆាប់រួសរាន់ទាន់សេចក្តីប្រាថ្នា ហោង ។

ឥមិនា បុញ្ញកម្មេន ឥមិនា ឧទ្ទិសេន ច
ខិប្បាហំ សុលភេ ចេវ តណ្ហុបាទានឆេទនំ
យេ សន្តានេ ហីនា ធម្មា យាវ និព្វានតោ មមំ
នស្សន្តុ សព្វទាយេវ យត្ថ ជាតោ ភវាភវេ
ឧជុចិត្តោ សតិប្បញ្ញោ សល្លេខោ វិរិយោម្ហិ វា
មារា លភន្តុ នោកាសំ កាតុញ្ច វិរិយេសុ មេ
ពុទ្ធា ទិបវរោ នាថោ ធម្មោ នាថោ វរុត្តមោ
នាថោ បច្ចេកពុទ្ធោ ច សង្ឃោ នាថោត្តរោ មមំ
តេសោត្តមានុភាវេន មារោកាសំ លភន្តុ មា ។

ដោយបុញ្ញកម្មនេះផង ដោយការឧទ្ទិសនេះផង សូមឱ្យខ្ញុំបានដោយងាយយ៉ាងរួសរាន់ទាន់ចិត្ត នូវមគ្គផលជាគ្រឿងផ្ដាច់បង់នូវតណ្ហានិងឧបាទាន ធម៌ទាំងឡាយ ណា ជាធម៌ថោកទាប គឺអកុសលធម៌ នៅក្នុងសន្ដានចិត្តខ្ញុំ សូមឱ្យ(ហីនធម៌ជាអកុសលទាំងនោះ) វិនាសបាត់រវៀងរាល់កាលទៅ រហូតដល់ខ្ញុំបានសម្រេចព្រះនិព្វាន(ក្នុងបច្ឆិមជាតិ)(បើ) ខ្ញុំអន្ទោលទៅចាប់កំណើតក្នុងភពតូចនិងភពធំណា១ សូមឱ្យខ្ញុំជាបុគ្គលមានចិត្តត្រង់ មានសតិនិងបញ្ញា មានចិត្តស្អាតផូរផង់ទាំងសូមឱ្យព្យាយាមផង (ក្នុងភពនោះ១) មារទាំងឡាយចូរកុំបាននូវឱកាស

ដើម្បីឱ្យខូចព្យាយាមខ្ញុំឡើយ ព្រះពុទ្ធដូចជាប្រទីប ឬ កោះដ៏ប្រសើរ ជាទីពឹងនៃខ្ញុំ ព្រះធម៌ជាទីពឹងដ៏ប្រសើរខ្ពង់ខ្ពស់នៃខ្ញុំ ទាំងព្រះបច្ចេកពុទ្ធក៏ជាទីពឹងនៃខ្ញុំដែរ ព្រះសង្ឃក៏ជាទីពឹងដ៏ខ្ពង់ខ្ពស់នៃខ្ញុំដែរ ព្រះសង្ឃក៏ជាទីពឹងដ៏ខ្ពង់ខ្ពស់នៃខ្ញុំដែរ ដោយឧត្តមានុភាព នៃព្រះពុទ្ធ. ព្រះធម៌ ព្រះបច្ចេកពុទ្ធនិងព្រះសង្ឃនោះ មារចូរកុំបាននូវឱកាសចូលមកជ្រៀតជ្រែកឡើយ" ។

## ការសូមខមាទោសចំពោះសព្វសត្វ

យេ កេចិ ខុទ្ទកា បាណា មហន្តាបិ មយា ហតា
យេ បាណេកេ បមាទេន កាយវាចាមនេហិ វា
បុញ្ញំ មេ អនុមោទន្តុ គណ្ហន្តុ ផលមុត្តមំ
វេរិនោ ចេ បមុញ្ចន្តុ សព្វទោសំ ខមន្តុ មេ ។

សត្វទាំងឡាយណាមួយ ទោះតូចក្តីធំក្តី ដែលខ្ញុំបានបៀតបៀនហើយ មួយទៀត សត្វទាំងឡាយ ពួកខ្លះ (ដែលខ្ញុំបានធ្វើទុក្ខបុកម្នេញហើយ) ព្រោះសេចក្តីប្រមាទភ្លាត់ភ្លាំង ដោយកាយវាចាចិត្ត (សត្វទាំងឡាយនោះ) ចូរអនុមោទនានូវបុណ្យរបស់ខ្ញុំចុះ ចូរទទួលយកនូវផលបុណ្យដ៏ឧត្តមចុះ. សូមអត់ទោសទាំងពួងដល់ខ្ញុំផង" ។

## សេចក្ដីរំលឹកចំពោះអ្នករក្សាសីល

កកីវ អណ្ឌំ ចមរីវ វាលធី
បិយំវ បុត្តំ នយនំវ ឯកកំ
តថេវ សីលំ អនុរក្ខមានកា
សុបេសលា ហោថ សទា សគារវា ។

មេត្រដេរិច រក្សានូវស៊ុតវា យ៉ាងណាមិញ សត្វចាមរី រក្សានូវកន្ទុយវា យ៉ាងណាមិញ. មាតារក្សានូវកូនប្រុសជាទីស្រឡាញ់តែមួយ យ៉ាងណាមិញ ជនមានភ្នែកតែម្ខាង រក្សានូវភ្នែក យ៉ាងណាមិញ. អ្នកទាំងឡាយ កំពុងរក្សាសីល ជាអ្នកមានសីលជាទីស្រឡាញ់ក្រៃលែង ចូរជាអ្នកប្រកបដោយសេចក្ដីគោរពសីល ឲ្យបានសព្វកាល ក៏យ៉ាងនោះដែរ ៕

សីលំ យោគិស្ស លង្ការោ សីលំ យោគិស្ស មណ្ឌនំ
សីលេហិ លង្កតោ យោគី មណ្ឌនេ អគ្គតំ គតោ

សីលជាគ្រឿងអលង្ការរបស់យោគី (អ្នករក្សាសីល) សីលជាគ្រឿងប្រដាប់របស់យោគី (អ្នករក្សាសីល) យោគី (អ្នករក្សាសីល) ប្រដាប់តាក់តែងដោយសីលទាំងឡាយ បានដល់នូវភាវៈខ្ពង់ខ្ពស់ ក្នុងការប្រដាប់ (រាងកាយ) ។

## អធិប្បាយសង្ខេប

សីលនេះលោករាប់ថា ជាអរិយទ្រព្យ ជាទ្រព្យប្រសើរវិសេសថ្លៃថ្លា ជាងទ្រព្យមានវិញ្ញាណឥតវិញ្ញាណ របស់បុរសស្ត្រីក្នុងលោកនេះ ។ ពុទ្ធសាសនិកជន អ្នកមានវិចារណញ្ញាណ គង់នឹងអាចរិះរកឃើញយល់បានដោយងាយ ៗ ។

ន បុប្ផគន្ធោ បដិវាតមេតិ

ន ចន្ទនំ តគ្គរមល្លិកា វា

សតញ្ច គន្ធោ បដិវាតមេតិ

សព្វា ទិសា សប្បុរិសោ បវាយតិ ។

ក្លិនផ្កាបក់ផ្សាយច្រាសខ្យល់ពុំបានទេ ក្លិនខ្លឹមចន្ទន៍ក្តី ក្លិនក្រស្នាក្តី ក្លិនផ្កាម្លិះរួតក្តី បក់ផ្សាយច្រាសខ្យល់ពុំបានទេ មានតែក្លិននៃពួកសប្បុរស (អ្នកមានសីល) ទើបបក់ផ្សាយច្រាសខ្យល់បាន សប្បុរស (អ្នកមានសីល) បក់ផ្សាយក្លិនសព្វទិសានុទិស ទាំងបណ្តោយខ្យល់ ទាំងច្រាសខ្យល់ ។

ចន្ទនំ តគរំ វាបិ ឧប្បលំ អថ វស្សិកី

ឯតេសំ គន្ធជាតានំ សីលគន្ធោ អនុត្តរោ ។

ខ្លឹមចន្ទន៍ក្តី ក្រស្នាក្តី ផ្កាឧប្បលក្តី ផ្កាម្លិះលាក្តី (សុទ្ធតែមានក្លិនក្រអូប) ប៉ុន្តែក្លិនសីល ក្រអូបក្រៃលែងជាងគន្ធជាតិទាំងនុះ (ឥតមានគន្ធជាតិអ្វីក្រអូបដូច

ក្ខិនសីលឡើយ) ។

## ធម៌នាំឱ្យកើតសីល ២ យ៉ាងគឺ

១-ហិរិ សេចក្ដីខ្មាសបាប

២-ឱត្តប្ប សេចក្ដីខ្លាចបាប ។

វេរកឋិនទានមួយបែបទៀត

ឥមំ ភន្តេ កឋិនចីវរំ សានិសង្សំ សង្ឃស្ស ឲ (៣ ចប់)

សាធុ នោ ភន្តេ សង្ឃោ ឲ

ឥមំ កឋិនចីវរំ សានិសង្សំ បដិគ្គណ្ហតុ កឋិនំ អត្ថរតុ មាតាបិតុ អាទីនញ្ច គុណវន្តានំ អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ឲ ទុតិយម្បិ តតិយម្បិ

ប្រែថា បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើន យើងខ្ញុំទាំងឡាយ សូមវេរប្រគេននូវកឋិនចីវរនេះ ព្រមទាំងអានិសង្សលាភនេះដល់ព្រះសង្ឃ ។

បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើន សូមព្រះសង្ឃមេត្តាទទួលយកនូវកឋិនចីវររបស់យើងខ្ញុំទាំងឡាយនេះ ព្រមទាំងអានិសង្សលាភ ដើម្បីក្រាលគ្រងកឋិននេះចុះ ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ នឹងសេចក្ដីសុខ ដល់អ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់យើងខ្ញុំទាំងឡាយផង អស់កាលជាអង្វែងទៅហោង អស់វារៈពីរដងផង អស់វារៈបីដងផង ហោង ។

# តេជះខ្ញុំសាង

តេជះខ្ញុំសាង សំអិតសំអាង ឱនកាយវាចា
សូមសុខសុភាព រួចពីទុក្ខា ឆ្លងដល់ត្រើយមហា
ពោលគឺនិព្វាន ។

គ្រប់ជាន់គ្រប់ជាតិ កុំឱ្យខ្ញុំឃ្លាត ពីសីលនឹងទាន
គំនិតខ្ញុំកើត កំណើតខ្ញុំមាន មគ្គផលជាស្ពាន
ដល់ស្ថានថ្លៃថ្លា ។

ខ្ញុំសូមសច្ចា កើតជាតិណាៗ សូមមានប្រាជ្ញា
ដូចព្រះសារីបុត្ត មានរិទ្ធិអំណាច ដូចព្រះមោគ្គលាន
ត្រង់ថាពាក្យអត់ និងពាក្យថាគ្មាន កុំឱ្យកើតមាន
ដូចព្រះអនុរុទ្ធ សូមមានវិរិះ ដូចនាងអមរា
ចេះដោះប្រស្នា ដូចព្រះមហោសថ អង់អាចមុះមុត
ដូចព្រះនាគសេន ។

សូមជូនមគ្គផល ចំពោះទៅដល់ មាតាបិតា
គុណគ្រូឧប ជ្ឈាយាចារ គុណញាតិកា
ប្រាំពីរសន្តាន ។

ជីដូនជីតា រស់នៅក្តីណា លោកម្ចាស់ចែកឋាន
សូមជូនមគ្គផល កុសលថ្កើងថ្កាន សូមសុខក្សេមក្សាន្ត
ដល់ស្ថានផុតទុក្ខ ។

ព្រះគ្រូ វិសុទ្ធញ្ញាណ រស់ កែវ (រតនញ្ញាណោ)
ម.ឧ. គ្រូសូត្រស្តាំ វត្តពិភពឆ្មរង្សី សង្កាត់លេខ២ ក្រុងភ្នំពេញ
រៀបរៀង

ព.ស ២៥០៩ គ.ស ១៩៦៦

ចប់ ៗ

ការផ្សាយសៀវភៅ នេះជា eBook បាន បង្កើតឡើងដោយ

មូលនិធិខ្មែរសម្រាប់ការសិក្សា **និង** ក្សរុណាខ្មែរ

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ សៀង ស៊ីវ៉ាន់

សីហា ឆ្នាំ ២០១៥

គាំទ្រដោយ កូនប្រុស ស្រី

លោក ស៊ី ដារា និងលោកស្រី សុន ដារី ព្រមទាំងលោកស្រី បុប្ផា ដឺឡូប៉ែស

ដើម្បី ឧទិសកុសល ដល់វិញ្ញាណក្ខន្ធ

លោកឪពុក សង្វារ ដឺ ឡូប៉ីស និងលោកម្តាយ ឱន សៅខុន

សូមអរគុណ

ខ្ចៅ យុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org